

ឯកសារគម្ពីព្រះត្រៃបិដកស្កេននេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ៥១ ដល់ ភាគ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ៥000ឆ្នាំ បូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ៗ

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្គិចណៃ ៗ

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ៗ

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ៗ

ថតស្កេនដោយ
ប្អូនប្រុស ម៉ាន់ សាវ៉េត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងក្រៃលែងអំពី៖

- ឧបាសិកា កាំង ហ៊ុចណៃ (ភ្នំពេញ)
- ឧបាសក ដុត លីស្រ៊ុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សរ ចន និង ឧបាសិកា អ៊ូច សាទៀង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវត្ថានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនី ស្រីមុំ (ភ្នំពេញ)
- ឧបាសក ជែង យឿន (កូរ៉េ)
- លោក ស៊ុក ចាន់សេរី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ារី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រ៊ុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
  ព្រមទាំងបុត្រ ចាន់ណា សុធារនីរាជ, ចាន់ណា សុធារនិរោធ (ភ្នំពេញ)
- លោកស្រី ស្រ៊ុង ចាន់រស្មី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រ៊ុង ចាន់រតនា (ភ្នំពេញ)
- លោក ស្រ៊ុង យូហេង (ភ្នំពេញ)
- លោក នង សុផល (កូរ៉េ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទូត សេរីស័ក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រចនា (បាត់ដំបង)
- កញ្ញា ឌីស សុផារី (បាត់ដំបង)
- កញ្ញា យឿម សុផានី (បាត់ដំបង)
- លោក ម៉ៅ តន្ធា និងលោកស្រី ធៀង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជុំ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)

# ព្រះ
# ត្រៃបិដកបាលី
## និង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ខុទ្ទកនិកាយ ពុទ្ធវំសៈ
# ចរិយាបិដក
# ៧៧

បោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

ព. ស. ២៥០៧

## ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្មារតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

# អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន " ក្រុមជំនុំព្រះត្រៃបិដក " នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណាប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណាប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្តានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្តីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើឃោរឃៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឱ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ខត្តឫក្ស កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

**អ្នកតំណាងចាត់ការ** The Rev. Seikyo Muchaku

**ប្រធានការិយាល័យ** The Rev. Eiitsu Shinohara

**អ្នកចាត់ការ**

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

# 『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを恕し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年7月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

# Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

**TRIPITAKA PUBLISHING SUPPORT COMMITTEE**
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

7

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ពុទ្ធវំសៈ

# ចរិយាបិដក

៧៧

ព. ស. ២៥០៧

# សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស

# ពុទ្ធវំសោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## រតនចង្កមនកណ្ឌោ

[១] ព្រហ្មា ច លោកាធិបតី សហម្បតី
កតញ្ជលី អនធិវរំ អយាចថ
សន្តីធ សត្តាប្បរជក្ខជាតិកា
ទេសេហិ ធម្មំ អនុកម្បិមំ បជន្តិ ។
ភគវា លោកាធិបតី នរុត្តមោ
កតញ្ជលី ព្រហ្មគណេហិ យាចិតោ
សន្តីធ ធីរប្បរជក្ខជាតិកា
ទេសេតុ ធម្មំ អនុកម្បិមំ បជំ ។

# សុត្តន្តបិដក ខុទ្ទកនិកាយ

# ពុទ្ធវង្ស

---

សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## រតនចង្កមនកណ្ឌ

[១] គ្រានោះ សហម្បតីព្រហ្ម ជាអធិបតីនៃលោក ធ្វើអញ្ជលីអារាធនាព្រះសម្ពុទ្ធថា ពួកសត្វក្នុងលោកនេះ មានធូលីគឺរាគាទិក្កិលេសក្នុងភ្នែក ស្រាលស្តើងហើយ សូមព្រះអង្គសម្តែងធម៌ សូមព្រះអង្គអនុគ្រោះពួកសត្វនេះ ។ ពួកព្រហ្មធ្វើអញ្ជលី អារាធនាព្រះមានព្រះភាគ ជាអធិបតីនៃលោក ខ្ពង់ខ្ពស់ជាងនរជនថា ពួកសត្វក្នុងលោកនេះ មានប្រាជ្ញា មានធូលី គឺរាគាទិក្កិលេសក្នុងភ្នែកស្រាលស្តើងហើយ សូមព្រះអង្គសម្តែងធម៌ សូមព្រះអង្គអនុគ្រោះពួកសត្វនេះ ។

ទេសេតុ សុគតោ ធម្មំ ទេសេតុ អមតំ បទំ
លោកានមនុកម្បាយ ធម្មំ ទេសេតុ នាយក(១)។

សម្បន្នវិជ្ជាចរណស្ស តាទិនោ
ជុតិន្ធរស្សន្តិមទេហធារិនោ
តថាគតស្សប្បដិបុគ្គលស្ស
ឧប្បជ្ជិ ការុញ្ញតា សព្វសត្តេ ។

តំ សុត្វា ភគវា សត្ថា ឥទំ វចនមព្រវិ

អបារុតា តេ អមតស្ស ទ្វារា
យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ
វិហឹសសញ្ញី បគុណំ ន ភាសឹ
ធម្មំ បណីតំ មនុជេសុ ព្រហ្មេ ។

---

១ ឱ. ម. ភគវា លោកាធិបតី នរុត្តមោ . . . ធម្មំ ទេសេតុ នាយកន្តិ ឥទំយេវ គាថាទ្វយំ ន ទិស្សតិ ។

សូមព្រះសុគតសម្តែងធម៌ សូមសម្តែងព្រះនិព្វានឈ្មោះអមតៈ បពិត្រព្រះនាយក សូមព្រះមានព្រះភាគ សម្តែងធម៌ ដើម្បីអនុគ្រោះដល់សត្វលោកទាំងឡាយ ។

ព្រះតថាគត ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ
ជាតាទិបុគ្គល ទ្រទ្រង់នូវពន្លឺ ទ្រទ្រង់នូវកាយ
ជាទីបំផុត ព្រះអង្គឥតមានបុគ្គលផ្ទឹមបាន ទ្រង់
មានសេចក្តីករុណា កើតឡើង ក្នុងសត្វទាំងពួង ។

ព្រះមានព្រះភាគ ជាសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យនោះហើយ ក៏ទ្រង់ពោលនូវពាក្យនេះថា

ទ្វារនៃព្រះនិព្វាននោះ របើកហើយ សត្វទាំង
ឡាយណា មានសោតប្បសាទ សត្វទាំងនោះ
ចូរបញ្ចេញនូវសទ្ធាចុះ បពិត្រព្រហ្ម តថាគត
សំគាល់ នូវសេចក្តីនឿយលំបាក បានជាមិន
សម្តែងធម៌ ដ៏ឧត្តម ដែលតថាគតស្ទាត់ហើយ
ចំពោះមនុស្សទាំងឡាយ ។

## រតនចង្កមនកណ្ឌ

ភគវា តស្មឹ សមយេ     វេនេយ្យានំ នុកម្បកោ
អជបាលនិគ្រោធម្ហា     បាយាសិ មុចលិន្ទកេ ៗ
អនុក្កមេន គមនេន     ពារាណសិមុបាគមិ
តស្មឹ ហិ បល្លង្កវរេ     និសីទិ ភគវា តទា ៗ
បញ្ចន្នំ វគ្គិយានញ្ច     ធម្មចក្កម្បវត្តយិ
ទុក្ខំ ទុក្ខសមុប្បាទំ     និរោធំ មគ្គមុត្តមំ ៗ
បវត្តយិ តំ ភគវា     ឥសី តេ បញ្ចវគ្គិយា
អដ្ឋារសកោដិ តទា     ព្រហ្មទេវគណា សហ ៗ
បឋមស្មឹ សន្និបាតេ     ធម្មាភិសមយា លភុ
កោណ្ឌញ្ញោ ភទ្ទិយោ វប្បោ មហានាមោ ច អស្សជិ ៗ
វិនីតា តេន បរេន     សព្វេបិ អនុបុព្វសោ
អដ្ឋារសកោដិ តទា     ព្រហ្មទេវគណា សហ ៗ
បឋមស្មឹ សន្និបាតេ     សោតាបត្តិផលំ តទា
អនុក្កមេន គមនេន     រាជគហាមុបសង្កមិ ៗ

## រតនចង្កមនកណ្ឌ៍

សម័យនោះ ព្រះមានព្រះភាគ ទ្រង់អនុគ្រោះដល់ពួកវេនេយ្យសត្វ ព្រះអង្គទ្រង់ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់ពុទ្ធ-ដំណើរទៅអំពីដើមអជបាលនិគ្រោធ ។ ព្រះអង្គស្តេចចូលទៅកាន់ក្រុងពារាណសី ដោយព្រះពុទ្ធដំណើរ តាមលំដាប់ គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់លើបល្ល័ង្កដ៏ប្រសើរនោះឯង ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម្មចក្រ គឺទុក្ខសច្ច ១ ទុក្ខសមុប្បាទសច្ច ១ និរោធសច្ច ១ មគ្គសច្ចដ៏ឧត្តម ១ ឲ្យប្រព្រឹត្តទៅ ដល់ពួកបញ្ចវគ្គិយភិក្ខុ ។ លុះព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម្មចក្រនោះឲ្យប្រព្រឹត្តទៅហើយ គ្រានោះ ពួកឥសីគឺបញ្ចវគ្គិយភិក្ខុទាំងនោះ គឺ កោណ្ឌញ្ញៈ ភទ្ទិយៈ វប្បៈ មហានាម អស្សជិ ព្រមទាំងពួកព្រហ្មនិងទេវតា ១៨ កោដិ ក៏បានត្រាស់ដឹងនូវធម៌ ក្នុងបឋមសន្និបាត ។ គ្រានោះឯង ពួកបញ្ចវគ្គិយភិក្ខុទាំងអស់ ព្រមទាំងពួកព្រហ្ម និងទេវតា ១៨ កោដិ ដែលព្រះមានព្រះភាគ ទ្រង់ណែនាំពន្យល់ដោយធម្មចក្រនោះ និងដោយធម៌ដទៃទៀត ក៏បានលុះសោតាបត្តិ-ផល ក្នុងបឋមសន្និបាតនោះ តាមលំដាប់ ។ ព្រះសាស្តាស្តេចទៅកាន់ក្រុងរាជគ្រឹះ ដោយពុទ្ធដំណើរ តាមលំដាប់ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

វេឡុវនមហាវិហារេ    វិហាសិ មុនិបុង្គវោ
តំ សុត្វា ពិម្ពិសារោ ច    កតវន្ទុបសង្កមិ ។
ទ្វាទសនហុតេហេវ    បរិវារ មហា អហុ
ទីបគន្ធធូបមាលាទីនិ    កតវន្ទមភិបូជយិ ។
តស្មឹ សមាគមេ យេវ    កាមាទីនវំ ទេសយិ
ទេសនាបរិយោសានេ    រាជាធម្មមុជំ តទា ។
ចតុរាសីតិសហស្សានំ    ធម្មាភិសមយោ អហុ
តំ សុត្វាន បិតា រាជា    នវ ទូតានិ បេសយិ ។
នវសហស្សបរិវារេហិ    បព្វជ្ជំ យាចតេ មុនឹ
នវសហស្សបរិវារ    អរហត្តមុបាគមុំ ។
កាឡុទាយិ បរិយោសានេ    ភិក្ខុវេសំ គហេត្វា សោ
សហស្សបរិវារេហិ    កតវន្ទំ និមន្តយិ ។
និមន្តមធិវាសេត្វា    មហាមគ្គំ បដិបជ្ជតិ
វីសតិសហស្សភិក្ខូហិ    បាយាសិ សក្យបុង្គវោ ។

ព្រះពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់គង់នៅ ក្នុងវេឡុវនមហាវិហារ ព្រះបាទពិម្ពិសារ ទ្រង់ឮដំណឹងនោះហើយ ក៏ស្តេចចូលទៅគាល់ព្រះមានព្រះភាគ ។ ព្រះរាជាមានពួកបរិវារច្រើន ចំនួន ១១ ម៉ឺនរូប កាន់ប្រទីប គ្រឿងក្រអូប ធូប និងផ្កាកម្រងជាដើម បូជាព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងទោសនៃកាម ក្នុងទីប្រជុំនោះឯង លុះចប់ទេសនា ព្រះរាជាកើតសេចក្តីរីករាយ ក្នុងកាលនោះ ។ ពួកសត្វ ៨ ម៉ឺន ៤ ពាន់រូប បានត្រាស់ដឹងធម៌ ព្រះរាជាជាពុទ្ធបិតា លុះឮដំណឹងនោះហើយ ទើបបញ្ជូនទូត ៩ រូបទៅ ។ ទូតទាំងឡាយ ព្រមទាំងបរិវារ ៩ ពាន់ ក៏សូមផ្នួសនឹងព្រះមុនី ពួកទូតទាំងនោះ មានបរិវារ ៩ ពាន់ ក៏បានលុះព្រះអរហត្ត ។ ក្នុងកាលជាខាងក្រោយបំផុត កាឡុទាយិមានបរិវារមួយពាន់ កាន់យកភេទជាភិក្ខុហើយ លោកក៏និមន្តព្រះមានព្រះភាគមក ។ ព្រះពុទ្ធជាសក្យៈដ៏ប្រសើរ ទ្រង់ទទួលនិមន្តហើយ ក៏ស្តេចទៅកាន់ផ្លូវធំ ស្តេចទៅជាមួយនឹងភិក្ខុពីរម៉ឺនរូប ។

## រតនចង្កមនកណ្ឌោ

អនុត្តមេន គមនេន   កបិលវត្ថុមាគមិ
រោហិណិយា នទីតីរេ   បាដិហារមកាសិ សោ ។
តស្មឹ បល្លង្កមជ្ឈម្ហិ   និសីទិ សក្យបុត្តកោ
មហាវេស្សន្តរជម្ពុំ   ទេសេត្វា ភគវា បិតុ
ចតុរាសីតិសហស្សានំ   ធម្មាភិសមយោ អហុ(១) ។

ន ហោតេ(២) ជានន្តិ សទេវមនុស្សា(៣)
ពុទ្ធោ អយំ កីទិសកោ នរុត្តមោ
ឥទ្ធិពលំ បញ្ញាពលញ្ច កីទិសំ
ពុទ្ធពលំ លោកហិតស្ស កីទិសំ ។

ន ហោតេ(២) ជានន្តិ សទេវមនុស្សា(៣)
ពុទ្ធោ អយំ ឦទិសកោ(៤) នរុត្តមោ
ឥទ្ធិពលំ បញ្ញាពលញ្ច ឦទិសំ(៥)
ពុទ្ធពលំ លោកហិតស្ស ឦទិសំ(៥) ។

---

១ ឱ. ម. តំ សុត្វា ភគវា សត្ថា . . . ធម្មាភិសមយោ អហូតិ ឥមា គាថាយោ ន ទិស្សន្តិ ។
២ ឱ. ន កោ តេតិ ទិស្សតិ ។ ៣ ឱ. ម. សទេវមានុសាតិ ទិស្សតិ ។ ៤ ឱ. ម. ឯទិសកោ ។
៥ ឱ. ម. ឯទិសំ ។

## រតនចង្កមនកណ្ឌ

ព្រះអង្គស្តេចទៅកាន់ក្រុងកបិលវត្ថុ ដោយព្រះដំណើរ តាមលំដាប់ ទ្រង់ធ្វើបាដិហារិយ៍ត្រង់ឆ្នេរស្ទឹងរោហិណី ។ ព្រះមានព្រះភាគ ជាសក្យៈដ៏ប្រសើរ ទ្រង់គង់ត្រង់កណ្ដាលនៃបល្ល័ង្កនោះ សម្ដែងមហាវេស្សន្តរជាតក ថ្វាយព្រះវរបិតា ពួកសត្វ ៨ ម៉ឺន ៤ ពាន់រូប ក៏បានត្រាស់ដឹងនូវធម៌ ។

ពួកមនុស្សព្រមទាំងទេវតាទុ៎ះ មិនបានដឹងដូច្នេះ
ថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាងនរជនដូចម្ដេច
ឥទ្ធិពលនិងបញ្ញាពល តើដូចម្ដេច ពុទ្ធពល
របស់ព្រះសាស្ដា ជាប្រយោជន៍ដល់សត្វលោក
ដូចម្ដេច ។ ពួកមនុស្សព្រមទាំងទេវតាទុ៎ះ មិន
បានដឹងដូច្នេះថា ព្រះពុទ្ធអង្គនេះ ទ្រង់ឧត្តមជាង
នរជនបែបនេះ ឥទ្ធិពលនិងបញ្ញាពល បែប
នេះ ពុទ្ធពល របស់ព្រះសាស្ដា ជាប្រយោជន៍
សត្វលោក បែបនេះ ។

ហន្ទាហំ ទស្សយិស្សាមិ ពុទ្ធពលំ អនុត្តរំ

ចង្កមំ មាបយិស្សាមិ នភេ រតនមណ្ឌិតំ ។

ភុម្មា មហារាជិកា តាវតឹសា

យាមា ច ទេវា តុសិតា ច និម្មិតា

បរនិម្មិតា យេបិច ព្រហ្មកាយិកា

អានន្ទិតា វិបុលមកំសុ ឃោសំ ។

ឱភាសិតា ច បឋវី សទេវកា

បុថូ ច លោកន្តរិកា អសំវុតា

តមោ ច តិព្វោ វិហតោ តទា អហុ

ទិស្វាន អច្ឆេរកបាដិហីរំ ។

សទេវគន្ធព្វមនុស្សរក្ខសេ

អាភា ឧឡារា វិបុលា អជាយថ

(ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យ នៃមនុស្សនិងទេវតាទាំងនោះដូច្នោះហើយ) ទើបទ្រង់ព្រះចិន្តាថា បើដូច្នោះ តថាគតនឹងសម្តែងនូវពុទ្ធពលដ៏ប្រសើរ និម្មិតទីចង្ក្រមប្រដាប់ដោយកែវ ឰដ៏អាកាស ។

ទេវតាទាំងឡាយណា គឺ ភុម្មទេវតាក្តី មហារាជិកទេវតាក្តី តាវត្តឹសទេវតាក្តី យាមទេវតាក្តី តុសិតទេវតាក្តី និម្មានរតីទេវតាក្តី បរនិម្មិតវសវត្តីទេវតាក្តី ព្រហ្មទាំងឡាយណាក្តី ពួកទេវតានិងព្រហ្មទាំងនោះរីករាយហើយ បានធ្វើនូវសម្លេង ឲ្យឮកងរំពងខ្ទរខ្ទារ ។ ផែនដីព្រមទាំងទេវលោក ក៏ក្ញឺក្រោងក្រោត ទាំងពួកសត្វនរក នៅក្នុងលោកន្តរដ៏ច្រើន ក៏ឥតមានអ្វីបិទបាំង ទាំងងងឹតដ៏ខ្លាំងក្លាទៀតសោត ក៏ខ្ចាត់ខ្ចាយចេញក្នុងកាលនោះ គេអាចមើលឃើញនូវបាដិហារ្យជាអស្ចារ្យបាន ។ ពន្លឺដ៏ធំទូលាយលើសលុប កើតឡើងដល់ពួកទេវតា គន្ធព្វ មនុស្ស និង អារក្ស ។

## រតនចង្កមនកណ្ឌោ

ឥមស្មឹ លោកេ បរស្មឹ ចូភយេ
អធោបិ ឧទ្ធំ តិរិយញ្ច វិត្ថតំ ។
សត្តុត្តមោ អនធិវរោ វិនាយកោ
សត្ថា អហុ ទេវមនុស្សបូជិតោ
មហានុភាវោ សតបុញ្ញលក្ខណោ
ទស្សេសិ អច្ឆេរកបាដិហីរិយំ(១) ។

តស្មឹ សមាគមេ សត្ថា អព្ភុគ្គន្ត្វា នភេ តលេ
សិនេរុបព្វតំ រម្មំ ចង្កមំ មាបយី ជិនោ ។
ទសសហស្សិលោកធាតុ-ទេវតា ជិនសន្តិកេ
តថាគតំ នមស្សិត្វា ពុទ្ធបូជំ ករឹសុ តេ(២) ។

សោ យាចិតោ ទេវវរេន ចក្ខុមា
អត្ថំ សមេក្ខិត្វា តទា នរុត្តមោ
ចង្កមំ(៣) មាបយិ លោកនាយកោ
សុនិដ្ឋិតំ សព្វរតននិម្មិតំ ។

---

១ ឱ. អច្ឆេរកំបាដិហីរំ ។ ២ ឱ. ម. តស្មឹ សមាគមេ សត្ថា . . . ពុទ្ធបូជំ ករឹសុ តេតិ ឥទំយេវ គាថាទ្វយ ន ទិស្សតិ ។ ៣ ឱ. ឯត្ថន្តរេ តត្ថាតិ ទិស្សតិ ។

## រតនចង្កមនកណ្ឌ

ព្រះសាស្តាព្រះអង្គឧត្តមជាងសត្វ មិនមានអ្នក
ណាមួយប្រសើរលើស តែងដឹកនាំសត្វ ដែល
ទេវតានិងមនុស្សតែងបូជា មានអានុភាពច្រើន
មានបុញ្ញលក្ខណៈច្រើន ទ្រង់សម្តែងបាដិហា-
រិយ៍ជាអស្ចារ្យ ផ្សាយទៅក្នុងលោកទាំងពីរ គឺ
លោកនេះ និងលោកដទៃផង ក្នុងទិសខាង
ក្រោម ទិសខាងលើ និងទិសទទឹងផង ។

ព្រះជិនស្រីជាសាស្តាចារ្យ ទ្រង់ហោះទៅឰដ៏ផ្ទៃអាកាស
ទ្រង់និម្មិតភ្នំសិនេរុជាទីរីករាយ ឲ្យជាទីចង្ក្រមក្នុងទីប្រជុំនោះ ។
ទេវតាទាំងមួយម៉ឺនលោកធាតុនោះ ក៏បានក្រាបថ្វាយបង្គំព្រះ
តថាគត ក្នុងសំណាក់នៃព្រះជិនស្រី ហើយធ្វើពុទ្ធបូជា ។

គ្រានោះ ព្រះពុទ្ធមានចក្ខុអង្គនោះ ទ្រង់ឧត្តមជាងនរៈ
ដែលទេវតាដ៏ប្រសើរអារាធនាហើយ ក៏ទ្រង់ពិចារណា
នូវអត្ថ ព្រះលោកនាយក ទ្រង់និម្មិតទីចង្ក្រម តាក់
តែងដោយរតនៈទាំងអស់ សម្រេចដោយល្អហើយ ។

ឥទ្ធិ ច អាទេសនានុសាសនី
តិបាដិហីរេ ភគវា វសី អហុ
ចង្កមំ មាបយិ លោកនាយកោ
សុនិដ្ឋិតំ សព្វរតននិម្មិតំ ។

ទសសហស្សិលោកធាតុយា សិនេរុបព្វតុត្តមេ ថម្ភេវ
ទស្សេសិ បដិបាដិយា ចង្កមេ រតនាមយេ ។
ទសសហស្សំ អតិក្កម្ម ចង្កមំ មាបយី ជិនោ
សព្វសោវណ្ណមយា បស្សេ ចង្កមេ រតនាមយេ ។
តុលាសង្ឃាដានុវត្តា(១) សោវណ្ណផលកត្ថតា
វេទិកា សព្វសោវណ្ណា ទុភតោ បស្សេសុ និម្មិតា ។
មណិមុត្តាវាលុកាកិណ្ណោ និម្មិតោ រតនាមយោ
ឱភាសេតិ ទិសា សព្វា សតរំសីវ ឧគ្គតោ ។

១ ឱ. តូលាសង្ឃាដានុវត្តា ។ ម. តុលាសង្ឃាដានុវត្តា ។

ព្រះមានព្រះភាគទ្រង់ស្ទាត់ក្នុងបាដិហារ្យ ៣ យ៉ាង គឺ ឥទ្ធិបាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ព្រះលោកនាយក ទ្រង់និម្មិតទីចង្ក្រម តាក់តែងដោយរតនៈទាំងអស់ សម្រេចល្អហើយ ។

ព្រះអង្គទ្រង់សម្តែង (នូវបាដិហារ្យ) លើទីចង្ក្រម សម្រេចដោយកែវលើភ្នំសិនេរុដ៏ឧត្តម ដោយលំដាប់ ដូចជាសសរនៃលោកធាតុទាំងមួយម៉ឺន ។ ព្រះជិនស្រី ទ្រង់និម្មិតទីចង្ក្រមជាវិការៈនៃមាសសុទ្ធ ត្រង់ខាងនៃទីចង្ក្រមដ៏សម្រេចដោយកែវកន្លងលោកធាតុមួយម៉ឺន ។ ទ្រង់និម្មិតនូវថែវទាំងឡាយ ជាវិការៈនៃមាសសុទ្ធ មានមេជម្ពូលនិងផ្តោងប្រព្រឹត្តទៅ ក្រាលដោយក្តារមាស ត្រង់ចំហៀងទាំងសងខាង (នៃរតនចង្ក្រមនិងសុវណ្ណចង្ក្រមនោះ) ។ ព្រះសម្ពុទ្ធទ្រង់និម្មិតរតនចង្ក្រមដ៏ពោរពាសដោយខ្សាច់ ជាវិការៈនៃកែវមណីនិងកែវមុក្តា ញុំាងទិសទាំងពួងឲ្យភ្លឺព្រោងព្រាយ ហាក់ដូចជាព្រះអាទិត្យរះឡើង ។

## រតនចង្កមនកណ្ឌោ

តស្មឹ ចង្កមនេ ធីរោ ទ្វត្តឹសវរលក្ខណោ
វិរោចមានោ សម្ពុទ្ធោ ចង្កមេ ចង្កមី ជិនោ ។
ទិព្វំ មន្ទារវំ បុប្ផំ បទុមំ បារិឆត្តកំ
ចង្កមនេ ឱកិរន្តិ សព្វេ ទេវា សមាគតា ។
បស្សន្តិ តំ ទេវសង្ឃា ទសសហស្សី សមាគតា
នមស្សមានា និបតន្តិ តុដ្ឋហដ្ឋា បមោទិតា ។
តាវតឹសា ច យាមា ច តុសិតា ចាបិ ទេវតា
និម្មានរតិនោ ទេវា យេ ទេវា វសវត្តិនោ
ឧទគ្គចិត្តា សុមនា បស្សន្តិ លោកនាយកំ ។

សទេវគន្ធព្វមនុស្សរក្ខសា
នាគា សុបណ្ណា អថវាបិ កិន្នរា
បស្សន្តិ តំ លោកហិតានុកម្បកំ
នភេវ អច្ចុគ្គតចន្ទមណ្ឌលំ ។

## រតនចង្កមនកណ្ឌ

ព្រះសម្ពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ទ្រង់រុងរឿងក្នុងទីចង្ក្រមនោះ ព្រះជិនស្រីទ្រង់ចង្ក្រម លើទីចង្ក្រម ។ ទេវតាទាំងអស់មកប្រជុំគ្នាហើយ រោយរាយនូវផ្កាមន្ទារវៈ ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ក្នុងទីចង្ក្រម ។ ពួកទេវតាមួយម៉ឺនលោកធាតុ ដែលមកប្រជុំគ្នា បានឃើញព្រះមានភាគអង្គនោះ ក៏មានចិត្តត្រេកអររីករាយ ហើយក្រាបថ្វាយបង្គំ ។ ទេវតាទាំងឡាយណា ជាន់តាវត្តិង្សផង ជាន់យាមៈផង ជាន់តុសិតផង ទេវតាជាន់និម្មានរតីផង ទេវតាជាន់វសវត្តីផង ទេវតាទាំងនោះ មានចិត្តអណ្តែតខ្ពស់ឡើង មានចិត្តរីករាយ រមិលមើលព្រះលោកនាយក ។

ពួកទេវតា ពួកគន្ធព្វ ពួកមនុស្ស និងពួកអារក្ស
ពួកនាគ ពួកគ្រុឌ ទាំងពួកកិន្នរ ក៏ឃើញព្រះ
សម្ពុទ្ធម្ចាស់ ទ្រង់មានព្រះទ័យអនុគ្រោះ ដោយ
ប្រយោជន៍ ដល់សត្វលោកនោះ ហាក់ដូចជា
មណ្ឌលព្រះចន្ទ្រខ្ពស់ត្រដែត ឰដ៏អាកាស ។

អាភស្សរា សុភកិណ្ហា វេហប្ផលា អកនិដ្ឋា ច(១)
សុសុទ្ធសុក្កវត្ថវសនា តិដ្ឋន្តិ បញ្ជលីកតា ។

មុញ្ចន្តិ បុប្ផំ បន បញ្ចវណ្ណិកំ
មន្ទារវំ ចន្ទនចុណ្ណមិស្សកំ
ភមេន្តិ ចេលានិ ច អម្ពរេ តទា
អហោ ជិនោ លោកហិតានុកម្បកោ ។

តុវំ សត្ថា ច កេតុ ច ធជោ យូបោ ច បាណិនំ
បរាយនោ បតិដ្ឋា ច ទីបោ ច ទិបទុត្តមោ ។

ទសសហស្សិលោកធាតុយា ទេវតាយោ មហិទ្ធិកា
បរិវារេត្វា នមស្សន្តិ តុដ្ឋហដ្ឋា បមោទិតា ។

---

១ ឱ. ម. ឥតោ បរំ ទេវតាតិ ទិស្សតិ ។

ពួកព្រហ្មជាន់អាភស្សរៈផង ជាន់សុភកិណ្ហៈផង ជាន់វេហប្ផលៈផង ជាន់អកនិដ្ឋៈផង ស្លៀកសំពត់សសុទ្ធ ឈរផ្គងអញ្ជលី ។

(ពួកព្រហ្មទាំងនោះ) បញ្ចេញនូវផ្កាមន្ទារវបុស្ប
មានពណ៌ ៥ ដ៏លាយដោយលំអិតខ្លឹមចន្ទន៍ផង
បង្វិលគ្រវីសំពត់ទាំងឡាយផង ឰដ៏អាកាសក្នុង
កាលនោះ (ហើយពោលថា) អើហ្ន៎ ព្រះ
ជិនស្រី ទ្រង់អនុគ្រោះ ដោយប្រយោជន៍ដល់
សត្វលោក ។

ព្រះអង្គជាសាស្តាចារ្យផង ជាទង់ផង ជាទង់ជ័យផង ជាប្រាសាទផង ជាទីពឹងប្រព្រឹត្តទៅខាងមុខផង ជាប្រទីបរបស់ពួកសត្វផង ទ្រង់ឧត្តមជាងសត្វជើង ២ ផង ។ ពួកទេវតាក្នុងមួយម៉ឺនលោកធាតុ ដែលមានឫទ្ធិច្រើន មានចិត្តត្រេកអរស្រស់ស្រាយ រីករាយ មកហោមរោម ហើយថ្វាយបង្គំ ។

## រតនចង្កមនកណ្ឌោ

ទេវា ទេវកញ្ញា ច  បសន្នា តុដ្ឋមានសា
បញ្ចង្គិកតុរិយេហិ  បូជយន្តិ នរាសភំ ៗ
បស្សន្តិ តំ ទេវសង្ឃា  បសន្នា តុដ្ឋមានសា
បញ្ចង្គិកតុរិយេហិ  បូជយន្តិ នរាសភំ ៗ
អហោ អច្ឆរិយំ លោកេ  អព្ភុតំ លោមហំសនំ
ន មេទិសំ ភូតបុព្វំ  អច្ឆេរំ លោមហំសនំ ៗ
សកសកម្ហិ ភវនេ  និសីទិត្វាន ទេវតា
ហសន្តិ តា មហាហសិតំ  ទិស្វានច្ឆេរកំ នភេ ៗ
អាកាសដ្ឋា ច ភុម្មដ្ឋា  តិណោសដិនិវាសិនោ(១)
កតញ្ជលី នមស្សន្តិ  តុដ្ឋហដ្ឋា បមោទិតា ៗ
យេបិ ទីឃាយុកា នាគា  បុញ្ញវន្តោ មហិទ្ធិកា
បមោទិតា នមស្សន្តិ  បូជយន្តិ នរុត្តមំ ៗ

---

១ ឱ. តិណបគ្គនិវាសិនោ ។ ម. តិណបន្តនិវាសិនោ ។

## រតនបង្កមនកណ្ឌ៍

ពួកទេវតានិងពួកទេពកញ្ញា មានចិត្តជ្រះថ្លា មានចិត្តត្រេកអរ បូជាព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងនរៈ ដោយផ្កាមានពណ៌ ៥ ៗ ពួកទេវតាទាំងឡាយ មានចិត្តជ្រះថ្លា មានចិត្តត្រេកអរ ឃើញព្រះអង្គ ក៏នាំគ្នាបូជាព្រះសម្ពុទ្ធ ទ្រង់ប្រសើរជាងនរៈ ដោយផ្កាមានពណ៌ ៥ (ហើយពោលថា) ឱហ្ន៎ ! អស្ចារ្យចម្លែកណាស់ គួរឲ្យព្រឺរោម ក្នុងលោក ឯសេចក្តីអស្ចារ្យគួរឲ្យព្រឺរោម បែបនេះ មិនដែលកើតឡើងសោះឡើយ ៗ ពួកទេវតាទាំងនោះ អង្គុយក្នុងភព របស់ខ្លួន ៗ រីករាយខ្លាំង ព្រោះឃើញនូវសេចក្តីអស្ចារ្យ ក្នុងអាកាស ។ ពួកអាកាសដ្ឋកទេវតា ពួកភុម្មដ្ឋកទេវតា និងពួកទេវតាដែលនៅអាស្រ័យក្នុងស្មៅ និងឈើជាថ្នាំ ត្រេកអរស្រស់ស្រាយ រីករាយខ្លាំង នាំគ្នាផ្គងអញ្ជលីនមស្ការ ៗ ទាំងពួកនាគដែលមានអាយុវែង មានបុណ្យច្រើន មានឫទ្ធិច្រើន ក៏រីករាយ ថ្វាយបង្គំ បូជាព្រះពុទ្ធ ដ៏ខ្ពង់ខ្ពស់ជាងនរៈដែរ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

សង្គីតិយោ បវត្តន្តិ អម្ពរេ អនិលញ្ជសេ
ចម្មនទ្ធានិ វាទេន្តិ ទិស្វានច្ឆេរកំ លោកេ ។
សង្ខា ច បណវា ចេវ អថោបិ ទេណ្ឌិមា(១) ពហូ
អន្តលិក្ខស្មឹ វជ្ជយន្តិ ទិស្វានច្ឆេរកំ លោកេ ។
អព្ភុតោ វត នោ អជ្ជ ឧប្បជ្ជិ លោមហំសនោ
ធុវមត្ថសិទ្ធឹ លភាម ខណោ នោ បដិបាទិតោ ។
ពុទ្ធោតិ តេសំ សុត្វាន បីតិ ឧប្បជ្ជិ តាវទេ
ពុទ្ធោ ពុទ្ធោតិ កថយន្តា តិដ្ឋន្តិ បញ្ជលីកតា ។
ហិង្ការំ សាធុការញ្ច ឧក្កុដ្ឋិ សម្បនាទនំ
បជា ច(២) វិវិធា គគនេ វន្ទន្តិ បញ្ជលីកតា ។

គាយន្តិ សេឡេន្តិ ច វាទយន្តិ ច
ភុជានិ ផោដេន្តិ ច នច្ចយន្តិ ច
មុញ្ចន្តិ បុប្ផំ បន បញ្ចវណ្ណិកំ
មន្ទារវំ ចន្ទនចុណ្ណមិស្សកំ ។

---

១ ឱ. ម. ទិន្ទិមា ។ ២ ឱ. បសន្តោ ឥតិ ។

បម្រៀនទាំងឡាយប្រព្រឹត្តទៅ ឰដ៏អាកាស ជាផ្លូវនៃខ្យល់ ពួកទេវតា ក៏រាយស្គរ ព្រោះឃើញនូវសេចក្តីអស្ចារ្យ ឰដ៏អាកាស ស័ង្ខ ស្រឡៃ សំភោរដ៏ច្រើន ក៏ប្រគំលាន់ឮឡើង ក្នុងកណ្តាលអាកាស ព្រោះឃើញនូវសេចក្តីអស្ចារ្យ ឰដ៏អាកាស ។ ការព្រឺរោម កើតឡើងដល់ពួកយើង ក្នុងថ្ងៃនេះ ចំឡែកពេកណាស់ហ្ន៎ ពួកយើងបាននូវការសម្រេចប្រយោជន៍ ដ៏ទៀងទាត់ ខណៈឈ្មោះថាពួកយើងបានទាន់ហើយ ។ បីតិក៏កើតឡើង ដល់ទេវតាទាំងនោះ ក្នុងខណៈនោះឯង ព្រោះឮពាក្យថាព្រះពុទ្ធ ទេវតាទាំងនោះ ឈរផ្គងអញ្ជលី ពោលសរសើរថាព្រះពុទ្ធៗ ។ ពួកសត្វផ្សេងៗ ផ្គងអញ្ជលី ញុំាងសំឡេងទ្រហឹងអឺងកង សំឡេងសាធុការ សំឡេងហៅឲ្យប្រព្រឹត្តទៅ ក្នុងកណ្តាលអាកាស ។

ទេវតាទាំងឡាយ ច្រៀង ហួច ប្រគំ ទះដៃ
រាំ ជម្រុះនូវផ្កាមន្ទារវៈ មានពណ៌ ៥ ដែល
លាយប្រឡំ ដោយលំអិត នៃខ្លឹមចន្ទន៍ ។

## រតនបង្គមនកណ្ណោ

យថា តុយ្ហំ មហាវីរ បាទេសុ ចក្កលក្ខណំ
ធជំ វជិរបដាកំ វឌ្ឍមានង្កុសាចិតំ ។

រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ
វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ ។

ទសនាគពលំ កាយេ តុយ្ហំ បាកតិកំ ពលំ
ឥទ្ធិពលេន អសមោ ធម្មចក្កប្បវត្តនេ ។

ឯវំ សព្វគុណូបេតំ សព្វង្គសមុបាគតំ
មហាមុនឹ ការុណិកំ លោកនាថំ នមស្យហ ។

អភិវាទនំ ថោមនញ្ច វន្ទនញ្ច បសំសនំ
នមស្សនញ្ច បូជញ្ច សព្វំ អរហសិ តុវំ ។

## រតនចង្កមនកណ្ឌ

(ហើយពោលថា) បពិត្រព្រះអង្គមានព្យាយាមធំ លក្ខណៈនៃចក្រ ទង់ជ័យ កែវវជីរ ទង់ជ្រុង តាក់តែងដោយកង្វេរ កំពុងបំរើនត្រង់ព្រះបាទាទាំងគូ របស់ព្រះអង្គ ៗ ព្រះមានព្រះភាគ ឥតមានបុគ្គលស្មើ បំពោះព្រះរូបផង សីលផង សមាធិផង ប្រាជ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ បំពោះវិមុត្តិ និងការញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ៗ កម្លាំងក្នុងព្រះកាយនៃព្រះអង្គ ជាកម្លាំងប្រក្រតី ស្មើនឹងកម្លាំងដំរី ១០ ព្រះអង្គឥតមានបុគ្គលប្រៀបផ្ទឹមស្មើ ដោយកម្លាំងនៃឫទ្ធិ ក្នុងការញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ៗ អ្នកទាំងឡាយ ចូរនាំគ្នាក្រាបថ្វាយបង្គំនូវព្រះមហាមុនី ព្រះអង្គបរិបូណ៌ដោយគុណទាំងពួង ប្រកបដោយអវយវៈទាំងពួង ទ្រង់មានករុណាជាទីពឹងនៃលោក ៗ ព្រះអង្គជាបុគ្គលគួរទទួលនូវកិច្ចទាំងពួង របស់ពួកជន គឺការក្រាបសំពះ ការស្ងើច ការថ្វាយបង្គំ ការសរសើរ ការនមស្ការ និងការបូជា ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

យេកេចិ លោកេ វត្តន្តេយ្យា វត្តំ អរហន្តិ យេ
សព្វេសេដ្ឋា មហាវីរ សទិសោ តេ ន វិជ្ជតិ ។
សារីបុត្តោ មហាបញ្ញោ សមាធិជ្ឈានកោវិទោ
កិច្ចត្ថេ ឋិតោយេវ បស្សតិ លោកនាយកំ ។
សុផុល្លំ សាលរាជំវ ចន្ទំវ គគនេ យថា
មជ្ឈន្តិកេវ សុរិយំ ឱលោកេតិ នភសំ ។
ជលន្តំ ទីបរុក្ខំវ តរុណសុរិយំវ ឧគ្គតំ
ព្យាមប្បភានុរញ្ជិតំ បស្សតិ លោកនាយកំ ។
បញ្ចន្នំ ភិក្ខុសតានំ កតកិច្ចាន តាទិនំ
ខីណាសវានំ វិមលានំ ខណេន សន្និបាតយិ ។
លោកប្បសាទនំ នាម បាដិហីរំ និទស្សយិ
អម្ហេបិ តត្ថ គន្ត្វាន វន្ទិស្សាម មយំ ជិនំ ។

ជនទាំងឡាយណាមួយ ក្នុងលោក ដែលគួរគេថ្វាយបង្គំ ឬជនទាំងឡាយណា គួរដល់ការថ្វាយបង្គំ បពិត្រព្រះអង្គមានព្យាយាមធំ ព្រះអង្គជាបុគ្គលប្រសើរបំផុត ជាងជនទាំងអស់នោះ បុគ្គលស្មើទឹងព្រះអង្គមិនមានឡើយ ។ ព្រះសារីបុត្រមានប្រាជ្ញាច្រើន ជាអ្នកឈ្លាសក្នុងសមាធិនិងឈាន ឋិតនៅលើភ្នំគិជ្ឈកូដ ឃើញព្រះលោកនាយក ។ សំឡឹងមើលព្រះសម្ពុទ្ធទ្រង់ប្រសើរជាងទេវៈ ហាក់ដូចជាដើមរាំងភ្នំ ដែលមានផ្ការីកស្គុះស្គាយ ដូចព្រះចន្ទ្រកណ្ដាលអាកាស ឬដូចជាព្រះអាទិត្យត្រង់ជាក់ ។ ឃើញព្រះលោកនាយក មានរស្មីផ្សាយចេញមួយព្យាម រុងរឿងដូចឈើប្រទាំទីប ឬដូចព្រះអាទិត្យស្រទន់ ដែលទើបទឹងរះឡើង ។ ខណៈនោះ ព្រះសារីបុត្របានប្រជុំពួកភិក្ខុចំនួន ៥០០ រូប ជាអ្នកមានសោឡសកិច្ចធ្វើហើយ ជាតាទិបុគ្គល ជាព្រះខីណាស្រព ប្រាសចាកមន្ទិលហើយសម្ដែងនូវបាដិហារិយៈ ឈ្មោះលោកប្បសាទនៈថា ពួកយើងនឹងទៅក្នុងទីនោះ ហើយថ្វាយបង្គំព្រះជិនស្រី ។

## វតខបង្កមខកណ្ឌោ

ឯថ សព្វេ គមិស្សាម　　បុច្ឆិស្សាម មយំ ជិនំ
កង្ខំ វិនោទយិស្សាម　　បស្សិត្វា លោកនាយកំ ។
សាធូតិ តេ បដិស្សុត្វា　　និបកា សំវុតិន្ទ្រិយា
បត្តចីវរមាទាយ　　តរមានា ឧបាគមុំ ។
ខីណាសវេហិ វិមលេហិ　　ទន្តេហិ ឧត្តមេ ទមេ
សារីបុត្តោ មហាបញ្ញោ　　ឥទ្ធិយា ឧបសង្កមិ ។
តេហិ ភិក្ខូហិ បរិវុតោ　　សារីបុត្តោ មហាគណី
លឡន្តោ(១) ទេវោវ គគនេ　　ឥទ្ធិយា ឧបសង្កមិ ។
ឧក្កាសិតញ្ច ខិបិតញ្ច　　អជ្ឈុបេក្ខិត្វាន សុព្វតា
សគារវា សប្បតិស្សា　　សម្ពុទ្ធំ ឧបសង្កមុំ ។
ឧបសង្កមិត្វា បស្សន្តិ　　សយម្ភុំ លោកនាយកំ
នភេ អព្ភុគ្គតំ វីរំ　　ចន្ទំវ គគនេ យថា ។

---

១ ម. កីឡន្តោ ។

## រតនចង្កមនកណ្ឌ

លោកទាំងឡាយចូរមក យើងទាំងអស់គ្នា នឹងទៅសាក-សួរព្រះជិនស្រី បានចួបព្រះលោកនាយកហើយ នឹងបន្ទោ-បង់នូវសេចក្ដីសង្ស័យ ៗ ឯពួកភិក្ខុទាំងនោះ ជាអ្នកមានប្រាជ្ញាចាស់ក្លា សង្រួមឥន្ទ្រិយ ក៏ទទួលព្រមថាសាធុ ហើយប្រដាប់បាត្រនិងចីវរ ដើរទៅជាប្រញាប់ ៗ ព្រះសារីបុត្រមានប្រាជ្ញាច្រើន (ឋិតនៅ) ក្នុងការទូន្មានដ៏ឧត្ដម ក៏ចូលទៅរក (ព្រះមានព្រះភាគ) ដោយឫទ្ធិ ជាមួយនឹងព្រះខីណាស្រពទាំងឡាយ ដែលជាអ្នកប្រាសចាកមន្ទិល មានឥន្ទ្រិយទូន្មាន ៗ ព្រះសារីបុត្រ ដែលមានពួកភិក្ខុទាំងនោះហែហម ជាអ្នកមានពួកដ៏ធំ ចូលទៅដោយឫទ្ធិ ដូចទេវតាកាលលេងសប្បាយដ៏ឰអាកាស ៗ ពួកភិក្ខុទាំងនោះ ជាអ្នកមានវត្តល្អ ប្រកបដោយសេចក្ដីគោរព ប្រកបដោយសេចក្ដីកោតក្រែង អត់ទ្រាំនូវការក្អកនិងកណ្ដាស់ ចូលគាល់ព្រះសម្ពុទ្ធ ៗ លុះចូលទៅគាល់ហើយ ក៏បានឃើញព្រះសយម្ភូ ជាលោកនាយក មានព្យាយាម ទ្រង់ហោះទៅឰដ៏អាកាស ហាក់ដូចជាព្រះចន្ទ្រ នាកណ្ដាលអាកាស ៗ

ជលន្តំ ទីបរុក្ខំវ វិជ្ជុវ គគនេ យថា
មជ្ឈន្តិកេវ សុរិយំ បស្សន្តិ លោកនាយកំ ។
បញ្ចភិក្ខុសតា សព្វេ បស្សន្តិ លោកនាយកំ
រហទមិវ វិប្បសន្នំ សុផុល្លំ បទុមំ យថា ។
អញ្ជលឹ បគ្គហេត្វាន តុដ្ឋហដ្ឋា បមោទិតា
នមស្សមានា និបតន្តិ សត្ថុនោ ចក្កលក្ខណេ ។
សារីបុត្តោ មហាបញ្ញោ កោរណ្ឌសមសាទិសោ
សមាធិជ្ឈានកុសលោ វន្ទតិ លោកនាយកំ ។
គជ្ជិតោ កាលមេឃោវ នីលុប្បលសមសាទិសោ
ឥទ្ធិពលេន អសមោ មោគ្គល្លានោ មហិទ្ធិកោ ។
មហាកស្សបោបិ ថេរោ ឧត្តតកនកសន្និភោ
ធុតគុណេ អគ្គនិក្ខិត្តោ ថោមិតោ សត្ថុវណ្ណិតោ ។
ទិព្វចក្ខូន យោ អគ្គោ អនុរុទ្ធោ មហាគណី
ញាតិសេដ្ឋោ ភគវតោ អវិទូរេវ តិដ្ឋតិ ។

ឃើញព្រះលោកនាយក រុងរឿងដូចឈើប្រចាំទ្វីប ដូចផ្កេក-បន្ទោរពួងអាកាស ឬដូចព្រះអាទិត្យត្រង់ជាក់ ៗ ភិក្ខុទាំង ៥០០ រូប ឃើញព្រះលោកនាយក ទ្រង់ថ្លាស្អាត ដូចអន្លង់ទឹក ឬដូចផ្កាឈូកដែលរីកស្គុះស្គាយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ ហើយផ្គងអញ្ជលីក្រាបថ្វាយបង្គំព្រះបាទាដ៏ប្រដាប់ដោយលក្ខណៈនៃចក្រ របស់ព្រះសាស្តា ៗ ព្រះសារីបុត្រ មានប្រាជ្ញាច្រើន ប្រាកដស្មើដោយផ្កាស្មៅកន្ទុយដំរី ជាអ្នកឈ្លាសក្នុងសមាធិនិងឈាន ក្រាបថ្វាយបង្គំនូវព្រះលោកនាយក ៗ ព្រះមោគ្គល្លានមានឫទ្ធិច្រើន ឥតមានបុគ្គលស្មើ ដោយកម្លាំងនៃឫទ្ធិ ប្រាកដស្មើដោយផ្កាឧប្បលខៀវ ប្រៀបដូចជាកាលមេឃគំទរ ៗ ព្រះមហាកស្សបត្ថេររុងរឿងដូចជាមាស ដែលព្រះសាស្តាសរសើរ លើកតម្កើងតំកល់ក្នុងឋានៈដ៏ប្រសើរ ខាងធុតង្គគុណ ៗ ឯព្រះអនុរុទ្ធជាអ្នកប្រសើរ ជាងពួកបុគ្គលមានចក្ខុទិព្វ មានពួកច្រើនជាអ្នកប្រសើរក្នុងញាតិ ឋិតនៅក្នុងទីជិតព្រះមានព្រះភាគ ៗ

## រតនបង្កមនកណ្ឌោ

អាបត្តិអនាបត្តិយា  សតេកិច្ឆាយ ទេសនា
វិនយេ អគ្គនិក្ខិត្តោ  ឧបាលិ សត្ថុវណ្ណិតោ ។
សុខុមនិបុណត្ថបដិវិទ្ធោ  កថិកានំ បវរោ គណី
ឥសិ មន្តានិយា បុត្តោ  បុណ្ណោ នាមាតិ វិស្សុតោ ។
ឯតេសំ ចិត្តមញ្ញាយ  ឱបម្មកុសលោ មុនិ
កង្ខច្ឆេទោ មហាវីរោ  កថេសិ អត្តនោ គុណំ ។
ចត្តារោ តេ អសង្ខេយ្យា  កោដិ យេសំ ន នាយតិ
សត្តកាយោ ច អាកាសោ  ចក្កវាឡា អនន្តកា
ពុទ្ធញាណំ អប្បមេយ្យំ  ន សក្កា ឯតេ វិជានិតុំ ។
កិមេតំ អច្ឆរិយំ លោកេ  យំ មេ ឥទ្ធិវិកុព្វនំ
អញ្ញេ ពហូ អច្ឆរិយា  អព្ភុតា លោមហំសនា ។

## រតនបង្គមនកណ្ឌ

ព្រះឧបាលិ អ្នកឈ្លាសក្នុងអាបត្តិ និងអនាបត្តិ ទាំងអាបត្តិនៅកែបាន ដែលព្រះសាស្តាសរសើរតាំងទុក ថាជាអ្នកប្រសើរខាងវិន័យ ។ ភិក្ខុជាកូននៃនាងមន្តានី ប្រាកដនាមថា បុណ្ណៈ អ្នកចាក់ធ្លុះនូវអត្ថដ៏ល្អិតល្អន់ ប្រសើរជាងពួកធម្មកថិក ជាអ្នកមានពួក ។ ព្រះមុនី ទ្រង់ឈ្លាសក្នុងពាក្យឧបមា ទ្រង់ជ្រាបនូវចិត្តនៃភិក្ខុទាំងឡាយនុ៎ះ ទ្រង់មានព្យាយាមធំ កាត់នូវសេចក្តីសង្ស័យ ទ្រង់សម្តែងនូវគុណ របស់ព្រះអង្គ ។ ទីបំផុតនៃអសង្ខ្យេយ្យទាំងឡាយណា ដែលបុគ្គលដឹងមិនបាន អសង្ខ្យេយ្យទាំងនោះ មាន ៤ ប្រការ អសង្ខ្យេយ្យទាំងនុ៎ះ គឺ ពួកសត្វ ១ អាកាស ១ ចក្កវាឡមិនមានទីបំផុត ១ ពុទ្ធញាណដែលប្រមាណមិនបាន ១ បុគ្គលមិនអាចដឹងបានឡើយ ។ ( ព្រះសាស្តាទ្រង់ត្រាស់ថា ) ការដែលតថាគតធ្វើឫទ្ធិប្លែកៗ ណា ការធ្វើឫទ្ធិប្លែកៗនុ៎ះ នឹងទុកជាហេតុអស្ចារ្យក្នុងលោក ដូចម្តេចបាន ព្រោះហេតុជាអស្ចារ្យចម្លែកគួរព្រឺរោម ដទៃទៀត នៅមានច្រើន ។

យថាហំ តុសិតេ កាយេ   សន្តុសិតោ នាមហំ តទា
ទសសហស្សី សមាគម្ម   យាចន្តិ បញ្ជលី មមំ ។
កាលោយំ តេ មហាវីរ   ឧប្បជ្ជ មាតុកុច្ឆិយំ
សទេវកំ តារយន្តោ   ពុជ្ឈស្សុ អមតំ បទំ ។
តុសិតា កាយា ចវិត្វាន   យទា ឱក្កមិ កុច្ឆិយំ
ទសសហស្សី លោកធាតុ   កម្បិត្ថ ធរណី តទា ។
យទាហំ មាតុកុច្ឆិតោ   សម្បជានោវ និក្ខមឹ
សាធុការំ បវត្តេន្តិ   ទសសហស្សី បកម្បថ ។
ឱក្កន្តិ មេ សមោ នត្ថិ   ជាតិតោ អភិនិក្ខមេ
សម្ពោធិយំ អហំ សេដ្ឋោ   ធម្មចក្កប្បវត្តនេ ។
អហោ អច្ឆរិយំ លោកេ   ពុទ្ធានំ គុណមហន្តតា
ទសសហស្សី លោកធាតុ   ឆប្បការំ[១] បកម្បថ ។

---

១. ឱ. ឆព្ពិការំ ។

កាលដែលតថាគត នៅជាទេវបុត្រឈ្មោះសន្តុសិតៈ ក្នុងពួកទេវបុត្រជាន់តុសិត កាលនោះ ទេវតាមួយម៉ឺនលោកធាតុ មកប្រជុំគ្នា ធ្វើអញ្ជលីអារាធនាតថាគតថា បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះគួរដល់ព្រះអង្គហើយ សូមព្រះអង្គទ្រង់កើត ក្នុងផ្ទៃនៃព្រះមាតា ចម្លងមនុស្សលោកព្រមទាំងទេវលោក សូមទ្រង់ត្រាស់ដឹងនូវព្រះនិព្វាន ឈ្មោះអមតៈ ។ កាលណា តថាគតច្យុតចាកពួកទេវតាជាន់តុសិត មកចាប់បដិសន្ធិក្នុងផ្ទៃ (នៃមាតា) កាលនោះ លោកធាតុមួយម៉ឺន និងព្រះធរណី ញាប់ញ័រ ។ កាលដែលតថាគតប្រសូតចាកផ្ទៃមាតា ក៏ដឹងខ្លួនច្បាស់លាស់ ពួកទេវតាញុំាងសាធុការឲ្យប្រព្រឹត្តទៅ លោកធាតុមួយម៉ឺន ញាប់ញ័រ ។ តថាគត មិនមានបុគ្គលស្មើ ក្នុងការចុះកាន់គភ៌ព្រះមាតានៃតថាគតជាបុគ្គលប្រសើរបំផុត ក្នុងការប្រសូតិចាកផ្ទៃមាតា ក្នុងការត្រាស់ដឹង និងការញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ។ ឱ ! ព្រះពុទ្ធទាំងឡាយមានគុណដ៏ធំ ជាអស្ចារ្យក្នុងលោក ពេកណាស់ លោកធាតុមួយម៉ឺន ញាប់ញ័រ អស់វារៈ ៦ លើក ។

## រតនចង្កមនកណ្ឌោ

ឱភាសោ ច មហា អាសិ អច្ឆរំ លោមហំសនំ
ភកភ ច តម្ហិ សមយេ លោកជេដ្ឋោ នរាសភោ ។
សនេវកំ ទស្សយន្តោ ឥទ្ធិយា ចង្កមី ជិនោ
ចង្កមេ ចង្កមន្តោវ កថេសិ លោកនាយកោ ។
អគ្គភ ឯ ធិវត្តតិ ចតុហត្ថេ ចង្កមេ យថា
សារីបុត្តោ មហាបញ្ញោ សមាធិជ្ឈានកោវិទោ ។
បញ្ញាយ បារមិប្បត្តោ បុច្ឆតិ លោកនាយកំ
កីទិសោ តេ មហាវីរ អភិនីហារោ នរុត្តម ។
កម្ហិ កាលេ តយា វីរ បត្ថិតា ពោធិមុត្តមា
ទានំ សីលញ្ច នេក្ខម្មំ បញ្ញាវីរិយញ្ច កីទិសំ ។
ខន្តិសច្ចមធិដ្ឋានំ មេត្តុបេក្ខា ច កីទិសា
ទសបារមី មហាវីរ កីទិសា លោកនាយក
កថំ ឧបបារមី បុណ្ណា បរមត្ថបារមី កថំ ។

## រតនចង្កមនកណ្ឌ

ពន្លឺដ៏ធំក៏កើតមាន ទាំងសេចក្ដីអស្ចារ្យ គួរព្រឺរោម ក៏កើតឡើង ៗ សម័យនោះ ព្រះជិនស្រីមានព្រះភាគ ជាចម្បងក្នុងលោក ប្រសើរជាងនរៈ ទ្រង់ចង្ក្រមបង្ហាញឲ្យមនុស្ស-លោក ព្រមទាំងទេវលោក មើលឃើញដោយឫទ្ធិ ៗ ព្រះលោកនាយក ចង្ក្រមក្នុងទីចង្ក្រម ទ្រង់មានព្រះបន្ទូល ទ្រង់មិនត្រឡប់វិញ ត្រង់ពាក់កណ្ដាល ហាក់ដូចជាចង្ក្រមក្នុងទីចង្ក្រមប្រវែង៤ហត្ថ ៗ ព្រះសារីបុត្រមានប្រាជ្ញាច្រើន ឆ្លៀវឆ្លាសក្នុងសមាធិនិងឈាន ជាអ្នកដល់នូវបារមីនៃប្រាជ្ញា បានក្រាបបង្គំទូលសួរព្រះលោកនាយកដូច្នេះថា បពិត្រព្រះអង្គមានព្យាយាមធំ ទ្រង់ប្រសើរជាងនរៈ អភិនីហាររបស់ព្រះអង្គតើដូចម្ដេច បពិត្រព្រះអង្គមានព្យាយាម ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ព្រះអង្គប្រាថ្នា តាំងពីក្នុងកាលណា ៗ ទាន សីល នេក្ខម្មៈ បញ្ញានិងវីរិយៈ តើដូចម្ដេច ខន្តិ សច្ចៈនិងអធិដ្ឋាន មេត្តានិងឧបេក្ខា តើដូចម្ដេចៗ បពិត្រព្រះអង្គមានព្យាយាមធំ ជាលោក-នាយក បារមី ១០ តើដូចម្ដេច ឧបបារមី ១០ ដែលបរិបូណ៌ តើដូចម្ដេច បរមត្ថបារមី ១០ ដែលបរិបូណ៌ តើដូចម្ដេច ៗ

កតិកម្មអធិដ្ឋាយ អធិបតី ច កីទិសា
កីទិសា បារមី ហោន្តិ ធីរ លោកស្មិ កីទិសា ។
មេត្តា ករុណា មុទិតា ឧបេក្ខា ចាបិ កីទិសា
កីទិសំ ពុទ្ធធម្មំ កេវលំ បរិបូរយ(១) ។
តស្ស បុដ្ឋោ វិយាកាសិ(២) ករវីកមធុរគិរោ
និព្វាបយន្តោ ហទយំ ហាសយន្តោ សទេវកំ ។

អតីតពុទ្ធានំ ជិនានំ ទេសិតំ
និកីឡិតំ ពុទ្ធបរម្បរាគតំ
បុព្វេ និវាសានុគតាយ ពុទ្ធិយា
បកាសយី លោកហិតំ សទេវកេ ។

---

១ ឱ.ម. កតិកម្មអធិដ្ឋយ . . . កេវលំ បរិបូរយាតិ ឥមេ បាឋា ន ទិស្សន្តិ ។ ២ ឱ. វ្យាកាសិ ។

អធិបតីធម៌ទាំងឡាយ អធិដ្ឋាននូវកតិកម្ម ដូចម្តេច បារមីទាំងឡាយ ដូចម្តេច អ្នកប្រាជ្ញទាំងឡាយក្នុងលោក តើដូចម្តេច ៗ មេត្តា ករុណា មុទិតា និងឧបេក្ខា តើដូចម្តេច ព្រះពុទ្ធទ្រង់បំពេញពុទ្ធធម៌ ដ៏ពេញលេញ ដូចម្តេច ៗ ព្រះពុទ្ធទ្រង់មានព្រះសូរសៀងពីរោះ ដូចជាសត្វករវិក ទ្រង់ញុំាងហឫទ័យ (នៃពួកសត្វ) ឲ្យរលត់ ញុំាងមនុស្សលោក ព្រមទាំងទេវលោក ឲ្យស្រស់ស្រាយ ដែលព្រះសារីបុត្តសាកសួរហើយ ទ្រង់ដោះស្រាយដល់ព្រះសារីបុត្រនោះវិញ ៗ

ព្រះសម្ពុទ្ធទ្រង់ប្រកាស នូវរឿង(១) ដែលព្រះ
ជិនស្រីជាអតីតពុទ្ធទាំងឡាយ ទ្រង់សម្តែងចង
ទុកហើយ ដែលជាប់តមកតាំងពីព្រះពុទ្ធទីបង្ករ
ជាប្រយោជន៍ ក្នុងលោក ព្រមទាំងទេវលោក
ដោយប្រាជ្ញាដែលប្រព្រឹត្តទៅតាមបុព្វេនិវាស ៗ

---

១– រឿងដែលលោកចងទុក គឺ គោត្រ អាយុ ដើមពោធិព្រឹក្ស សាវកសាវិកាសន្និបាត ឧបដ្ឋាក មាតា បិតា បុត្រ ភរិយាជាដើម ។ អដ្ឋកថា ។

បីតិបាមោជ្ជជននំ សោកសល្លវិនោទនំ
សព្វសម្បត្តិបដិលាភំ ចិត្តី(១) កត្វា សុណាថ មេ ។
មទនិម្មទនំ សោកនុទំ សំសារបរិមោចនំ
សព្វទុក្ខក្ខយំ មគ្គំ សក្កច្ចំ បដិបជ្ជថ ។

រតនចង្កមនកណ្ឌោ និដ្ឋិតោ ។

# បឋមោ ទីបង្ករពុទ្ធវំសោ

(២) កប្បេ ច សតសហស្សេ ចតុរោ ច អសង្ខិយេ
អមរំ នាម នគរំ ទស្សនេយ្យំ មនោរមំ ។
ទសហិ សទ្ទេហិ អវិវិត្តំ អន្នបានសមាយុតំ
ហត្ថិសទ្ទំ . អស្សសទ្ទំ ភេរិសង្ខរថានិ ច ។

---

១ ឱ. ម. ចិត្តិ ។

ទីបង្ករពុទ្ធវង្ស ទី ១

អ្នកទាំងឡាយ ចូរតាំងចិត្តប្រុងស្ដាប់ (នូវពុទ្ធវង្សទេសនា) របស់តថាគត ជាគ្រឿងញុំាងបីតិនិងបាមោជ្ជៈឲ្យកើត បន្ទាបង់នូវសរ គឺសេចក្ដីសោកក្ងាន ជាហេតុបាននូវសម្បត្តិទាំងពួង ៗ អ្នកទាំងឡាយចូរប្រតិបត្តិនូវមគ្គ ជាគ្រឿងញុំាញីនូវសេចក្ដីស្រវឹង បន្ទោបង់នូវសេចក្ដីសោក អាចដោះខ្លួនឲ្យរួចចាកសង្សារ ជាគ្រឿងអស់ទៅ នៃទុក្ខទាំងពួងបាន ដោយគោរពចុះ ៗ

ចប់ រតនចង្កមនកណ្ឌ ។

## ទីបង្ករពុទ្ធវង្ស ទី ១

(២) ក្នុង ៤ អសង្ខេយ្យនិងមួយសែនកប្ប មាននគរឈ្មោះអមរវតី ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌ដោយបាយនិងទឹក ទាំងមិនស្ងាត់ ដោយមានសំឡេង ១០ យ៉ាង គឺ សម្លេងដំរី សម្លេងសេះ សម្លេងស្គរ សម្លេងស័ង្ខ និងសម្លេងរថ ជាដើម ៗ

ខាទថ បិវថ ចេវ
អន្នបានេន ឃោសិតំ
នគរំ សព្វង្គសម្បន្នំ
សព្វកម្មមុបាគតំ(១) ។
សត្តរតនសម្បន្នំ
នានាជនសមាកុលំ
សមិទ្ធំ ទេវនគរំវ(២)
អាវាសំ បុញ្ញកម្មិនំ ។
នគរេ អមរវតិយា
សុមេធោ នាម ព្រាហ្មណោ
អនេកកោដិសន្និចយោ
បហូតធនធញ្ញវា ។
អជ្ឈាយិកោ មន្តធរោ
តិណ្ណំ វេទាន បារគូ
លក្ខណេ ឥតិហាសេ ច
សទ្ធម្មេ បារមឹ គតោ ។
រហោគតោ និសីទិត្វា
ឯវំ ចិន្តេសហំ តទា
ទុក្ខោ បុនព្ភវោ នាម
សរីរស្ស បភេទនំ(៣) ។
សម្មោហំ មរណំ ទុក្ខំ
ជរាយ អភិមទ្ទិតំ(៤)
ជាតិធម្មោ ជរាធម្មោ
ព្យាធិធម្មោ(៥) ចហន្តទា(៦)
អជរំ អមរំ ខេមំ
បរិយេសិស្សាមិ និព្ពុតឹ ។

---

១ ម. សព្វកាមមុបាគតំ ។ ២ ឱ.ម. ឥវសទ្ទោ នត្ថិ ។ ៣ ឱ.ម. សរីរស្សប ភេទនន្តិ ទិស្សតិ ។ ៤ ឱ.អ. ឥទំ គាថាបាទទ្វយំ នត្ថិ ។ ៥ ឱ. វ្យាធិធម្មោ ។ ៦ ម. សហំ តទា ។

ទាំងជានគរគឹកកងដោយសម្លេង ដែលប្រកបដោយបាយ និងទឹកថា ចូរស៊ី ចូរផឹក ជានគរសម្បូណ៌ដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ដោយការងារគ្រប់យ៉ាង ។ បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេង ៗ សម្រេច (ដោយគ្រឿងបរិភោគ និងឧបភោគទាំងពួង) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។ វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមី ក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ។ កាលនោះ តថាគត នៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្តីទុក្ខដូចគ្នា (សេចក្តីស្លាប់ប្រកបដោយមោហៈនាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។

## បឋមោ ទីបង្ករពុទ្ធវំសោ

យន្នូនិមំ បូតិកាយំ នានាកុណបបូរិតំ
ឆឌ្ឌយិត្វាន គច្ឆេយ្យំ អនបេក្ខោ អនត្ថិកោ ។
អត្ថិ ហេហិតិ សោ មគ្គោ ន សោ សក្កា ន ហេតុយេ
បរិយេសិស្សាមិ តំ មគ្គំ ភវតោ បរិមុត្តិយា ។
យថាបិ ទុក្ខេ វិជ្ជន្តេ សុខំ នាមបិ វិជ្ជតិ
ឯវំ ភវេ វិជ្ជមានេ វិភវោ ឥច្ឆិតព្វកោ ។
យថាបិ ឧណ្ហេ វិជ្ជន្តេ អបរំ វិជ្ជតិ សីតលំ
ឯវំ តិវិធគ្គិ វិជ្ជន្តេ និព្វានំ ឥច្ឆិតព្វកំ ។
យថាបិ បាបេ វិជ្ជន្តេ កល្យាណមបិ វិជ្ជតិ
ឯវមេវ ជាតិ វិជ្ជន្តេ អជាតិ ឥច្ឆិតព្វកំ ។
យថា គូថគតោ បុរិសោ តឡាកំ ទិស្វាន បូរិតំ
ន គវេសតិ តឡាកំ ន ទោសោ តឡាកស្ស សោ ។

## ទីបន្តរពុទ្ធវិស្ស ទី ១

បើដូច្នោះ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះនឹងមានពិត ផ្លូវនោះ មិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។ កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មាន យ៉ាងនោះដែរ ។ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើជាតិមាន ព្រះនិព្វានមិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នាក៏មាន យ៉ាងនោះដែរ ។ បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក ហើយមិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ឯវំ កិលេសមលធោវំ   វិជ្ជន្តេ អមតន្តឡេ

ន គវេសតិ តំ តឡាកំ   ន ទោសោ អមតន្តឡេ ។

យថា អរីហិ បរិរុទ្ធោ   វិជ្ជន្តេ គមនំបថេ

ន បលាយតិ សោ បុរិសោ   ន ទោសោ អញ្ជសស្ស

សោ ។

ឯវំ កិលេសបរិរុទ្ធោ   វិជ្ជមានេ សិវេ បថេ

ន គវេសតិ តំ មគ្គំ   ន ទោសោ សិវមញ្ជសេ ។

យថា ព្យាធិតោ បុរិសោ   វិជ្ជមានេ តិកិច្ឆកេ

ន តិកិច្ឆាបេតិ តំ ព្យាធឹ   ន សោ ទោសោ តិកិច្ឆកេ ។

ឯវំ កិលេសព្យាធីហិ   ទុក្ខិតោ បរិបីឡិតោ

ន គវេសតិ អាចរិយំ   ន សោ ទោសោ វិនាយកេ ។

កាលបើស្រះ គឺព្រះនិព្វាន មានហើយ បុគ្គលមិនស្វែងរកស្រះ សម្រាប់លាង នូវកិលេសជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ៗ បុរស ដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោស នៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ៗ បុរសដែលមានជម្ងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជម្ងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គលត្រូវជម្ងឺ គឺកិលេសទាំងឡាយ បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះមិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ៗ

## បឋមោ ទីបង្ករពុទ្ធវំសោ

យន្នូនិមំ បូតិកាយំ    នានាកុណបបូរិតំ

ឆឌ្ឌយិត្វាន គច្ឆេយ្យំ    អនបេក្ខោ អនត្ថិកោ[១] ។

យថាបិ កុណបំ បុរិសោ    កណ្ឋេ ពទ្ធំ ជិគុច្ឆិយំ

មោចយិត្វាន គច្ឆេយ្យ    សុខី សេរី សយំវសី ។

តថេវិមំ បូតិកាយំ    នានាកុណបសញ្ចយំ

ឆឌ្ឌយិត្វាន គច្ឆេយ្យំ    អនបេក្ខោ អនត្ថិកោ ។

យថា ឧស្សាសឋានម្ហិ[១]    ករីសំ នរនារិយោ

ឆឌ្ឌយិត្វាន គច្ឆន្តិ    អនបេក្ខា អនត្ថិកា ។

ឯវមេវាហំ ឥម កាយំ    នានាកុណបបូរិតំ

ឆឌ្ឌយិត្វាន គច្ឆិស្សំ    វច្ចំ កត្វា យថា កុដឹ ។

## ទីបង្ករពុទ្ធវង្ស ទី ១

(បើដូច្នោះ) គួរតែអាត្មាអញ លះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេង ៗ ចេញ គប្បីជាអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ហើយចេញទៅ ។ បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើម ដែលជាប់ឭដ៏ក គប្បីជាអ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមក នូវសាកសពផ្សេងៗចេញ ហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ចេញទៅ យ៉ាងនោះដែរ ។ បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសៈ ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញ ទឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេង ៗ ចេញទៅ ដូចបុរសស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

យថាបិ ជជ្ជរំ នាវំ បលុត្តំ(១) ឧទកគាហិនឹ
សាមិកា ឆឌ្ឌយិត្វាន(២) អនបេក្ខា អនត្ថិកា ។
ឯវមេវាហំ ឥមំ កាយំ នវច្ឆិទ្ទំ ធុវស្សវំ
ឆឌ្ឌយិត្វាន គច្ឆិស្សំ ជិណ្ណនាវំវ សាមិកា ។
យថា បុរិសោ ចោរេហិ គច្ឆន្តោ ភណ្ឌមាទិយ
ភណ្ឌច្ឆេទភយំ ទិស្វា ឆឌ្ឌយិត្វាន គច្ឆតិ ។
ឯវមេវ អយំ កាយោ មហាចោរសមោ វិយ
បហាយិមំ គមិស្សាមិ កុសលច្ឆេទនា ភយា ។
ឯវាហំ ចិន្តយិត្វាន នេកកោដិសតំ ធនំ
នាថានាថានំ ទត្វាន ហិមវន្តំ ឧបាគមឹ ។
ហិមវន្តស្សាវិទូរេ ធម្មិកោ នាម បព្វតោ
អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។
ចង្កមំ តត្ថ មាបេសឹ បញ្ចទោសវិវជ្ជិតំ
អដ្ឋគុណសមុបេតំ អភិញ្ញាពលមាហរឹ ។

---

១ ឱ.ម. បលុគ្គំ ។ ២ ឱ. សាមី ឆឌ្ឌេត្វា គច្ឆន្តិ ជហិតុក្កមោ ។

ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានទ្វារ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូកលះបោលទូកចាស់ដូច្នោះឯង ។ បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ។ លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយ ឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រមសាងបណ្ណសាលាក្បែរភ្នំនោះ ។ តថាគត និម្មិតនូវទីសង្ក្រម ដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពលៈ ដែលប្រកបដោយគុណ ៨ ប្រការ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

សាដកំ បជហិំ តត្ថ    នវទោសមុបាគតំ
វាកចីរំ និវាសេសិំ    ទ្វាទសគុណមុបាគតំ ។
អដ្ឋទោសសមាកិណ្ណំ    បជហិំ បណ្ណសាលកំ
ឧបាគមិំ រុក្ខមូលំ    គុណេហិ ទសហុបាគតំ ។
វាបិតំ រោបិតំ ធញ្ញំ    បជហិំ និរវសេសតោ
អនេកគុណសម្បន្នំ    បវត្តផលមាទិយិំ ។
តត្ថប្បធានំ បទហិំ    និសជ្ជដ្ឋានចង្កមេ
អព្ភន្តរម្ហិ សត្តាហេ    អភិញ្ញាពលបាបុណិំ ។
ឯវំ មេ សិទ្ធិបត្តស្ស    វសីភូតស្ស សាសនេ
ទីបង្ករោ នាម ជិនោ    ឧប្បជ្ជិ លោកនាយកោ ។
ឧប្បជ្ជន្តេ ច ជាយន្តេ    ពុជ្ឈន្តេ ធម្មទេសនេ
ចតុរោ និមិត្តេ នាទ្ទសំ    ឈានរតិសមប្បិតោ ។

លះបង់សំពត់សាដក ដែលប្រកបដោយទោស៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង ។ លះបង់ស្រូវដែលគេព្រោះគេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯងបរិបូណ៌ដោយគុណច្រើនប្រការ ។ តថាគតផ្គងព្យាយាមក្នុងអាស្រមបទនោះ (ញុំាងយប់និងថ្ងៃឲ្យកន្លងទៅ) ក្នុងទីអង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពលៈ ក្នុងរវាង ៧ ថ្ងៃ ។ កាលតថាគត សម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុងសាសនានៃតាបស កាលនោះ ព្រះជិនស្រី ព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង ។ កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្រផង តថាគតជាអ្នកឆ្អែតស្កប់ស្កល់ ដោយសេចក្តីត្រេកអរក្នុងឈាន ប៉ុន្តែមិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

បច្ចន្តទេសវិសយេ និមន្តេត្វា តថាគតំ
តស្ស អាគមនំ មគ្គំ សោធេន្តិ តុដ្ឋមានសា ។
អហន្តេន សមយេន និក្ខមិត្វា សកស្សមា
ធុនន្តោ វាកចីរានិ គច្ឆាមិ អម្ពរេ តទា ។
វេទជាតំ ជនំ ទិស្វា តុដ្ឋហដ្ឋំ បមោទិតំ
ឱរោហិត្វាន គគនា មនុស្សេ បុច្ឆិ តាវទេ ។
តុដ្ឋហដ្ឋោ បមុទិតោ វេទជាតោ មហាជនោ
កស្ស សោធិយតិ មគ្គោ អញ្ជសំ វដុមាយនំ ។
តេ មេ បុដ្ឋា វិយាកំសុ ពុទ្ធោ លោកេ អនុត្តរោ
ទីបង្ករោ នាម ជិនោ ឧប្បជ្ជិ លោកនាយកោ
តស្ស សោធិយតេ មគ្គោ អញ្ជសំ វដុមាយនំ ។
ពុទ្ធោតិ មម សុត្វាន បីតិ ឧប្បជ្ជិ តាវទេ
ពុទ្ធោ ពុទ្ធោតិ កថយន្តោ សោមនស្សំ បវេទយឹ ។

ពួកមហាជនក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរ និមន្តព្រះតថាគត បាននាំគ្នាជំរះផ្លូវជាទីមក នៃព្រះតថាគតនោះ ៗ សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញជនកំពុងតែពេញចិត្តត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះអំពីអាកាសហើយសួរមនុស្សទាំងឡាយ ក្នុងខណៈនោះថា មហាជនត្រេកអរ ស្រស់ស្រាយ រីករាយ ពេញចិត្ត ជំរះផ្លូវ គន្លង ប្រឡាយ ដើម្បីអ្នកណា ៗ ពួកជនទាំងនោះដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយកទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជំរះផ្លូវ គន្លង ប្រឡាយដើម្បីព្រះពុទ្ធទីបង្ករនោះ ៗ បីតិកើតឡើងដល់តថាគត ក្នុងខណៈនោះ ព្រោះតែឮពាក្យថាព្រះពុទ្ធ តថាគតទន្ទេញថាព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ហើយក៏បាននូវសោមនស្ស ៗ

## បឋមោ ទីបង្ករពុទ្ធវំសោ

តត្ថ ឋត្វា វិចិន្តេសឹ តុដ្ឋោ សំវិគ្គមានសោ
ឥធ វីជានិ រោបិស្សំ ខណោ វេ មា ឧបច្ចគា ។
យទិ ពុទ្ធស្ស សោតេន ឱកាសំ ជនាថ មេ
អហំបិ សោធយិស្សាមិ អញ្ជសំ វដុមាយនំ ។
អទំសុ តេ មមោកាសេ សោធេតុំ អញ្ជសំ តទា
ពុទ្ធោ ពុទ្ធោតិ ចិន្តេន្តោ មគ្គំ សោធេមហន្តទា ។
អនិដ្ឋិតេ មមោកាសេ ទីបង្ករោ មហាមុនិ
ចតូហិ សតសហស្សេហិ ឆឡភិញ្ញេហិ តាទិហិ
ខីណាសវេហិ វិមលេហិ បដិបជ្ជិ អញ្ជសំ ជិនោ ។

បច្ចុគ្គមនា វត្តន្តិ វជ្ជន្តិ ភេរិយោ ពហូ
អាមោទិតា នរមរូ សាធុការំ បវត្តយុំ ។
ទេវា មនុស្សេ បស្សន្តិ មនុស្សា បស្សន្តិ ទេវតា
ឧភោបិ តេ បញ្ជលិកា អនុយន្តិ តថាគតំ ។

ទីបង្ករពុទ្ធវង្ស ទី ១

តថាគតឋិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជកុសល ក្នុងបុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ៗ (លុះគិតដូច្នេះហើយ ក៏និ-យាយទៅរកមហាជនថា) បើអ្នកទាំងឡាយជំរះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជំរះផ្លូវប្រឡាយដែរ ៗ កាលនោះ ពួកជនទាំងនោះ ក៏ឲ្យឱកាសមួយ ដល់តថាគតដើម្បីជំរះផ្លូវ តថាគតគិតថា ព្រះពុទ្ធព្រះពុទ្ធ ដូច្នេះ ជំរះផ្លូវបណ្តើរក្នុងឱកាសនោះ ៗ កាលដែលឱកាស (ផ្លូវ) របស់តថាគត ធ្វើមិនទាន់សម្រេចនៅឡើយ ស្រាប់តែព្រះជិនស្រីជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមកតាមផ្លូវជាមួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាកមន្ទិល ៗ ការក្រោកទទួល (ព្រះសាស្តា) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើនក៏លាន់ឮឡើងគគ្រឹកគគ្រេង ពួកមនុស្សនិងទេវតា ក៏ត្រេក-អរ ញុំាងសាធុការឲ្យប្រព្រឹត្តទៅ ៗ ពួកទេវតាឃើញពួកមនុស្ស ឯពួកមនុស្សក៏ឃើញពួកទេវតា ទេវតានិងមនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលី ដើរដង្ហែព្រះតថាគត ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ទេវា ទិព្វេហិ តុរិយេហិ មនុស្សា មានុសេហិ ច
ឧភោបិ តេ វជ្ជយន្តា អនុយន្តិ តថាគតំ ។
ទិព្វំ មន្ទារវំ បុប្ផំ បទុមំ បារិឆត្តកំ
ទិសោទិសំ ឱកិរន្តិ អាកាសេ នភគា[១] មរូ ។
ទិព្វំ ចន្ទនចុណ្ណញ្ច វរគន្ធញ្ច កេវលំ
ទិសោទិសំ ឱកិរន្តិ អាកាសេ នភគា[១] មរូ ។
ចម្បកំ សលលំ នីបំ នាគបុន្នាគកេតកំ
ទិសោទិសំ ឱកិរន្តិ[២] ភូមិតលគតា នរា ។
កេសេ មុញ្ចិត្វាហំ តត្ថ វាកចីរញ្ច ចម្មកំ
កលលេ បត្ថរិត្វាន អវកុជ្ជោ និបជ្ជហំ ។
អក្កមិត្វាន មំ ពុទ្ធោ សហ សិស្សេហិ គច្ឆតុ
មា នំ កលលំ អក្កមិត្ថ ហិតាយ មេ ភវិស្សតិ ។

---

១ ឱ. អាកាសេ នភគា ។ ម. អាកាសេ នភគតា ។ ២ ឱ. ឧក្ខិបន្តិ ។

ពួកទេវតាប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្សក៏ប្រគំតូរ្យ-តន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលឋិត-នៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្ស ផ្កាឈូក ផ្កាបារិ-ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាសអំពីទិសតូចទិសធំ ។ ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយលំអិតខ្លឹមចន្ទន៍ទិព្វផងគ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អា-កាស ។ ពួកមនុស្សដែលឋិតនៅលើផែនដី ក៏រោយរាយផ្កាចម្បា ផ្កាស្រល់ ផ្កាក្ទម្ព ផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកាកេសអំពីទិសតូចទិសធំ ។ តថាគត រំសាយសក់ ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ (អធិដ្ឋានថា) សូមព្រះពុទ្ធព្រមទាំងពួកសិស្ស ជាន់អាត្មាអញយាងទៅចុះ សូមកុំជាន់ភក់ឡើយការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

បឋវិយំ និបន្នស្ស ឯវំ មេ អាសិ ចេតសោ
ឥច្ឆមានោ អហំ អជ្ជ កិលេសេ ឈាបយេ មម ។
កិំ មេ អញ្ញាតវេសេន ធម្មំ សច្ឆិកតេនិធ
សព្វញ្ញុតំ បាបុណិត្វា ពុទ្ធោ ហោមេ(១) សទេវកេ ។
កិំ មេ ឯកេន តិណ្ណេន បុរិសេន ថាមទស្សិនា
សព្វញ្ញុតំ បាបុណិត្វា សន្តារេស្សំ សទេវកេ ។
ឥមិនា មេ អធិការេន កតេន បុរិសុត្តមេ
សព្វញ្ញុតំ បាបុណាមិ តារេមិ ជនតំ ពហុំ ។
សំសារសោតំ ឆិន្ទិត្វា វិទ្ធំសេត្វា តយោ ភវេ
ធម្មនាវំ សមារុយ្ហ សន្តារេស្សំ សទេវកេ(២) ។

---

១ ឱ. ម. ពុទ្ធោ ហេស្សន្តិ ទាយតិ ។ ២ ឱ. ឥតោ បរំ មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ បព្វជា គុណសម្បត្តិ អធិការោ ច ឆន្ទតា អដ្ឋធម្មសមោធានា អភិនីហារោ សមិជ្ឈតីតិ ឥមេ បាឋ ទិស្សន្តិ ។

## ទីបង្ករពុទ្ធវង្ស ទី ១

កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្ត យ៉ាងនេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយរបស់អញ ក្នុងថ្ងៃនេះក៏បាន ។ តែថាប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោកព្រមទាំងទេវលោក ឲ្យរួចរដោះ (ចាក-សង្សារ) ។ ប្រយោជន៍អ្វីអាត្មាអញជាបុរស សម្តែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោកព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។ តថា-គតនឹងកាត់ខ្សែសង្សារ កំចាត់បង់ភពទាំង ៣ ឡើងជិះលើនាវាគឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ទីបង្ករោ លោកវិទូ អាហុតីនំ បដិគ្គហោ
ឧស្សីសកេ មំ ឋត្វាន ឥទំ វចនមព្រវិ ។
បស្សថ ឥមំ តាបសំ ជដិលំ ឧគ្គតាបនំ
អបរិមេយ្យេ ឥតោ កប្បេ ពុទ្ធោ លោកេ ភវិស្សតិ ។
អហុ(១) កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ(២) សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

---

១ ឱ. អបិ ។ ម. អហោ ។ ២ ឱ.ម. អាទា ។

ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈ របស់តថាគត ត្រាស់ពាក្យនេះថា (ម្នាលភិក្ខុទាំងឡាយ) អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញចាកក្រុងឈ្មោះកបិលវត្ថុ ជាទីរីករាយ តំកល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បានទទួលបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មកតាមផ្លូវដែលគេតាក់តែងយ៉ាងប្រសើរ (អង្គុយ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។

## បឋមោ ទីបង្ករពុទ្ធវំសោ

ឥមស្ស ជនិកា មាតា    មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម    អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច    អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា    សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ    ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច    អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា    សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ    អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ    អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា    អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស    គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ    អសមស្ស មហេសិនោ
អាមោទិតា នរមរូ    ពុទ្ធវីជង្កុរោ អយំ ។

## ទីបង្ករពុទ្ធវង្ស ទី ១

ព្រះជនិកាមាតា របស់តាបសនោះ ទ្រង់មាននាមថាព្រះនាងមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបសនេះ ទ្រង់មានឈ្មោះថាព្រះគោតម អគ្គសាវ័កទាំងពីររូបគឺ កោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ ទ្រង់បម្រើព្រះជិនស្រីនេះ ៗ អគ្គសាវិកាពីររូបគឺ នាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ៗ ឈើជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺ ចិត្តៈ ១ ហត្ថាឡវកៈ ១ ៗ នាងនន្ទមាតានិងនាងឧត្តរា ជាឧបដ្ឋាយិកាដ៏ប្រសើរ ព្រះគោតមមានយសនោះ មានព្រះជន្ម ១០០ វស្សា ៗ ពួកមនុស្សនិងទេវតា លុះឮពាក្យព្យាករណ៍របស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយដោយគិតថា សុមេធតាបសនេះ ជាពូជពន្លក នៃព្រះពុទ្ធ ៗ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ(១) ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
ទីបង្ករោ លោកវិទូ អាហុតីនំ បដិគ្គហោ
មម កម្មំ បកិត្តេត្វា ទក្ខិណបាទមុទ្ធរិ ។
យេ តត្ថ អាសុំ ជិនបុត្តា សព្វេ បទក្ខិណមកំសុ មំ
ទេវា មនុស្សា អសុរា យក្ខា អភិវាទេត្វាន បក្កមុំ ។

---

១ ឱ.ម. អព្ភោថេន្តិ ។

សាមន្តហោទាំងឡាយ ក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ៗ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថាឆ្លងស្ទឹងធំដែរ យ៉ាងណាវិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ៗ ព្រះពុទ្ធទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ៗ សាវ័កទាំងឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវ័កទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ស ក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ៗ

## បឋមោ ទីបង្ករពុទ្ធវំសោ

ទស្សនំ មេ អតិក្កន្តេ សសង្ឃេ លោកនាយកេ
សយនា វុដ្ឋហិត្វាន បល្លង្កំ អាភុជឹ តទា ៗ
សុខេន សុខិតោ ហោមិ បាមោជ្ជេន បមោទិតោ
បីតិយា ច អភិស្សន្នោ បល្លង្កំ អាភុជឹ តទា ៗ
បល្លង្កេន និសីទិត្វា ឯវំ ចិន្តេសហំ តទា
វសីភូតោ អហំ ឈានេ អភិញ្ញាបារមិង្គតោ ៗ
សហស្សិយម្ហិ(១) លោកម្ហិ ឥសយោ នត្ថិ មេ សមា
អសមោ ឥទ្ធិធម្មេសុ អលភឹ ឦទិសំ សុខំ ៗ
បល្លង្កាភុជនេ មយ្ហំ ទសសហស្សាធិវាសិនោ
មហានាទំ បវត្តេសុំ ធុវំ ពុទ្ធោ ភវិស្សសិ ៗ
យា បុព្វេ ពោធិសត្តានំ បល្លង្កវរមាភុជេ
និមិត្តានិ បទិស្សន្តិ តានិ អជ្ជ បទិស្សរេ ៗ
សីតំ ព្យបគតំ ហោតិ ឧណ្ហញ្ច ឧបសម្មតិ
តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ៗ

---

១ ម. ទសសហស្សី ។

## ទីបង្ករពុទ្ធវង្ស ទី ១

កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញរបស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ៗ តថាគតជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយដោយបាមោជ្ជៈ ផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែនក្នុងកាលនោះ ៗ តថាគតអង្គុយពែនភ្នែន គិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ៗ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសី ស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ ៗ ក្នុងកាលដែលតថាគត អង្គុយពែនភ្នែនគិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសម្លេងខ្លាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែន នៃពោធិសត្វទាំងឡាយប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ៗ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ

ទសសហស្សី លោកធាតុ និស្សទ្ទា ហោតិ និរាកុលា
តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
មហាវាតា ន វាយន្តិ ន សន្ទន្តិ សវន្តិយោ
តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
ថលជា ជលជា(១) បុប្ផា សព្វេ បុប្ផន្តិ តាវទេ
តេបជ្ជ បុប្ផិតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។
លតា វា យទិ វា រុក្ខា ផលំ ធារេន្តិ(២) តាវទេ
តេបជ្ជ ផលិតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។
អាកាសដ្ឋា ច ភុម្មដ្ឋា រតនា ជោតន្តិ តាវទេ
តេបជ្ជ រតនា ជោតន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
មានុស្សកា ច ទិព្វា ច តុរិយា វជ្ជន្តិ តាវទេ
តេបជ្ជុភោ អភិរវន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

---

១ ឱ.ម. ទកជា ។ ២ ម. ផលភារា ហោន្តីតិ ទិស្សតិ ។

លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសម្លេង ឥតគឹកគរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ផ្កាទាំងពួង ដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនិងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែ ក្នុងខណៈនោះ វល្លិនិងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ កែវទាំងឡាយ ដែលឋិតនៅឰដ៏អាកាសក្តី ឋិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្យ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ

## បឋមោ ទីបង្ករពុទ្ធវំសោ

វិចិត្តបុប្ផា គគនា អភិវស្សន្តិ តាវទេ
តេបិ អជ្ជ បទិស្សន្តិ(១) ធុវំ ពុទ្ធោ ភវិស្សសិ ។
មហាសមុទ្ទោ អាភុជតិ ទសសហស្សី បកម្បតិ
តេបជ្ជុភោ អភិរវន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
និរយេ ទសសហស្សា អគ្គី និព្វន្តិ តាវទេ
តេបជ្ជ និព្វុតា អគ្គី ធុវំ ពុទ្ធោ ភវិស្សសិ ។
វិមលោ ហោតិ សុរិយោ សព្វា ទិស្សន្តិ តារកា
តេបិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
អនោវុដ្ឋេន(២) ឧទកំ មហិយា ឧព្ភិជ្ជិ តាវទេ
តំបជ្ជុព្ភិជ្ជតេ មហិយា ធុវំ ពុទ្ធោ ភវិស្សសិ ។
តារគណា វិរោចន្តិ នក្ខត្តា គគនមណ្ឌលេ
វិសាខា ចន្ទិមាយុត្តា ធុវំ ពុទ្ធោ ភវិស្សសិ ។

---

១ ម. បវិស្សន្តិ ។ ២ ឱ. អនោវដ្ឋេន ។

## ទីបង្ករពុទ្ធរង្ស ទី ១

ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ មហាសមុទ្រ ក៏ស្រកចុះ លោកធាតុទាំងមួយម៉ឺន ក៏ញាប់ញ័រ ក្នុងខណៈនោះ មហាសមុទ្រនិងលោក-ធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ភ្លើងក្នុងនរកទាំងមួនម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ព្រះអាទិត្យ ប្រាសចាកមន្ទិលផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យនិងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនិងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដី ក្នុងខណៈនោះទឹកក៏ផុសឡើងលើផែនដី ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្ត-ឫក្សទាំងឡាយ ប្រកបដោយព្រះចន្ទវិសាខ (ក៏រុងរឿង) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ

វិលាសយា ទរីសយា    និក្ខមន្តិ សកាសយា
តេបជ្ជ អាសយា ឆុទ្ធា    ធុវំ ពុទ្ធោ ភវិស្សសិ ។
ន ហោតិ អរតិ សត្តានំ    សន្តុដ្ឋា ហោន្តិ តាវទេ
តេបជ្ជ សព្វេ សន្តុដ្ឋា    ធុវំ ពុទ្ធោ ភវិស្សសិ ។
រោគា តទុបសម្មន្តិ(១)    ជិឃច្ឆា ច វិនស្សតិ
តានិបជ្ជ បទិស្សន្តិ    ធុវំ ពុទ្ធោ ភវិស្សសិ ។
រាគោ តទា តនុ ហោតិ    ទោសោ មោហោ វិនស្សតិ
តេបជ្ជ វិគតា សព្វេ    ធុវំ ពុទ្ធោ ភវិស្សសិ ។
ភយំ តទា ន ភវតិ    អជ្ជបេតំ បទិស្សតិ
តេន លិង្គេន ជានាម    ធុវំ ពុទ្ធោ ភវិស្សសិ ។

---

១ ឱ.ម. តទុបសម្មតិ ។

ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ សេចក្តីអផ្សុកមិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេកអរ ក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ រោគទាំងឡាយ ដ៏ស្រាល ៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ រោគក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ទៅ ក្នុងកាលនោះ រោគនិងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ឯភ័យមិនមាន ក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ

## បឋមោ ទីបង្ករពុទ្ធវំសោ

រជោនុទ្ធំសតិ ឧទ្ធំ    អជ្ជបេតំ បទិស្សតិ
តេន លិង្គេន ជានាម    ធុវំ ពុទ្ធោ ភវិស្សសិ ។
អនិដ្ឋគន្ធោ បក្កមតិ    ទិព្វគន្ធោ បវាយតិ
សោបជ្ជ វាយតិ គន្ធោ    ធុវំ ពុទ្ធោ ភវិស្សសិ ។
សព្វេ ទេវា បទិស្សន្តិ    ឋបេត្វា ច(១) អរូបិនោ
តេបជ្ជ សព្វេ ទិស្សន្តិ    ធុវំ ពុទ្ធោ ភវិស្សសិ ។
យាវតា និរយា នាម    សព្វេ ទិស្សន្តិ តាវទេ
តេបជ្ជ សព្វេ ទិស្សន្តិ    ធុវំ ពុទ្ធោ ភវិស្សសិ ។
កុដា(២) កវាដា សេលា ច    ន ហោន្តាវរណា តទា
អាកាសភូតា តេបជ្ជ    ធុវំ ពុទ្ធោ ភវិស្សសិ ។
ចុតិ ច ឧបបត្តិ ច    ខណេ តស្មឹ ន វិជ្ជតិ
តានិ អជ្ជ បទិស្សន្តិ    ធុវំ ពុទ្ធោ ភវិស្សសិ ។

---

១ ឱ. ម. ឋបយិត្វា ។ ២ ឱ, កុដ្ឋា ។

ទីបង្ករពុទ្ធវង្ស ទី ១

ផ្លូវក៏ខ្វាត់ខ្វាយទៅខាងលើ ការខ្វាត់ខ្វាយផ្លូវ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ក្លិនស្អុយ ក៏ផាត់ចេញ ក្លិនទិព្វ ក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរក ទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែងសន្ទះទ្វារនិងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអាកាស (ប្រាកដ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ ចុតិនិងឧបបត្តិ មិនមាន ក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

(ឥមេ និមិត្តា ទិស្សន្តិ សម្ពោធត្ថាយ ទាណានិ[១])

ទឡ្ហំ បគ្គណ្ហ វីរិយំ មា និវត្ត អភិក្កម

មយំបេតំ វិជានាម ធុវំ ពុទ្ធោ ភវិស្សសិ ។

ពុទ្ធស្ស វចនំ សុត្វា ទសសហស្សីន ឧភយំ

តុដ្ឋហដ្ឋា បមោទិតា ឃរំ ចន្ទេសិហាន្តតា ។

អទ្វេជ្ឈវចនា ពុទ្ធា អមោឃវចនា ជិនា

វិតថំ នត្ថិ ពុទ្ធានំ ធុវំ ពុទ្ធោ ភវាមិហំ ។

យថា ខិត្តំ នភេ លេឌ្ឌុំ[២] ធុវំ បតតិ ភូមិយំ

តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។

---

១ ឱ. ម. ឥមេ ៣ហិ ៤ ទិស្សន្តិ ។ ២ ឱ. លេឌ្ឌុ ។ ម. លឌ្ឌុ ។

(និមិត្តទាំងនេះក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មោធិញ្ញាណ) (ពួកសត្វពោលថា បពិត្រសុមេធតាបស) សូមលោកផ្គងព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ តថាគតលុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតា ទាំងមួយម៉ឺនចក្រវាឡហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះយ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រីទាំងឡាយមិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយមិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដីដែលគេចោលទៅ ឰដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញ យ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

វិតថំ នត្ថិ ពុទ្ធានំ　　ធុវំ ពុទ្ធោ ភវាមហំ

យថាបិ សព្វសត្តានំ　　មរណំ ធុវសស្សតំ

តថេវ ពុទ្ធសេដ្ឋានំ　　វចនំ ធុវសស្សតំ។

យថា រត្តិក្ខយេ បត្តេ　　សុរិយុគ្គមនំ ធុវំ

តថេវ ពុទ្ធសេដ្ឋានំ　　វចនំ ធុវសស្សតំ ។

យថា និក្ខន្តសយនស្ស　　សីហស្ស នទនំ ធុវំ

តថេវ ពុទ្ធសេដ្ឋានំ　　វចនំ ធុវសស្សតំ ។

យថា អាបន្នសត្តានំ　　ភារមោរោបនំ ធុវំ

តថេវ ពុទ្ធសេដ្ឋានំ　　វចនំ ធុវសស្សតំ ។

ហន្ទ ពុទ្ធករេ ធម្មេ　　វិចិនាមិ ឥតោ ចិតោ

ឧទ្ធំ អធោ ទសទិសា　　យាវតា ធម្មធាតុយា ។

## ទីបង្ករពុទ្ធវង្ស ទី ១

ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្ដីស្លាប់របស់សត្វសត្វ ទៀងទាត់ប្រាកដ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធប្រសើរទាំងឡាយ ទៀងទាត់ប្រាកដ ដូច្នោះដែរ ៗ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណា ព្រះបន្ទូល របស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ៗ សីហៈដែលចេញអំពីដំណេកតែងបន្លឺសម្លេង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ៗ ការសម្រាលគភ៌ នៃស្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ៗ បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ៗ

វិចិនន្តោ តទា ទក្ខឹ  បឋមំ ទានបារមឹ
បុព្វកេហិ មហេសីហិ  អនុចិណ្ណំ មហាបថំ ។
ឥមំ ត្វំ បឋមំ តាវ  ទឡ្ហំ កត្វា សមាទិយ
ទានបារមិតំ គច្ឆ  យទិ ពោធឹ បត្តុមិច្ឆសិ ។
យថាបិ កុម្ភោ សម្បុណ្ណោ  យស្ស កស្សចិ
អធោកតោ
វមតេ ឧទកំ និស្សេសំ  ន តត្ថ បរិរក្ខតិ ។
តថេវ យាចកេ ទិស្វា  ហីនមុក្កដ្ឋមជ្ឈិមេ
ទទាហិ ទានំ និស្សេសំ  កុម្ភោ វិយ អធោកតោ ។
ន ហេតេ ឯត្តកាយេវ  ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ  យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ទក្ខឹ  ទុតិយំ សីលបារមឹ
បុព្វកេហិ មហេសីហិ  អាសេវិតំ និសេវិតំ ។

កាលនោះ តថាគត កំពុងជ្រើសរើស ក៏បានឃើញទាន-
បារមី ជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពី
បុរាណធ្លាប់សន្សំមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធ-
បណ្ឌិត) អ្នកចូរសមាទាន ធ្វើនូវទានបារមី ជាដំបូងនេះ
ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទាន-
បារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយ ផ្កាប់
ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាង
ណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬ
មធ្យម ចូរឲ្យទាន កុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេ
ផ្កាប់ដូច្នោះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះ
ទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជា
ធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគត
កំពង់ជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិ-
សត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក

ឥមំ ត្វំ ទុតិយំ តាវ ទឡ្ហំ កត្វា សមាទិយ
សីលបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។
យថាបិ ចាមរី វាលំ កិស្មិញ្ចិ បដិលគ្គិតំ
ឧបេតិ មរណំ តត្ថ ន វិកោបេតិ វាលធឹ ។
តថេវ ចតូសុ ភូមីសុ សីលានិ បរិបូរយ
បរិរក្ខ សព្វទា សីលំ ចាមរី វិយ វាលធឹ ។
ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ទក្ខឹ តតិយំ នេក្ខម្មបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ តតិយំ តាវ ទឡ្ហំ កត្វា សមាទិយ
នេក្ខម្មបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

ទីបង្ករពុទ្ធវង្ស ទី ១

(ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកឯងចូរសមាទាន ធ្វើសីលបារមីទី ២ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី (កាលឃើញ) រោមកន្ទុយចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរី រក្សាកន្ទុយ យ៉ាងនោះចុះ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មា-អញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិ-សត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះ ឲ្យមាំមួន បើអ្នកចង់លុះ នូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

យថា អន្ទឃរេ បុរិសោ ចិរំ វុដ្ឋោ ទុក្ខទ្ទិតោ
ន តត្ថ រាគំ អភិជនេតិ មុត្តិំយេវ គវេសតិ ។
តថេវ ត្វំ សព្វភវេ បស្ស អន្ទឃរេ វិយ(១)
នេក្ខម្មាភិមុខោ ហោហិ ភវតោ បរិមុត្តិយា ។
ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ទក្ខិំ ចតុត្ថំ បញ្ញាបារមិំ
បុព្វកេហិ មហេសីហិ អាសេវិតនិសេវិតំ ។
ឥមំ ត្វំ ចតុត្ថំ តាវ ទឡ្ហំ កត្វា សមាទិយ
បញ្ញាបារមិតំ គច្ឆ យទិ ពោធិំ បត្តុមិច្ឆសិ ។
យថាបិ ភិក្ខុ ភិក្ខន្តោ ហីនមុក្កដ្ឋមជ្ឈិមេ
កុលានិ ន វិវជ្ជេន្តោ ឯវំ លភតិ យាបនំ ។
តថេវ ត្វំ សព្វកាលំ បរិបុច្ឆន្តោ ពុធំ ជនំ
បញ្ញាបារមិតំ គន្ត្វា សម្ពោធិំ បាបុណិស្សសិ ។

---

១ ឱ.ម. អន្ទុឃរេ វិយ ។

បុរសដែលជាប់នៅក្នុងគូថ អស់កាលយូរ ត្រូវសេចក្ដីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្ដីត្រេកអរ ឲ្យកើតឡើងក្នុងគូថនោះទេ រមែងស្វែងរកការរួច (ចាកគូថនោះ) យ៉ាងណា អ្នកចូរឃើញ នូវភពទាំងអស់ ដូចជាគូថចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភព យ៉ាងនោះដែរ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះ ឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជនជាអ្នកប្រាជ្ញ សព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ទក្ខឹ បញ្ចមំ វីរិយបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ បញ្ចមំ តាវ ទឡ្ហំ កត្វា សមាទិយ
វីរិយបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។
យថាបិ សីហោ មិគរាជា និសជ្ជដ្ឋានចង្កមេ
អលីនវីរិយោ ហោតិ បគ្គហិតមនោ សទា ។
តថេវ ត្វំ សព្វភវេ បគ្គណ្ហ វីរិយំ ទឡ្ហំ
វីរិយបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។
ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

## ទីបង្ករពុទ្ធវង្សទី ១

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គូផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គូផ្គងព្យាយាមឲ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណ មិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ឆដ្ឋមំ ខន្តិបារមឹ

បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

ឥមំ ត្វំ ឆដ្ឋមំ តាវ ទឡ្ហំ កត្វា សមាទិយ

តត្ថ អទ្វេជ្ឈមានសោ សម្ពោធឹ បាបុណិស្សសិ ។

យថាបិ បឋវី នាម សុចិម្បិ អសុចិម្បិ ច

សព្វំ សហតិ និក្ខេបំ ន ករោតិ បដិឃទយំ ។

តថេវ ត្វំបិ សព្វេសំ(១) សម្មានាវមានក្ខមោ

ខន្តិបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ

អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

---

១ ម. ត្វំ សព្វភវេ ។

កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយ អំពីបុរាណភ្ជាប់សេពភ្ជាប់អាស្រ័យមក (ហើយខ្ញុំនាំខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុងខន្តិបារមីនោះ ទឹងបានដល់នូវពោធិញ្ញាណ មិនខានឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំ ចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំ នូវការរាប់អាន និងការមើលងាយ របស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ ទឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើស រកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណ ឲ្យសម្រេច ។

## បឋមោ ទីបង្ករពុទ្ធវំសោ

វិចិនន្តោ តទា ធម្មេ សត្តមំ សច្ចបារមី
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ សត្តមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ អទ្វេជ្ឈវចនោ សម្ពោធឹ បាបុណិស្សសិ ។
យថាបិ ឱសធិ នាម តុលាភូតា សទេវកេ
សមយេ ឧតុវស្សេ វា ន វោក្កមតិ វីថិតោ ។
តថេវ ត្វំបិ សច្ចេសុ មា វោក្កមសិ វីថិតោ
សច្ចបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។
ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ធម្មេ អដ្ឋមំ អធិដ្ឋានបារមី
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។

## ទីបង្ករពុទ្ធវង្ស ទី ១

កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះ ឲ្យមាំមួន កុំមានពាក្យបែកជាពីរ ក្នុងសច្ចបារមីនោះ ទើបបានសម្រេច សម្ពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផ្កាយព្រឹក ជាដញ្ជីង របស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថី ក្នុងរដូវក្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ៗ អ្នកកុំឃ្លាត ចាកវិថី ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវ សច្ចបារមីហើយ ទើបបានសម្រេចសម្ពោធិញ្ញាណ មិនខាន ឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញ ទើបជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះតថាគត កំពុង ជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក

ឥមំ ត្វំ អដ្ឋមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ ត្វំ និច្ចលោ ហុត្វា សម្ពោធឹ បាបុណិស្សសិ ។
យថាបិ បព្វតោ សេលោ អចលោ សុបតិដ្ឋិតោ
ន កម្បតិ ភុសវាតេហិ សកដ្ឋានេវ តិដ្ឋតិ ។
តថេវ ត្វំ អធិដ្ឋានេ សព្វទា អចលោ ភវ
អធិដ្ឋានបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។
ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ទក្ខឹ នវមំ មេត្តាបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ នវមំ តាវ ទឡ្ហំ កត្វា សមាទិយ
មេត្តាយ អសមោ ហោហិ យទិ ពោធឹ បត្តុមិច្ឆសិ ។

(ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទានធ្វើអធិដ្ឋានបារមីទី៨ នេះឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញាណមិនខានឡើយ ។ ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយ ដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅ ក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើក ក្នុងអធិដ្ឋានបារមី សព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញាណមិនខានឡើយ ។ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀតដែលជាធម៌ញុំាងពោធិញាណ ឲ្យសម្រេច ។ កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយអំពីបូរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញាណ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

យថាបិ ឧទកំ នាម  កល្យាណេ បាបកេ ជនេ
សមំ ផរតិ សីតេន  បវាហេតិ រជោមលំ ។
តថេវ ត្វំ ហិតាហិតេ  សមំ មេត្តាយ ភាវយ
មេត្តាបារមិតំ គន្ត្វា  សម្ពោធឹ បាបុណិស្សសិ ។
ន ហេតេ ឯត្តកាយេវ  ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ  យេ ធម្មា ពោធិបាចនា ។
វិចិនន្តោ តទា ទក្ខឹ  ទសមំ ឧបេក្ខាបារមឹ
បុព្វកេហិ មហេសីហិ  អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ ទសមំ តាវ  ទឡ្ហំ កត្វា សមាទិយ
តុលាភូតោ ទឡ្ហោ ហុត្វា  សម្ពោធឹ បាបុណិស្សតិ ។
យថាបិ បឋវី នាម  និក្ខិត្តំ អសុចឹ សុចឹ
ឧបេក្ខតិ ឧភោបេតេ  កោបានុនយវជ្ជិតា ។

## ទីបង្ករពុទ្ធវង្ស ទី ១

ធម្មតាទឹករមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អទាំងអាក្រក់ រមែងកំចាត់បង់នូវធូលីនិងមន្ទិល យ៉ាងណា ៗ អ្នកចូរបំពេញមេត្តាឲ្យស្មើ ចំពោះមិត្រនិងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ៗ ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណ ឲ្យសម្រេច ៗ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះ ឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ៗ ធម្មតាផែនដីតែងព្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធនិងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា

តថេវ ត្វំ សុខទុក្ខេ តុលាភូតោ សទា ភវ
ឧបេក្ខាបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។
ឯត្តកាយេវ តេ លោកេ យេ ធម្មា ពោធិបាចនា
តទុទ្ធំ នត្ថិ អញ្ញត្រ ទឡ្ហំ តត្ថ បតិដ្ឋហ ។
ឥមេ ធម្មេ សម្មសតោ សភាវសរសលក្ខណេ
ធម្មតេជេន វសុធា ទសសហស្សី បកម្បថ ។
ចលតិ រវតិ បថវី ឧច្ឆុយន្តំវ បីឡិតំ
តេលយន្តំ យថា ចក្កំ ឯវំ កម្បតិ មេទនី ។
យាវតា បរិសា អាសិ ពុទ្ធស្ស បរិវេសនេ
បវេធមានា សា តត្ថ មុច្ឆិតា សេតិ ភូមិយំ ។
ឃដានេកសហស្សានិ កុម្ភីនញ្ច សតា ពហូ
សញ្ចុណ្ណមថិតា តត្ថ អញ្ញមញ្ញំ បឃដ្ដិតា ។

អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីង ចំពោះសុខនិងទុក្ខ សព្វកាល យ៉ាងនោះដែរ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញាណពុំខាន ។ ធម៌ទាំងឡាយណា ជាគ្រឿងញុំាងពោធិញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោក ត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃ ក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះ ឲ្យមាំមួនចុះ ។ កាលតថាគតពិចារណា នូវបារមីធម៌ទាំងនេះ ដោយសភាវសារលក្ខណៈ ផែនដីទាំងមួយមុឺនលោកធាតុ ក៏ញាប់ញ័រ ដោយតេជះនៃធម៌ ។ ផែនដីកំរើកបន្លឺឡើង ដូចជាឃ្នាបអំពៅដែលត្រូវគេគាប ឬចក្រយន្តប្រេង ត្រូវគេគាបហើយ (វង្វិលញ័រ) យ៉ាងណា ផែនដីក៏ញាប់ញ័រ យ៉ាងនោះដែរ ។ បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាស បរិស័ទនោះ ក៏ញាប់ញ័រដេកជ្រប់លើផែនដី ក្នុងទីអង្គាសនោះ ។ ឆ្នាំងជាច្រើនពាន់និងក្អមជាច្រើនរយ ក៏ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ ក្នុងទីនោះ ។

ឧព្ពិគ្គា តសិតា ភីតា ភន្តា ព្យថិតមានសា
មហាជនា សមាគម្ម ទីបង្ករមុបាគមុំ ។
កឹ ភវិស្សតិ លោកស្ស កល្យាណំ អថ បាបកំ
សព្វោ ឧបទ្ទុតោ លោកោ តំ វិនោទេហិ ចក្ខុមា ។
តេសំ តទា សញ្ញាបេសិ ទីបង្ករោ មហាមុនិ
វិសដ្ឋា ហោថ មា ភាថ ឥមស្មឹ បឋវិកម្បនេ ។
យមហំ អជ្ជ ព្យាកាសឹ ពុទ្ធោ លោកេ ភវិស្សតិ
ឯសោ សម្មសតី ធម្មំ បុព្វកំ ជិនសេវិតំ ។
តស្ស សម្មសតោ ធម្មំ ពុទ្ធភូមិមសេសតោ
តេនាយំ កម្បតី បឋវី ទសសហស្សី សទេវកេ ។

## ទីបង្ករពុទ្ធវង្ស ទី ១

ពួកមហាជនមានចិត្តរន្ធត់តក់ស្លុត ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័របំប្រប់ មកប្រជុំគ្នាហើយចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្តេច នឹងមានដល់មនុស្សលោក លោកទាំងមូល ត្រូវសេចក្តីអន្តរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្តីអន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញុំាងមហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមានសេចក្តីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ដ្បិតតថាគតបានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក (ក្នុងកាលជាអនាគត) សុមេធបណ្ឌិត + នុះ កំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពីបូរាណធ្លាប់សេពមក ។ កាលសុមេធបណ្ឌិតពិចារណាធម៌គឺពុទ្ធភូមិ ដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោកព្រមទាំងទេវលោក ញាប់ញ័រ ។

ពុទ្ធស្ស វចនំ សុត្វា  មនោ និព្វាតិ(១) តាវទេ
សព្វេ មំ ឧបសង្កម្ម  បុនបិ អភិវន្ទិសុ ។
សមាទយិត្វា ពុទ្ធគុណំ  ទឡ្ហំ កត្វាន មានសំ
ទីបង្ករំ នមស្សិត្វា  អាសនា វុដ្ឋហឹ តទា ។
ទិព្វំ មានុស្សិកំ បុប្ផំ  ទេវា មានុសកា ឧភោ
សមោកិរន្តិ បុប្ផេហិ  វុដ្ឋហន្តស្ស អាសនា ។
វេទយន្តិ ច តេ សោត្ថឹ  ទេវា មានុសកា ឧភោ
មហន្តំ បត្ថិតំ តុយ្ហំ  តំ លភស្សុ យថិច្ឆិតំ ។
សព្វីតិយោ វិវជ្ជន្តុ  សោកោ រោគោ វិនស្សតុ(២)
មា តេ ភវត្វន្តរាយោ  ផុស្សុ ខិប្បំ ពោធិមុត្តមំ ។
យថា សមយេ សម្បត្តេ  បុប្ផន្តិ បុប្ផិនោ ទុមា
តថេវ ត្វំ មហាវីរ  ពុទ្ធញាណេន បុប្ផសិ ។

១ ឱ. ម. និព្វាយិ ។ ២ ឱ. សព្វរោគោ វិនស្សតូតិ ទិស្សតិ ។

ចិត្ត (នៃមហាជន) ក៏រលត់ស្ងប់ ក្នុងខណៈនោះភ្លាម ព្រោះបានស្ដាប់ព្រះបន្ទូល របស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្ដងទៀត ។ គ្រានោះ តថាគត សមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ។ ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតានិងពួកមនុស្ស ទាំងពីរពួកនោះ បាននូវសួស្ដី (ពោលថា) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាន នូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបវៀសចៀសចេញទៅ សេចក្ដីសោកនិងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្ដីអន្តរាយ កុំបីមានដល់លោកឡើយ សូមលោកបានលុះ នូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ ឆាប់ ៗ ចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កា ដោយពុទ្ធញ្ញាណ យ៉ាងនោះដែរ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

យថា យេ កេចិ សម្ពុទ្ធា ពូរយុំ ទសបារមី
តថេវ ត្វំ មហាវីរ ពូរយ ទសបារមី ។
យថា យេ កេចិ សម្ពុទ្ធា ពោធិមណ្ឌម្ហិ ពុជ្ឈរេ
តថេវ ត្វំ មហាវីរ ពុជ្ឈស្សុ ជិនពោធិយំ ។
យថា យេ កេចិ សម្ពុទ្ធា ធម្មចក្កំ បវត្តយុំ
តថេវ ត្វំ មហាវីរ ធម្មចក្កំ បវត្តយ ។
បុណ្ណមាយំ យថា ចន្ទោ បរិបុណ្ណោ វិរោចតិ
តថេវ ត្វំ បុណ្ណមនោ វិរោច ទសសហស្សិយំ ។
រាហុមុត្តោ យថា សុរិយោ តាបេន អតិរោចតិ
តថេវ លោកា មុញ្ចិត្វា វិរោច សិរិយា តុវំ ។
យថា យា កាចិ នទិយោ ឱសរន្តិ មហោទធឹ
ឯវំ សទេវកា លោកា ឱសរន្តិ តវន្តិកេ ។

## ទីបង្ករពុទ្ធវង្ស ទី ១

ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញហើយ នូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ៗ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹង ទៀបគល់ពោធិមណ្ឌ: យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរត្រាស់ដឹង ទៀបគល់ពោធិមណ្ឌ: នៃព្រះជិនស្រី យ៉ាងនោះ ៗ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅ យ៉ាងនោះចុះ ៗ ព្រះចន្ទ្រពេញវង់ រមែងរុង-រឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញចូររុងរឿងក្នុងលោកធាតុ ទាំងមួយម៉ឺន យ៉ាងនោះ ៗ ព្រះអាទិត្យដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកំដៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះដែរ ៗ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួកលោកព្រមទាំងទេវលោកក៏រមែងប្រជុំក្នុងសំណាក់ របស់លោក យ៉ាងនោះដែរ ៗ

តេហិ ថុតិប្បសត្ថោ សោ ទសធម្មេ សមាទិយ
តេ ធម្មេ បរិបូរេន្តោ បវនំ បាវិសី តទា ។

## សុមេធកថា[1] និដ្ឋិតា ។

តទា តេ ភោជយិត្វាន សសង្ឃំ លោកនាយកំ
ឧបគញ្ឆុំ សរណំ តស្ស ទីបង្ករស្ស សត្ថុនោ ។
សរណាគមនេ កញ្ចិ និវេសេសិ តថាគតោ
កញ្ចិ បញ្ចសុ សីលេសុ សីលេ ទសវិធេ បរំ ។
កស្សចិ ទេតិ សាមញ្ញំ ចតុរោ ផលមុត្តមេ
កស្សចិ អសមេ ធម្មេ ទេតិ សោ បដិសម្ភិទា ។
កស្សចិ វរសមាបត្តិយោ អដ្ឋ ទេតិ នរាសភោ
តិស្សោ កស្សចិ វិជ្ជាយោ ឆឡភិញ្ញា បវេច្ឆតិ ។

---

១ ឱ. សុមេធវត្ថុកថា ។ ម. សុមេធបត្ថនា កថា ។

គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតានិងមនុស្សទាំងនោះ ស្ញើចសរសើរហើយ ក៏សមាទាននូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ។

ចប់ សុមេធកថា ។

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្តាទីបង្ករនោះជាទីពឹង ។ ព្រះតថាគត ទ្រង់ញុំាងបុគ្គលខ្លះ ឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះ ឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គ ដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើ ដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរ ដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។

## បឋមោ ទីបង្ករពុទ្ធវំសោ

តេន យោគេន ជនកាយំ ឱវទតិ មហាមុនិ
តេន វិត្ថារិតំ អាសិ លោកនាថស្ស សាសនំ ។

មហាហនុសភក្ខន្ធោ ទីបង្ករសនាមកោ
ពហុ ជនេ តារយតិ បរិមោចេតិ ទុគ្គតឹ ។

ពោធនេយ្យជនំ ទិស្វា សតសហស្សេបិ យោជនេ
ខណេន ឧបគន្ត្វាន ពោធេតិ តំ មហាមុនិ ។

បឋមាភិសមយេ ពុទ្ធោ កោដិសតមពោធយិ
ទុតិយាភិសមយេ នាថោ នវុតិកោដិមពោធយិ ។

យទា ច ទេវភវនម្ហិ ពុទ្ធោ ធម្មមទេសយិ
នវុតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។

សន្និបាតា តយោ អាសុំ ទីបង្ករស្ស សត្ថុនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។

## ទីបង្ករពុទ្ធវង្ស ទី ១

ព្រះមហាមុនីទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះលោកនាថជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា (ដូចព្រះចន្ទ្រក្នុងថ្ងៃ ១២ កើត) មានជង្គួនមូលកុំដូចគោឧសភ ទ្រង់ចម្លងពួកជនច្រើន ឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ឋិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិតហើយញុំាងពួកជននោះឲ្យត្រាស់ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញុំាងពួកទេវតា ១០០ កោដិ ឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាថ ទ្រង់ញុំាងពួកទេវតានិងមនុស្ស ៩០ កោដិឲ្យត្រាស់ដឹង ។ កាលណា ព្រះពុទ្ធទ្រង់សម្តែងធម៌ក្នុងភពនៃទេវតា កាលនោះ ពួកទេវតា ៩០ ពាន់កោដិ (បានត្រាស់ដឹង) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករ មានសាវកសន្និបាត (ការជួបជុំសាវក) ៣លើក គឺ សន្និបាតលើក ទី ១ មានភិក្ខុសង្ឃមួយសែនកោដិ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

បុន នារទកូដម្ហិ បវិវេកគតេ ជិនេ
ខីណាសវា វិមលា សមឹសុ សតកោដិយោ ។
យម្ហិ កាលេ មហាវីរោ សុទស្សនសិលុច្ចយេ
នវុតិកោដិសហស្សេហិ បវារេសិ មហាមុនិ ។
អហំ តេន សមយេន ជដិលោ ឧគ្គតាបនោ
អន្តលិក្ខម្ហិ ចរណោ បញ្ចាភិញ្ញាសុ បារគូ ។
ទសវីសសហស្សានំ ធម្មាភិសមយោ អហុ
ឯកទ្វិន្នំ អភិសមយោ គណនាតោ អសង្ខិយោ ។
វិត្ថារិកំ ពហុជញ្ញំ ឥទ្ធំ ផីតំ អហុ តទា
ទីបង្ករស្ស ភគវតោ សាសនំ សុវិសោធិតំ ។
ចត្តារិ សតសហស្សានិ ឆឡភិញ្ញា មហិទ្ធិកា
ទីបង្ករំ លោកវិទុំ បរិវារេន្តិ សព្វទា ។
យេ កេចិ តេន សមយេន ជហន្តិ មានុសម្ភវំ
អប្បត្តមានសា សេក្ខា គរហិតា ភវន្តិ តេ ។

កាលដែលព្រះជិនស្រី ទ្រង់យាងទៅក្នុងទីស្ងាត់លើកំពូលភ្នំនារទ: ពួកព្រះខីណាស្រព ប្រាសចាកមន្ទិលចំនួន ១០០ កោដិ មកប្រជុំគ្នា (នេះជាសន្និបាតលើកទី ២) ។ កាលព្រះមហាមុនី មានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០កោដិ ឰដ៏ភ្នំសុទស្សន: (នេះជាសន្និបាតលើកទី ៣) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឰដ៏អាកាស ជាអ្នកបានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ច: ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ។ សាសនារបស់ព្រះទីបង្ករ មានព្រះភាគ ជាគុណជាតដ៏ទូលាយ មានជនច្រើន ស្តុកស្តម្ភ សាយភាយ គឺព្រះអង្គទ្រង់ជំរះល្អហើយ ក្នុងកាលនោះ ។ ពួកព្រះខីណាស្រព ចំនួន ៤ សែនរូប បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករ ដែលទ្រង់ជ្រាបច្បាស់នូវលោកសព្វកាល ។ ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។

## បឋមោ ទីបង្ករពុទ្ធវំសោ

សុបុប្ផិតំ បាវចនំ    អរហន្តេហិ តាទិហិ
វីតរាគេហិ វិមលេហិ    ឧបសោភតិ សព្វទា ៗ

នគរំ រម្មវតី នាម    សុទេវោ នាម ខត្តិយោ
សុមេធា នាម ជនិកា    ទីបង្ករស្ស សត្ថុនោ ៗ
ទស វស្សសហស្សានិ    អគារំ អជ្ឈាវសី ជិនោ
ហំសា កោញ្ចា មយូរា ច    តយោ បាសាទមុត្តមា ៗ
តីណិ សតសហស្សានិ    នារិយោ សមលង្កតា
បទុមា នាម សា នារី    ឧសភក្ខន្ធោ នាម អត្រជោ ៗ
និមិត្តេ ចតុរោ ទិស្វា    ហត្ថិយានេន និក្ខមិ
អនូនទសមាសានិ    បធានំ បទហី ជិនោ ៗ
បធានចារំ ចរិត្វាន    អពុជ្ឈិ មានសា មុនិ
ព្រហ្មុនា យាចិតោ សន្តោ    ទីបង្ករោ មហាមុនិ ៗ
វត្តចក្កោ មហាវីរោ    នន្ទារាមេ វសី ជិនោ
និសិន្នោ សិរីសមូលម្ហិ    អកាសិ តិត្ថិយមទ្ទនំ ៗ

សាសនា (របស់ព្រះពុទ្ធទីបង្ករនោះ) រីកសាយល្អ រុងរឿង ដោយពួកព្រះអរហន្ត ខីណាស្រព ជាតាទិបុគ្គល ប្រាស-ចាកមន្ទិល សព្វកាល ។ នគររបស់ព្រះសាស្តាព្រះនាមទី-បង្ករ ឈ្មោះរម្មវតី ក្សត្រិយ៍ព្រះនាមសុទេវៈ (ជាព្រះបិតា) ព្រះជនិកាព្រះនាមសុមេធា ។ ព្រះជិនស្រី នៅគ្រប់គ្រងផ្ទះ អស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់ មាន ៣ ខ្នង គឺហង្ស-ប្រាសាទ ១ កោញ្ចប្រាសាទ ១ មយុរប្រាសាទ ១ ។ ពួកនារី ៣ សែននាក់ សុទ្ធសឹងតែតាក់តែងយ៉ាងល្អ នារីឈ្មោះបទុមានោះ (ជាមហេសី) ព្រះឱរសព្រះនាមឧសភក្ខន្ធ ។ ព្រះជិនស្រីឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅ (បួស) ដោយយានដំរី ទ្រង់ផ្គងព្យាយាម អស់ ១០ ខែឥតខ្វះ ។ លុះព្រះមុនីមានព្រះទ័យប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ជាព្រះពុទ្ធ ព្រះមហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះជិនស្រីមានព្យាយាមធំ ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងវត្តនន្ទៈ ទ្រង់គង់ទៀបគល់ប្រេស ធ្វើនូវការញាំញីតិរ្ថិយ ។

សុមន្តោ ច តិស្សោ ច   អហេសុំ អគ្គសាវកា
សាគតោ នាមុបដ្ឋាកោ   ទីបង្ករស្ស សត្ថុនោ ។
នន្ទា ចេវ សុនន្ទា ច   អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ   បិប្ផលីតិ បវុច្ចតិ ។
តបុស្ស ភល្លិកា នាម   អហេសុំ អគ្គុបដ្ឋកា
សិរិមា សោណា ឧបដ្ឋិកា   ទីបង្ករស្ស សត្ថុនោ ។
អសីតិហត្ថមុព្វេធោ   ទីបង្ករោ មហាមុនិ
សោភតិ ទីបរុក្ខោវ   សាលរាជាវ ផុល្លិតោ ។
បភា និទ្ធាវតី តស្ស   សមន្តា ទសយោជនេ
សតសហស្សវស្សានិ   អាយុ តស្ស មហេសិនោ ។
តាវតា តិដ្ឋមានោ សោ   តារេសិ ជនតំ ពហុំ
ជោតយិត្វាន សទ្ធម្មំ   មន្តារេត្វា មហាជនំ ។
ជលិត្វា អគ្គិក្ខន្ធោវ   និព្វុតោ សោ សសាវកោ
សា ច ឥទ្ធិ សោ ច យសោ   តានិ ច បាទេសុ ចក្ក-
រតនានិ ។

ព្រះសុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវ័ក ព្រះសាគតៈជា ឧបដ្ឋាករបស់ព្រះសាស្ដាទីបង្ករ ។ នាងនន្ទានិងសុនន្ទា ជា អគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេ ហៅថាដើមលៀប ។ ឧបាសកឈ្មោះតបុស្សៈនិងភល្លិកៈ ជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមានិងនាងសោណា ជាឧបដ្ឋា-យិកា របស់ប្រះសាស្ដាទីបង្ករ ។ ព្រះមហាមុនីទីបង្ករ មាន កំពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជ-ព្រឹក្ស មានផ្ការីកស្គុះស្គាយ ។ រស្មីរបស់ព្រះអង្គផ្សាយទៅ ចម្ងាយ ១០០ យោជន៍ជុំវិញ ព្រះមហេសីនោះ មានព្រះជន្ម មួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញុំាង ព្រះសទ្ធម្មឲ្យរុងរឿង ចម្លងមហាជន ញុំាងប្រជុំជនច្រើនឲ្យ ឆ្លងចាកសង្សារវដ្ដ ។ ព្រះទីបង្ករនោះ ព្រមទាំងសាវ័កនិព្វាន ទៅ ដូចគំនរភ្លើងដែលរុងរឿងរលត់ទៅដូច្នោះ ឫទ្ធិនោះក្ដី យសនោះក្ដី ទាំងចក្ករតនៈត្រង់ព្រះបាទានោះក្ដី ក៏រលត់ទៅ ។

សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ
ទីបង្ករោ ជិនោ សត្ថា នន្ទារាមម្ហិ និព្វុតោ ។
តត្ថេវ តស្ស ជិនថូបោ ឆត្តឹសុព្វេធយោជនោ
បត្តចីវរំ បរិក្ខារំ បរិភោគញ្ច សត្ថុនោ
ពោធិមូលេ តទា ថូបោ តិយោជនសមុគ្គតោ(១) ។

ទីបង្ករពុទ្ធវំសោ បឋមោ ។

## ទុតិយោ កោណ្ឌញ្ញពុទ្ធវំសោ

[៣] ទីបង្ករស្ស អបរេន កោណ្ឌញ្ញោ នាម នាយកោ
អនន្តតេជាមិតយសោ អប្បមេយ្យោ ទុរាសទោ ។
ធរណូបមោ ខមនេន សីលេន សាគរូបមោ
សមាធិនា មេរូបមោ ញាណេន គគនូបមោ ។

---

១ ឱ. ម. អយំ បច្ឆិមគាថា ន ទិស្សតិ ។

សម្បត្តិទាំងអស់ ក៏អន្តរធានទៅ ឱហ្ន៎! សម្ភារទាំងពួងជារបស់សូន្យទទេ ព្រះជិនស្រីជាសាស្ដាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។ ព្រះស្តូបរបស់ព្រះជិនស្រីនោះ កំពស់៣៦ យោជន៍ (គេសាងទុក) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកំពស់ ៣ យោជន៍ ទៀបគល់ពោធិព្រឹក្ស (សម្រាប់បញ្ចុះ) បាត្រ និង ចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់ របស់ព្រះសាស្ដា ។

ចប់ ទីបង្ករពុទ្ធវង្ស ទី ១ ។

## កោណ្ឌញ្ញពុទ្ធវង្ស ទី ២

(៣) សម័យខាងក្រោយ អំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោកនាយក ព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជះរកទីបំផុតគ្មាន មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយបុគ្គលគ្រប់សង្កត់បាន ។ ព្រះអង្គមានការអត់ធន់ប្រៀបដោយធរណី មានសីលប្រៀបដោយសាគរ មានសមាធិប្រៀបដោយភ្នំសុមេរុ មានញាណប្រៀបដោយអាកាស ។

ឥន្ទ្រិយពលពោជ្ឈង្គ- មគ្គសច្ចប្បកាសនំ
បកាសេសិ សទា ពុទ្ធោ ហិតាយ សព្វបាណិនំ ។
ធម្មចក្កំ បវត្តេន្តេ កោណ្ឌញ្ញេ លោកនាយកេ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។
តតោ បរំបិ ទេសេន្តេ នរមរូនំ សមាគមេ
នវុតិកោដិសហស្សានំ ទុតិយាភិសមយោ អហុ ។
តិត្ថិយេ អភិមទ្ទន្តោ យទា ធម្មមទេសយិ
អសីតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ កោណ្ឌញ្ញស្ស មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ
ទុតិយោ កោដិសហស្សានំ តតិយោ នវុតិកោដិនំ ។
អហំ តេន សមយេន វិជិតាវី នាម ខត្តិយោ
សមុទ្ទំ អន្តមន្តេន ឥស្សរិយំ(១) វត្តយាមិហំ ។

---
១ ម. ឥស្សេរំ ។

ព្រះសម្ពុទ្ធ ទ្រង់ប្រកាសហើយ នូវការប្រកាសឥន្ទ្រិយពលៈ ពោជ្ឈង្គ និងមគ្គសច្ច ដើម្បីប្រយោជន៍ដល់សព្វសត្វទាំងឡាយ សព្វកាល ។ កាលព្រះកោណ្ឌញ្ញៈ ជាលោកនាយក ទ្រង់សម្ដែងធម្មចក្ក ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផល លើកទី ១ ។ លំដាប់តអំពីនោះ កាលព្រះអង្គទ្រង់សម្ដែងធម៌ ក្នុងសមាគម នៃមនុស្សនិងទេវតា ពួកសត្វ ៩០ ពាន់កោដិ បានសម្រេចមគ្គផល លើកទី ២ ។ កាលព្រះលោកនាយក ទ្រង់សម្ដែងធម៌ញ៉ាំញីពួកតិរ្ថិយ ពួកសត្វ ៨០ ពាន់កោដិ បានសម្រេចមគ្គផល លើកទី ៣ ។ ព្រះមហេសីកោណ្ឌញ្ញៈ មានសាវកសន្និបាត ៣ លើក គឺ សន្និបាតទី ១ មានព្រះខីណាស្រព ដែលប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ចំនួនមួយសែនកោដិ សន្និបាតទី ២ មានព្រះខីណាស្រពមួយពាន់កោដិ សន្និបាតទី ៣ មានព្រះខីណាស្រព ៩០ កោដិ ។ ក្នុងសម័យនោះ តថាគតបានកើតជាក្សត្រ មានឈ្មោះថា វិជិតាវី បានញ៉ាំងឥស្សរិយយសឲ្យប្រព្រឹត្តទៅ រហូតដល់សមុទ្រជាទីបំផុត ។

## ទុតិយោ កោណ្ឌញ្ញពុទ្ធវំសោ

កោដិសតសហស្សានំ វិមលានំ មហេសិនំ
សហ លោកគ្គនាថេន បរមន្នេន តប្បយឹ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ កោណ្ឌញ្ញោ លោក-
នាយកោ
អបរិមេយ្យិតោ កប្បេ ពុទ្ធោ លោកេ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ(១)
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ(២)
អស្សត្ថរុក្ខមូលម្ហិ(៣) ពុជ្ឈិស្សតិ មហាយសោ ។

---

១ ឱ. ម. ឥទំ គាថាបាទទ្វយំ ន ទិស្សតិ ។ ២ ឱ. ម. សព្វត្ថ ឋានេសុ អជបាលរុក្ខមូលស្មឹ ។ល។ ពោធិមណ្ឌំ អនុត្តរន្តិ ឥមេ បាទា ន វិជ្ជន្តិយេវ ។ ៣ ឱ. ម. អស្សត្ថមូលេ សម្ពុទ្ធោតិ ញាយតិ ។

## កោណ្ឌញ្ញពុទ្ធវង្ស ទី ២

តថាគតបាននិមន្តព្រះខីណាស្រព មួយសែនកោដិ ដែលប្រាសចាកមន្ទិល ស្វែងរកគុណដ៏ធំ ព្រមទាំងព្រះសម្ពុទ្ធ ជាទីពឹងដ៏ប្រសើរ របស់សត្វលោក ឲ្យឆាន់ស្កប់ស្កល់ ដោយម្ហូបចំណីដ៏ថ្លៃថ្លា ។ ព្រះសម្ពុទ្ធ ជាលោកនាយក ព្រះនាមកោណ្ឌញ្ញៈអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ បុរសនេះ នឹងបានជាព្រះពុទ្ធក្នុងលោក ។ សត្វ (នេះ) នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វ (នេះ) នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ។ តអំពីនោះមក សត្វ (នេះ) មានយសច្រើន ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស (ដើមពោធិ) ។

ឥមស្ស ជនិកា មាតា    មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម    អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច    អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា    សន្តចិត្តា សមាហិតា ។
អានន្ទោ នាមុបដ្ឋាកោ    ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច    អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា    សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ    អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ    អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា    អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស    គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ    អសមស្ស មហេសិនោ
អាមោទិតា នរមរូ    ពុទ្ធវីជង្កុរោ អយំ ។

ព្រះមាតាបង្កើត នៃព្រះសម្ពុទ្ធនេះ ទ្រង់មានព្រះនាមថាមាយា ព្រះបិតា មានព្រះនាមថាសុទ្ធោទនៈ ឯព្រះពុទ្ធអង្គនេះ មានព្រះនាមថាគោតម ព្រះថេរៈ ឈ្មោះកោលិតៈ១ ឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទ្រង់ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ ទ្រង់ជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តតម្កល់មាំ ទ្រង់ជាអគ្គសាវិកា ។ ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកជាឧបដ្ឋាកដ៏ប្រសើរ ឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ។ ឧបាសិកាជាឧបដ្ឋាយិកាដ៏ប្រសើរ ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ព្រះគោតម ដ៏ទ្រង់យសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់ភាសិតរបស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំនេះហើយ ក៏រីករាយថា បុរសនេះជាពូជពន្លកនៃព្រះពុទ្ធ ។

## ទុតិយោ កោណ្ឌញ្ញពុទ្ធវំសោ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ(១) ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស វិរជ្ជិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ជិយ
ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាហំ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ
តមេវ អត្ថំ សាធេន្តោ មហារជ្ជំ ជិនេ អទំ
មហារជ្ជំ ទទិត្វាន(២) បព្វជឹ តស្ស សន្តិកេ ។
សុត្តន្តំ វិនយញ្ចាបិ នវង្គសត្ថុសាសនំ
សព្វំ បរិយាបុណិត្វាន សោភយឹ ជិនសាសនំ ។

---

១ ឱ. ម. អប្ផោដេន្តីតិបិ បាឋោ ។ ២ ឱ. បជិត្វាន ។

## កោណ្ឌញ្ញពុទ្ធវង្ស ទី ២

ពួកមនុស្សព្រមទាំងទេវតាមួយហ្វូន មានសំឡេងហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះលោកនាថកោណ្ឌញ្ញៈអង្គនេះ គង់នឹងបានជួបចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា យើងទាំងអស់គ្នា បើលះបង់ព្រះជិនស្រីនេះហើយ គង់នឹងបានជួបចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ។ តថាគត បានស្តាប់នូវព្រះតម្រាស់ របស់ព្រះសម្ពុទ្ធអង្គនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក កាលញុំាងប្រយោជន៍នោះឲ្យសម្រេច បានថ្វាយរាជសម្បត្តិដ៏ធំ ចំពោះព្រះជិនស្រី លុះថ្វាយរាជសម្បត្តិដ៏ធំហើយ ទើបបួសក្នុងសំណាក់របស់ព្រះអង្គ ។ តថាគត បានរៀនព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនាមានអង្គ ៩ ទាំងអស់ ហើយញុំាងសាសនានៃព្រះជិនស្រីឲ្យរុងរឿង ។

តត្ថប្បមត្តោ វិហរន្តោ    និសជ្ជដ្ឋានចង្កមេ
អភិញ្ញាបារមឹ គន្ត្វា    ព្រហ្មលោកមគញ្ឆិហំ ៕
នគរំ រម្មវតី នាម    សុនន្ទោ នាម ខត្តិយោ
សុជាតា នាម ជនិកា    កោណ្ឌញ្ញស្ស មហេសិនោ ៕
ទស វស្សសហស្សានិ    អគារមជ្ឈេ ច សោ វសិ
រុចិ សុរុចិ សុភោ ច    តយោ បាសាទមុត្តមា ៕
តីណិ សតសហស្សានិ    នារិយោ សមលង្កតា
រុចិទេវី នាម សា នារី    ជីវិតសេនោ នាម អត្រជោ ៕
និមិត្តេ ចតុរោ ទិស្វា    រថយានេន និក្ខមិ
អនូនទសមាសានិ    បធានំ បទហី ជិនោ ៕

ព្រហ្មុនា យាចិតោ សន្តោ    កោណ្ឌញ្ញោ ទិបទុត្តមោ
វត្តចក្កោ(១) មហាវីរេ    ទេវានញ្ច(២) មហាវនេ(៣) ៕
ភទ្ទោ ចេវ សុភទ្ទោ ច    អហេសុំ អគ្គសាវកា
អនុរុទ្ធោ នាមុបដ្ឋាកោ    កោណ្ឌញ្ញស្ស មហេសិនោ ៕

---

១. ឱ.ម. វត្តិចក្កំ ៕ ២ ឱ.ម. បសន្នោ ឧត្តិ ៕ ៣ ឱ.ម. នាគវុត្តមេ ៕

តថាគតមិនប្រមាទ កាលនៅក្នុងទីនោះ បានសម្រេចអភិញ្ញាបារមី ក្នុងទីអង្គុយនិងទីចង្ក្រម ក៏បានទៅកើតក្នុងព្រហ្មលោក ។ ព្រះពុទ្ធព្រះនាមកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះរម្មវតី មានព្រះបិតា ព្រះនាមសុនន្ទៈ ព្រះមាតាព្រះនាមនាងសុជាតាទេវី ។ ព្រះអង្គគង់នៅក្នុងកណ្ដាលផ្ទះ អស់មួយម៉ឺនឆ្នាំ ឯប្រាសាទដ៏ប្រសើរសម្រាប់ព្រះអង្គ មាន ៣ គឺ រុចិប្រាសាទ ១ សុរុចិប្រាសាទ ១ សុភប្រាសាទ ១ ។ នារី ៣ សែន មានគ្រឿងប្រដាប់សមរម្យ នារីជាកិរិយានោះព្រះនាមរុចិទេវី មានព្រះរាជបុត្រ ១ ព្រះអង្គព្រះនាមវិជិតសេន ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ទ្រង់ចេញដោយរថយាន ទៅតាំងសេចក្ដីព្យាយាម អស់១០ខែឥតខ្វះ ។ ព្រះសម្ពុទ្ធព្រះនាមកោណ្ឌញ្ញៈ មានព្រះទ័យស្ងប់រម្ងាប់ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ មានចក្រប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនា ក្នុងមហាវ័ន របស់ពួកទេវតា ។ ព្រះថេរៈឈ្មោះភទ្ទៈ ១ សុភទ្ទៈ ១ ជាអគ្គសាវក ព្រះថេរៈឈ្មោះអនុរុទ្ធជាឧបដ្ឋាករបស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកគុណដ៏ធំ ។

## ទុតិយោ កោណ្ឌញ្ញពុទ្ធវំសោ

តិស្សា ច ឧបតិស្សា ច  អហេសុំ អគ្គសាវិកា
សាលកល្យាណិកា ពោធិ  កោណ្ឌញ្ញស្ស មហេ-
សិនោ ។

សោណោ ច ឧបសោណោ ច  អហេសុំ អគ្គុបដ្ឋកា
នន្ទា ចេវ សិរិមា ច  អហេសុំ អគ្គុបដ្ឋិកា ។
សោ អដ្ឋាសីតិហត្ថានិ  អច្ចុគ្គតោ មហាមុនិ
សោភតិ ឧឡុរាជាវ  សុរិយោ មជ្ឈន្តិកេ យថា ។
វស្សសតសហស្សានិ  អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ  តារេសិ ជនតំ ពហុំ ។
ខីណាសវេហិ វិមលេហិ  វិចិត្តា អាសិ មេទនី
យថា គគនំ ឧឡូហិ  ឯវំ សោ ឧបសោភថ ។
តេបិ នាគា អប្បមេយ្យា  អសង្ខោភា ទុរាសទា
វិជ្ជុចាតំវ ទស្សេត្វា  និព្វុតា តេ មហាយសា ។

## កោណ្ឌញ្ញពុទ្ធវង្ស ទី ២

ភិក្ខុនី ឈ្មោះតិស្សា ១ ឧបតិស្សា ១ ជាអគ្គសាវិកា សាលកល្យាណិព្រឹក្សជាពោធិ របស់ព្រះពុទ្ធកោណ្ឌញ្ញៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ឧបាសក ឈ្មោះសោណៈ ១ ឧបសោណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនន្ទា ១ សិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីអង្គនោះ មានកំពស់ ៨៨ ហត្ថ ទ្រង់ល្អល្អះដូចព្រះចន្ទ្រ ពុំនោះសោត ដូចព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ ។ ព្រះអង្គមានព្រះជន្មាយុ មួយសែនឆ្នាំជាកំណត់ ទ្រង់ឋិតនៅ អស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ( ចាកវាលវដ្តសង្សារ ) ។ ផែនដីដ៏វិចិត្រ ដោយព្រះខីណាស្រពទាំងឡាយ ដែលអស់មន្ទិល ព្រះសម្ពុទ្ធអង្គនោះ ទ្រង់រុងរឿងដូចមេឃ ដែលល្អដោយពួកផ្កាយ ។ ព្រះនាគត្ថេរ ទាំងអម្បាលនោះ មានគុណប្រមាណមិនបាន មានសន្តានមិនកម្រើក បុគ្គលចូលទៅរកបានដោយកម្រ សម្ដែងនូវឫទ្ធិ ដូចការធ្លាក់ចុះនៃផ្លេកបន្ទោរ ព្រះអរហន្តដ៏មានយសធំទាំងនោះ និព្វានហើយ ។

សា ច អតុលិយា ជិនស្ស ឥទ្ធិ ញាណបរិភាវិតោ
សមាធិ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារា ។
កោណ្ឌញ្ញោ សិរិឃនោ(១) ពុទ្ធោ នន្ទារាមម្ហិ(២) និព្វុតោ
តត្ថេវ ចេតិយេ តស្ស សត្តយោជនមុស្សិតោ ។

កោណ្ឌញ្ញពុទ្ធវំសោ ទុតិយោ ។

# តតិយោ មង្គលពុទ្ធវំសោ

[៤] កោណ្ឌញ្ញស្ស អបរេន មង្គលោ នាម នាយកោ
តមំ លោកេ និហន្ត្វាន ធម្មោក្កមភិធារយិ ។
អតុលាសិ បភា តស្ស ជិនេហញ្ញេហិ ឧត្តរិ
ចន្ទសុរិយប្បភំ ហន្ត្វា ទសសហស្សី វិរោចតិ ។
សោបិ ពុទ្ធោ បកាសេសិ ចតុរោ សច្ចវរុត្តមេ
តេ តេ សច្ចរសំ បិត្វា វិនោទេន្តិ មហាតមំ ។

១ ឱ. ម. បវរោ ។ ២ ឱ. ម. ចន្ទារាមម្ហិ ។

ចំណែកឫទ្ធិ របស់ព្រះជិនស្រីនោះ ជាគុណឥតប្រឹងថ្លែងបាន សមាធិមានញាណអប់រំហើយ របស់ទាំងអស់ វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះកោណ្ឌញ្ញ-សម្ពុទ្ធ ព្រះអង្គទ្រង់ទ្រង់សិរី ទ្រង់បរិនិព្វានក្នុងនន្ទារាម ពួកមហាជនបានបញ្ចុះ (ព្រះអដ្ឋិ) របស់ព្រះអង្គនោះ ក្នុងចេតិយមានកម្ពស់ ៧ យោជន៍ ក្នុងនន្ទារាមនោះឯង ។

ចប់ កោណ្ឌញ្ញពុទ្ធវង្ស ទី ២ ។

# មង្គលពុទ្ធវង្ស ទី ៣

[៤] កាលខាងក្រោយ អំពីព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះលោកនាយកព្រះនាមមង្គលៈ ទ្រង់កំចាត់បង់ងងឹតក្នុងលោក ព្រះអង្គទ្រង់ទ្រង់នូវគប់ភ្លើងគឺព្រះធម៌ ។ ពន្លឺរបស់ព្រះអង្គឥតប្រឹងបាន ជាពន្លឺលើសលុបជាងព្រះជិនស្រីដទៃ គ្របសង្កត់ពន្លឺព្រះចន្ទនិងព្រះអាទិត្យ រុងរឿងអស់មួយហ្មឺនលោកធាតុ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់ប្រកាសសច្ចៈ៤ដ៏ប្រសើរ ពួកសត្វនោះៗ បានផឹករសសច្ចៈ ហើយកំចាត់ងងឹតគឺមោហៈ ។

## តតិយោ មង្គលពុទ្ធវំសោ

បត្វាន ពោធិមតុលំ បឋមេ ធម្មទេសនេ
កោដិសតសហស្សានំ បឋមាភិសមយោ(១) អហុ ។
សុរិន្ទទេវភវនេ ពុទ្ធោ ធម្មមទេសយិ
តទា កោដិសតសហស្សានំ ទុតិយាភិសមយោ អហុ
យទា សុនន្ទោ ចក្កវត្តិ សម្ពុទ្ធមុបសង្កមិ
តទា អាហនិ សម្ពុទ្ធោ ធម្មភេរឹ វរុត្តមំ ។
សុនន្ទស្សានុចរ ជ(២) តទាសុំ នវុតិកោដិយោ
សព្វេ តេ និរវសេសា អហេសុំ ឯហិភិក្ខុកា ។
សន្និបាតា តយោ អាសុំ មង្គលស្ស មហេសិនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។
កោដិសតសហស្សានំ ទុតិយោ អាសិ សមាគមោ
តតិយេ នវុតិកោដីនំ តតិយោ អាសិ សមាគមោ ។

---

១ ម. ធម្មាភិសមយោ ។ ២ ឱ. ម. សុនន្ទស្សានុចរា ជនតាតិ ទិស្សតិ ។

## មង្គលពុទ្ធវង្ស ទី ៣

ព្រះសម្ពុទ្ធអង្គនោះ បានដល់នូវពោធិញ្ញាណ ជាគុណឥតប្រឹងបាន កាលសម្តែងធម៌ជាដំបូង ពួកសត្វមួយសែនកោដិបានសម្រេចមគ្គផល លើកទី ១ ។ ព្រះសម្ពុទ្ធទ្រង់សម្តែងធម៌ក្នុងសុរិន្ទទេវភព កាលនោះ ពួកសត្វមួយសែនកោដិ បានសម្រេចមគ្គផល លើកទី ២ ។ កាលព្រះបាទសុនន្ទចក្រពត្តិទ្រង់ចូលទៅគាល់ព្រះសម្ពុទ្ធ កាលនោះ ព្រះសម្ពុទ្ធទ្រង់វាយស្គរ គឺព្រះធម៌ដ៏ប្រសើរខ្ពង់ខ្ពស់ ។ កាលនោះ ពួកជនដែលតាមហែព្រះបាទសុនន្ទៈ មានចំនួន ៩០ កោដិ ជនទាំងអស់នោះ បានជាឯហិភិក្ខុ ឥតសេសសល់ (លើកទី ៣) ព្រះមង្គលសម្ពុទ្ធ ព្រះអង្គស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយកោដិ សន្និបាតលើកទី ២ មានព្រះខីណាស្រព មួយសែនកោដិ សន្និបាតលើកទី ៣ មានព្រះខីណាស្រព ៩០ កោដិ ។

ខីណាសវានំ វិមលានំ តទា អាសិ សមាគមោ(១)

អហំ តេន សមយេន សុរុចិ នាម ព្រាហ្មណោ ។

អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ

តមហំ ឧបសង្កម្ម សរណំ គន្ត្វាន សត្ថុនោ ។

សម្ពុទ្ធប្បមុខំ សង្ឃំ គន្ធមាលេន បូជយឹ

បូជេត្វា គន្ធមាលេន គវបានេន តប្បយឹ ។

សោបិ មំ ពុទ្ធោ ព្យាកាសិ មង្គលោ ទិបទុត្តមោ

អបរិមេយ្យេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។

អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ(២)

បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

---

១ ឱ. ទុតិយោ កោដិសហស្សានំ តតិយោ នវុតិកោដិនំ

ខីណាសវានំ វិមលានំ តទា អាសិ សមាគមោតិ ទិស្សតិ ។

ម. ទុតិយោ កោដិសតសហស្សានំ តតិយោ នវុតិកោដិនំ

ខីណាសវានំ វិមលានំ តទា អាសិ សមាគមោតិ ទិស្សតិ ។

២ ឱ. ម. សព្វត្ថ ឋានេសុ ឥទំ គាថាបាទទ្វយំ ន ទិស្សតិយេវ ។

សមាគមក្នុងកាលនោះ សុទ្ធតែព្រះខីណាស្រព ប្រាសចាក
មន្ទិល សម័យនោះ តថាគតជាព្រាហ្មណ៍ ឈ្មោះសុរុចិ ។
តថាគតអ្នករៀនមន្ត ចងចាំមន្ត ដល់ត្រើយនៃវេទទាំង ៣
ចូលទៅគាល់ព្រះសម្ពុទ្ធអង្គនោះ ហើយបានដល់ព្រះសាស្តា
ជាទីពឹង ។ តថាគតបានបូជាព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន
ដោយគ្រឿងក្រអូប និងផ្កាកម្រង លុះបូជាដោយគ្រឿង
ក្រអូប និងផ្កាកម្រងហើយ ក៏ញុំាងព្រះភិក្ខុសង្ឃឲ្យឆាន់ស្កប់
ស្កល់ ដោយទឹកដោះគោ ។ ព្រះសម្ពុទ្ធព្រះនាមមង្គលៈនោះ
ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ទ្រង់ទំនាយតថាគតថា ក្នុង
រវាងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ បុរសនេះនឹង
បានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិល-
ពស្តុ ជាទីរីករាយ តាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។

## តតិយោ មង្គលពុទ្ធវំសោ

អជបាលរុក្ខមូលស្មឹ   និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ   នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ   បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន   ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា   ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ   ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា   មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម   អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច   អគ្គា ហេស្សន្តិ សាវកា ។
អានន្ទោ នាមុបដ្ឋាកោ   ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច   អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា ។

មង្គលពុទ្ធវង្ស ទី ៣

សត្វ (នេះ) នឹងអង្គុយទៀបគល់អជបាលព្រឹក្ស បានទទួលបាយាសក្តន៍ទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ៗ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅជិតគល់ នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែង ៗ លំដាប់អំពីនោះទៅ ព្រះជិនស្រី មានយសច្រើន នឹងធ្វើប្រទក្សិណនូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ៗ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធអង្គនេះ នឹងមានព្រះនាមថា មាយា ព្រះបិតាព្រះនាមថា សុទ្ធោទនៈ ឯបុរសនេះជាព្រះពុទ្ធ ព្រះនាមគោតម ៗ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងបានជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ៗ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ មានចិត្តតម្កល់មាំ នឹងបានជាអគ្គសាវិកា ៗ

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ពោធិ តស្ស ភគវតោ    អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ    អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា    អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស    គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ    អសមស្ស មហេសិនោ
អាមោទិតា នរមរូ    ពុទ្ធពីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ    អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ    ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស    វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទី តរន្តា    បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន    ឧត្តរន្តិ មហានទី ។

ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគ អង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ( ដើមពោធិ ) ឧបាសកឈ្មោះចិត្ត ១ ហត្ថាឡវកៈ ១ ទឹងបានជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ទឹងបានជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានឮព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធមិនមានបុគ្គលស្មើ ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្ស ព្រមទាំងទេវតាមួយហ្មឺនលោកធាតុ មានសំឡេងហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើឃ្លាងមគ្គផលក្នុងសាសនា របស់ព្រះលោកនាថនេះ គង់ទឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខគង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។

## តតិយោ មង្គលពុទ្ធវំសោ

ឃវមេវ មយំ សតេ្វ　　យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ　　ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា　　ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ　　ទសបារមិបូរិយា ។
តទា បីតិមនុព្រូហន្តោ　　សម្ពោធិវរបត្តិយា
ពុទ្ធេ ទត្វាន មំ គេហំ　　បព្វជឹ តស្ស សន្តិកេ ។
សុត្តន្តំ វិនយញ្ចាបិ　　នវង្គសត្ថុសាសនំ
សព្វំ បរិយាបុណិត្វាន　　សោភយឹ ជិនសាសនំ ។
តត្ថប្បមត្តោ វិហរន្តោ　　ព្រហ្មំ ភាវេត្វា ភាវនំ
អភិញ្ញាសុ បារមឹ គន្ត្វា　　ព្រហ្មលោកមគញ្ឆហំ ។
នគរំ ឧត្តរំ នាម　　ឧត្តរោ នាម ខត្តិយោ
ឧត្តរា នាម ជនិកា　　មង្គលស្ស មហេសិនោ ។

## មង្គលពុទ្ធវង្ស ទី ៣

យើងទាំងអស់គ្នា បើឃ្លាតព្រះជិនស្រីអង្គនេះ គង់នឹងបាន
សម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជា
អនាគតមិនខាន យ៉ាងនោះដែរ ។ តថាគត បានស្តាប់ព្រះ
តម្រាស់ របស់ព្រះពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃពេក
បានអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមី ១០ ។
ក្នុងកាលនោះ តថាគតចំរើនបីតិ ថ្វាយផ្ទះរបស់តថាគត បំ-
ពោះព្រះពុទ្ធ ហើយបួសក្នុងសំណាក់ព្រះអង្គ ដើម្បីសម្រេច
ពោធិញាណដ៏ប្រសើរ ។ តថាគតបានរៀនព្រះសូត្រ ព្រះ
វិន័យនិងសត្ថុសាសនាមានអង្គ៩ ទាំងអស់ ហើយញុំាងសា-
សនានៃព្រះជិនស្រីឲ្យល្អរុងរឿង ។ តថាគតមិនប្រមាទ កាល
នៅក្នុងទីនោះ ចំរើនព្រហ្មវិហារ បានសម្រេចអភិញ្ញាបារមី
ហើយក៏បានទៅកើត ក្នុងព្រហ្មលោក ។ ព្រះមង្គលសម្ពុទ្ធ
ទ្រង់ស្វែងរកនូវគុណធំ មាននគរឈ្មោះឧត្តរៈ មហាក្សត្រ
ព្រះនាមឧត្តរៈ ជាព្រះបិតា ព្រះមាតា ព្រះនាមឧត្តរា ។

នវ វស្សសហស្សានិ　　អគារំ អជ្ឈាវសិ សោ
យសវា សុចិមា សិរិមា　　តយោ បាសាទមុត្តមា ។
សមត្តឹសសហស្សានិ　　នារិយោ សមលង្កតា
យសវតី នាម នារី　　សីវលោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា　　អស្សយានេន និក្ខមិ
អនូនអដ្ឋមាសានិ　　បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ　　មង្គលោ លោកនាយកោ
វត្តចក្កោ មហាវីរោ　　ចរេសិ ទិបទុត្តមោ ។
សុទេវោ ធម្មសេនោ ច　　អហេសុំ អគ្គសាវកា
បាលិតោ នាមុបដ្ឋាកោ　　មង្គលស្ស មហេសិនោ ។
សីវលា ច អសោកា ច　　អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ　　នាគរុក្ខោតិ វុច្ចតិ ។
នន្ទោ ចេវ វិសាខោ ច　　អហេសុំ អគ្គុបដ្ឋកា
អនុឡា ចេវ សុមនា ច　　អហេសុំ អគ្គុបដ្ឋិកា ។

ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងរាជដំណាក់ អស់ ៩ ពាន់ឆ្នាំ មានប្រាសាទ ៣ ដ៏ល្អឧត្តម គឺ យសវប្រាសាទ ១ សុចិមប្រាសាទ ១ សិរិមប្រាសាទ ១ មានពួកនារី ៣ ហ្មឺននាក់ មានខ្លួនប្រដាប់សមរម្យ នារីជាភរិយា ឈ្មោះយសវតី មានព្រះរាជបុត្រ ឈ្មោះសីវល: ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ ហើយទ្រង់ចេញទៅ ដោយយានសេះ តាំងសេចក្តីព្យាយាម អស់ ៨ ខែឥតខ្ចះ ។ ព្រះលោកនាយក ព្រះនាមមង្គល: មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាម ទ្រង់ប្រសើរជាងសត្វទ្វេបាទ ត្រូវមហាព្រហ្មអារាធនាហើយ ទើបស្តេចត្រាច់ទៅ គឺសម្តែងធម៌ ។ ព្រះថេរ: ឈ្មោះសុទេវ: ១ ធម្មសេន: ១ ជាអគ្គសាវក ព្រះថេរ:ឈ្មោះបាលិត: ជាឧបដ្ឋាករបស់ព្រះមង្គលសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះសីវលា ១ អសោកា ១ ជាអគ្គសាវិកា ដើមឈើត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ ហៅថានាគព្រឹក្ស (ដើមខ្លឹង) ។ ឧបាសកឈ្មោះនន្ទ: ១ វិសាខ: ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះអនុឡា ១ សុមនា ១ ជាអគ្គឧបដ្ឋាយិកា ។

## តតិយោ មង្គលពុទ្ធវំសោ

អដ្ឋាសីតិរតនានិ អច្ចុគ្គតោ មហាមុនិ
តតោ និទ្ធាវតី រំសិ អនេកសតសហស្សិយោ ។
នវុតិ វស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
យថាបិ សាគរេ ឧម្មិ(១) ន សក្កា តេ គណេតុយេ
តថេវ សាវកា តស្ស ន សក្កា តេ គណេតុយេ ។
យាវ អដ្ឋាសិ សម្ពុទ្ធោ មង្គលោ លោកនាយកោ
ន តស្ស សាសនេ អត្ថិ សកិលេសមរណំ តទា ។
ធម្មោក្កំ ធារយិត្វាន សន្តារេត្វា មហាជនំ
ជលិត្វា ធុមកេតូវ និព្វុតោ សោ មហាយសោ ។
សង្ខារានំ សភាវត្តំ ទស្សយិត្វា សទេវកេ
ជលិត្វា អគ្គិក្ខន្ធោវ សុរិយោ អត្ថង្គតោ យថា ។
ឧយ្យានេ វេស្សរេ នាម ពុទ្ធោ និព្វាយិ មង្គលោ
តត្ថេវស្ស ជិនថូបោ តឹសយោជនមុគ្គតោតិ ។

មង្គលពុទ្ធវំសោ តតិយោ ។

---

១ ឱ.ម. ឧមិ ។

## មង្គលពុទ្ធវង្ស ទី ៣

ព្រះមហាមុនីទ្រង់មានកម្ពស់ ៨៨ ហត្ថ រស្មីច្រើនសែន ផ្សាយចេញអំពីកាយព្រះអង្គ ។ ព្រះជន្មាយុរបស់ព្រះអង្គ ៩ ហ្មឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ឋិតនៅដរាបនោះ ញុំាងពួកជនច្រើនឲ្យឆ្លង (វដ្តសង្សារ) ។ រលកក្នុងសាគរ គេមិនអាចរាប់បានយ៉ាងណាមិញ សាវកទាំងឡាយរបស់ព្រះអង្គ ក៏គេមិនអាចរាប់បាន យ៉ាងនោះដែរ ។ ព្រះមង្គលសម្ពុទ្ធ ជាលោកនាយកទ្រង់បានឋិតនៅ ដរាបណា មារណៈប្រកបដោយកិលេស មិនមានក្នុងសាសនានៃព្រះអង្គ ដរាបនោះ ។ ព្រះសម្ពុទ្ធទ្រង់មានយសច្រើនអង្គនោះ ទ្រទ្រង់នូវគប់ភ្លើងគឺព្រះធម៌ ហើយញុំាងមហាជនឲ្យឆ្លង ដ៏រុងរឿងដូចជាផ្កាយដុះកន្ទុយ ទ្រង់បរិនិព្វាន ។ ព្រះសម្ពុទ្ធទ្រង់សម្ដែង នូវសភាពប្រែប្រួល នៃសង្ខារ ដល់ពួកមនុស្ស ព្រមទាំងទេវតា រុងរឿងដូចគំនរភ្លើង ពុំនោះសោតដូចព្រះអាទិត្យដែលទើបនឹងអស្ដង្គត ។ ព្រះមង្គលសម្ពុទ្ធ ទ្រង់បរិនិព្វាន ក្នុងឧទ្យានឈ្មោះវេស្សរៈ ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកំពស់ ៣០ យោជន៍ មាននៅក្នុងទីនោះឯង ។

ចប់ មង្គលពុទ្ធវង្ស ទី ៣ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

# ចតុត្ថោ សុមនពុទ្ធវំសោ

(៨) មង្គលស្ស អបរេន  សុមនោ នាម នាយកោ
សព្វធម្មេហិ អសមោ  សព្វសត្តានមុត្តមោ ។
តទា អមតភេរិំ យោ(១)  អាហនិ មេខលេ បុរេ
ធម្មសង្ខសមាយុត្តំ(២)  នវង្គំ ជិនសាសនំ ។
វិជិនិត្វាន កិលេសេ សោ  បត្វា សម្ពោធិមុត្តមំ
មាបេសិ នគរំ សត្ថា  សទ្ធម្មបុរវុត្តមំ ។
និរន្តរំ អកុដិលំ  ឧជុំ វិបុលវិត្ថតំ
មាបេសិ សោ មហាវីថិំ  សតិបដ្ឋានវរុត្តមំ ។
ផលេ ចត្តារិ សាមញ្ញេ  ចតស្សោ បដិសម្ភិទា
ឆឡភិញ្ញាដ្ឋសមាបត្តី  បសារេសិ តត្ថ វីថិយំ ។
យេ អប្បមត្តា អខិលា  ហិរិវីរិយេហុបាគតា
តេ តេ ឥមេ គុណវរេ  អាទិយន្តិ យថា សុខំ ។

---

១ ឱ. សោបិ តទា អមតភេរិំ ។ ម. តទា អមតភេរិំ សោ ។ ២ ធម្មសង្ខសមាយុត្តំ អដ្ឋកថាយំ ទិស្សតិ ។

# សុមនពុទ្ធវង្ស ទី ៤

(៩) កាលខាងក្រោយ អំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក ព្រះនាមសុមនៈ រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអង្គឧត្តមជាងសព្វសត្វ ។ កាលនោះ ព្រះអង្គទ្រង់ទូងស្គរ គឺអមតៈ ប្រកបដោយស័ង្ខ គឺធម៌ជាសាសនារបស់ព្រះជិនស្រីមានអង្គ៩ ក្នុងមេខលបុរី ។ ព្រះសាស្ដាអង្គនោះ ទ្រង់ឈ្នះកិលេស ហើយសម្រេចនូវសម្ពោធិញ្ញាណដ៏ប្រសើរ ទ្រង់សាងនគរជាបុរី គឺព្រះសទ្ធម្មដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះអង្គទ្រង់សាងផ្លូវធំ មិនមានបន្ទោះ ជាផ្លូវមិនវៀច ជាផ្លូវត្រង់ មានទទឹងដ៏ធំទូលាយ គឺសតិប្បដ្ឋាន ដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះអង្គទ្រង់លាតសាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ សមាបត្តិ ៨ ក្នុងផ្លូវនោះ ។ ពួកសត្វណាមិនមានសេចក្ដីប្រមាទ មិនរឹងរូស ប្រកបដោយសេចក្ដីខ្មាសបាប និងសេចក្ដីព្យាយាម ពួកសត្វនោះ ៗ តែងកាន់យកគុណ ដ៏ប្រសើរទាំងនេះ តាមសប្បាយ ។

## ចតុត្ថោ សុមនពុទ្ធវំសោ

ឯវមេវ តេន យោគេន ឧទ្ធរន្តោ មហាជនំ
ពោធេសិ បឋមំ សត្ថា កោដិសតសហស្សិយោ ។
យម្ហិ កាលេ មហាវីរោ ឱវទិ តិត្ថិយេ គណេ
កោដិសតសហស្សានិ(១) ទុតិយេ ធម្មទេសនេ ។
យទា ទេវា មនុស្សា ច សមគ្គា ឯកមានសា
និរោធបញ្ហំ បុច្ឆឹសុ សំសយញ្ចាបិ មានសំ ។
តទាបិ ធម្មទេសនេ និរោធបរិទីបនេ
នវុតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ សុមនស្ស មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
វស្សំ វុដ្ឋស្ស ភគវតោ អភិឃុដ្ឋេ បវារណេ
កោដិសតសហស្សេហិ បវារេសិ តថាគតោ ។

---

១ ឱ. កោដិសហស្សាភិសមឹសុ ឥតិ ទិស្សតិ ។

## សុមនពុទ្ធវង្ស ទី ៤

ព្រះសាស្ដា ទ្រង់ស្រោចស្រង់មហាជន ដោយសេចក្ដីព្យាយាម នោះ យ៉ាងនេះឯង បានញ៉ាំងសត្វ មួយសែនកោដិ ឲ្យត្រាស់ដឹង លើកទី ១ ។ ព្រះសាស្ដា មានព្យាយាមច្រើន ទ្រង់ឲ្យឱវាទពួកតិត្ថិយ ក្នុងកាលណា កាលនោះ សត្វមួយសែនកោដិ (បានសម្រេចគុណវិសេស) ក្នុងធម្មទេសនា លើកទី ២ ។ ពួកទេវតានិងមនុស្ស មានសេចក្ដីព្រមព្រៀងគ្នា មានចិត្តស្រួលបួល សួរប្រស្នា ក្នុងនិរោធផង សេចក្ដីសង្ស័យផង សេចក្ដីប្រាថ្នាក្នុងចិត្តផង ក្នុងកាលណា កាលនោះ ពួកសត្វ៩០ ពាន់កោដិ បានសម្រេចមគ្គផល លើកទី ៣ ក្នុងធម្មទេសនាជាគ្រឿងបំភ្លឺនូវនិរោធ ។ ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង ។ កាលព្រះមានព្រះភាគ ទ្រង់ចេញវស្សាហើយ កាលភិក្ខុសង្ឃប្រកាសបវារណាហើយ ព្រះតថាគត ទ្រង់បវារណា ដោយភិក្ខុចំនួនមួយសែនកោដិ (នេះជាសន្និបាត លើកទី ១) ។

តតោ បរំ សន្និបាតេ វិមលេ កញ្ចនបព្វតេ
នវុតិកោដិសហស្សានំ ទុតិយោ អាសិ សមាគមោ ។
យទា សក្កោ ទេវរាជា ពុទ្ធទស្សនុបាគមិ
អសីតិកោដិសហស្សានំ តតិយោ អាសិ សមាគមោ ។
អហំ តេន សមយេន នាគរាជា មហិទ្ធិកោ
អតុលោ នាម នាមេន ឧប្បន្នកុសលសញ្ចយោ ។
តទាហំ នាគភវនា និក្ខមិត្វា សញាតិភិ
នាគានំ ទិព្វតុរិយេហិ សសង្ឃំ ជិនមុបដ្ឋហឹ ។
កោដិសតសហស្សានិ អន្នបានេន តប្បយឹ
បច្ចេកទុស្សយុគំ ទត្វា សរណំ តមុបាគមឹ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ សុមនោ លោកនាយកោ
អបរិមេយ្យេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

ក្នុងការប្រជុំជនទាំងពីរនោះមក មានសន្និបាតលើកទី ២ នៃព្រះខីណាស្រព ៩០ ពាន់កោដិ លើកញ្ចូនបតិតមិនមានមន្ទិល ។ កាលសក្កទេវរាជចូលមកគាល់ព្រះសម្ពុទ្ធ ជាសន្និបាតលើកទី ៣ របស់ព្រះខីណាស្រព ៨០ ពាន់កោដិ ។ ក្នុងសម័យនោះ តថាគត កើតជាស្តេចនាគ មានឫទ្ធិច្រើន មានឈ្មោះថា អតុល: ជាអ្នកសន្សំកុសល ។ កាលនោះ តថាគតចេញអំពីភពនាគ ជាមួយនឹងពួកញាតិ បានទៅបម្រើព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយតន្ត្រីជាទិព្វរបស់នាគ ។ តថាគត បានញុំាងព្រះភិក្ខុសង្ឃ មួយសែនកោដិ ឲ្យឆាន់ស្កប់ស្កល់ ដោយបាយទឹក ហើយថ្វាយសំពត់មួយគូ ៗ មួយអង្គ ហើយយកព្រះភិក្ខុសង្ឃនោះជាទីពឹង ។ ព្រះសម្ពុទ្ធព្រះនាមសុមន: ជាលោកនាយកអង្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះ នាគរាជនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់សេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។

## ចតុត្ថោ សុមនពុទ្ធវំសោ

អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

## សុមនពុទ្ធវង្ស ទី ៤

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ៗ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលមក ទៀបគល់ពោធិព្រឹក្ស តាមផ្លូវដែលគេតាក់តែងដ៏ប្រសើរ ៗ លំដាប់តពីនោះមក ព្រះសម្ពុទ្ធមានយសច្រើនអង្គនោះ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ៗ ព្រះមាតាបង្កើត របស់ព្រះសម្ពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯនាគរាជនេះ នឹងបានត្រាស់ជាព្រះសម្ពុទ្ធ ព្រះនាមគោតម ៗ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ មិនមានរាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធវីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស វិរជ្ជិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។

ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមាន អាសវៈ មិនមានរាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទាំងជាអគ្គសាវិកា ៗ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្ត ១ ហត្ថាឡវកៈ ១ ទាំងជាអគ្គឧបដ្ឋាក ៗ ឧបាសិកាឈ្មោះ នន្ទមាតា ១ ឧត្តរា ១ ទាំងជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់មានយសអង្គនោះ ទ្រង់មានព្រះជន្ម ១០០ ឆ្នាំ ៗ ពួកមនុស្សទាំងទេវតា បានស្តាប់ពុទ្ធដីកានេះ របស់ព្រះមហេសីមិនមានបុគ្គលស្មើ ហើយក៏រីករាយថា នាគរាជនេះ ទាំងជាពូជពន្ធុកនៃព្រះពុទ្ធ ៗ ពួកមនុស្ស ព្រមទាំងទេវតាមួយម៉ឺនលោកធាតុ ស្រែកហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា យើងទាំងឡាយ បើនឹងឃ្លាងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ៗ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ៗ

## ចតុត្ថោ សុមនពុទ្ធវំសោ

ឯវមេវ មយំ សព្វេ  យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា  ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ  ទសបារមិបូរិយា ។
មេខលំ នាម នគរំ  សុទត្តោ នាម ខត្តិយោ
សិរិមា នាម ជនិកា  សុមនស្ស មហេសិនោ ។
នវ វស្សសហស្សានិ  អគារំ អជ្ឈាវសិ សោ
ចន្ទោ សុចន្ទោ វដំសោ  តយោ បាសាទមុត្តមា ។
តេសដ្ឋិសតសហស្សានិ  នារិយោ សមលង្កតា
វដំសកី នាម នារី  អនូបមោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា  ហត្ថិយានេន និក្ខមិ
អនូនទសមាសានិ  បធានំ បទហី ជិនោ ។

## សុមនពុទ្ធវង្ស ទី ៤

យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបាន សម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាល ជាអនាគតមិនខាន ក៏យ៉ាងនោះដែរ ៗ តថាគតបានស្តាប់ ព្រះតម្រាស់ របស់ព្រះសម្ពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លា ក្រៃពេក បានអធិដ្ឋាននូវវត្តតទៅទៅទៀត ដោយការបំពេញ បារមី ១០ ៗ ព្រះសុមនសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានទី ក្រុងឈ្មោះមេខលៈ មានមហាក្សត្រព្រះនាមសុទត្តៈ ជាព្រះ បិតា មានព្រះមាតាព្រះនាម សិរិមា ៗ ព្រះអង្គគ្រប់គ្រងព្រះ រាជដំណាក់ អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ គឺ ចន្ទប្រាសាទ ១ សុចន្ទប្រាសាទ ១ វដំសប្រាសាទ ១ ៗ ពួក នារី ៦៣ សែននាក់ មានរូបប្រដាប់សមរម្យ នារី (ជាអគ្គ-មហេសី) ព្រះនាមវដំសកី ព្រះរាជបុត្រ ព្រះនាមអនូបមៈ ៗ ព្រះជិនស្រីឃើញនិមិត្ត ៤ ហើយទ្រង់ចេញបព្វជ្ជា ដោយ យានដំរី ទ្រង់តាំងសេចក្តីព្យាយាម អស់ ១០ ខែឥតខ្ចះ ៗ

ព្រហ្មុនា យាចិតោ សន្តោ សុមនោ លោកនាយកោ
វត្តចក្កោ មហាវីរោ មេខលេ បុរវរុត្តមេ ។
សរណោ ភាវិតត្តោ ច អហេសុំ អគ្គសាវកា
ឧទេនោ នាមុបដ្ឋាកោ សុមនស្ស មហេសិនោ ។
សោណា ច ឧបសោណា ច អហេសុំ អគ្គសាវិកា
សោបិ ពុទ្ធោ អសមសមោ នាគមូលេ អពុជ្ឈថ ។
វរុណោ ចេវ សរណោ ច អហេសុំ អគ្គុបដ្ឋកា
ចាលា ច ឧបចាលា ច អហេសុំ អគ្គុបដ្ឋិកា ។
ឧច្ចត្តនេន សោ ពុទ្ធោ នវុតិហត្ថមុគ្គតោ
កញ្ចនគ្ឃិកសង្កាសោ ទសសហស្សី វិរោចតិ ។
នវុតិ វស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

ព្រះលោកនាយក ព្រះនាមសុមនៈ មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាមធំ ត្រូវព្រហ្មអាកធនា ក្នុងមេខលបុរីដ៏ប្រសើរខ្ពង់ខ្ពស់ ។ ព្រះថេរៈឈ្មោះសរណៈ ១ ភាវិតត្តៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះឧទេន ជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធ ព្រះនាមសុមនៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ។ ព្រះថេរីឈ្មោះសោណា ១ ឧបសោណា ១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ទ្រង់បានត្រាស់ដឹង ទៀបគល់នាគព្រឹក្ស ។ ឧបាសកឈ្មោះវរុណៈ ១ សរណៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះចាលា ១ ឧបចាលា ១ ជាអគ្គឧបដ្ឋាយិកា ។ ឯព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានកំពស់ ៩០ ហត្ថ មានលំអនៃព្រះរូប ប្រហែលដូចគ្រឿងបូជាមាស ទ្រង់រុងរឿងក្នុងមួយហ្មឺនលោកធាតុ ។ ព្រះជន្មាយុ (របស់ព្រះអង្គ) ៩ ហ្មឺនឆ្នាំជាកំណត់ ព្រះអង្គទ្រង់ឋិតនៅដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើន ឲ្យឆ្លង (វដ្ដសង្សារ) ។

## ចតុត្ថោ សុមនពុទ្ធវំសោ

តារណីយេ តារយិត្វា ពោធនេយ្យេ អពោធយិ
បរិនិព្វាយិ សម្ពុទ្ធោ ឧឡុរាជាវ អត្ថមិ ។

តេ ច ខីណាសវា ភិក្ខូ សោ ច ពុទ្ធោ អសាទិសោ
អតុលំ បភំ ទស្សយិត្វា និព្វុតា តេ មហាយសា ។

តញ្ច ញាណមតុលិយំ តានិ ច អតុលិយានិ រតនានិ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារា ។

សុមនោ យសធរោ ពុទ្ធោ អង្គារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ជិនថូបោ ចតុយោជនមុគ្គតោ ។

សុមនពុទ្ធវំសោ ចតុត្ថោ ។

## សុមនពុទ្ធវង្ស ទី ៤

ព្រះសម្ពុទ្ធ ទ្រង់ចម្លងពួកសត្វដែលគួរចម្លង ទ្រង់បានដាស់តឿនពួកសត្វដែលគួរដាស់តឿន ហើយទ្រង់បរិនិព្វាន ដូចព្រះចន្ទ្រអស្តង្គត ។ ភិក្ខុទាំងឡាយនោះ ជាព្រះខីណាស្រពក៏ ព្រះសម្ពុទ្ធអង្គនោះក៏ ទ្រង់មិនមានបុគ្គលណាស្មើ ទ្រង់បញ្ចេញរស្មីឥតថ្លឹងថ្លែងបាន ព្រះខីណាស្រព មានយសច្រើនទាំងនោះ និព្វានហើយ ។ ព្រះញាណនោះ ជាគុណឥតមានអ្វីថ្លឹងបានផង រតនៈទាំងនោះ ឥតមានអ្វីថ្លឹងបានផង របស់ទាំងអស់នេះវិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះសុមនសម្ពុទ្ធ ទ្រទ្រង់យស ទ្រង់បរិនិព្វានក្នុងអង្គារាម ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកំពស់ ៤ យោជន៍ ប្រតិស្ឋាននៅក្នុងអារាមនោះ ។

ចប់ សុមនពុទ្ធវង្ស ទី ៤ ។

# បញ្ចមោ រេវតពុទ្ធវំសោ

(១) សុមនស្ស អបរេន    រេវតោ នាម នាយកោ
អនុបមោ អសទិសោ    អតុលោ ឧត្តមោ ជិនោ ។
សោបិ ធម្មំ បកាសេសិ    ព្រហ្មុនា អភិយាចិតោ
ខន្ធធាតុវវត្ថានំ    អប្បវត្តំ ភវាភវេ ។
តស្សាភិសមយា តីណិ    អហេសុំ ធម្មទេសនេ
គណនាយ ន វត្តព្វោ    បឋមាភិសមយោ អហុ ។
យទា អរិន្ទមំ រាជំ    វិនេសិ រេវតោ មុនិ
តទា កោដិសហស្សានំ    ទុតិយាភិសមយោ អហុ ។
សត្តាហំ បដិសល្លានា    វុដ្ឋហិត្វា នរាសភោ
កោដិសតំ នរមរូ    វិនេសិ ឧត្តមេ ផលេ ។

## រេវតពុទ្ធវង្ស ទី ៥

[១] កាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមសុមនៈមក មានព្រះលោកនាយក ព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រឹងបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ ។ ព្រះសម្ពុទ្ធអង្គនោះ លុះមហាព្រហ្មអារាធនាហើយ ទ្រង់ប្រកាសធម៌ ដ៏កំណត់ដោយខន្ធនិងធាតុ ជាធម៌មិនប្រព្រឹត្តទៅក្នុងភពតូចភពធំ ។ ក្នុងការសម្តែងធម៌នៃព្រះរេវតសម្ពុទ្ធនោះ មានការត្រាស់ដឹងមគ្គផល ៣ លើក គឺការត្រាស់ដឹងលើកទី ១ មិនគប្បីពោលដោយការរាប់ចំនួនបាន ។ ព្រះមហាមុនី ព្រះនាមរេវតៈ ទ្រង់ទូន្មានព្រះបាទអរិន្ទមៈ ក្នុងកាលណា កាលនោះ ពួកសត្វមួយពាន់កោដិ បានត្រាស់ដឹងមគ្គផល លើកទី ២ ។ ព្រះនរាសភៈ ទ្រង់ក្រោកចាកទីពួនសម្ងំ អស់ ៧ ថ្ងៃ ហើយទូន្មានពួកមនុស្សនិងទេវតាមួយរយកោដិ (ឲ្យតាំងនៅ) ក្នុងផលដ៏ឧត្តម លើកទី ៣ ។

## បញ្ចមោ រេវតពុទ្ធវំសោ

សន្និបាតា តយោ អាសុំ    រេវតស្ស មហេសិនោ
ខីណាសវានំ វិមលានំ    សុវិមុត្តាន តាទិនំ ។
អតិក្កន្តគណនបថា    បឋមា យេ សមាគតា
កោដិសតសហស្សានំ    ទុតិយោ អាសិ សមាគមោ ។
យោ សោ បញ្ញាយ អសមោ    តស្ស ចក្កានុវត្តកោ
សោ តទា ព្យាធិតោ អាសិ    បត្តោ ជីវិតសំសយំ ។
តស្ស គិលានបុច្ឆាយ    យេ តទា ឧបគតា មុនី
កោដិសតសហស្សានំ(១) តតិយោ អាសិ សមាគមោ ។
អហំ តេន សមយេន    អតិទេវោ នាម ព្រាហ្មណោ
ឧបគន្ត្វា រេវតំ ពុទ្ធំ    សរណំ តស្ស គញ្ឆហំ ។
តស្ស សីលំ សមាធិញ្ច    បញ្ញាគុណមនុត្តរំ
ថោមយិត្វា យថាថាមំ    ឧត្តរិយំ អទាសហំ ។

---

១ ឱ. កោដិសតសហស្សា អរហន្តោ ។ ម. កោដិសហស្សា អរហន្តោ ។

## រេវតពុទ្ធវង្ស ទី ៥

ព្រះសម្ពុទ្ធព្រះនាមរេវតៈ ទ្រង់ស្វែងរកគុណធំ មានសាវកសន្និបាត ៣ លើក សុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យរួចស្រឡះដោយប្រពៃ មានបិត្តទឹងធឹង គឺ សន្និបាតលើកទី ១ កន្លងផុតផ្លូវនៃការរាប់ (រាប់ពុំបាន) សន្និបាតលើកទី ២ មានព្រះអរហន្តមួយសែនកោដិ ។ ព្រះអគ្គសាវកអង្គណា រកបុគ្គលស្មើគ្មានដោយប្រាជ្ញា ជាអ្នកប្រព្រឹត្តតាមធម្មចក្រ នៃព្រះសម្ពុទ្ធអង្គនោះ កាលនោះ ព្រះអគ្គសាវកនោះ មានព្យាធិ ដល់នូវការសង្ស័យក្នុងជីវិត ។ កាលនោះ ពួកព្រះអរហន្តចូលទៅគាល់ព្រះមុនី ដើម្បីសាកសួរអាពាធ របស់ព្រះអគ្គសាវកនោះ មានចំនួនមួយសែនកោដិ នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាព្រាហ្មណ៍ ឈ្មោះអតិទេវៈ បានចូលទៅគាល់ព្រះរេវតសម្ពុទ្ធ ហើយបានយកព្រះអង្គជាទីពឹង ។ តថាគតបានសរសើរសីល សមាធិ និងបញ្ញា គុណដ៏ប្រសើររបស់ព្រះអង្គ ហើយបានថ្វាយសំពត់ឧត្តរាសង្គៈ តាមកម្លាំង ។

សោបិ មំ ពុទ្ធោ ព្យាកាសិ រេវតោ លោកនាយកោ
អបរិមេយ្យិតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

ព្រះសម្ពុទ្ធព្រះនាមរេវតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយ ទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេបានតាក់តែង ។ លំដាប់អំពីនោះមក ព្រះទ្រង់យសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រាហ្មណ៍នេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម ។

## បញ្ចមោ វេរិតពុទ្ធំសោ

អនាសវា វីតមលា សន្តចិត្តា សមាហិតា

កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា

អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា

អនាសវា វីតមលា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។

## បវិតពុទ្ធវង្ស ទី ៥

ព្រះថេរៈ ឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាកបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរី ឈ្មោះខេមា ១ ឧប្បល-វណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតម ទ្រង់យសអង្គនោះ មានព្រះជន្ម ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ មិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំហើយ ត្រេកអរថា ព្រាហ្មណ៍នេះ នឹងបានជាពូជពន្លកនៃព្រះពុទ្ធ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ    អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ    ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស    វិរជ្ជិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទី តរន្តា    បដិតិត្ថំ វិរជ្ជិយ
ហេដ្ឋាតិត្ថេ គហេត្វាន    ឧត្តរន្តិ មហានទី ។
ឯវមេវ មយំ សព្វេ    យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា    ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ    ទសបារមិបូរិយា ។
តទាបិ តំ ពុទ្ធធម្មំ    សរិត្វា អនុព្រូហយឹ
អាហរិស្សាមិ តំ ធម្មំ    យំ មយ្ហំ អភិបត្ថិតំ ។

ពួកមនុស្សព្រមទាំងទេវតា មួនហ្មឺនលោកធាតុ ស្រែកហ៊ោឡើងផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផង ថា ពួកយើងបើឃ្លាងមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានជួបក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះតម្រាស់ របស់ព្រះសម្ពុទ្ធនោះហើយ ក៏ធ្វើចិត្តឲ្យត្រេកអរក្រៃពេក បានអធិដ្ឋាននូវវត្តទៅទៀត ដោយការបំពេញបារមី ១០ ។ កាលនោះ តថាគតនឹកឃើញ ហើយបានអប់រំពុទ្ធការកធម៌នោះ ទាំងបានបំពេញនូវពុទ្ធការកធម៌នោះ តាមគួរដល់សេចក្តីប្រាថ្នានៃតថាគត ។

## បញ្ចមោ រេវតពុទ្ធវំសោ

នគរំ សុធញ្ញកំ នាម   វិបុលោ នាម ខត្តិយោ
វិបុលា នាម ជនិកា   រេវតស្ស មហេសិនោ ។
ឆព្វស្សសហស្សានិ   អគារំ អជ្ឈាវសិ សោ
សុទស្សនោ ច រតនគ្ឃិ   អាវេឡោ ច វិភូសិតោ
បុញ្ញកម្មាភិនិព្វត្តា   តយោ បាសាទមុត្តមា ។
តេត្តឹសសតសហស្សានិ   នារិយោ សមលង្កតា
សុទស្សនា នាម នារី   វរុណោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា   រថយានេន និក្ខមិ
អនូនសត្តមាសានិ   បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ   រេវតោ លោកនាយកោ
វត្តចក្កោ មហាវីរោ   វរុណារាមេ សិរី ជិនោ ។

## រេវតពុទ្ធវង្ស ទី ៤

ព្រះរេវតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានទីក្រុង ឈ្មោះ សុធញ្ញក: មានព្រះមហាក្សត្រព្រះនាមវិបុល: ជាព្រះបិតា មាន ព្រះមាតា ព្រះនាមវិបុលា ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់នៅ គ្រប់គ្រងព្រះរាជដំណាក់អស់ ៦ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ ដែលកើតដោយបុញ្ញកម្ម មាន ៣ គឺ សុទស្សនប្រាសាទ ១ រតនគ្ឃិប្រាសាទ ១ អាវេឡប្រាសាទ ១ ដែលគេស្អិតស្អាង ហើយ ។ ពួកនារី ៣៣ សែននាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមសុទស្សនា មានព្រះរាជបុត្រ ព្រះនាមវរុណ: ។ ព្រះជិនស្រី ទ្រង់ឃើញនិមិត្ត ៤ យ៉ាង ហើយទ្រង់ចេញបព្វជ្ជា ដោយរថយាន ហើយតាំងសេចក្តី ព្យាយាម អស់ ៧ ខែឥតខ្វះ ។ ព្រះសម្ពុទ្ធ ទ្រង់ព្រះនាម រេវត: ជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ ទ្រង់ញុំាង ចក្រឲ្យប្រព្រឹត្តទៅ ទ្រង់មានព្យាយាមច្រើន ទ្រង់ឈ្នះមារ ត្រូវមហាព្រហ្មអារាធនាហើយ ទ្រង់គង់នៅក្នុងវរុណារាម ។

វរុណោ ព្រហ្មទេវោ ច អហេសុំ អគ្គសាវកា
សម្ភវោ នាមុបដ្ឋាកោ រេវតស្ស មហេសិនោ ។
ភទ្ទា ចេវ សុភទ្ទា ច អហេសុំ អគ្គសាវិកា
សោបិ ពុទ្ធោ អសមសមោ នាគមូលេ អពុជ្ឈថ ។
វរុណោ ច សរភោ ច អហេសុំ អគ្គុបដ្ឋកា
ចាលា ច ឧបចាលា ច អហេសុំ អគ្គុបដ្ឋិកា ។
ឧច្ចត្តនេន សោ ពុទ្ធោ អសីតិហត្ថមុគ្គតោ
ឱភាសេតិ ទិសា សព្វា ឥន្ទកេតុវ ឧគ្គតោ ។
តស្ស សរីរេ និព្វត្តា បភាមាលា អនុត្តរា
ទិវា វា យទិ វា រត្តឹ សមន្តា ផរតិ យោជនំ ។
សដ្ឋិវស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

ព្រះថេរៈឈ្មោះវរុណៈ ១ ព្រហ្មទេវៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសម្ភវៈ ជាឧបដ្ឋាក របស់ព្រះរេវតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ៗ ព្រះថេរី ឈ្មោះភទ្ទា ១ សុភទ្ទា ១ ជាអគ្គសាវិកា ឯព្រះសម្ពុទ្ធឥតមានបុគ្គលស្មើអង្គនោះ ទ្រង់បានត្រាស់ដឹង ទៀបដើមខ្ទឹង ៗ ឧបាសកឈ្មោះវរុណៈ ១ សរភៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះបាលា ១ ឧបបាលា១ ជាអគ្គឧបដ្ឋាយិកា ៗ ព្រះពុទ្ធអង្គនោះ ទ្រង់មានកំពស់ព្រះអង្គ ៨០ ហត្ថ ទ្រង់ញុំាងទិសទាំងពួង ឲ្យភ្លឺរុងរឿង ដូចទង់ជ័យរបស់ព្រះឥន្ទ្រ ដ៏ខ្ពង់ខ្ពស់ ៗ កម្រងរស្មីដ៏ប្រសើរ កើតក្នុងសរីរៈនៃព្រះអង្គ ផ្សាយចេញមួយយោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់ ៗ ព្រះសម្ពុទ្ធអង្គនោះ មានព្រះជន្មាយុ ៦ ហ្មឺនឆ្នាំ ជាកំណត់ ទ្រង់ឋិតនៅអស់កាលដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង (ចាកវដ្តសង្សារ) ៗ

ទស្សយិត្វា ពុទ្ធពលំ  អមតំ លោកេ បកាសយិ
និព្វាសិ អនុបាទានោ  យថគ្គុបាទានសង្ខយា ។
សោ ច កាយោ រតននិភោ សោ ច ធម្មោ អសាទិសោ
សព្វំ សមន្តរហិតំ  ននុ រិត្តា សព្វសង្ខារាតិ ។
រេវតោ យសធរោ ពុទ្ធោ  និព្វុតោ សោ មហាបុញ្ញោ
ធាតុវិត្ថារិកំ អាសិ  តេសុ តេសុ បទេសតោតិ ។

រេវតពុទ្ធវំសោ បញ្ចមោ ។

# ឆដ្ឋោ សោភិតពុទ្ធវំសោ

(៧) រេវតស្ស អបរេន  សោភិតោ នាម នាយកោ
សមាហិតោ សន្តចិត្តោ  អសមោ អប្បដិបុគ្គលោ ។

ព្រះសម្ពុទ្ធទ្រង់សម្តែងកម្លាំងនៃព្រះពុទ្ធ ហើយទ្រង់ប្រកាសអមតធម៌ ក្នុងលោក ព្រះអង្គមិនមានសេចក្តីប្រកាន់ ទ្រង់បរិនិព្វាន ព្រោះអស់ឧបាទាន ដូចភ្លើងដែលអស់កំញម ។ ព្រះកាយរបស់ព្រះអង្គនោះ មានពណ៌ដូចកែវ ព្រះធម៌របស់ព្រះអង្គ មិនមានអ្វីស្មើដូចទេ របស់ទាំងអស់វិនាសសូន្យទៅ សង្ខារទាំងពួងទទេពិត ។ ព្រះរេវតសម្ពុទ្ធ ទ្រទ្រង់យសអង្គនោះ ទ្រង់មានបុណ្យច្រើន ទ្រង់បរិនិព្វានហើយ ព្រះធាតុរបស់ព្រះអង្គ បានសាយភាយទៅ ក្នុងប្រទេសនោះដោយចំណែកៗ ។

ចប់ រេវតពុទ្ធវង្ស ទី ៥ ។

# សោភិតពុទ្ធវង្ស ទី ៦

(៧) កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមរេវតៈមក មានព្រះលោកនាយកព្រះនាមសោភិតៈ មានព្រះហឫទ័យតំកល់ខ្ជាប់ មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹម ។

សោ ជិនោ សកគេហម្ហិ មានសំ វិនិវត្តយិ
បត្វាន កេវលំ ពោធឹ ធម្មចក្កំ បវត្តយិ ។
យាវ ឧទ្ធំ អវីចិតោ ភវគ្គា ចាបិ ហេដ្ឋតោ
ឯត្ថន្តរេ ឯកបរិសា អហោសិ ធម្មទេសនេ ។
តាយ បរិសាយ សម្ពុទ្ធោ ធម្មចក្កំ បវត្តយិ
គណនាយ ន វត្តព្វោ បឋមាភិសមយោ អហុ ។
តតោ បរំបិ ទេសេន្តេ នរមរូនំ សមាគមេ
នវុតិកោដិសហស្សានំ ទុតិយាភិសមយោ អហុ ។
បុនាបរំ រាជបុត្តោ ជយសេនោ នាម ខត្តិយោ
អារាមំ រោបយិត្វាន ពុទ្ធេ និយ្យាទយី តទា ។
តស្ស យាគំ បកិត្តេន្តោ ធម្មំ ទេសេសិ ចក្ខុមា
តទា កោដិសហស្សានំ តតិយាភិសមយោ អហុ ។

ព្រះជិនស្រីអគ្គនោះ ទ្រង់ញុំាងបំណងក្នុងព្រះទ័យឲ្យប្រព្រឹត្តទៅ ក្នុងព្រះដំណាក់របស់ព្រះអគ្គ ទ្រង់បានសម្រេចសម្ពោធិញ្ញាណដោយសព្វគ្រប់ ហើយទ្រង់សម្ដែងព្រះធម្មចក្រ ។ ខាងលើ រាប់អំពីអវិចិនរកឡើងទៅ ខាងក្រោម រាប់អំពីភវគ្គព្រហ្មចុះមក ក្នុងចន្លោះនេះ ពេញដោយបរិស័ទតែម្យ៉ាង ក្នុងការសម្ដែងធម្មទេសនា ។ កាលព្រះសម្ពុទ្ធ ទ្រង់សម្ដែងព្រះធម្មចក្រ ដល់បរិស័ទនោះ ការត្រាស់ដឹងធម៌លើកទី១ គេមិនគប្បីពោលដោយការរាប់ចំនួនបានឡើយ ។ លំដាប់អំពីនោះមកទៀត កាលព្រះសម្ពុទ្ធ ទ្រង់សម្ដែងធម៌ក្នុងទីសមាគម នៃមនុស្សនិងទេវតា មានពួកបរិស័ទ៩ ម៉ឺនកោដិ ត្រាស់ដឹងធម៌ លើកទី២ ។ មួយវិញទៀត កាលនោះ ព្រះរាជបុត្រ ជាក្សត្រ ព្រះនាមជយសេន ដាំសួនវេរថ្វាយព្រះសម្ពុទ្ធ ។ ព្រះឧត្តមសម្ពុទ្ធ ទ្រង់ប្រកាសការបូជានៃព្រះបាទជយសេននោះ ហើយសម្ដែងធម្មទេសនា ក្នុងកាលនោះ មានបរិស័ទមួយពាន់កោដិ ត្រាស់ដឹងធម៌ លើកទី ៣ ។

## ឆដ្ឋោ សោភិតពុទ្ធវំសោ

សន្និបាតា តយោ អាសុំ សោភិតស្ស មហេសិនោ

ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

ឧគ្គតោ នាម សោ រាជា ទានំ ទេតិ នរុត្តមេ

តម្ហិ ទានេ សមាគញ្ឆុំ អរហន្តា សតកោដិយោ ។

បុនាបរំ បូគគណោ ទានំ ទេតិ នរុត្តមេ

តទា នវុតិកោដីនំ ទុតិយោ អាសិ សមាគមោ ។

ទេវលោកេ វសិត្វាន យទា ឱរោហតី ជិនោ

តទា អសីតិកោដីនំ តតិយោ អាសិ សមាគមោ ។

អហំ តេន សមយេន សុជាតោ នាម ព្រាហ្មណោ

តទា សសាវកំ ពុទ្ធំ អន្នបានេន តប្បយឹ ។

## សោភិតពុទ្ធវង្ស ទី ៦

ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺកាលព្រះរាជាព្រះនាមឧគ្គតៈអង្គនោះ ទ្រង់ថ្វាយទានចំពោះព្រះសម្ពុទ្ធថ្លៃថ្លាជាងនរជន ក្នុងវេលាថ្វាយទាននោះ មានអរហន្តមួយរយកោដិ និមន្តមកប្រជុំគ្នា (នេះជាសន្និបាតលើកទី ១) ។ មួយវិញទៀត មានពួកបរិស័ទថ្វាយទាន ចំពោះព្រះសម្ពុទ្ធថ្លៃថ្លាជាងពួកនរជន ក្នុងកាលនោះ មានពួកបរិស័ទ ៩០ កោដិ (មកប្រជុំគ្នា) នេះជាសន្និបាតលើកទី ២ ។ ព្រះជិនស្រីទ្រង់គង់ក្នុងទេវលោក ហើយស្តេចចុះ ចាកទេវលោក ក្នុងកាលណា កាលនោះ មានពួកបរិស័ទ ៨០ កោដិ (មកប្រជុំគ្នា) នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគតកើតជាព្រាហ្មណ៍ឈ្មោះសុជាតៈ កាលនោះ តថាគតនិមន្តព្រះពុទ្ធព្រមទាំងសាវ័ក ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

សោបិ មំ ពុទ្ធោ ព្យាកាសិ សោភិតោ លោក-
នាយកោ

អបរិមេយ្យេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

ព្រះសម្ពុទ្ធព្រះនាមសោភិតៈ ជាលោកនាយកអង្គនោះ ទ្រង់ព្យាករថាគតថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ព្រាហ្មណ៍នេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្ដីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយនៅទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅគង់ទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ លំដាប់អំពីនោះមក ព្រះជិនស្រី ទ្រង់យសធំអង្គនោះ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹងទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើត របស់ព្រះពុទ្ធអង្គនោះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រាហ្មណ៍នេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។

## នន្ទោ សោភិតពុទ្ធវំសោ

អនាសវា វីតមលា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតមលា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។

## សោភិតពុទ្ធវង្ស ទី ៦

ព្រះថេរៈឈ្មោះកាលិតៈ ១ ឧបតិស្ស ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទាំងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ ទាំងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ៗ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទាំងជាអគ្គសាវិកា ៗ ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧ-បាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ទាំងជាអគ្គឧបដ្ឋាក ៗ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ទាំងជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្ម ១០០ ឆ្នាំ ៗ ពួកមនុស្សទាំងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះសោភិតសម្ពុទ្ធ ឥតមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយក៏រីករាយថា ព្រាហ្មណ៍នេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ    អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ    ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស    វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា    បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថេ គហេត្វាន    ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ    យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា    តុដ្ឋា សំវិគ្គមានសោ
តមេវត្ថមនុប្បត្តិយា    ឧគ្គំ ធិតិមកាសហំ ។
សុធម្មំ នាម នគរំ    សុធម្មោ នាម ខត្តិយោ
សុធម្មា នាម ជនិកា    សោភិតស្ស មហេសិនោ ។
នវវស្សសហស្សានិ(១)    អគារំ អជ្ឈាវសិ សោ(២)
កុមុទោ នឡិនោ បទុមោ    តយោ បាសាទមុត្តមា ។

---

១ ឱ. នវវស្សសហស្សានំ ។ ម. ទសវស្សសហស្សានិ ។ ២ ឱ. ម. អជ្ឈេសោ វសិ ។

ពួកមនុស្សព្រមទាំងទេវតា ក្នុងមួយហ្មឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា ពួកយើង បើនឹងឃ្លាតមគ្គផល ក្នុងសាសនារបស់ព្រះលោកនាថនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត មិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាតកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាតព្រះជិនស្រីអង្គនេះទៅ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះសម្ពុទ្ធអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្តាប់ព្រះពុទ្ធដីការបស់ព្រះសម្ពុទ្ធអង្គនោះ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុតហើយបានធ្វើនូវប្រាជ្ញាឲ្យខ្ពង់ខ្ពស់ ដើម្បីសម្រេចប្រយោជន៍នោះ ។ ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះសុធម្មៈ ព្រះមហាក្សត្រព្រះនាមសុធម្មៈ ជាព្រះបិតាព្រះមាតា ព្រះនាមសុធម្មា ព្រះសោភិតសម្ពុទ្ធអង្គនោះ ទ្រង់គ្រប់គ្រងដំណាក់ អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ គឺ កុមុទប្រាសាទ ១ នឡិនប្រាសាទ ១ បទុមប្រាសាទ ១ ។

## ឆដ្ឋោ សោភិតពុទ្ធវំសោ

តិចត្តារិ(១) សហស្សានិ  នារិយោ សមលង្កតា
មិខិលា នាម សា(២) នារី  សីហោ នាមាសិ អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា  បាសាទេនាភិនិក្ខមិ
សត្តាហំ បធានចារំ  ចរិត្វា បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ  សោភិតោ លោកនាយកោ
វត្តចក្កោ មហាវីរោ  សុធម្មុយ្យានមុត្តមេ ។
អសមោ ច សុនេត្តោ ច  អហេសុំ អគ្គសាវកា
អនោមោ នាមុបដ្ឋាកោ  សោភិតស្ស មហេសិនោ ។
នកុលា ច សុជាតា ច  អហេសុំ អគ្គសាវិកា
ពុជ្ឈមានោ ច សោ ពុទ្ធោ  នាគមូលេ អពុជ្ឈថ ។
រម្មោ ចេវ សុនេត្តោ(៣) ច  អហេសុំ អគ្គុបដ្ឋកា
នកុលា ចេវ ចិត្តា ច  អហេសុំ អគ្គុបដ្ឋិកា ។

---

១ ឱ. អសត្តតិ ។ ម. សត្តតីស ។ ២ ឱ. សមង្គី នាម សា ។ ម. សា មេខិលា នាម ។
៣ ឱ. ម. សុទត្តោ ។

## សោភិតពុទ្ធវង្ស ទី ៦

ពួកនារី ៤ ពាន់នាក់ មានរូបតាក់តែងសមរម្យ ឯនារីជាអគ្គមហេសី ឈ្មោះកិមិលា មានព្រះរាជបុត្រ ឈ្មោះសីហៈ ។ ព្រះសម្ពុទ្ធទ្រង់ខ្ពស់ជាងបុរស ទ្រង់ឃើញនិមិត្ត ៤ យ៉ាង ហើយស្តេចចេញទៅទ្រង់ព្រះផ្នួស ដោយប្រាសាទ ទៅប្រព្រឹត្តបធានចារៈ អស់ ៧ ថ្ងៃ ។ ព្រះសោភិតសម្ពុទ្ធជាលោកនាយក មានព្រះទ័យស្ងប់ស្ងាប់ ទ្រង់មានចក្រប្រព្រឹត្តទៅ មានព្យាយាមច្រើន ត្រូវមហាព្រហ្មអារាធនាហើយ ក្នុងសុធម្មឧទ្យានដ៏ប្រសើរ ។ ព្រះថេរៈ ឈ្មោះអសមៈ ១ សុនេត្តៈ ១ ជាអគ្គសាវ័ក ព្រះថេរៈ ឈ្មោះអនោមៈ ជាឧបដ្ឋាករបស់ព្រះសោភិតសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ ។ ព្រះថេរី ឈ្មោះនកុលា ១ សុជាតា ១ ជាអគ្គសាវិកា ព្រះសម្ពុទ្ធអង្គនោះ កាលត្រាស់ដឹង ទ្រង់ត្រាស់ទៀបដើមខ្លឹង ។ ឧបាសកឈ្មោះរម្មៈ ១ សុនេត្តៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះនកុលា ១ ចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។

អដ្ឋបញ្ញាសរតនំ អច្ចុគ្គតោ មហាមុនិ
ឱភាសេតិ ទិសា សព្វា សតរំសីវ ឧគ្គតោ ។
យថា សុផុល្លំ បវនំ នានាគន្ធេហិ ធូបិតំ
តថេវ តស្ស បាវចនំ សីលគន្ធេហិ ធូបិតំ ។
យថាបិ សាគរោ នាម ទស្សនេន អតប្បិយោ
តថេវ តស្ស បាវចនំ សវនេន អតប្បិយំ ។
នវុតិវស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
ឱវាទំ អនុសិដ្ឋិញ្ច ទត្វាន សេសកេ ជនេ
ហុតាសនោវ តាបេត្វា និព្វុតោ សោ សសាវកោ ។
សោ ច ពុទ្ធោ អសមសមោ តេ ច សាវកា ពលប្បត្តា
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ ។

ព្រះមហាមុនី ទ្រង់មានកំពស់ ៥៨ ហត្ថ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺរុងរឿង ដូចព្រះអាទិត្យរះឡើង ។ ព្រៃធំដែលមានផ្កាឈើល្អ ដែលអប់ដោយក្លិនក្រអូបផ្សេង ៗ យ៉ាងណា ពាក្យប្រដៅ របស់ព្រះសម្ពុទ្ធអង្គនោះ តែងអប់ដោយក្លិនក្រអូបគឺសីល ក៏យ៉ាងនោះដែរ ។ ធម្មតាសាគរ គេតែងមិនឆ្អែត ដោយការរមិលមើល យ៉ាងណា ពាក្យប្រដៅរបស់ព្រះសម្ពុទ្ធអង្គនោះ គេមិនឆ្អែត ដោយការស្តាប់ ក៏យ៉ាងនោះដែរ ។ ព្រះអង្គមានព្រះជន្ម៩ ហ្មឺនឆ្នាំជាកំណត់ ព្រះអង្គគង់នៅដរាបអស់កាលប៉ុណ្ណោះ ទ្រង់ញុំាងប្រជុំជនឲ្យឆ្លង (វដ្តសង្សារ) ។ ព្រះអង្គព្រមទាំងសាវ័ក ទ្រង់ឲ្យឱវាទ នឹងការប្រៀនប្រដៅចំពោះជនដ៏សេស ហើយញុំាងជនទាំងនោះឲ្យមានព្យាយាមផុតកំដៅកិលេសដូចភ្លើង រួចបរិនិព្វាន ។ ព្រះសម្ពុទ្ធស្មើ ដោយព្រះពុទ្ធ ឥតមានបុគ្គលស្មើអង្គនោះក្តី ពួកសាវ័កទាំងនោះ ដែលដល់នូវកម្លាំងក្តី របស់ទាំងអស់នេះ ក៏វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។

សោភិតោ វរសម្ពុទ្ធោ  សីហារាមម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ  តេសុ តេសុ បទេសតោ ។

សោភិតពុទ្ធវំសោ ឆដ្ឋោ ។

## សត្តមោ អនោមទស្សិពុទ្ធវំសោ

(៨) សោភិតស្ស អបរេន  សម្ពុទ្ធោ ទិបទុត្តមោ
អនោមទស្សី អមិតយសោ  តេជសី ទុរតិក្កមោ ។

សោ ឆេត្វា ពន្ធនំ សព្វំ  វិទ្ធំសេត្វា តយោ ភវេ
អនិវត្តិគមនំ មគ្គំ  ទេសេសិ ទេវមានុសេ ។

សាគរោវ អសង្ខោភោ  បព្វតោវ ទុរាសទោ
អាកាសោវ អនន្តោ សោ  សាលរាជាវ ផុល្លិតោ ។

ព្រះសោភិតសម្ពុទ្ធដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងសីហារាម ព្រះធាតុ (របស់ព្រះអង្គ) សាយភាយទៅ ក្នុងប្រទេសនោះ តាមចំណែក ៗ ។

ចប់ សោភិតពុទ្ធវង្ស ទី ៦ ។

# អនោមទស្សីពុទ្ធវង្ស ទី ៧

(៨) កាលជាខាងក្រោយ អំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធ ព្រះនាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់ក្រមបុគ្គលកន្លងបាន ។ ព្រះសម្ពុទ្ធទ្រង់កាត់បំណងទាំងអស់ កំចាត់បង់ភពទាំង ៣ ហើយសម្ដែងផ្លូវសម្រាប់ដើរឆ្ពោះទៅរកនិព្វាន មិនត្រឡប់វិញ បំពោះទេវតានិងមនុស្ស ៗ ព្រះអនោមទស្សីអង្គនោះ ទ្រង់មិនរំភើប ដូចជាសាគរ គេគ្របសង្កត់បានដោយក្រ ដូចជាភ្នំ ទ្រង់មានគុណរកទីបំផុតគ្មាន ដូចជាអាកាស មានព្រះកាយរីកពេញ ដូចជាស្ដេចឈើ ៗ

ទស្សនេនបិ តំ ពុទ្ធំ តោសិតា ហោន្តិ បាណិនោ
ព្យាហរន្តំ គិរំ សុត្វា អមតំ បាបុណន្តិ តេ ។
ធម្មាភិសមយោ តស្ស ឥទ្ធោ ផីតោ តទា អហុ
កោដិសតានិ អភិសមឹសុ បឋមេ ធម្មទេសនេ ។
តតោ បរំ អភិសមយេ វស្សន្តេ ធម្មវុដ្ឋិយោ
អសីតិកោដី អភិសមឹសុ ទុតិយេ ធម្មទេសនេ ។
តតោ បរំ ហិ វស្សន្តេ តប្បយន្តេ៍ បាណិនំ
អដ្ឋសត្តតិកោដីនំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ តស្សាបិ ច មហេសិនោ
អភិញ្ញាពលប្បត្តានំ បុប្ផិតានំ វិមុត្តិយា ។
អដ្ឋសតសហស្សានំ សន្និបាតា តទា អហុ
បហីនមទមោហានំ សន្តចិត្តាន តាទិនំ ។

ពួកសត្វ គ្រាន់តែឃើញព្រះសម្ពុទ្ធអង្គនោះ ក៏មានសេចក្តីត្រេកអរ សត្វទាំងនោះ លុះបានស្តាប់មធុរវាចា ដែលលាន់ឮ ក៏បានដល់អមតនិព្វាន ៗ កាលនោះ ការត្រាស់ដឹងធម៌របស់ព្រះអង្គ ក៏ធំទូលាយផ្សាយទៅ ចំនួនពួកសត្វ ១០០ កោដិ បានត្រាស់ដឹងក្នុងការសម្តែងធម៌ លើកទី ១ ៗ លំដាប់អំពីនោះមក កាលព្រះសម្ពុទ្ធបង្អុរចុះ នូវភ្លៀងគឺធម៌ ក្នុងអភិសម័យ ពួកសត្វ ៨០ កោដិ បានត្រាស់ដឹង ក្នុងការសម្តែងធម៌ លើកទី ២ ៗ តអំពីនោះមកទៀត កាលព្រះសម្ពុទ្ធ ទ្រង់បង្អុរចុះគ្រាប់ភ្លៀង គឺធម៌ ទ្រង់ញុំាងពួកសត្វឲ្យឆ្អែតស្កប់ស្កល់ (ដោយធម៌) ពួកសត្វ ៧៨ កោដិ បានសម្រេចមគ្គផល លើកទី ៣ ៗ ព្រះអនោមទស្សីអង្គនោះ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះអរហន្ត បានសម្រេចអភិញ្ញាពលៈ រីកពេញដោយវិមុត្តិ គឺសន្និបាតលើកទី ១ កាលនោះ មានព្រះអរហន្ត ៨ សែន ដែលមានសេចក្តីស្រវឹង និងសេចក្តីវង្វេង លះបង់ហើយ មានសន្តានស្ងប់រម្ងាប់ ទាំងមានចិត្តនឹងធឹង ៗ

## សត្តមោ អនោមទស្សីពុទ្ធវំសោ

សត្តសតសហស្សានំ ទុតិយោ អាសិ សមាគមោ
អនង្គណានំ វិរជានំ ឧបសន្តាន តាទិនំ ។
ឆន្នំ សតសហស្សានំ តតិយោ អាសិ សមាគមោ
អភិញ្ញាពលប្បត្តានំ និព្វុតានំ តបស្សិនំ ។
អហន្តេន សមយេន យក្ខោ អាសឹ មហិទ្ធិកោ
នេកានំ យក្ខកោដីនំ វសវត្តិម្ហិ ឥស្សរោ ។
តទាបិ តំ ពុទ្ធវរំ ឧបគន្ត្វា មហេសិនំ
អន្នបានេន តប្បេសឹ សសង្ឃំ លោកនាយកំ ។
សោបិ មំ តទា ព្យាកាសិ វិសុទ្ធនយនោ មុនិ
អបរិមេយ្យិតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កាបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

## អនោមទស្សិពុទ្ធវង្ស ទី ៣

សន្និបាតលើកទី ២ មានព្រះអរហន្ត ៧ សែន ដែលមិនមានទីទួលគឺកិលេស ប្រាសចាកធូលីគឺកិលេស ទាំងមានសន្តានស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ សន្និបាតលើកទី ៣ មានព្រះអរហន្ត ៦ សែន ដែលបានសម្រេចអភិញ្ញាពលៈ មានទុក្ខរំលត់ហើយ មានព្យាយាមដុតកំដៅកិលេស ។ សម័យនោះ តថាគតកើតជាយក្ស មានឫទ្ធិច្រើន ជាធំជាងពួកយក្សច្រើនកោដិ ក្នុងវសវត្តីទេវលោក ។ កាលនោះ តថាគតបានចូលទៅគាល់ព្រះសម្ពុទ្ធប្រសើរអង្គនោះ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ហើយអង្គាសព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។ ឯព្រះមុនីអង្គនោះ ទ្រង់មានព្រះនេត្រដ៏បរិសុទ្ធ ទ្រង់ព្យាករតថាគតថា ក្នុងកប្បមានប្រមាណមិនបាន អំពីកប្បនេះទៅ យក្សនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុជាទីរីករាយ ហើយតាំងសេចក្ដីព្យាយាម ធ្វើទុក្ករកិរិយា ។

អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឃហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។

សត្វនេះ នឹងអង្គុយនៅទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ រួចហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយក៏ចូលទៅ ឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ។ តអំពីនោះមក ព្រះជិនស្រី មានយសច្រើន ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយបានត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះសម្ពុទ្ធនេះ នឹងមានព្រះនាមថាមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ យក្សនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម ។ ព្រះថេរៈ ឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ នឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរីឈ្មោះខេមា ១ ឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។

## សត្តមោ អនោមទស្សីពុទ្ធវំសោ

ពោធិ តស្ស ភគវតោ  អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ  អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា  អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស  គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ  អសមស្ស មហេសិនោ
អាមោទិតា នរមរូ  ពុទ្ធវីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ  អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ  ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស  វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទីតរន្តា  បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន  ឧត្តរន្តិ មហានទី ។

## អនោមទស្សីពុទ្ធវង្ស ទី ៧

ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ គេហៅ ជាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះបិត្តៈ ១ ហត្ថាឡវកៈ ១ ទឹងជាអគ្គឧបដ្ឋាក ៗ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ទឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមដ៏ប្រង់យសអង្គនោះ មាន ព្រះជន្មាយុ ១០០ ឆ្នាំ ៗ ពួកមនុស្សទិងទេវតា លុះបានស្តាប់ ព្រះពុទ្ធដីកានេះ របស់ព្រះអនោមទស្សី មិនមានបុគ្គលស្មើ ទ្រង់ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា យក្សនេះ ជាពូជពន្ទុកនៃព្រះពុទ្ធ ៗ ពួកមនុស្សព្រមទាំងទេវតា មួយ ហ្មឺនលោកធាតុ នាំគ្នាស្រែកហ៊ោផង ទះដៃផង សើចផង ធ្វើអញ្ជលីនមស្ការផងថា ពួកយើង បើនឹងឃ្លាងមគ្គផលក្នុង សាសនា របស់ព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តានេះ ក្នុងកាលជាអនាគតមិន ខាន ៗ ពួកមនុស្ស កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំ យ៉ាងណា ៗ

ឯវមេវ មយំ សព្វេ   យទិ មុញ្ចាមិមំ ជិនំ

អនាគតម្ហិ អទ្ធានេ   ហេស្សាម សម្មុខា ឥមំ ។

តស្សាបិ វចនំ សុត្វា   តុដ្ឋោ សំវិគ្គមានសោ

ឧត្តរិំ វត្តមធិដ្ឋាសិំ   ទសបារមិបូរិយា ។

នគរំ ចន្ទវតី នាម   យសវា នាម ខត្តិយោ

មាតា យសោធរា នាម   អនោមទស្សិស្ស សត្ថុនោ ។

ទសវស្សសហស្សានិ   អគារំ អជ្ឈាវសិ សោ

សិរិ ឧបសិរិ វឌ្ឍោ   តយោ បាសាទមុត្តមា ។

តេវីសតិសហស្សានិ   នារិយោ សមលង្កតា

សិរិមា នាម សា នារី   ឧបសាលោ នាម អត្រជោ ។

និមិត្តេ ចតុរោ ទិស្វា   សិវិកាយាភិនិក្ខមិ

អនូនទសមាសានិ   បធានំ បទហី ជិនោ ។

ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបាន សម្រេច ចំពោះព្រះភក្ត្រព្រះពុទ្ធអង្គនេះ ក្នុងកាលជាអនាគត មិនខាន ក៏យ៉ាងនោះដែរ ។ ចំណែកតថាគត លុះបានស្ដាប់ ព្រះពុទ្ធដីកា របស់ព្រះអនោមទស្សីអង្គនោះ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត បានអធិដ្ឋាន នូវវត្តតទៅទៀត ដោយការ បំពេញបារមីទាំង ១០ ។ ព្រះសាស្ដា ព្រះនាមអនោមទស្សី មាននគរឈ្មោះចន្ទវតី មហាក្សត្រព្រះនាមយសវ៉ា ជាព្រះបិតា ព្រះមាតា ព្រះនាមយសោធរា ។ ព្រះអនោមទស្សីអង្គនោះ ទ្រង់នៅគ្រប់គ្រងព្រះរាជដំណាក់ អស់មួយហ៊ឺនឆ្នាំ ប្រាសាទដ៏ ប្រសើរ មាន ៣ គឺ សិរិប្រាសាទ ១ ឧបសិរិប្រាសាទ ១ វឌ្ឍប្រាសាទ ១ (សម្រាប់ព្រះអង្គ) ។ ពួកនារី ២ ហ៊ឺន ៣ ពាន់ នាក់ មានរូបប្រដាប់សមរម្យ នារីជាអគ្គមហេសីនោះ ព្រះនាម សិរិមា មានព្រះរាជបុត្រ ព្រះនាមឧបសាលៈ ។ ព្រះជិនស្រី ទ្រង់បានឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្ដេចចេញទៅដោយវ (វ៉ែគ្រស្នួង) ទ្រង់តាំងសេចក្ដីព្យាយាម អស់ ១០ ខែឥតខ្វះ ។

## សត្តមោ អនោមទស្សីពុទ្ធវំសោ

ព្រហ្មុនា យាចិតោ សត្ថា អនោមទស្សី មហាមុនិ
វត្តចក្កោ មហាវីរោ សុទស្សនុយ្យានមុត្តមេ ។
និសភោ ច អនោមោ ច អហេសុំ អគ្គសាវកា
វរុណោ នាមុបដ្ឋាកោ អនោមទស្សិស្ស សត្ថុនោ ។
សុន្ទរា ច សុមនា ច អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ អជ្ជុនោតិ បវុច្ចតិ ។
នន្ទិវឌ្ឍោ សិរិវឌ្ឍោ អហេសុំ អគ្គុបដ្ឋកា
ឧប្បលា ច បទុមា ច អហេសុំ អគ្គុបដ្ឋិកា ។
អដ្ឋបណ្ណាសរតនំ អច្ចុគ្គតោ មហាមុនិ
បភា និទ្ធាវតី តស្ស សតរំសីវ ឧគ្គតោ ។
វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

## អនោមទស្សីពុទ្ធវង្ស ទី ៣

ព្រះអនោមទស្សីមហាមុនី មានព្រះទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ដែលព្រហ្មអារាធនាហើយ ទ្រង់សម្ដែងធម្មចក្រ ក្នុងសុទស្សនឧទ្យានដ៏ឧត្ដម ។ ព្រះថេរៈ ឈ្មោះនិសភៈ ១ អនោមៈ ១ ជាអគ្គសាវក ឯព្រះថេរៈ ឈ្មោះវរុណៈ ជាឧបដ្ឋាក របស់ព្រះសាស្ដា ព្រះនាមអនោមទស្សីនោះ ។ ព្រះថេរី ឈ្មោះសុន្ទរា ១ សុមនា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថាអជ្ជុនព្រឹក្ស (ដើមអង្គ្រង) ។ ឧបាសក ឈ្មោះនន្ទិវឌ្ឍៈ ១ សិរិវឌ្ឍៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ ឧបលា ១ បទុមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី មានកំពស់ ៥៨ ហត្ថ ពន្លឺនៃព្រះអង្គផ្សាយចេញទៅ ដូចព្រះអាទិត្យរះឡើង ។ ព្រះអង្គមានព្រះជន្មាយុ មួយសែនឆ្នាំ ជាកំណត់ ទ្រង់ឋិតនៅអស់កាលដរាបនោះ ទ្រង់ញ៉ាំងប្រជុំជនច្រើនឲ្យឆ្លង (វដ្ដសង្សារ) ។

សុបុប្ផិតំ បាវចនំ   អរហន្តេហិ តាទិហិ
វីតរាគេហិ វិមលេហិ   សោភតិ ជិនសាសនំ ។

សោ ច សត្ថា អមិតយសោ   យុគានិ តានិ អតុលិយានិ
សព្វំ សមន្តរហិតំ   ននុ រិត្តា សព្វសង្ខារា ។

អនោមទស្សី ជិនោ សត្ថា   ធម្មារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ជិនថូបោ   ឧព្វេធោ បន វីសតីតិ ។

អនោមទស្សិពុទ្ធវំសោ សត្តមោ ។

# អដ្ឋមោ បទុមពុទ្ធវំសោ

(៩) អនោមទស្សិស្ស អបរេន   សម្ពុទ្ធោ ទិបទុត្តមោ
បទុមោ នាម នាមេន   អសមោ អប្បដិបុគ្គលោ ។

ពាក្យជាប្រធាន គឺសាសនា កែល្អហើយ ដោយពួកអរហន្ត ជាតាទិបុគ្គល ប្រាសចាកពកៈ ប្រាសចាកមន្ទិល សាសនារបស់ព្រះជិនស្រី ល្អរុងរឿង ។ ឯព្រះសាស្តាអង្គនោះ មានយសរាប់មិនបានក្តី គូនៃសាវ័កទាំងនោះ មានគុណប្រឹងមិនបានក្តី របស់ទាំង (នោះ) វិនាសសូន្យទៅ សង្ខារទាំងពួង ជារបស់ទទេពិត ។ ព្រះជិនស្រី ជាសាស្តា ព្រះនាមអនោមទស្សី ទ្រង់បរិនិព្វានក្នុងធម្មារាម ឯព្រះស្តូបបញ្ចុះព្រះធាតុ របស់ព្រះជិនស្រីអង្គនោះ មានកំពស់ ២០ យោជន៍ ប្រតិស្ឋានទៅក្នុងអារាមនោះ ។

ចប់ អនោមទស្សីពុទ្ធវង្ស ទី ៧ ។

## បទុមពុទ្ធវង្ស ទី ៨

(៩) ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោម-ទស្សីមក មានព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។

## អដ្ឋមោ បទុមពុទ្ធវំសោ

តស្សាបិ អសមំ សីលំ សមាធិបិ អនន្តកោ
អសង្ខេយ្យំ ញាណវរំ វិមុត្តិបិ អនូបមា ។

តស្សាបិ អតុលតេជស្ស ធម្មចក្កប្បវត្តនេ
អភិសមយា តយោ អាសុំ មហាតមបវាហនា ។

បឋមាភិសមយេ ពុទ្ធោ កោដិសតមពោធយិ
ទុតិយាភិសមយេ ធីរោ នវុតិកោដិមពោធយិ ។

យទា ច បទុមោ ពុទ្ធោ ឱវទិ សកមត្រជំ
តទា អសីតិកោដីនំ តតិយាភិសមយោ អហុ ។

សន្និបាតា តយោ អាសុំ បទុមស្ស មហេសិនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។

កឋិនត្ថារសមយេ ឧប្បន្នេ កឋិនចីវរេ
ធម្មសេនាបតិត្ថាយ ភិក្ខូ សិព្វិំសុ ចីវរំ ។

បទុមពុទ្ធវង្ស ទី ៨

សីលនៃព្រះអង្គ ឥតមានសីលនៃបុគ្គលដទៃស្មើ ទាំងសមាធិក៏កេទីបំផុតគ្មាន ព្រះញាណដ៏ប្រសើរ ទឹងរាប់ពុំបាន ទាំងវិមុត្តិក៏មិនមានឧបមា ។ កាលដែលព្រះពុទ្ធ ព្រះនាមបទុមៈ ព្រះអង្គនោះ មានតេជះថ្លឹងមិនបាន ទ្រង់ញ៉ាំងធម្មចក្រឱ្យប្រព្រឹត្តទៅមានការត្រាស់នូវធម៌បីលើក ដែលជាគ្រឿងបន្សាត់បង់ នូវងងឹតដ៏ធំ ។ គឺព្រះពុទ្ធ ទ្រង់ញ៉ាំងសត្វ ១០០ កោដិ ឱ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ញ៉ាំងសត្វ ៩០ កោដិ ឱ្យត្រាស់ដឹង ក្នុងការត្រាស់ដឹង ទី ២ ។ មួយទៀតព្រះពុទ្ធ ព្រះនាមបទុមៈ ទ្រង់ទូន្មានព្រះឱរសរបស់ព្រះអង្គ ក្នុងកាលណា កាលនោះ ពួកសត្វ ៨០ កោដិ ត្រាស់ដឹង លើកទី ៣ ។ ព្រះពុទ្ធព្រះនាមបទុមៈ ជាមហេសី មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានភិក្ខុមួយសែនកោដិ ។ កាលកឋិនចីវរកើតឡើងហើយ ក្នុងសម័យជាទីក្រាលនូវកឋិន ភិក្ខុទាំងឡាយ បានដេរនូវចីវរ ដើម្បីប្រគេនព្រះធម្មសេនាបតី ។

តទា តេ វិមលា ភិក្ខូ ឆឡភិញ្ញា មហិទ្ធិកា
តីណិ សតសហស្សានិ សមឹសុ អបរាជិតា ។

បុនាបរំ សោ នរាសភោ បវនេ វាសំ ឧបាគមិ
តទា សមាគមោ អាសិ ទ្វិន្នំ សតសហស្សានំ ។

អហន្តេន សមយេន សីហោ អាសឹ មិគាភិភូ
វិវេកមនុព្រូហន្តំ បវនេ អទ្ទសំ ជិនំ ។

វន្ទិត្វា សិរសា បាទេ កត្វាន តំ បទក្ខិណំ
តិក្ខត្តុំ អភិនាទិត្វា សត្តាហំ ជិនមុបដ្ឋហឹ ។

សត្តាហំ វរសមាបត្តិយា វុដ្ឋហិត្វា តថាគតោ
មនសា ចិន្តយិត្វាន កោដិភិក្ខូ សមានយិ ។

តទាបិ សោ មហាវីរោ តេសំ មជ្ឈេ វិយាករិ
អបរិមេយ្យឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។

ក្នុងកាលនោះ ភិក្ខុទាំង ៣ សែនរូបនោះ សុទ្ធតែប្រាសចាក មន្ទិល មានអភិញ្ញា ៦ មានឫទ្ធិច្រើន ជាអ្នកមិនញាប់ញ័រ បានមកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។ មួយវិញទៀត ព្រះពុទ្ធ ព្រះនាមបទុមៈអង្គនោះ ទ្រង់ប្រសើរជាងពួកនរៈ ស្តេចចូលទៅកាន់លំនៅក្នុងព្រៃធំ ក្នុងកាលនោះ មានភិក្ខុ ២ សែនរូបជួបជុំគ្នា នេះជាសន្និបាតលើកទី ៣ ។ សម័យនោះ តថាគត កើតជាសត្វសីហៈ គ្របសង្កត់លើពួកម្រឹគ បាន ឃើញព្រះជិនស្រី ព្រះអង្គកំពុងចំរើននូវវិវេក ក្នុងព្រៃធំ ។ តថាគតបានថ្វាយបង្គំនូវព្រះបាទទាំងគូ ដោយសិរ្សៈ ហើយ ធ្វើប្រទក្សិណព្រះអង្គ រួចបន្លឺឡើងនូវសីហនាទ អស់ ៣ ដង បានបម្រើព្រះជិនស្រី អស់ ៧ ថ្ងៃ ។ ព្រះតថាគតទ្រង់ ចេញចាកសមាបត្តិដ៏ប្រសើរ អស់ ៧ ថ្ងៃ ហើយទ្រង់ព្រះ ចិន្តាដោយព្រះហឫទ័យ រួចទ្រង់ប្រមូលមក នូវភិក្ខុចំនួន មួយកោដិ ។ កាលនោះ ព្រះមហាវីរៈនោះ ទ្រង់ព្យាករក្នុង កណ្តាលភិក្ខុសង្ឃ ទាំងមួយកោដិនោះថា ក្នុងកប្បប្រមាណ មិនបាន អំពីកប្បនេះ សត្វសីហៈនេះ នឹងបានជាព្រះពុទ្ធ ។

## អដ្ឋមោ បទុមពុទ្ធវំសោ

អហុ កបិលវ្ហយា រម្មា  និក្ខមិត្វា តថាគតោ

បធានំ បទហិត្វាន  កត្វា ទុក្ករការិកំ ។

អជបាលរុក្ខមូលស្មឹ  និសីទិត្វា តថាគតោ

តត្ថ បាយាសំ បគ្គយ្ហ  នេរញ្ជរមុបេហិតិ ។

នេរញ្ជរាយ តីរម្ហិ  បាយាសំ អទិ សោ ជិនោ

បដិយត្តវរមគ្គេន  ពោធិមូលម្ហិ ឯហិតិ ។

តតោ បទក្ខិណំ កត្វា  ពោធិមណ្ឌំ អនុត្តរំ ។

អស្សត្ថរុក្ខមូលម្ហិ  ពុជ្ឈិស្សតិ មហាយសោ ។

ឥមស្ស ជនិកា មាតា  មាយា នាម ភវិស្សតិ

បិតា សុទ្ធោទនោ នាម  អយំ ហេស្សតិ គោតមោ ។

អនាសវា វីតរាគា  សន្តចិត្តា សមាហិតា

កោលិតោ ឧបតិស្សោ ច  អគ្គា ហេស្សន្តិ សាវកា

អានន្ទោ នាមុបដ្ឋាកោ  ឧបដ្ឋិស្សតិមំ ជិនំ ។

## បទុមពុទ្ធវង្ស ទី ៣

សត្វនេះ នឹងចេញចាកក្រុងជាទីត្រេកអរ ឈ្មោះកបិលពស្តុ ហើយតម្កល់សេចក្តីព្យាយាម នឹងធ្វើនូវទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅ ទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេជម្រះហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំទ្រង់ធ្វើនូវការប្រទក្សិណពោធិមណ្ឌៈ ដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតនៃព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះសម្ពុទ្ធអង្គនេះ នឹងមានព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងបានជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធវីជង្កុរោ អយំ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

ព្រះនាងខេមា ១ ព្រះនាងឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ទឹងជាអគ្គសាវិកា ៗ ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ ទឹងជាអគ្គឧបដ្ឋាក ៗ នាងនន្ទមាតា ១ នាងឧត្តរា ១ ទឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម មានយសអង្គនោះ កំណត់ ១០០ ឆ្នាំ ៗ ទេវតានិងមនុស្សទាំងឡាយ លុះបានស្តាប់នូវព្រះបន្ទូលនេះ របស់ព្រះពុទ្ធព្រះនាមមទុមៈ ទ្រង់ស្វែងរកនូវគុណធំ រកបុគ្គលស្មើគ្មាន ក៏មានចិត្តត្រេកអរថា សត្វសីហៈនេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ សម្លេងហ៊ោឡើង ក៏ប្រព្រឹត្តទៅ ឯមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ ក៏ទះដៃសើច ផ្គងអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះពុំខាន ៗ

# អដ្ឋមោ បទុមពុទ្ធវំសោ

យថា មនុស្សា នទី តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថេ គហេត្វាន ឧត្តរន្តិ មហានទី ។

ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

តស្សាបិ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ ទសបារមិបូរិយា ។

ចម្បកំ នាម នគរំ អសមោ នាម ខត្តិយោ
អសមា នាម ជនិកា បទុមស្ស មហេសិនោ ។

ទសវស្សសហស្សានិ អគារំ អជ្ឈាវសិ សោ(១)
នន្ទា វសុ យសុត្តរោ(២) តយោ បាសាទមុត្តមា ។

តេត្តឹសសហស្សានិ នារិយោ សមលង្កតា
ឧត្តរា នាម សា នារី រម្មោ នាមាសិ អត្រជោ ។

---

១ ឱ. ម. អជ្ឈ សោ វសីតិ ទិស្សតិ ។ ២ ឱ. នន្ទា ច សុយសា ឧត្តរាតិ ខាយតិ ។ ម. នន្ទា សុយសុត្តរាតិ ទិស្សតិ ។

## បទុមពុទ្ធវង្ស ទី ៨

មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងនូវកំពង់ក្នុងទីចំពោះមុខ គង់កាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ៗ ឯតថាគតលុះបានឮព្រះបន្ទូល នៃព្រះសម្ពុទ្ធ ទ្រង់ព្រះនាមបទុមៈនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋាននូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង ១០ ៗ ព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះចម្បកៈ មានមហាក្សត្រ ព្រះនាមអសមៈជាបិតា មានព្រះមាតាព្រះនាមអសមា ៗ ព្រះសម្ពុទ្ធព្រះនាមបទុមៈនោះនៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ ខ្នង គឺនន្ទប្រាសាទ១ វសុប្រាសាទ១ យសត្តរប្រាសាទ១ ៗ មាននារីបីម៉ឺនបីពាន់រូប សឹងតាក់តែងល្អ ឯនារីជាអគ្គមហេសីនោះ ឈ្មោះនាងឧត្តរា មានព្រះរាជឱរស ព្រះនាមរម្មៈ ៗ

និមិត្តេ ចតុរោ ទិស្វា  រថយានេន និក្ខមិ
អនូនអដ្ឋមាសានិ(១)  បធានំ បទហី ជិនោ ។

ព្រហ្មុនា យាចិតោ សន្តោ  បទុមោ លោកនាយកោ
វត្តចក្កោ មហាវីរោ  ធនញ្ជុយ្យានមុត្តមេ ។

សាលោ ច ឧបសាលោ ច  អហេសុំ អគ្គសាវកា
វរុណោ នាមុបដ្ឋាកោ  បទុមស្ស មហេសិនោ ។

រាធា ចេវ សុរាធា ច  អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ  មហាសោណោតិ វុច្ចតិ ។

សភិយោ ចេវ អសមោ ច  អហេសុំ អគ្គុបដ្ឋកា
រុចិ ច នន្ទិមារា ច  អហេសុំ អគ្គុបដ្ឋិកា ។

អដ្ឋបណ្ណាសរតនំ  អច្ចុគ្គតោ មហាមុនិ
បភា និទ្ធាវតី តស្ស  អសមា សព្វតោ ទិសា ។

---

១ ឱ. អនូនកំ អឌ្ឍមាសត្តិ ទិស្សតិ ។

ព្រះជិនស្រី ទ្រង់បានឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្តេចចេញមហាភិនិស្ក្រម ដោយយានគឺរថ ទ្រង់តម្កល់នូវព្យាយាម អស់ ៨ ខែគត់ ៗ ព្រះសម្ពុទ្ធព្រះនាមបទុម: ជាលោកនាយក ជាមហាវីរ: ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះធនញ្ជ: ៗ ភិក្ខុឈ្មោះសាល: ១ ឈ្មោះឧបសាល: ១ ជាអគ្គសាវក ភិក្ខុឈ្មោះវរុណ: ជាឧបដ្ឋាករបស់ព្រះពុទ្ធ ព្រះនាមបទុម: ទ្រង់ស្វែងរកនូវគុណធំ ៗ ព្រះនាងរាធា ១ ព្រះនាងសុរាធា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា មហាសោណ: (ដើមម្រុំ) ៗ ឧបាសកឈ្មោះសភិយ: ១ ឈ្មោះអសម: ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះ រុចិ ១ ឈ្មោះនន្ទិមារា ១ ជាអគ្គឧបដ្ឋាយិកា ៗ ព្រះសម្ពុទ្ធព្រះនាមបទុម: ជាមហាមុនី ទ្រង់មានកំពស់ ៥៨ ហត្ថ កម្រងរស្មីនៃព្រះមហាមុនីអង្គនោះ តែងផ្សាយចេញសព្វទិស ទាំងឥតមានអ្វីស្មើ ៗ

## អដ្ឋមោ បទុមពុទ្ធវំសោ

ចន្ទប្បភា សុរិយប្បភា រតនគ្គិមណិប្បភា
សព្វាបិ តា ហតា ហោន្តិ បត្វា ជិនប្បភុត្តមំ ។
វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
បរិបក្កមានសេ សត្តេ ពោធយិត្វា អសេសតោ
សេសញ្ញេ(១) អនុសាសេត្វា និព្វុតោ សោ សសាវកោ ។
ឧរគោវ តចំ ជិណ្ណំ វុឌ្ឍបត្តំវ បាទបោ
ជហិត្វា សព្វសង្ខារេ និព្វុតោ សោ យថា សិខីតិ ។
បទុមោ ជិនវរោ សត្ថា ធម្មារាមម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោតិ ។

បទុមពុទ្ធវំសោ អដ្ឋមោ ។

---

១ ឱ. សេសកេ ។

## បទុមពុទ្ធវង្ស ទី ៧

ស្មើព្រះចន្ទ ស្មើព្រះអាទិត្យ ស្មើកែវមណី ស្មើទាំងអស់នោះ ក៏សាបសូន្យទៅ ព្រោះប៉ះទីផុតទីរបស់ព្រះជិនស្រីដ៏ឧត្តម ។ ព្រះជន្មាយុ (របស់ព្រះមហាមុនីនោះ) មួយសែនឆ្នាំជាកំណត់ ព្រះមហាមុនីអគ្គនោះ កាលទ្រង់ព្រះជន្មនៅដរាបនោះ ទ្រង់ញុំាងប្រជុំជនច្រើនឲ្យឆ្លង (ចាកសង្សារ) ។ ព្រះមហាមុនីអគ្គនោះ ទ្រង់ញុំាងសត្វដែលមានឥន្ទ្រិយចាស់ក្លា ឲ្យត្រាស់ដឹងមិនមានសេសសល់ ទ្រង់ប្រៀនប្រដៅសត្វទាំងឡាយ ដែលសេសសល់ ទ្រង់បរិនិព្វានទៅ ជាមួយនឹងសាវ័ក ។ ព្រះមហាមុនីអគ្គនោះ ទ្រង់លះបង់នូវសង្ខារទាំងពួង ដូចជាពស់ដែលលះបង់នូវសំណកចាស់ ឬដូចជាដើមឈើជម្រុះនូវស្លឹកចាស់ ហើយទ្រង់បរិនិព្វានទៅ ដូចជាអណ្តាតប្រទីបផុតពន្លត់ ។ ព្រះសាស្តាព្រះនាមបទុមៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងធម្មារាម មានព្រះធាតុផ្សាយទៅ ក្នុងប្រទេសនោះ ៗ ។

ចប់ បទុមពុទ្ធវង្ស ទី ៨ ។

# ទសមោ នារទពុទ្ធវំសោ

(១០) បទុមស្ស អបរេន សម្ពុទ្ធោ ទ្វិបទុត្តមោ
នារទោ នាម នាមេន អសមោ អប្បដិបុគ្គលោ ។
សោ ពុទ្ធោ ចក្កវត្តិស្ស ជេដ្ឋោ ទយិតឱរសោ
អាមុត្តមាល្យាភរណោ(១) ឧយ្យានំ ឧបសង្កមិ ។
តត្ថាសិ រុក្ខោ វិបុលោ អភិរូបោ ព្រហា(២) សុចិ
តមជ្ឈបត្វា និសីទិ មហាសោណស្ស ហេដ្ឋតោ ។
តត្ថ(៣) ញាណវរុប្បជ្ជិ អនន្តំ វជិរូបមំ
តេន វិចិនិ សង្ខារេ ឧក្កុជ្ជមវកុជ្ជកំ ។
តត្ថ សព្វកិលេសានិ អសេសមភិវាហយិ
បាបុណិ កេវលំ ពោធឹ ពុទ្ធញាណេ ច ចុទ្ទស ។

---

១ ឱ. អាមុត្តមល្យាភរណោ ។ ម. អាមុត្តមាលាភរណោ ។ ២ ឱ. ព្រហ្មា ។ ៣ ឱ. តស្ស ។

# នារទពុទ្ធវង្ស ទី ៩

(១០) ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមបទុមៈមក មានព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។ ព្រះអង្គនោះ ជាព្រះរាជបុត្រច្បង ជាព្រះរាជឱរសជាទីស្រឡាញ់របស់ស្តេចចក្រពត្តិ ទ្រង់បានពាក់នូវកែវមណី និងគ្រឿងអាភរណៈ ហើយស្តេចចូលទៅកាន់ឧទ្យាន ។ ក្នុងឧទ្យាននោះ មានឈើមួយដើម ឈ្មោះមហាសោណព្រឹក្ស ជាឈើសមរម្យ ធំ ល្អស្អាត ព្រះសម្ពុទ្ធស្តេចទៅដល់ នូវដើមឈើនោះហើយ ទ្រង់គង់ខាងក្រោមនៃឈើនោះ ។ ព្រះញាណប្រសើរកទីបំផុតគ្មាន មានឧបមាដូចជាកែវវជីរ បានកើតឡើង (ដល់ព្រះអង្គ) ក្នុងទីនោះ ព្រះអង្គពិចារណានូវសង្ខារទាំងឡាយ ដោយព្រះញាណនោះ ដូចជាបុគ្គលដែលផ្កាប់ឬផ្ងារឡើងនូវភាជនៈ ។ ក្នុងទីនោះ ព្រះអង្គទ្រង់បន្សាត់បង់ នូវកិលេសទាំងពួង មិនឲ្យសេសសល់ ហើយបានសម្រេចនូវពោធិញ្ញាណទាំងអស់ផង នូវពុទ្ធញ្ញាណទាំង ១៤ ផង ។

## នវមោ នារទពុទ្ធវំសោ

បាបុណិត្វាន សម្ពោធឹ ធម្មចក្កំ បវត្តយិ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។

មហាទោណំ នាគរាជំ វិនយន្តោ មហាមុនិ
បាដិហេរំ តទាកាសិ ទស្សយន្តោ សទេវកេ ។

តទា ទេវមនុស្សានំ តម្ហិ ធម្មប្បកាសនេ
នវុតិកោដិសហស្សានិ តរឹសុ សព្វសំសយំ ។

យម្ហិ កាលេ មហាវីរោ ឱវទិ សកមត្រជំ
អសីតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។

សន្និបាតា តយោ អាសុំ នារទស្ស មហេសិនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។

យទា ពុទ្ធោ ពុទ្ធគុណំ សនិទានំ បកាសយិ
នវុតិកោដិសហស្សានិ សមឹសុ វិមលា តទា ។

លុះព្រះអង្គសម្រេចនូវសម្ពោធិហើយ ទើបទ្រង់សម្តែង នូវធម្មចក្រ សត្វមួយសែនកោដិ បានត្រាស់ដឹងជាដំបូង ។ ព្រះមហាមុនីទូន្មានស្តេចនាគ ឈ្មោះមហាទោណៈ ក្នុងកាលនោះ ទ្រង់ពន្យល់នូវពួកមនុស្សព្រមទាំងទេវតា ហើយទ្រង់ធ្វើនូវបាដិហារ្យ ។ ក្នុងកាលនោះ ទេវតានិងមនុស្សទាំងឡាយ ៩០ ពាន់កោដិ បានឆ្លងផុតនូវសេចក្តីសង្ស័យទាំងអស់ ក្នុងការប្រកាសនូវព្រះធម៌នោះ នេះជាការត្រាស់ដឹងទី ២ ។ ព្រះមហាវីរៈ ទ្រង់ទូន្មាននូវបុត្របង្កើតរបស់ព្រះអង្គ ក្នុងកាលណា (កាលនោះ) ពួកសត្វចំនួន ៨០ កោដិ បានត្រាស់ដឹង ក្នុងលើកទី ៣ ។ ព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកដំបូង មានពួកព្រះអរហន្តប្រមាណមួយសែនកោដិ ។ ព្រះសម្ពុទ្ធទ្រង់ប្រកាសពុទ្ធគុណ ព្រមទាំងនិទានក្នុងកាលណា កាលនោះ ព្រះអរហន្តប្រមាណ ៩០ ពាន់កោដិ ប្រាសចាកមន្ទិល មកប្រជុំគ្នា នេះជាសន្និបាតលើកទី ២ ។

យទា វេរោចនោ នាគោ ទានំ ទទាតិ សត្ថុនោ
តទា សមឹសុ ជិនបុត្តា អសីតិសតសហស្សិយោ ។
អហន្តេន សមយេន ជដិលោ ឧគ្គតាបនោ
អន្តលិក្ខចរោ អាសឹ បញ្ចាភិញ្ញាសុ បារគូ ។
តទាហំ អសមសមំ សសង្ឃំ សបរិជនំ
អន្នបានេន តប្បេត្វា ចន្ទនេនាភិបូជយឹ ។
សោបិ មំ តទា ព្យាកាសិ នារទោ លោកនាយកោ
អបរិមេយ្យេ ឥតោ កប្បេ ពុទ្ធោ លោកេ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។

នាគរាជឈ្មោះវេរោចនៈ បានថ្វាយទានដល់ព្រះសាស្តា ក្នុងកាលណា កាលនោះ ពួកសាវ័កជាបុត្តនៃព្រះជិនស្រី ប្រមាណ ៨០ សែន បានមកប្រជុំគ្នា (នេះជាសន្និបាតលើកទី ៣) ។ សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមក្លៀវក្លា បានដល់ត្រើយ នៃអភិញ្ញាទាំង៥ ត្រាច់ទៅតាមអាកាសបាន ។ គ្រានោះ តថាគតបានញុំាងព្រះសម្ពុទ្ធ ដែលស្មើដោយព្រះពុទ្ធមិនមានបុគ្គលស្មើ ព្រមទាំងព្រះសង្ឃ និងជនជាបរិស័ទ ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ហើយបូជាដោយខ្លឹមចន្ទន៍ ។ គ្រានោះ ព្រះនារទៈជាលោកនាយកអគ្គនោះ ទ្រង់បានព្យាករតថាគតថា ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ តាបសនេះ នឹងបានជាព្រះពុទ្ធ ក្នុងលោក ។ សត្វនេះនឹងចេញចាកក្រុងកបិលពស្តុ ជាទីត្រេកអរ តម្កល់ទុកនូវសេចក្តីព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះនឹងគង់ទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ រួចចូលទៅកាន់ស្ទឹងនេរញ្ជរា ។

## នវមោ នារទពុទ្ធវំសោ

នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។

## នារទពុទ្ធវង្ស ទី ៩

ព្រះជិនស្រីអង្គនោះ ទ្រង់សោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលមកទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះពុទ្ធទ្រង់មានយសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈ ដ៏ប្រសើរហើយទ្រង់ត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ទ្រង់ជាអគ្គសាវក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទៈ ទ្រង់បំរើព្រះជិនស្រីនេះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ តាំងមានចិត្តតាំងមាំ ទ្រង់ជាអគ្គសាវិកា ។

ពោធិ តស្ស ភគវតោ   អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ   អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា   អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស   គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ   អសមស្ស មហេសិនោ

អាមោទិតា នរមរូ   ពុទ្ធពីជង្កុរោ អយំ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ   អប្ផោដេន្តិ ហសន្តិ ច

កតញ្ជលី នមស្សន្តិ   ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស   វិរជ្ឈិស្សាម សាសនំ

អនាគតម្ហិ អទ្ធានេ   ហេស្សាម សម្មុខា ឥមំ ។

យថា មនុស្សា នទឹ តរន្តា   បដិតិត្ថំ វិរជ្ឈិយ

ហេដ្ឋាតិត្ថេ គហេត្វាន   ឧត្តរន្តិ មហានទឹ ។

ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅជាអស្សត្ថព្រឹក្ស ឧបាសក ឈ្មោះបិត្តគហបតី១ ឈ្មោះហត្ថាឡវកគហបតី ១ ទាំងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ទាំងជាអគ្គឧបដ្ឋាយិកា ។ ព្រះជន្មាយុរបស់ព្រះគោតមមានយសអង្គនោះ កំណត់១០០ឆ្នាំ ។ ទេវតានិងមនុស្សទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះ របស់ព្រះសម្ពុទ្ធ ព្រះអង្គមិនមានបុគ្គលស្មើ ទ្រង់ស្វែងរកនូវគុណធំ ក៏ត្រេកអរថា ជដិលនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សម្រែងហ៊ោ ក៏ប្រព្រឹត្តទៅ មនុស្សព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃ សើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ។ មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងនូវកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណាមិញ ។

## នវមោ នារទពុទ្ធវំសោ

ឃរមេវ មយំ សត្ថេ យទិ បុញ្ញមិទំ ជិនំ,
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាហំ វចនំ សុត្វា ភិយ្យោ ហាសេត្វាន មានសំ
អធិដ្ឋហឹ វត្តំ ឧគ្គំ ឧសភារមិប្បិយា ។
នគរំ ធញ្ញវតី នាម សុទេវោ នាម ខត្តិយោ
អនោមា នាម ជនិកា នារទស្ស មហេសិនោ ។
នវវស្សសហស្សានិ អគារំ អជ្ឈាវសិ សោ(១)
ជិតោ វិជិតាភិរាមោ តយោ បាសាទមុត្តមា ។
តិចត្តារិ សហស្សានិ នារិយោ សមលង្កតា
វិជិតសេនា នាម សា នារី នន្ទុត្តរោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា បទសា គមនេន និក្ខមិ
សត្តាហំ បធានចារំ អចរិ បុរិសុត្តមោ ។

១ ឧ. ម. អជ្ឈ សោ វសីតិ ទិស្សតិ ។

## នារទពុទ្ធវង្ស ទី ៩

បើយើងទាំងអស់គ្នា ឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ក៏យ៉ាងនោះដែរ ។ តថាគតបានបានឮព្រះពុទ្ធដីកា នៃព្រះពុទ្ធអង្គនោះហើយ ក៏ញុំាងចិត្តឲ្យរីករាយ ដោយក្រៃលែង បានអធិដ្ឋាននូវវត្ត ដ៏លើសលុបដោយការបំពេញនូវបារមីទាំង១០ ។ ព្រះពុទ្ធព្រះនាមនារទៈទ្រង់ស្វែងរកនូវគុណដ៏ធំ មាននគរឈ្មោះធញ្ញវតី មហាក្សត្រព្រះនាមសុទេវៈ ជាព្រះបិតា ព្រះមាតា ព្រះនាមអនោមា ។ព្រះនារទៈនោះ នៅគ្រប់គ្រងផ្ទះ អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ ខ្នង គឺ ជិតប្រាសាទ ១ វិជិតប្រាសាទ ១អភិរាមប្រាសាទ ១ ។ មាននារី ៣-៤ ពាន់រូប សុទ្ធសឹងស្អិតស្អាងល្អ ព្រះនារី (ដែលជាអគ្គមហេសី) នោះ ព្រះនាមវិជិតសេនា ឯព្រះរាជបុត្រ ព្រះនាមនន្ទុត្តរៈ ។ ព្រះពុទ្ធជាបុរសរត្នដ៏ប្រសើរ ទ្រង់ទតឃើញ នូវនិមិត្តទាំង ៤ហើយស្ដេចចេញមហាភិនិស្ក្រម ដោយការយាងទៅដោយព្រះបាទផ្ទាល់ ហើយទ្រង់ប្រព្រឹត្តព្យាយាម អស់ ៧ ថ្ងៃ ។

ព្រហ្មុនា យាចិតោ សន្តោ នារទោ លោកនាយកោ

វត្តចក្កោ មហាវីរោ ធនញ្ជុយ្យានមុត្តមេ ។

ភទ្ទសាលោ ជិតមិត្តោ អហេសុំ អគ្គសាវកា

វាសេដ្ឋោ នាមុបដ្ឋាកោ នារទស្ស មហេសិនោ ។

ឧត្តរា ផគ្គុនី ចេវ អហេសុំ អគ្គសាវិកា

ពោធិ តស្ស ភគវតោ មហាសោណោតិ វុច្ចតិ ។

ឧគ្គរិន្ទោ វសភោ ច អហេសុំ អគ្គុបដ្ឋកា

ឥន្ទវរី ច គណ្ឌី ច អហេសុំ អគ្គុបដ្ឋិកា ។

អដ្ឋាសីតិរតនានិ អច្ចុគ្គតោ មហាមុនិ

កញ្ចនគ្ឃិកសង្កាសោ ទសសហស្សី វិរោចតិ ។

ព្រះនារទៈជាលោកនាយក ជាមហាវីរបុរស ត្រូវព្រហ្ម អារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះធនញ្ជៈ ។ ភិក្ខុឈ្មោះភទ្ទសាលៈ ១ ឈ្មោះជិតមិត្តៈ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះវាសេដ្ឋៈ ជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធនារទៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ ៗ នាងឧត្តរា ១ នាងផគ្គុនី ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា មហាសោណព្រឹក្ស ។ ឧបាសកឈ្មោះឧគ្គរិន្ទៈ ១ ឈ្មោះវសភៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះឥន្ទវរី ១ ឈ្មោះគណ្ឌី ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី ទ្រង់មានកំពស់ ៨៨ ហត្ថក្រពុំ មានព្រះរូប ស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស បានញ៉ាំងលោកធាតុទាំងមួយម៉ឺន ឲ្យភ្លឺរុងរឿង ។

## នវមោ នារទពុទ្ធវំសោ

តស្ស ព្យាមប្បភាកាយោ និទ្ធាវតិ ទិសោទិសំ
និរន្តរំ ទិវា រត្តឹ យោជនំ ផរតេ សទា ។
ន កោចិ តេន សមយេន សមន្តា យោជនេ ជនា
ឧក្កា បទីបេ ឧជ្ជលេន្តិ ពុទ្ធរំសីហិ ឱត្ថតា ។
នវុតិវស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
យថា ឧឡូហិ គគនំ វិចិត្តំ ឧបសោភតិ
តថេវ សាសនំ តស្ស អរហន្តេហិ សោភតិ ។
សំសារសោតំ តរណាយ សេសកេ បដិបន្នកេ
ធម្មសេតុំ ទឡ្ហំ កត្វា និព្វុតោ សោ នរាសភោ ។
សោបិ ពុទ្ធោ អសមសមោ តេបិ ខីណាសវា
អតុលតេជា
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ ។

ព្រះកាយរបស់ព្រះអង្គ មានរស្មីប្រមាណមួយព្យាយាម តែងផ្សាយទៅកាន់ទិសតូចទិសធំ តែងផ្សាយទៅកាន់ទីប្រមាណ ១ យោជន៍ ទាំងថ្ងៃទាំងយប់ ជានិរន្តរ៍ សព្វ ៗ កាល ៗ សម័យនោះ ជនទាំងឡាយពួកខ្លះ នៅក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញ ត្រូវរស្មីទាំងឡាយនៃព្រះពុទ្ធ គ្របសង្កត់ហើយ មិនចាំបាច់អុជភ្លើងគប់ ឬអុជភ្លើងប្រទីបទាំងឡាយឡើយ ៗ ព្រះជន្មាយុកំណត់ ប្រាំបួនសែនឆ្នាំគត់ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែងញ៉ាំងប្រជុំជនដ៏ច្រើនឲ្យឆ្លង ចាកសង្សារ ៗ អាកាសដ៏វិចិត្ររុងរឿង ដោយផ្កាយទាំងឡាយ យ៉ាងណា សាសនា របស់ព្រះនារទៈអង្គនោះ ក៏រុងរឿងដោយព្រះអរហន្តទាំងឡាយ ក៏យ៉ាងនោះដែរ ៗ ព្រះពុទ្ធព្រះនាមនារទៈ ប្រសើរជាងពួកនរៈអង្គនោះ ទ្រង់ធ្វើស្ពាន គឺព្រះធម៌ឲ្យមាំ ដើម្បីបម្លងនូវជនទាំងឡាយដ៏សេស ដែលកំពុងដើរទៅ ដើម្បីឆ្លងនូវខ្សែទឹក គឺសង្សារ ហើយបរិនិព្វាន ៗ ព្រះពុទ្ធស្មើដោយព្រះពុទ្ធ ដែលគ្មានបុគ្គលស្មើអង្គនោះក្តី ព្រះខីណាស្រពទាំងឡាយ មានតេជៈថ្លឹងពុំបាន ទាំងអម្បាលនោះក្តី ក៏និព្វានបាត់បង់អស់ របស់ទាំងពួងក៏អន្តរធានអស់ ឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សោះសូន្យពិត ៗ

នារទោ ជិនវុសភោ   និព្វុតោ សុទស្សនេ បុរេ
តថេវ ថូបវរោ   ចតុយោជនមុគ្គតោតិ ។

នារទពុទ្ធវំសោ នវមោ ។

# ទសមោ បទុមុត្តរពុទ្ធវំសោ

(១១) នារទស្ស អបរេន   សម្ពុទ្ធោ ទីបទុត្តមោ
បទុមុត្តរោ នាម ជិនោ   អក្ខោភោ សាគរូបមោ ។
មណ្ឌកប្បោ ច សោ អាសិ   យម្ហិ ពុទ្ធោ អជាយថ
ឧស្សន្នកុសលា ជនតា   តម្ហិ កប្បេ អជាយថ ។
បទុមុត្តរស្ស ភគវតោ   បឋមេ ធម្មទេសនេ
កោដិសតសហស្សានំ   ធម្មាភិសមយោ អហុ ។
តតោ បរំបិ វស្សន្តេ   តប្បយន្តេ ច បាណិនេ
សត្តតឹសសហស្សានំ   ទុតិយាភិសមយោ អហុ ។

ព្រះនារទៈ ជាព្រះជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងព្រះសុទស្សនបុរី ព្រះស្តូបដ៏ប្រសើរ មានកម្ពស់ប្រមាណ ៤ យោជន៍ ។

ចប់ នារទពុទ្ធវង្ស ទី ៩ ។

# បទុមុត្តរពុទ្ធវង្ស ទី ១០

[១១] ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ។ ព្រះពុទ្ធនេះទ្រង់កើតឡើង ក្នុងកប្បណា កប្បនោះ ឈ្មោះមណ្ឌកប្ប ប្រជុំជនមានកុសលដុះឡើងហើយ តែងកើតក្នុងកប្បនោះ ។ កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ ទ្រង់សម្តែងនូវព្រះធម៌ជាជម្រុង សត្វទាំងឡាយ ប្រមាណមួយសែនកោដិ ក៏បានត្រាស់ដឹងនូវមគ្គនិងផល ។ លំដាប់តអំពីនោះមក កាលព្រះបរមសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ទ្រង់បង្អុរចុះនូវធម៌ ទ្រង់ញុំាងពួកសត្វ ឲ្យឆ្អែតស្កប់ស្កល់ ពួកសត្វប្រមាណ ៣ ម៉ឺន ៧ ពាន់ បានត្រាស់ដឹងក្នុងលើកទី ២ ។

## ទសមោ បទុមុត្តរពុទ្ធវំសោ

យម្ហិ កាលេ មហាវីរោ អានន្ទំ ឧបសង្កមិ
បិតុ សន្តិកំ ឧបគន្ត្វា អាហនិ អមតទុន្ទុភឹ ។
អាហតេ អមតភេរិម្ហិ វស្សន្តេ ធម្មវុដ្ឋិយា
បញ្ញាសសតសហស្សានំ តតិយាភិសមយោ អហុ ។
ឱវាទកោ វិញ្ញាបកោ តារកោ សព្វបាណិនំ
ទេសនាកុសលោ ពុទ្ធោ តារេសិ ជនតំ ពហុំ ។
សន្និបាតា តយោ អាសុំ បទុមុត្តរស្ស សត្ថុនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។
យទា ពុទ្ធោ អសមសមោ វសិ វេភារបព្វតេ
នវុតិកោដិសហស្សានំ ទុតិយោ អាសិ សមាគមោ ។
បុន ចារិកំ បក្កន្តេ គាមនិគមរដ្ឋតោ
អសីតិកោដិសហស្សានំ តតិយោ អាសិ សមាគមោ ។

បទុមុត្តរពុទ្ធវង្ស ទី ១០

ក្នុងកាលណា ព្រះមហាបុរស ស្ដេចចូលទៅរកព្រះបាទអា· នន្ទជាព្រះបិតា លុះស្ដេចចូលទៅកាន់សំណាក់ព្រះបិតាហើយ ទ្រង់ទូងស្គរ គឺអមតធម៌ ៗ កាលស្គរ គឺអមតធម៌ ដែលព្រះអង្គទ្រង់ទូងហើយ ភ្លៀងគឺធម៌ក៏ធ្លាក់ចុះ (ក្នុងកាលនោះ) ពួកសត្វប្រមាណ ៥ លាន បានត្រាស់ដឹងក្នុងលើកទី ៣ ៗ ព្រះពុទ្ធទ្រង់ឈ្លាសក្នុងទេសនា ទ្រង់ទូន្មានពន្យល់ ចម្លងនូវសត្វទាំងពួង បានចម្លងហើយនូវប្រជុំជនជាច្រើន ៗ ព្រះសាស្ដាព្រះនាមបទុមុត្តរៈ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានព្រះខីណាស្រព ប្រមាណមួយសែនកោដិ ៗ កាលណា ព្រះសម្ពុទ្ធ ស្មើដោយព្រះអតីតពុទ្ធ រកបុគ្គលស្មើគ្មាន ទ្រង់គង់នៅលើភ្នំវេភារៈបព៌ត (ក្នុងកាលនោះ) ជាសន្និបាតលើកទី ២ មានព្រះខីណាស្រព ប្រមាណ ៩០ ពាន់កោដិ ៗ កាលព្រះសម្ពុទ្ធ បៀសចេញចាកស្រុក ចាកនិគមនិងដែន ទៅកាន់ចារិកម្ដងទៀត នេះជាសន្និបាតលើកទី ៣ មានព្រះខីណាស្រពប្រមាណ ៨០ ពាន់កោដិ ៗ

អហន្តេន សមយេន   ជដិលោ នាម រដ្ឋិកោ
សមុទ្ទប្បមុខំ សង្ឃំ   សភត្តំ ទុស្សមទាសិហំ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ   សង្ឃមជ្ឈេ និសីទិយ
សតសហស្សេ ឥតោ កប្បេ   អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា   និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន   កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ   និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ   នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ   បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន   ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា   ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ   ពុជ្ឈិស្សតិ មហាយសោ ។

សម័យនោះ តថាគតជាជដិល អ្នកនៅក្នុងដែន តថាគត បានថ្វាយសំពត់ព្រមទាំងភត្ត ដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយទ្រង់ព្យាករតថាគតថា ក្នុងកប្បទីមួយសែនអំពីកប្បនេះ ជដិលនេះ នឹងបានជាព្រះពុទ្ធមួយអង្គ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីត្រេកអរ តំកល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ ទ្រង់សោយបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅ ទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ។ លំដាប់នោះ ព្រះសម្ពុទ្ធទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។

## ទសមោ បទុមុត្តរពុទ្ធវំសោ

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។

ព្រះមាតាបង្កើត នៃព្រះសម្ពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ ឯព្រះសម្ពុទ្ធអង្គនេះ ព្រះនាមគោតម ៗ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអគ្គសាវ័កសុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ ទីដ៏បម្រើព្រះជិនស្រីអង្គនេះ ៗ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអគ្គ-សាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតាំងមាំ ៗ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហ-បតី១ ឈ្មោះហត្ថាឡវកគហបតី១ ទីដ៏ជាអគ្គឧបដ្ឋាក ៗ នាងនន្ទមាតា ១ នាងឧត្តរា ១ ទីដ៏ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុរបស់ព្រះគោតម ដ៏មានយសអង្គនោះ កំណត់ ១០០ ឆ្នាំ ៗ ទេវតា និងមនុស្សទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះនៃព្រះសម្ពុទ្ធ រកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយក៏ត្រេកអរថា ជដិលនេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា ឧត្តរឹ វត្តមធិដ្ឋហឹ
អកាសឹ ឧគ្គំ(១) ទឡ្ហំ ធិតឹ ទសបារមិបូរិយា ។
ព្យាហតា តិត្ថិយា សព្វេ វិមនា ទុម្មនា តទា
ន តេសំ កោចិ បរិចរន្តិ រដ្ឋតោ និច្ឆុភន្តិ តេ ។

---

១ ឱ. មគ្គំ ។

សម្លេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាតមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងគង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះគោតមនេះ ។ មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាតកំពង់ ក្នុងទីចំពោះមុខ គង់កាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណា ។ យើងទាំងអស់គ្នា បើឃ្លាតព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ តថាគតបានឮព្រះបន្ទូល នៃព្រះសម្ពុទ្ធអង្គនោះហើយ បានអធិដ្ឋានវត្តដ៏លើសលុបឡើងទៅ បានធ្វើនូវព្យាយាម ដ៏ខ្ពង់ខ្ពស់ មាំមួន ដោយការបំពេញនូវបារមីទាំង ១០ ។ ក្នុងកាលនោះ តិរ្ថិយទាំងពួងអាក់អន់តូចចិត្ត វិនាសខ្លាតខ្លាយ បរិស័ទពួកខ្លះនៃតិរ្ថិយទាំងនោះ មិនបំរើតិរ្ថិយទាំងនោះ ក៏នាំគ្នាចៀសចេញចាកដែនទៅ ។

## ទសមោ បទុមុត្តរពុទ្ធវំសោ

សព្វេ តត្ថ សមាគន្ត្វា ឧបគច្ឆុំ ពុទ្ធសន្តិកេ
តុវំ នាថោ មហាវីរ សរណំ ហោហិ ចក្ខុមា ។
អនុកម្បកោ ការុណិកោ ហិតេសី សព្វបាណិនំ
សម្បត្តេ តិត្ថិយេ សព្វេ បញ្ចសីលេ បតិដ្ឋហិ ។
ឯវំ និរាកុលំ អាសិ សុញ្ញតំ តិត្ថិយេហិ តំ
វិចិត្តំ អរហន្តេហិ វសីភូតេហិ តាទិហិ ។
នគរំ ហំសវតី នាម អានន្ទោ នាម ខត្តិយោ
សុជាតា នាម ជនិកា បទុមុត្តរស្ស សត្ថុនោ ។
នវ(១)វស្សសហស្សានិ អគារំ អជ្ឈាវសិ សោ
នារី ពាហនោ យសវតី តយោ បាសាទមុត្តមា ។

---

១ ឱ. ម. ទស ... ។

តិរិយទាំងពួង មកប្រជុំគ្នាក្នុងទីនោះ ហើយបានចូលទៅក្នុងសំណាក់ នៃព្រះពុទ្ធ (ហើយពោលថា) បពិត្រព្រះមហាវីរៈ សូមព្រះអង្គជាទីពឹងពំនាក់ (នៃយើងខ្ញុំទាំងឡាយ) បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គជាទីរឭក ។ ព្រះពុទ្ធទ្រង់អនុគ្រោះ ទ្រង់ប្រកបដោយករុណា ទ្រង់ស្វែងរកប្រយោជន៍ ដល់សត្វទាំងពួង ទ្រង់ញុំាងតិរិយទាំងអស់ ដែលមកប្រជុំហើយ ឲ្យឋិតនៅ ក្នុងសីល ៥ ។ សាសនា (របស់ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈនោះ) មិនកើត ជាសាសនាសូន្យ ចាកពួកតិរិយយ៉ាងនេះ សាសនានោះ វិចិត្រហើយដោយព្រះអរហន្តទាំងឡាយ ជាអ្នកស្ទាត់ជំនាញ ជាតាទិបុគ្គល ។ ព្រះសាស្តា ព្រះនាមបទុមុត្តរៈ មានព្រះនគរ ឈ្មោះហង្សវតី មានមហាក្សត្រព្រះនាមអានន្ទៈ ជាព្រះបិតា មានព្រះមាតាព្រះនាមសុជាតា ។ ព្រះអង្គទ្រង់នៅគ្រប់គ្រងផ្ទះ អស់ ៩ ពាន់ឆ្នាំ ប្រាសាទទាំងឡាយ ដ៏ប្រសើរមាន ៣ ខ្នង គឺ នារីប្រាសាទ ១ ពាហនប្រាសាទ ១ យសវតីប្រាសាទ ១ ។

តិចត្តារិ សហស្សានិ   នារិយោ សមលង្កតា
វសុលទត្តា នាម[1] នារី   ឧត្តរោ នាម[2] អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា   បាសាទេនាភិនិក្ខមិ
សត្តាហំ បធានចារំ   អចរិ បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ   បទុមុត្តរោ វិនាយកោ
វត្តចក្កោ មហាវីរោ   មិថិលុយ្យានមុត្តមេ ។
ទេវិលោ ច សុជាតោ ច   អហេសុំ អគ្គសាវកា
សុមនោ នាមុបដ្ឋាកោ   បទុមុត្តរស្ស សត្ថុនោ ។
អមិតា អសមា ចេវ   អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ   សលឡោតិ បវុច្ចតិ
អមិតោ[3] ចេវ តិស្សោ ច   អហេសុំ អគ្គុបដ្ឋិកា
ហត្ថា ចេវ សុចិត្តា ច   អហេសុំ អគ្គុបដ្ឋិកា ។

---

១ ឱ. ម. វសុទត្តា នាម ។ ២ ម. ឧត្តមោ ។ ៣ ឱ. ម. វិតិណ្ណោ ។

មាននារីបីបួនពាន់ គាក់តែងល្អ ឯនារីដែលជាអគ្គមហេសី ឈ្មោះវសុលទត្តា ព្រះរាជបុត្រព្រះនាមឧត្តរៈ ។ ព្រះជិនស្រីប្រសើរជាងបុរស ទ្រង់ឃើញនូវនិមិត្តទាំង ៤ យ៉ាង ហើយស្តេចចេញទៅ ដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាមអស់ ៧ ថ្ងៃ ។ ព្រះបទុមុត្តរសម្ពុទ្ធ ជានាយក ជាមហាវីរបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះមិថិលា ។ ភិក្ខុឈ្មោះទេវិល ១ ឈ្មោះសុជាតៈ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសុមនៈ ជាឧបដ្ឋាក របស់ព្រះសាស្តាព្រះនាមបទុមុត្តរៈ ។ ភិក្ខុនីឈ្មោះអមិតា ១ ឈ្មោះអសមា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគអង្គនោះ ហៅថា សលឡព្រឹក្ស (ដើមស្រល់) ។ ឧបាសកឈ្មោះអមិតៈ ១ ឈ្មោះតិស្សៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះហត្ថា ១ សុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។

## ទសមោ បទុមុត្តរពុទ្ធវំសោ

អដ្ឋបញ្ញាសរតនំ អច្ចុគ្គតោ មហាមុនិ
កញ្ចនគ្ឃិកសង្កាសោ ទ្វត្តឹសវរលក្ខណោ ។
កុឌ្ឌា(១) កវាដា ភិត្តិ ច រុក្ខា នគសិលុច្ចយា
ន តស្សាវរណំ អត្ថិ សមន្តា ទ្វាទសយោជនេ ។
វស្សសតសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
សន្តារេត្វា ពហុជញ្ញំ(២) ឆិន្ទិត្វា សព្វសំសយំ
ជលិត្វា អគ្គិក្ខន្ធោវ និព្វុតោ សោ សសាវកោ ។
បទុមុត្តរោ ជិនោ ពុទ្ធោ នន្ទារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ថូបវរោ ទ្វាទសុព្វេធយោជនោតិ ។

បទុមុត្តរពុទ្ធវំសោ ទសមោ ។

---

១ ឱ. ម. កុដា ។ ២ ឱ. ម. ពហុជនំ ។

## បទុមុត្តរពុទ្ធវង្ស ទី ១០

ព្រះសម្ពុទ្ធមហាមុនី ទ្រង់មានកំពស់ ៥៨ ហត្ថក្រពុំ មានព្រះអង្គដ៏ល្អល្អះ ប្រាកដស្មើដោយគ្រឿងបូជា ជាវិការៈនៃមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ទ្វារក្តី គន្ធះទ្វារក្តី ជញ្ជាំងក្តី ឈើក្តី ភ្នំក្តី ជាគ្រឿងពាំងពា នៃព្រះសម្ពុទ្ធនោះ ក្នុងទីប្រមាណ ១២ យោជន៍ដោយជុំវិញ មិនមានឡើយ ។ ព្រះជន្មាយុមានកំណត់ មួយសែនឆ្នាំ កាលព្រះសម្ពុទ្ធនោះ ទ្រង់ព្រះជន្មាយុនៅជាបនោះ ទ្រង់ញុំាងប្រជុំជនច្រើន ឲ្យឆ្លង (ពាកសង្សារ) លុះទ្រង់បម្លងជនជាច្រើនហើយ កាត់នូវសេចក្តីសង្ស័យទាំងពួង ហើយបរិនិព្វាន ជាមួយនឹងសាវ័ក ដូចជាគំនរភ្លើងដែលឆេះរុងរឿង ហើយរលត់ទៅដូច្នោះ ។ ព្រះពុទ្ធជិនស្រី ព្រះនាមបទុមុត្តរៈ ទ្រង់បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបដ៏ប្រសើរ របស់ព្រះអង្គ មានកំពស់ ១២ យោជន៍ (ដែលគេសាងហើយ) ក្នុងនន្ទារាមនោះ ។

ចប់ បទុមុត្តរពុទ្ធវង្ស ទី ១០ ។

# ឯកាទសមោ សុមេធពុទ្ធវំសោ

(១២) បទុមុត្តរស្ស អបរេន សុមេធោ នាម នាយកោ
ទុរាសទោ ឧគ្គតេជោ សព្វលោកុត្តមោ ជិនោ ។
បសន្ននេត្តោ សុមុខោ ព្រហា ឧជុ បតាបវា
ហិតេសី សព្វសត្តានំ ពហូ មោចេសិ ពន្ធនា ។
យទា ពុទ្ធោ បាបុណិត្វា កេវលំ ពោធិមុត្តមំ
សុទស្សនម្ហិ នគរេ ធម្មចក្កំ បវត្តយិ ។
តស្សាបិ អភិសមយា តីណិ អហេសុំ ធម្មទេសនេ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។
បុនាបរំ កុម្ភកណ្ណំ យក្ខញ្ច ទមយី ជិនោ
នវុតិកោដិសហស្សានំ ទុតិយាភិសមយោ អហុ ។

# សុមេធពុទ្ធវង្ស ទី ១១

(១២) ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈមក មានព្រះពុទ្ធព្រះនាមសុមេធៈ ព្រះអង្គជានាយក គេគ្របសង្កត់បានដោយក្រ ទ្រង់មានព្រះតេជៈដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រី ដ៏ប្រសើរឧត្តមជាងលោកទាំងមូល ។ ព្រះអង្គមានព្រះនេត្រថ្លាស្អាត មានព្រះភក្ត្រល្អល្អះ មានព្រះសរីរៈធំ មានព្រះសរីរៈត្រង់ល្អ មានព្រះតេជះ ទ្រង់ស្វែងរកប្រយោជន៍ដល់សត្វទាំងពួង ទ្រង់ញុំាងសត្វទាំងឡាយច្រើន ឲ្យរួចចាកចំណង ។ កាលណា ព្រះពុទ្ធទ្រង់បានដល់នូវពោធិញាណដ៏ឧត្តមសព្វគ្រប់ហើយ ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងនគរឈ្មោះសុទស្សនៈ ។ ក្នុងការសម្តែងធម៌ទេសនានៃព្រះពុទ្ធព្រះនាមសុមេធៈអង្គនោះ មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី១ មានពួកសត្វមួយសែនកោដិ ។ តមកទៀត ការត្រាស់ដឹងទី ២ មានពួកសត្វប្រមាណ ៩០ ពាន់កោដិ ក្នុងគ្រាដែលព្រះជិនស្រី ទ្រង់ទូន្មានយក្ស ឈ្មោះកុម្ភកណ្ណៈ ។

## ឯកាទសមោ សមេធពុទ្ធវំសោ

បុនាបរំ អមិតយសា ចតុសច្ចំ បកាសយិ
អសីតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ សុមេធស្ស មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ
សុទស្សនម្ហិ នគរេ ឧបគញ្ឆិ ជិនោ យទា
តទា ខីណាសវា ភិក្ខូ សមិំសុ សតកោដិយោ ។
បុនាបរំ ទេវកូដេ ភិក្ខូនំ កឋិនត្ថតេ
តទា នវុតិកោដីនំ ទុតិយោ អាសិ សមាគមោ ។
បុនាបរំ ទសពលោ យទា ចរតិ ចារិកំ
តទា អសីតិកោដីនំ តតិយោ អាសិ សមាគមោ ។
អហន្តេន សមយេន ឧត្តរោ នាម មាណវោ
អសីតិកោដិយោ មយ្ហំ ឃរេ សន្និចិតំ ធនំ ។

តមកទៀត ការត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ក្នុងគ្រាដែលព្រះសម្ពុទ្ធ មានយសរាប់មិនបាន ទ្រង់ប្រកាសនូវសច្ចៈ ៤ ប្រការ ។ ព្រះសុមេធមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង គឺក្នុងកាលដែលព្រះជិនស្រី ស្តេចចូលទៅក្នុងនគរសុទស្សនៈ មានភិក្ខុជាព្រះខីណាស្រព ១០០ កោដិ បានមកប្រជុំ (នេះសន្និបាតលើកទី ១) ។ តមកទៀត សន្និបាតលើកទី ២ មានភិក្ខុប្រមាណ ៩០ កោដិ (មកប្រជុំ) ក្នុងពេលក្រាលកឋិនលើភ្នំទេវកូដ ។ តមកទៀត សន្និបាតលើកទី ៣ មានភិក្ខុប្រមាណ ៨០ កោដិ មកប្រជុំ ក្នុងកាលព្រះទសពលស្តេចទៅកាន់ចារិក ។ សម័យនោះ តថាគតកើតជាមាណពឈ្មោះឧត្តរៈ តថាគតបានសន្សំទ្រព្យទុកក្នុងផ្ទះ ប្រមាណ ៨០ កោដិ ។

កេវលំ សព្វំ ទត្វាន សសង្ឃេ លោកនាយកេ
សរណំ តស្ស ឧបគច្ឆិំ បព្វជ្ជំ អភិរោចយិំ ។
សោបិ មំ តទា ព្យាកាសិ ករោន្តោ អនុមោទនំ
តិំសកប្បសហស្សម្ហិ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មិំ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

តថាគតថ្វាយទ្រព្យទាំងអស់ ឥតមានសេសសល់ ដល់ព្រះលោកនាយក ព្រមទាំងព្រះសង្ឃ ហើយបានយកព្រះលោកនាយកនោះជាទីពឹង បានពេញចិត្តបំពោះបព្វជ្ជា ។ គ្រានោះ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ហើយព្យាករតថាគតថា ក្នុងកប្បទី ៣០ ពាន់ មាណពនេះ នឹងបានជាព្រះពុទ្ធ (មួយអង្គ) សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយនៅ ទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកានស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅ ទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះមានយសធំនឹងធ្វើប្រទក្សិណ នូវពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើតរបស់ព្រះសម្ពុទ្ធអង្គនេះ នឹងមានព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះ ព្រះនាមគោតម ។

## ឯកាទសមោ សុមេធពុទ្ធវំសោ

អនាសវា វីតមលា សន្តចិត្តា សមាហិតា

កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា

អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា

អនាសវា វីតមលា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា នរមរូ ពុទ្ធវីជង្កុរោ អយំ ។

ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទឹងជាអគ្គសាវ័ក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ ទឹងបម្រើនូវព្រះជិនស្រីអង្គនោះ ៗ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទឹងជាអគ្គសាវិកា ៗ ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទឹងជាអគ្គឧបដ្ឋាក ៗ ឧបាសិកាឈ្មោះនន្ទមាតា ១ ឧត្តរា ១ ទឹងជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុព្រះគោតម មានយសនោះ មានកំណត់ ១០០ ឆ្នាំ ៗ ទេវតានឹងមនុស្សទាំងឡាយ លុះបានស្ដាប់នូវព្រះបន្ទូលនេះ នៃព្រះមហេសី មិនមានបុគ្គលស្មើ ក៏មានចិត្តត្រេកអរថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ　អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ　ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស　វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ　ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទី តរន្តា　បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន　ឧត្តរន្តិ មហានទី ។
ឯវមេវ មយំ សព្វេ　យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ　ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា　ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វតមធិដ្ឋាសឹ　ទសបារមិបូរិយា ។
សុត្តន្តំ វិនយញ្ចាបិ　នវង្គសត្ថុសាសនំ
សព្វំ បរិយាបុណិត្វាន　សោភយឹ ជិនសាសនំ ។
តត្ថប្បមត្តោ វិហរន្តោ　និសជ្ជដ្ឋានចង្កមេ
អភិញ្ញាបារមឹ បត្តោ　ព្រហ្មលោកមគញ្ឆិហំ ។

សម្លេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្សនិងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយ ផ្គងអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាតមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ៗ មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាតកំពង់នៅទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ៗ ពួកយើងទាំងអស់គ្នា បើឃ្លាតព្រះជិនស្រីនេះ ក្នុងកាលជាអនាគត គង់បានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ៗ តថាគត បានស្ដាប់ព្រះបន្ទូល នៃព្រះសម្ពុទ្ធអង្គនេះហើយ បានញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្ថុដ៏លើសលុប ដោយការបំពេញនូវបារមី ១០ ៗ តថាគតបានរៀននូវព្រះសូត្រ ព្រះវិន័យ និងសត្ថុសាសនៈ ដែលមានអង្គ ៩ ទាំងអស់ ហើយញុំាងសាសនានៃព្រះជិន-ស្រីឲ្យល្អរុងរឿង ៗ តថាគតជាអ្នកមិនប្រមាទ ក្នុងសាសនានោះ កាលតថាគតនៅ ក្នុងទីអង្គុយ ទីឈរ និងទីដើរ ក៏បានដល់អភិញ្ញាបារមី ហើយទៅកើតក្នុងព្រហ្មលោក ៗ

## ឯកាទសមោ សុមេធពុទ្ធវំសោ

សុទស្សនំ នាម នគរំ  សុទត្តោ នាម ខត្តិយោ
សុទត្តា នាម ជនិកា  សុមេធស្ស មហេសិនោ ។
នវវស្សសហស្សានិ  អគារំ អជ្ឈាវសិ សោ
សុចន្ទកញ្ចនសិរិវឌ្ឍា តយោ បាសាទមុត្តមា ។
តិសោឡសសហស្សានិ  នារិយោ សមលង្កតា
សុមនា នាម សា នារី  បុនព្វោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា  ហត្ថិយានេន និក្ខមិ
អនូនកំ អឌ្ឍមាសំ  បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ សុមេធោ លោកនាយកោ
វត្តចក្កោ មហាវីរោ  សុទស្សនុយ្យានមុត្តមេ ។
សរណោ ច សព្វកាមោ ច  អហេសុំ អគ្គសាវកា
សាគរោ នាមុបដ្ឋាកោ  សុមេធស្ស មហេសិនោ ។

## សុមេធពុទ្ធវង្ស ទី ១១

ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ជាមហេសី មានព្រះនគរឈ្មោះ សុទស្សនៈ ព្រះមហាក្សត្រ ព្រះនាមសុទត្តៈ ជាព្រះបិតា ព្រះមាតាបង្កើត ព្រះនាមសុទត្តា ។ ព្រះសុមេធសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះ អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ ខ្នង គឺសុចន្ទប្រាសាទ ១ កញ្ចនប្រាសាទ ១ សិរិវឌ្ឍ-ប្រាសាទ ១ ។ មាននារីប្រមាណ ១៦ ពាន់រូប សុទ្ធសឹងតែ តាក់តែងល្អហើយ ឯនារីដែលជាអគ្គមហេសីនោះ ព្រះនាម សុមនា ព្រះរាជបុត្រ ព្រះនាមបុនព្វៈ ។ ព្រះជិនស្រីទ្រង់ ឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្ដេចចេញទៅដោយហត្ថិ-យាន ទ្រង់តម្កល់ព្យាយាម អស់ ៨ ខែគត់ ។ ព្រះលោក-នាយក ព្រះនាមសុមេធៈ ជាមហាវីរៈ ត្រូវព្រហ្មអារាធនា ហើយ ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុទស្សនៈ ភិក្ខុឈ្មោះសរណៈ ១ ឈ្មោះសព្វកាមៈ ១ ជាអគ្គសាវ័ក របស់ព្រះសុមេធៈ ដែលទ្រង់ស្វែងរក នូវគុណដ៏ធំអង្គនោះ ភិក្ខុជាឧបដ្ឋាក ឈ្មោះសាគរៈ ។

រាមា ចេវ សុរាមា ច អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ និម្ពរុក្ខោតិ(១) បវុច្ចតិ ។
ឧរុវេឡោ ចេវ យសវតោ ច អហេសុំ អគ្គុបដ្ឋកា
យសា នាម សិរិកា ច(២) អហេសុំ អគ្គុបដ្ឋិកា ។
អដ្ឋាសីតិរតនានិ អច្ចុគ្គតោ មហាមុនិ
ឱភាសេតិ ទិសា សព្វា ចន្ទោ តារគណោ យថា ។
ចក្កវត្តិមណី នាម យថា តបតិ យោជនំ
តថេវ តស្ស រតនំ សមន្តា ផរតិ យោជនំ ។
នវុតិវស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
តេវិជ្ជឆឡភិញ្ញហិ ពលប្បត្តេហិ តាទិហិ
សមាកុលមិទំ អាសិ អរហន្តេហិ សាសនំ ។

---

១ ឱ. ម. មហានិម្ពោតិ ។ ២ ឱ. ម. យសោធរា សិរិមា នាម ទិស្សតិ ។

ភិក្ខុនីឈ្មោះរាមា ១ ឈ្មោះសុរាមា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា និម្ពព្រឹក្ស (ដើមស្តៅ) ។ ឧបាសកឈ្មោះឧរុវេលៈ ១ ឈ្មោះយសវៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះយសា ១ ឈ្មោះសិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនី ទ្រង់មានកំពស់ ៨៨ ហត្ថក្រពុំ ទ្រង់ញុំាងទិសទាំងពួងឲ្យភ្លឺ ដូចព្រះចន្ទ្រ រុងរឿងកន្លងពួកផ្កាយ ។ កែវមណីរបស់ស្ដេចចក្រពត្តិ ភ្លឺរុងរឿងអស់ទីប្រមាណមួយយោជន៍ យ៉ាងណា រតនៈ គឺពន្លឺនៃព្រះមានព្រះភាគនោះ តែងផ្សាយទៅកាន់ទី ប្រមាណមួយយោជន៍ដោយជុំវិញ ក៏យ៉ាងនោះដែរ ។ ព្រះជន្មាយុមានកំណត់៩ ម៉ឺនឆ្នាំគត់ ព្រះសុមេធអង្គនោះ កាលទ្រង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនច្រើនឲ្យឆ្លងចាកសង្សារ ។ ព្រះសាសនានេះ កុះករដោយពួកព្រះអរហន្ត ដែលមានវិជ្ជា ៣ និងអភិញ្ញា ៦ ដល់នូវកម្លាំង ជាតាទិបុគ្គល ។

តេបិ សព្វេ អមិតយសា  វិប្បមុត្តា និរូបធី
ញាណាលោកំ ទស្សយិត្វា  និព្វុតា តេ មហាយសា ។
សុមេធោ ជិនវរោ ពុទ្ធោ  មេធារាមម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ  តេសុ តេសុ បទេសតោ ។

សុមេធពុទ្ធវំសោ ឯកាទសមោ ។

## ទ្វាទសមោ សុជាតពុទ្ធវំសោ

(១៣) តត្ថេវ មណ្ឌកប្បម្ហិ  សុជាតោ នាម នាយកោ
សីហហនុ ឧសភក្ខន្ធោ  អប្បមេយ្យោ ទុរាសទោ ។
ចន្ទោវ វិមលោ សុទ្ធោ  សតរំសីវ បតាបវា
ឯវំ សោភតិ សម្ពុទ្ធោ  ជលន្តោ សិរិយា សទា ។
ចាកុណិត្វាន សម្ពុទ្ធោ  កេវលំ ពោធិមុត្តមំ
សុមង្គលម្ហិ នគរេ  ធម្មចក្កំ បវត្តយិ ។

ព្រះអរហន្តទាំងពួងនោះ សឹងតែមានយសកប់មិនបាន សុទ្ធតែរលុបផុតហើយ មិនមានឧបធិទាំងអស់ ព្រះអរហន្តទាំងនោះ មានយសធំ បានសម្តែងនូវពន្លឺ គឺព្រះញាណ ហើយនិព្វានទៅ ៗ ព្រះពុទ្ធព្រះនាមសុមេធៈ ជាព្រះជិនស្រីប្រសើរ ទ្រង់និព្វាន ក្នុងមេធារាម ព្រះធាតុផ្សាយទៅក្នុងប្រទេសទាំងឡាយនោះ ៗ ។

ចប់ សុមេធពុទ្ធវង្ស ទី ១១ ។

# សុជាតពុទ្ធវង្ស ទី ១២

(១៣) ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្មាសម្ពុទ្ធជានាយក ព្រះនាមសុជាតៈ ទ្រង់មានព្រះហនុកា ដូចជាចង្កានៃពជសីហៈ ទ្រង់មានព្រះសុរង ដូចជា-កនៃគោឧសភៈ ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្រប់សង្កត់មិនបាន ៗ ព្រះសម្ពុទ្ធដ៏បរិសុទ្ធប្រាសចាកមន្ទិល ដូចជាព្រះចន្ទ្រ មានតេជះ ដូចជាព្រះអាទិត្យភ្លឺរុងរឿងដោយព្រះសិរី សព្វ ៗ កាល យ៉ាងនេះ ៗ ព្រះសម្ពុទ្ធទ្រង់ដល់នូវពោធិញ្ញាណ ដ៏ប្រសើរសព្វគ្រប់ហើយ ទ្រង់ញ៉ាំងព្រះធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងព្រះនគរ ឈ្មោះសុមង្គលៈ ៗ

ទេសេន្តោ បវរំ ធម្មំ សុជាតោ លោកនាយកោ

អសីតិកោដី អភិសមឹសុ បឋមេ ធម្មទេសនេ ។

យទា សុជាតោ អមិតយសោ ទេវេ វស្សំ ឧបាគមិ

សត្តត្តឹសសតសហស្សានំ ទុតិយាភិសមយោ អហុ ។

យទា សុជាតោ អសមោ ឧបគញ្ឆិ បិតុ សន្តិកំ

សដ្ឋិសតសហស្សានំ តតិយាភិសមយោ អហុ ។

សន្និបាតា តយោ អាសុំ សុជាតស្ស មហេសិនោ

ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

អភិញ្ញាពលប្បត្តានំ អប្បត្តានំ ភវាភវេ

សដ្ឋិសតសហស្សានិ បឋមំ សន្និបតឹសុ តេ ។

បុនាបរំ សន្និបាតេ តិទិវោរោហណេ ជិនេ

បញ្ញាសសតសហស្សានំ ទុតិយោ អាសិ សមាគមោ ។

កាលព្រះលោកនាយក ព្រះនាមសុជាតៈ ទ្រង់សម្តែងនូវធម៌ដ៏ប្រសើរ សត្វទាំងឡាយចំនួន ៨០ កោដិ បានសម្រេចមគ្គផល ក្នុងព្រះធម្មទេសនាជាដំបូង ។ កាលណា ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ទ្រង់មានយសរាប់មិនបាន ស្តេចចូលទៅកាន់ព្រះវស្សាក្នុងទេវលោក កាលនោះ ការត្រាស់ដឹងនូវធម៌លើកទី ២ មានពួកសត្វ ៣៧ សែន ។ កាលណា ព្រះពុទ្ធ ព្រះនាមសុជាតៈ រកបុគ្គលស្មើគ្មាន ស្តេចចូលទៅកាន់សំណាក់ព្រះរាជបិតា កាលនោះ ការត្រាស់ដឹងនូវធម៌ទី ៣ មានពួកសត្វ ៦០ សែន ។ ព្រះសុជាតមហេសីមានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ ជាតាទិបុគ្គល ជាអ្នកដល់នូវអភិញ្ញានិងពលៈ ជាអ្នកមិនដល់ (នូវការកើត) ក្នុងភពតូចនិងភពធំ គឺព្រះអរហន្តទាំងនោះ ប្រមាណ ៦០ សែន បានមកប្រជុំ ជាសន្និបាតលើកដំបូង ។ តមកទៀត ការប្រជុំក្នុងកាលដែលព្រះជិនស្រី ទ្រង់ចុះចាកទេវលោក នេះជាសន្និបាតលើកទី ២ មានព្រះខីណាស្រព ចំនួន ៥០ សែន ។

ទ្វាទសមោ សុជាតពុទ្ធវំសោ

ឧបសង្កម្ម នរាសភំ(១) តស្ស យោ អគ្គសាវកោ
ចតូហិ សតសហស្សេហិ សម្ពុទ្ធំ ឧបសង្កមិ ។
អហន្តេន សមយេន ចតុទីបម្ហិ ឥស្សរោ
អន្តលិក្ខចរោ អាសី ចក្កវត្តិ មហាពលោ ។
ចតុទីបេ មហារជ្ជំ រតនេ សត្ត ឧត្តមេ
ពុទ្ធេ និយ្យាទយិត្វាន បព្វជឹ តស្ស សន្តិកេ ។
អារាមិកា ជនបទេ ឧដ្ឋានំ បដិបិណ្ឌិយ
ឧបនេន្តិ ភិក្ខុសង្ឃស្ស បច្ចយំ សយនាសនំ ។
សោបិ មំ តទា(២) ព្យាកាសិ ទសសហស្សម្ហិ ឥស្សរោ
តឹសកប្បសហស្សានំ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

---

១ ឧ. ឧបសង្កម្មន្តោ នរវិសភំ ។ ម. ឧបសង្កម្មន្តោ នរាសភំ ។ ២ ឧ. ម. ពុទ្ធោ ។

## សុជាតពុទ្ធវង្ស ទី ១២

អគ្គសាវកណា របស់ព្រះពុទ្ធ ព្រះនាមសុជាតៈនោះ បាន ចូលទៅគាល់ព្រះសម្ពុទ្ធ ដ៏ប្រសើរជាធំនរៈ អគ្គសាវកនោះ បានចូលទៅគាល់ព្រះសម្ពុទ្ធ មួយអន្លើដោយភិក្ខុ ប្រមាណ ៤ សែនរូប (នេះជាសន្និបាតលើកទី ៣) ។ សម័យនោះ តថាគតជាស្តេចចក្រពត្តិ មានកម្លាំងច្រើន ជាធំក្នុងទ្វីបទាំង ៤ អាចហោះទៅក្នុងអាកាសបាន ។ តថាគតបានថ្វាយនូវរាជ-សម្បត្តិជាច្រើនក្នុងទ្វីបទាំង ៤ នូវកែវដ៏ឧត្តមទាំង ៧ ប្រការ ចំពោះព្រះពុទ្ធ ហើយបួសក្នុងសំណាក់ នៃព្រះសម្ពុទ្ធអង្គ នោះ ។ អារាមិកជនទាំងឡាយ ក្នុងជនបទ បានប្រមូលមកនូវ សួយសាអាករ ជាបច្ច័យ ទីដេក ទីអង្គុយ ហើយនាំចូលទៅ ថ្វាយដល់ភិក្ខុសង្ឃ ។ កាលនោះ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់ព្យាករតថាគតថា ក្នុងទីបំផុតនៃកប្ប ៣០ ពាន់ ស្តេច ចក្រពត្តិអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ជាធំក្នុងមួយមឺន លោកធាតុ ។ សត្វនេះ នឹងស្តេចចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។

អជបាលរុក្ខមូលស្មឹ  និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ  នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ  បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន  ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា  ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ  ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា  មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម  អយំ ហេស្សតិ គោតមោ ។
អនាសវា វីតរាគា  សន្តចិត្តា សមាហិតា ។
កោលិតោ ឧបតិស្សោ ច  អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ  ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច  អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា  សន្តចិត្តា សមាហិតា ។

សត្ថានេះ នឹងអង្គុយនៅទៀបគល់អជបាលព្រឹក្ស ទទួលនូវបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ នឹងសោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចចូលទៅ ទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ។ លំដាប់នោះ ព្រះមានយសធំ ធ្វើប្រទក្សិណ នូវពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាបង្កើត របស់ព្រះសម្ពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវក ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើនូវព្រះជិនស្រីអង្គនេះ ។ នាងខេមា ១ នាងឧប្បលវណ្ណា ១ មិនមានអាសវៈ ប្រាសចាកតម្រេក មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ។

ពោធិ តស្ស ភគវតោ　អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ　អគ្គា ហេស្សន្តុបដ្ឋាកា ។
នន្ទមាតា ច ឧត្តរា　អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស　គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ　អសមស្ស មហេសិនោ
អាមោទិតា នរមរូ　ពុទ្ធវីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ　អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ　ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស　វិរជ្ជិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ　ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា　បដិតិត្ថំ វិរជ្ជិយ
ហេដ្ឋាតិត្ថំ គហេត្វាន　ឧត្តរន្តិ មហានទឹ ។

ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ឈ្មោះហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម ដ៏ទ្រង់យសអគ្គនោះ មានកំណត់ ១០០ឆ្នាំ ។ មនុស្ស និងទេវតាទាំងឡាយ លុះបានស្តាប់ព្រះបន្ទូលនេះ នៃព្រះពុទ្ធរកបុគ្គលស្មើគ្មាន ទ្រង់ស្វែងរកនូវគុណដ៏ធំ ហើយត្រេកអរថា ស្តេចចក្រពត្តិអង្គនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សម្លេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយ ធ្វើអញ្ជលី នមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគត ពួកយើងទាំងអស់គ្នា គង់បានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះពុំខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ក្នុងទីចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា

ឃរមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា ភិយ្យោ ហាសំ ជនេអហំ
អធិដ្ឋហឹ វត្តំ ឧគ្គំ ទសបារមិបូរិយា ។
សុត្តន្តំ វិនយញ្ចាបិ នវង្គសត្ថុសាសនំ
សព្វំ បរិយាបុណិត្វាន សោភយឹ ជិនសាសនំ ។
តត្ថប្បមត្តោ វិហរន្តោ ព្រហ្មំ ភាវេត្វា ភាវនំ
អភិញ្ញាសុ បារមឹ គន្ត្វា ព្រហ្មលោកមគញ្ឆិហំ ។
សុមង្គលំ នាម នគរំ ឧត្តរោ នាម ខត្តិយោ
មាតា បភាវតី នាម សុជាតស្ស មហេសិនោ ។
នវវស្សសហស្សានិ អគារំ អជ្ឈាវសិ សោ
សិរិ ឧបសិរិ ចន្ទោ តយោ បាសាទមុត្តមា ។

ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់នូវព្រះបន្ទូល នៃព្រះពុទ្ធនោះហើយ បានញុំាងសេចក្តីរីករាយឲ្យកើតដោយក្រៃលែង ហើយបានអធិដ្ឋាន នូវវត្តដ៏លើសលុប ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតបានរៀននូវព្រះសូត្រផង ព្រះវិន័យផង សត្ថុសាសនាដែលមានអង្គ ៩ ទាំងអស់ផង ហើយបានញុំាងសាសនានៃព្រះជិនស្រី ឲ្យល្អរុងរឿង ។ កាលតថាគត នៅក្នុងសាសនានោះជាអ្នកមិនមានប្រមាទ បានចំរើននូវភាវនាដ៏ប្រសើរ ហើយបានដល់នូវបារមី ក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក ។ ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ទ្រង់ស្វែងនូវគុណដ៏ធំ មានព្រះនគរឈ្មោះសុមង្គលៈ ព្រះមហាក្សត្រព្រះនាមឧគ្គតៈ ជាព្រះបិតា ព្រះមាតា ព្រះនាមបភាវតី ។ ព្រះសុជាតសម្ពុទ្ធនោះ ទ្រង់នៅគ្រប់គ្រងផ្ទះ អស់ ៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ (របស់ព្រះពុទ្ធនោះ) មាន ៣ ខ្នង គឺ សិរីប្រាសាទ ១ ឧបសិរីប្រាសាទ ១ ចន្ទប្រាសាទ ១ ។

## ទ្វាទសមោ សុជាតពុទ្ធវំសោ

តេវីសតិសហស្សានិ    នារិយោ សមលង្កតា
សិរិនន្ទា នាម នារី    ឧបសេនោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា    អស្សយានេន និក្ខមិ
អនូននវមាសានិ    បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ    សុជាតោ លោកនាយកោ
វត្តចក្កោ មហាវីរោ    សុមង្គលុយ្យានមុត្តមេ ។
សុទស្សនោ សុទេវោ ច    អហេសុំ អគ្គសាវកា
នារទោ នាមុបដ្ឋាកោ    សុជាតស្ស មហេសិនោ ។
នាគា នាគសមាលា ច    អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ    មហាវេឡូតិ វុច្ចតិ ។
សោ ច រុក្ខោ ឃនក្ខន្ធោ(១)    អច្ឆិទ្ទោ ហោតិ បត្តិកោ
ឧជុ វំសោ ព្រហា ហោតិ    ទស្សនេយ្យោ មនោរមោ ។

---

១ ឱ. ម. ឃនរុចិរោ ។

## សុជាតពុទ្ធវង្ស ទី ១២

មាននារីប្រមាណ ២ ម៉ឺន ៣ ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អហើយ ឯនារីដែលជាអគ្គមហេសី ព្រះនាមសិរិនន្ទា ព្រះរាជបុត្រ ព្រះនាមឧបសេនៈ ។ ព្រះជិនស្រីទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្តេចចេញទៅដោយយានសេះ តម្កល់នូវព្យាយាម អស់ ៩ ខែគត់ ។ ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ជាលោកនាយក ជាមហាវីរៈ ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ប្រសើរ ឈ្មោះសុមង្គលៈ ។ ភិក្ខុឈ្មោះសុទស្សនៈ ១ ឈ្មោះសុទេវៈ ១ ជាអគ្គសាវក ភិក្ខុឈ្មោះ នារទៈ ជាឧបដ្ឋាកនៃព្រះពុទ្ធ ព្រះនាមសុជាតៈ ទ្រង់ស្វែងរកគុណធំ ។ ភិក្ខុនីឈ្មោះនាគា ១ ឈ្មោះនាគសមានា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះហៅថា មហាវេឡុព្រឹក្ស (ដើមឫស្សីធំ) ។ ឫស្សីនោះ មានដើមតាន់ មិនមានប្រហោង មានស្លឹកច្រើន ជាឫស្សីមានដើមត្រង់ មានដើមធំ គួររមិលមើល ជាទីរីករាយនៃចិត្ត ។

ឯកក្ខន្ធោ បវឌ្ឍិត្វា តតោ សាខា ព ភិជ្ជតិ
យថា សុពទ្ធោ មោរហត្ថោ ឯវំ សោភតិ សោ ទុមោ ។
ន តស្ស កណ្ដកា ហោន្តិ នាបិ ឆិទ្ទំ មហា អហុ
វិតិណ្ណសាខោ អវិរឡោ សន្ទច្ឆាយោ មនោរមោ ។
សុទត្តោ ចេវ ចិត្តោ ច អហេសុំ អគ្គុបដ្ឋាកា
សុភទ្ទា ចេវ បទុមា ច អហេសុំ អគ្គុបដ្ឋិកា ។
បញ្ញាសរតនោ អាសិ ឧច្ចត្តនេន(១) សោ ជិនោ
សព្វាការវរូបេតោ សព្វគុណមុបាគតោ ។
តស្ស បភា អសមសមា និច្ឆរតិ សមន្តតោ
អប្បមាណោ អតុលិយោ ឧបមេហិ អនូបមោ ។
នវុតិវស្សសហស្សានិ អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

---

១ ឱ. ម. ឧច្ចត្តនេ ។

ជាឫស្សីតែមួយដើម លូតលាស់ឡើងហើយ ឯមែកក៏បែកចេញអំពីដើមនោះជា ៤ មែក ឫស្សីនោះជាឈើល្អ ដូចជាបាច់នៃកន្ទុយក្ងោក ដែលគេចងល្អហើយដូច្នោះ ។ ឫស្សីនោះ ជាឫស្សីឥតបន្លា ឥតប្រហោង មានមែកត្រសុំត្រសាយ ដេរដាសដោយមែក មានម្លប់ត្រឈៃ ជាទីរីករាយនៃចិត្ត ។ ឧបាសកឈ្មោះ សុទត្តៈ១ ឈ្មោះចិត្តៈ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះនាងសុភទ្រា ១ នាងបទុមា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះជិនស្រីអង្គនោះ មានកំពស់ ៥០ ហត្ថ ត្រកំពុំទ្រង់ប្រកបដោយអាការប្រសើរគ្រប់យ៉ាង ទ្រង់ប្រកបដោយគុណទាំងពួង ។ រស្មីនៃព្រះសម្ពុទ្ធអង្គនោះ ស្មើដោយរស្មីនៃព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ តែងផ្សាយចេញទៅក្នុងទីជុំវិញ ព្រះសម្ពុទ្ធនោះ មានព្រះគុណប្រមាណមិនបាន មានព្រះគុណប៉ុនមិនបាន មិនមានឧបមា ដោយសេចក្តីឧបមាទាំងឡាយឡើយ ។ ព្រះជន្មាយុ មានកំណត់ ៩០ ពាន់ឆ្នាំគត់ ព្រះពុទ្ធអង្គនោះ កាលគង់ព្រះជន្មាយុនៅដរាបនោះ តែងញុំាងប្រជុំជនជាច្រើន ឲ្យឆ្លង (បាកសង្សារ) ។

យថាបិ សាគរេ ឩម្មិ    គគនេ តារកា យថា
ឯវំ តទា បាវចនំ    អរហន្តេហិ ចិត្តិតំ ។
[តេវិជ្ជាឆឡភិញ្ញាហិ(១)    ពលប្បត្តេហិ តាទិហិ
សមាកុលមិទំ អាសិ    អរហន្តេហិ តាទិភិ]
សោ ច ពុទ្ធោ អសមសមោ    គុណានិ ច តានិ
អតុលិយានិ
សព្វំ សមន្តរហិតំ    ននុ រិត្តា សព្វសង្ខារាតិ ។
សុជាតោ ជិនវរោ ពុទ្ធោ    សេលារាមម្ហិ និព្វុតោ
តត្ថេវ ចេតិយោ សត្ថុ    តីណិ គាវុតមុគ្គតោតិ ។

សុជាតពុទ្ធវំសោ ទ្វាទសមោ ។

# តេរសមោ បិយទស្សិពុទ្ធវំសោ

[១៤] សុជាតស្ស អបរេន សយម្ភូ លោកនាយកោ
ទុរាសទោ អសមសមោ    បិយទស្សី មហាយសោ ។

---

១ តេវិជ្ជេហិ ឆឡភិញ្ញេហីតិ យុត្តតរមេវ ។

ក្នុងកាលនោះ សាសនារបស់ព្រះពុទ្ធនោះ ដ៏វិចិត្រដោយព្រះអរហន្តទាំងឡាយ ដូចជាលេកក្នុងសាគរ ឬដូចជាផ្កាយក្នុងអាកាស ។ សាសនានេះ កុះករដោយព្រះអរហន្តទាំងឡាយដែលមានវិជ្ជា៣ និងអភិញ្ញា៦ លោកដល់នូវកម្លាំង ជាតាទិបុគ្គល ។ ព្រះសម្ពុទ្ធនោះ ស្មើដោយព្រះពុទ្ធ រកបុគ្គលស្មើគ្មាន គុណទាំងឡាយនោះ ជាគុណថ្លឹងពុំបាន ធម្មជាតទាំងពួង ក៏អន្តរធានអស់ ទុំ ហ្ន៎ សង្ខារទាំងពួង ជារបស់សោះសូន្យទទេ ។ ព្រះសម្ពុទ្ធព្រះនាមសុជាតៈ ជាព្រះជិនស្រីប្រសើរ បរិនិព្វានក្នុងសេលារាម ព្រះចេតិយរបស់ព្រះសាស្ដាមានកំពស់ ៣ គាវុត (ដែលគេសាង) ក្នុងសេលារាមនោះ ។

បប់ សុជាតពុទ្ធវង្ស ទី ១២ ។

# បិយទស្សីពុទ្ធវង្ស ទី ១៣

(១៤) ក្នុងកាលជាខាងក្រោយ នៃព្រះសម្ពុទ្ធព្រះនាមសុជាតៈមក មានព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាសយម្ភូ ជាលោកនាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បានដោយក្រ ព្រះអង្គស្មើដោយព្រះពុទ្ធដែលឥតមានបុគ្គលស្មើ ។

សោបិ ពុទ្ធោ អមិតយសោ អាទិច្ចោវ វិរោចតិ
និហន្ត្វាន តមំ សព្វំ ធម្មចក្កំ បវត្តយិ ។
តស្សាបិ អតុលតេជស្ស អហេសុំ អភិសមយា តយោ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។
សុទស្សនោ ទេវរាជា មិច្ឆាទិដ្ឋិមរោចយិ
តស្ស ទិដ្ឋឹ វិនោទេន្តោ សត្ថា ធម្មមទេសយិ ។
ជនសន្និបាតោ អតុលោ មហា សន្និបតី តទា
នវ(១)កោដិសហស្សានំ ទុតិយាភិសមយោ អហុ ។
យទា ទោណមុខំ ហត្ថឹ វិនេតិ នរសារថិ
អសីតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ តស្សាបិ បិយទស្សិនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។

---

១ ឱ. ម. នវុតិ ។

ព្រះសម្ពុទ្ធអង្គនោះ ទ្រង់មានយសប្រមាណមិនបាន ទ្រង់រុងរឿងដូចជាព្រះអាទិត្យ ទ្រង់កំចាត់បង់នូវងងឹតទាំងពួង ទ្រង់ញុំាងធម្មចក្រទាំងពួងឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ មានតេជះថ្លឹងមិនបាន មានការត្រាស់ដឹង ៣ លើក គឺការត្រាស់ដឹងទី ១ មានពួកសត្វមួយសែនកោដិ ។ ទេវរាជព្រះនាមសុទស្សនៈ កាប់ព្រះទ័យនឹងមិច្ឆាទិដ្ឋិ ព្រះសាស្តា កាលទ្រង់បន្ទោបង់នូវទិដ្ឋិ នៃសុទស្សនទេវរាជនោះ ទ្រង់បានសម្តែងធម៌ ។ ក្នុងកាលនោះ ការប្រជុំជនច្រើនថ្លឹងមិនបាន ជាការប្រជុំធំ ឈ្មោះថាត្រាស់ដឹងទី ២ មានពួកសត្វ ៩ ពាន់កោដិ ។ ក្នុងកាលណា ព្រះពុទ្ធ ព្រះអង្គជាសារថីទូន្មាននរនរៈ ទ្រង់ទូន្មានដំរី ឈ្មោះគេណមុខៈ ក្នុងកាលនោះ ឈ្មោះថាត្រាស់ដឹងទី ៣ មានពួកសត្វ ៨០ កោដិ ។ ព្រះបិយទស្សីអង្គនោះ មានសាវកសន្និបាត ៣ លើក គឺសន្និបាតលើកទី ១ មានពួកព្រះអរហន្តមួយសែនកោដិ ។

## តេរសមោ បិយទស្សិពុទ្ធវំសោ

តតោ បរំ ឆន្នវុតិកោដី   សមឹសុ ឯកតោ មុនី
តតិយេ សន្និបាតម្ហិ   អសីតិកោដិយោ អហុ ។
អហន្តេន សមយេន   កស្សបោ នាម មាណវោ(១)
អជ្ឈាយិកោ មន្តធរោ   តិណ្ណំ វេទាន បារគូ ។
តស្ស ធម្មំ សុណិត្វាន   បសាទំ ជនយឹ អហំ
កោដិសតសហស្សេហិ   សង្ឃារាមំ អមាបយឹ ។
តស្ស ទត្វាន អារាមំ   ហដ្ឋោ សំវិគ្គមានសោ
សរណេ បញ្ចសីលេ ច   ទឡ្ហំ កត្វា សមាទយឹ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ   សង្ឃមជ្ឈេ និសីទិយ
អដ្ឋារសកប្បសតេ   អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា   និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន   កត្វា ទុក្ករការិកំ ។

---

១ ឱ. ម. ព្រាហ្មណោ ។

## បិយទស្សីពុទ្ធវង្ស ទី ១៣

តពីនោះមក ព្រះខីណាស្រពទាំងឡាយ ជាអ្នកប្រាជ្ញចំនួន ៩០ កោដិ បានមកប្រជុំព្រមក្នុងទីជាមួយគ្នា នេះជាសន្និបាតលើកទី ២ ក្នុងសន្និបាតលើកទី ៣ មានព្រះខីណាស្រព ៨០ កោដិ ៗ សម័យនោះ តថាគតកើតជាមាណព ឈ្មោះកស្សប ជាអ្នកស្វាធ្យាយមន្ត ចងចាំមន្ត ដល់នូវត្រើយនៃត្រៃវេទ ៗ តថាគត បានស្តាប់ធម៌ របស់ព្រះពុទ្ធ ព្រះនាមបិយទស្សីនោះ ហើយបានញុំាងសេចក្តីជ្រះថ្លា ឲ្យកើតឡើង តថាគត បានសាងនូវសង្ឃារាម ដោយទ្រព្យប្រមាណមួយសែនកោដិ ៗ តថាគត បានថ្វាយអារាម ដល់ព្រះពុទ្ធអង្គនោះ ហើយមានចិត្តរីករាយ មានចិត្តសង្វេគ បានសមាទានសរណគមន៍ និងសីល ៥ ធ្វើឲ្យមាំមួន ៗ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ក្នុងកណ្តាលសង្ឃហើយ ទ្រង់ព្យាករតថាគតថា មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ១.៨០០ ៗ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ទៅតម្កល់ការព្យាយាម ហើយធ្វើទុក្ករកិរិយា ៗ

អជបាលរុក្ខមូលស្មឹ　　និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ　　នេរញ្ជរមុបេហិតិ ៗ
នេរញ្ជរាយ តីរម្ហិ　　បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន　　ពោធិមូលម្ហិ ឯហិតិ ៗ
តតោ បទក្ខិណំ កត្វា　　ពោធិមណ្ឌំ អនុត្តរំ ៗ
អស្សត្ថរុក្ខមូលម្ហិ　　ពុជ្ឈិស្សតិ មហាយសោ ៗ
ឥមស្ស ជនិកា មាតា　　មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម　　អយំ ហេស្សតិ គោតមោ ៗ
អនាសវា វីតរាគា　　សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច　　អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ　　ឧបដ្ឋិស្សតិមំ ជិនំ ៗ
ខេមា ឧប្បលវណ្ណា ច　　អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា　　សន្តចិត្តា សមាហិតា ៗ

សត្វនេះ ទឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយទ្រង់ចូលទៅកាន់ស្ទឹងនេរញ្ជរា ៗ ព្រះជិនស្រីអង្គនោះ ទឹងទ្រង់សោយនូវបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្ដេចចូលទៅ ទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ៗ លំដាប់នោះ ព្រះមានយសធំ ទឹងធ្វើប្រទក្សិណ នូវពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ៗ ព្រះមាតាបង្កើតនៃព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ព្រះពុទ្ធអង្គនេះ ព្រះនាមគោតម ៗ ភិក្ខុឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់ម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទឹងបម្រើព្រះជិនស្រីអង្គនោះ ៗ នាងខេមា ១ នាងឧប្បលវណ្ណា ១ ជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់ម្ងាប់ មានចិត្តតាំងមាំ ៗ

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា នរមរូ ពុទ្ធវីជង្កុរោ អយំ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច

កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ

ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។

បិយទស្សិពុទ្ធវង្ស ទី ១៣

ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះបិត្តគហបតី ១ ឈ្មោះហត្ថាឡ្យ-វកគហបតី ១ ជាអគ្គឧបដ្ឋាក ។ ឧបាសិកា ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះជន្មាយុនៃព្រះគោតម មានយសអគ្គនោះ មានកំណត់ ១០០ ឆ្នាំ ។ ទេវតានិងមនុស្សទាំងឡាយ លុះបានស្ដាប់នូវព្រះបន្ទូលនេះ នៃព្រះមហេសី រកបុគ្គលស្មើគ្មាន ក៏ត្រេកអរថា មាណពនេះជាពូជពន្លកនៃព្រះពុទ្ធ ។ សម្លេងហ៊ោក៏ប្រព្រឹត្តទៅ មនុស្សនិងទេវតា ទាំងមួយម៉ឺនលោកធាតុ ក៏ទះដៃសើចក្អាកក្អាយធ្វើអញ្ជលីនមស្ការថា បើពួកយើង នឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ក្នុងកាលជាអនាគតពួកយើងគង់បានសម្រេចមគ្គផល បំពោះព្រះភក្ត្រ នៃព្រះគោតមនេះ មិនខាន ។ មនុស្សទាំងឡាយ កាលនឹងឆ្លងស្ទឹង បើឃ្លាងនូវកំពង់ ក្នុងទីបំពោះមុខហើយ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណា ។

ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វតមធិដ្ឋាសឹ ទសបារមិបូរិយា ។
សុធញ្ញំ នាម នគរំ សុទត្តោ នាម ខត្តិយោ
សុចន្ទា នាម ជនិកា បិយទស្សិស្ស សត្ថុនោ ។
នវវស្សសហស្សានិ អគារំ អជ្ឈាវសិ សោ
សុនិម្មលវិមលគិរិគុហា តយោ បាសាទមុត្តមា ។
តេត្តឹសតិសហស្សានិ នារិយោ សមលង្កតា
វិមលា នាម សា នារី កញ្ចនាវេឡុអត្រជោ ។
និមិត្តេ ចតុរោ ទិស្វា រថយានេន និក្ខមិ
ឆមាសំ បធានចារំ អចរិ បុរិសុត្តមោ ។

យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ លុះតថាគតបានស្តាប់ព្រះបន្ទូល នៃព្រះពុទ្ធអង្គនេះហើយ បានញុំាងចិត្តឲ្យជ្រះថ្លាដោយក្រៃលែង ហើយអធិដ្ឋានវត្តលើសលុប ដោយការបំពេញនូវបារមីទាំង ១០ ។ ព្រះសាស្តា ព្រះនាមបិយទស្សី មានព្រះនគរឈ្មោះសុធញ្ញៈ មានព្រះមហាក្សត្រព្រះនាមសុទត្តៈ ជាព្រះបិតា មានព្រះមាតា ព្រះនាមសុចន្ទា ។ ព្រះពុទ្ធអង្គនោះ ទ្រង់នៅគ្រប់គ្រងផ្ទះ អស់៩ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរមាន ៣ ខ្នង គឺសុនិម្មលប្រាសាទ ១ វិមលប្រាសាទ ១ គិរិគុហាប្រាសាទ ១ ។ មាននារីប្រមាណ ៣៣ ពាន់នាក់ សុទ្ធសឹងតែតាក់តែងល្អ ឯនារីដែលជាអគ្គមហេសីនោះ ព្រះនាមនាងវិមលា ព្រះរាជបុត្របង្កើត ព្រះនាមកញ្ចនាវេឡៈ ។ ព្រះជិនស្រី ជាបុរសប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ យ៉ាង ហើយស្តេចចេញទៅ ដោយយានគឺរថ ហើយទ្រង់ប្រព្រឹត្ត នូវសេចក្តីព្យាយាម អស់ ៦ ខែគត់ ។

## តេរសមោ បិយទស្សីពុទ្ធវំសោ

ព្រហ្មុនា យាចិតោ សន្តោ បិយទស្សី មហាមុនិ
វត្តចក្កោ មហាវីរោ ឧសភុយ្យានេ មនោរមេ ។
បាលិតោ សព្វទស្សី ច អហេសុំ អគ្គសាវកា
សោភិតោ នាមុបដ្ឋាកោ បិយទស្សិស្ស សត្ថុនោ ។
សុជាតា ធម្មទិន្នា ច អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ កកុធោតិ បវុច្ចតិ ។
សន្ទកោ ធម្មិកោ ចេវ អហេសុំ អគ្គុបដ្ឋកា
វិសាខា ធម្មទិន្នា ច អហេសុំ អគ្គុបដ្ឋិកា ។
សោបិ ពុទ្ធោ អមិតយសោ ទ្វត្តឹសវរលក្ខណោ
អសីតិហត្ថមុព្វេធោ សាលរាជាវ ទិស្សតិ ។
អគ្គិយា ចន្ទសុរិយានំ នត្ថិ តាទិសិកា បភា
យថា អហុ បភា តស្ស អសមស្ស មហេសិនោ ។

## បិយទស្សីពុទ្ធវង្ស ទី ១៣

ព្រះមហាមុនី ព្រះនាមបិយទស្សី ជាព្រះមហាបុរស ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧសភឧទ្យាន ជាទីរីករាយនៃចិត្ត ។ ភិក្ខុ ឈ្មោះបាលិតៈ ១ ឈ្មោះសព្វទស្សី ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសោភិតៈ ជាឧបដ្ឋាកនៃព្រះសាស្តា ព្រះនាមបិយទស្សី ។ ភិក្ខុនី ឈ្មោះសុជាតា ១ ឈ្មោះធម្មទិន្នា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹងនៃព្រះមានព្រះភាគនោះ គេហៅថា កកុធព្រឹក្ស (ដើមថ្កាន់) ។ ឧបាសកឈ្មោះសន្ទកៈ ១ ធម្មិកៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះនាងវិសាខា ១ ឈ្មោះនាងធម្មទិន្នា ១ ជាអគ្គឧបដ្ឋាយិកា ព្រះពុទ្ធអង្គនោះ ទ្រង់មានយសរាប់មិនបាន មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានកំពស់ ៨០ ហត្ថ ទ្រង់ប្រាកដដូចជាស្តេចនៃឈើ ឈ្មោះសាលព្រឹក្ស ។ រស្មីនៃភ្លើង រស្មីនៃព្រះចន្ទ្រ និងរស្មីនៃព្រះអាទិត្យ ប្រាកដដូចជារស្មីនៃព្រះពុទ្ធមហេសី ដែលរកបុគ្គលស្មើគ្មាននោះ មិនមានឡើយ ។

តស្សាបិ ទេវទេវស្ស អាយុ តាវត្តកា អហុ
នវុតិវស្សសហស្សានិ លោកេ អដ្ឋាសិ ចក្ខុមា ។
សោបិ ពុទ្ធោ អសមសមោ យុគានិបិ តានិ អតុលិយានិ
សព្វំ សមន្តរហិតំ[១] ននុ រិត្តា សព្វសង្ខារាតិ ។
បិយទស្សី មុនិវរោ អស្សត្ថារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ជិនថូបោ តីណិ យោជនមុគ្គតោតិ ។

បិយទស្សិពុទ្ធវំសោ តេរសមោ ។

# ចុទ្ទសមោ អត្ថទស្សិពុទ្ធវំសោ

(១៤) តត្ថេវ មណ្ឌកប្បម្ហិ អត្ថទស្សី មហាយសោ[២]
មហាតមំ និហន្ត្វាន បត្តោ សម្ពោធិមុត្តមំ ។

---

១ ម. តមន្តរហិតំ ។ ២ ឱ. ឱភាសកោ ។

ព្រះសម្ពុទ្ធ ជាទេវតាដ៏ប្រសើរអង្គនោះ មានព្រះជន្មាយុនៅដរាបនោះ គឺព្រះបច្ចុសម្ពុទ្ធ ទ្រង់ឋិតនៅក្នុងលោក អស់ ៩០ ពាន់ឆ្នាំ ។ ព្រះពុទ្ធដែលមិនមានបុគ្គលស្មើអង្គនោះក្តី គូនៃសាវ័កទាំងអម្បាលនោះក្តី មានគុណថ្លឹងពុំបាន របស់ទាំងអស់នេះ អន្តរធានទៅ ឱ! ហ្ន៎ សង្ខារទាំងពួង ជារបស់សោះសូន្យទទេ ។ ព្រះពុទ្ធព្រះនាមបិយទស្សី ជាព្រះមុនីប្រសើរ ទ្រង់បរិនិព្វាន ក្នុងអស្សត្ថារាម ព្រះស្តូបនៃព្រះជិនស្រីអង្គនោះ មានកំពស់ ៣ យោជន៍ (គេបានសាងហើយ) ក្នុងអស្សត្ថារាមនោះ ។

ចប់ បិយទស្សីពុទ្ធវង្ស ទី ១៣ ។

## អត្ថទស្សីពុទ្ធវង្ស ទី ១៤

(១៥) ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមអត្ថទស្សី មានយសធំ ទ្រង់កំចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ។

## ចុទ្ទសមោ អត្ថទស្សីពុទ្ធវំសោ

ព្រហ្មុនា យាចិតោ សន្តោ ធម្មចក្កំ បវត្តយិ
អមតេន តប្បយី លោកំ ទសសហស្សី សទេវកា ។
តស្សាបិ លោកនាថស្ស អហេសុំ អភិសមយា តយោ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។
យទា ពុទ្ធោ អត្ថទស្សី ចរតិ ទេវចារិកំ
កោដិសតសហស្សានំ ទុតិយាភិសមយោ អហុ ។
បុនាបរំ យទា ពុទ្ធោ ទេសេសិ បិតុ សន្តិកេ
កោដិសតសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ តស្សាបិ ច មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
អដ្ឋនវុតិសហស្សានំ បឋមោ អាសិ សមាគមោ
អដ្ឋាសីតិសហស្សានំ ទុតិយោ អាសិ សមាគមោ ។

## អត្ថទស្សីពុទ្ធវង្ស ទី ១៤

ព្រះសម្ពុទ្ធ ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ហើយញុំាងមនុស្សនិងទេវតា ទាំងមួយហ្មឺនលោកធាតុ ឲ្យឆ្អែតដោយទឹកអម្រឹត ។ ព្រះលោកនាថអង្គនោះទ្រង់មានការត្រាស់ដឹង ៣ លើក គឺ ការត្រាស់ដឹងលើកទី ១ មានពួកសត្វចំនួនមួយសែនកោដិ ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធ ទ្រង់ព្រះនាមអត្ថទស្សី ទ្រង់ត្រាច់ទៅកាន់ទេវចារិក ។ តមក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ចំនួនមួយសែនកោដិ ក្នុងកាលដែលព្រះពុទ្ធជាម្ចាស់ ទ្រង់សម្តែងព្រះធម៌ ក្នុងសំណាក់ព្រះបិតា ។ ព្រះមហេសីអង្គនោះ មានសាវកសន្និបាត (ការជួបជុំសាវ័ក) ៣ លើក ដែលសុទ្ធតែជាព្រះខីណាស្រព ប្រាសចាកមន្ទិល មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ គឺ សន្និបាតលើកទី ១ មានពួកព្រះខីណាស្រព ចំនួន ៩៨ ពាន់អង្គ សន្និបាតលើកទី ២ មានពួកព្រះខីណាស្រព ចំនួន ៨៨ ពាន់អង្គ ។

អដ្ឋសត្តតិសហស្សានិ   តតិយោ អាសិ សមាគមោ
អនុបាទាវិមុត្តានំ   វិមលានំ មហេសិនំ ។
អហន្តេន សមយេន   ជដិលោ ឧគ្គតាបនោ
សុសិមោ នាម នាមេន   មហិយា សេដ្ឋសម្មតោ ។
ទិព្វំ មន្ទារវំ បុប្ផំ   បទុមំ បារិឆត្តកំ
ទេវលោកា អាហរិត្វា   សម្ពុទ្ធំ អភិបូជយឹ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ   អត្ថទស្សី មហាមុនិ
អដ្ឋារសេ កប្បសតេ   អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា   និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន   កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ   និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ   នេរញ្ជរមុបេហិតិ ។

សន្និបាតលើក ទី ៣ មានពួកព្រះខីណាស្រព ចំនួន ៧៨ ពាន់អង្គ សុទ្ធតែមានព្រះទ័យផុតស្រឡះ ឥតប្រកាន់ ប្រាជាកមន្ទិល ជាអ្នកស្វែងរកគុណដ៏ធំ ៗ ក្នុងសម័យនោះ តថាគតកើតជាជដិល ឈ្មោះសុសិមៈ មានតបៈដ៏ខ្ពង់ខ្ពស់ ដែលគេសន្មតថា ជាបុគ្គលប្រសើរលើផែនដី ។ តថាគត បាននាំយកផ្កាមន្ទារវបុស្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្ស ជាទិព្វ អំពីទេវលោក មកបូជាចំពោះព្រះសម្ពុទ្ធ ។ ឯព្រះពុទ្ធ ជាមហាមុនី ព្រះនាមអត្ថទស្សីអង្គនោះ ទ្រង់បាន ព្យាករតថាគតថា តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុង កប្បទី ១.៨០០ ។ សត្វនេះ នឹងចេញអំពីបុរី ជាទីរីករាយ ឈ្មោះកបិលពស្តុ តម្កល់ព្យាយាម ហើយធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់ នៃអជបាលព្រឹក្ស ទទួល មធុបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។

## ពុទ្ធសមោ អត្ថទស្សីពុទ្ធវំសោ

នេរញ្ជរាយ តីរម្ហិ ឆាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ៗ
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ៗ
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ៗ
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ៗ
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ៗ
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ៗ

ព្រះជិនស្រីអង្គនោះ ទ្រង់សោយមធុបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ៗ លំដាប់នោះ ព្រះមានយសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈ ហើយត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ៗ ព្រះជននីនៃព្រះពោធិសត្វនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ បុរសនេះ ទ្រង់ជាព្រះពុទ្ធ ព្រះនាមគោតម ៗ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ទ្រង់ជាអគ្គសាវក ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទ្រង់បប្រើព្រះជិនស្រីអង្គនេះ ៗ ព្រះខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ ទ្រង់ជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ អស់រាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ ៗ ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស គហបតីឈ្មោះចិត្តៈ ១ គហបតីឈ្មោះហត្ថាឡវកៈ ១ ទ្រង់ជាអគ្គឧបដ្ឋាក ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

នន្ទមាតា ច ឧត្តរា　　អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស　　គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ　　អសមស្ស មហេសិនោ
អាមោទិតា នរមរូ　　ពុទ្ធវីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ　　អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ　　ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស　　វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ　　ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា　　បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន　　ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ　　យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ　　ហេស្សាម សម្មុខា ឥមំ ។

នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គុបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ មួយរយឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើហើយ ក៏រីករាយថា បុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សម្លេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃ អបអរ ធ្វើអញ្ជលីនមស្ការថា បើយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់នឹងទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមអង្គនេះ ក្នុងកាលជាអនាគត យ៉ាងនោះដែរ ។

## ពុទ្ធវំសោ អត្ថទស្សីពុទ្ធវំសោ

តស្សាបិ វចនំ សុត្វា ហដ្ឋោ សំវិគ្គមានសោ
ឧត្តរឹ វតមធិដ្ឋាសឹ ទសបារមិបូរិយា ។
សោភនំ នាម នគរំ សាគរោ នាម ខត្តិយោ
សុទស្សនា នាម ជនិកា អត្ថទស្សិស្ស មហេសិនោ ។
ទស វស្សសហស្សានិ អគារំ អជ្ឈាវសិ សោ(១)
អមរគិរិសុគិរិវាហនា(១) តយោ បាសាទមុត្តមា ។
តេត្តឹស តិសហស្សានិ នារិយោ សមលង្កតា
វិសាខា នាម សា នារី សេលោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា អស្សយានេន និក្ខមិ
អនូនអដ្ឋមាសានិ បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ អត្ថទស្សី មហាយសោ
វត្តចក្កោ មហាវីរោ អនោមុយ្យានេ នរាសភោ ។

១ ឱ. អមរគិរិ សុរគិរិ គិរិវាហនា ។ ម. អមរគិរិសុគិរិវាហនា ។

## អត្ថទស្សីពុទ្ធវង្ស ទី ១៤

លុះតថាគត បានស្តាប់ភាសិត នៃព្រះលោកនាថអង្គនោះហើយ ក៏មានចិត្តត្រេកអរ មានចិត្តតក់ស្លុត ខំអធិដ្ឋានវត្តតទៅទៀត ដើម្បីបំពេញបារមី ១០ ប្រការ ។ ព្រះមហេសី ព្រះនាមអត្ថទស្សី មានទីក្រុងឈ្មោះសោភណៈ មានព្រះមហាក្សត្រព្រះនាមសាគរ (ជាព្រះបិតា) មានព្រះជននីព្រះនាមសុទស្សនា ។ ព្រះអត្ថទស្សីអង្គនោះ ទ្រង់គ្រងគេហដ្ឋាន អស់ ៩.០០០ ឆ្នាំ មានប្រាសាទប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះអមរគិ ១ ប្រាសាទឈ្មោះសុរគិ ១ ប្រាសាទឈ្មោះគិរិវាហនៈ ១ ។ នារី ៣៣.០០០ រូប សឹងប្រដាប់យ៉ាងសមសួន ព្រះនារី (ជាអគ្គមហេសី) នោះ ព្រះនាមវិសាខា ព្រះរាជបុត្រ ព្រះនាមសេលៈ ។ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ហើយទ្រង់ស្តេចចេញទៅដោយយានសេះ តំកល់ព្យាយាម អស់ ៨ ខែគត់ ។ ព្រះអត្ថទស្សីមានយសធំ មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងឧទ្យានដ៏ថ្លៃថ្លា ។

សន្តោ ច ឧបសន្តោ ច អហេសុំ អគ្គសាវកា
អភយោ នាមុបដ្ឋាកោ អត្ថទស្សិស្ស មហេសិនោ ។
ធម្មា ចេវ សុធម្មា ច អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ ចម្បកោតិ បវុច្ចតិ ។
នកុលោ ចេវ និសភោ ច អហេសុំ អគ្គុបដ្ឋកា
មកិលា ច សុនន្ទា ច អហេសុំ អគ្គុបដ្ឋិកា ។
សោបិ ពុទ្ធោ អសមសមោ អសីតិហត្ថមុគ្គតោ
សោភតិ សាលរាជាវ ឧឡុរាជាវ បូរិតោ ។
តស្ស បាកតិកា រំសី អនេកសតកោដិយោ
ឧទ្ធំ អធោ ទសទិសា ផរន្តិ យោជនំ សទា ។
សោបិ ពុទ្ធោ នរាសភោ សព្វសត្តុត្តមោ មុនិ
វស្សសតសហស្សានិ លោកេ អដ្ឋាសិ ចក្ខុមា ។

ព្រះមហេសី ព្រះនាមអត្ថទស្សី មានអគ្គសាវ័កពីរអង្គ គឺ
ព្រះសន្ត: ១ ព្រះឧបសន្ត: ១ មានភិក្ខុជាឧបដ្ឋាក ឈ្មោះ
អភយ: ។ មានព្រះថេរីឈ្មោះធម្មា ១ សុធម្មា ១ ជាអគ្គសាវិកា
ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា
ចម្បកព្រឹក្ស ។ ឧបាសកឈ្មោះនកុល្ល: ១ ឈ្មោះនិសភ: ១
ជាអគ្គឧបដ្ឋាក នាងមកិលា ១ នាងសុនន្ទា ១ ជាអគ្គឧបដ្ឋា-
យិកា ។ ឯព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែល
មិនមានបុគ្គលស្មើ មានកំពស់ ៨០ ហត្ថ ទ្រង់រុងរឿងហាក់
ដូចដើមសាលរាជព្រឹក្ស ឬដូចព្រះចន្ទ្រពេញវង់ ។ រស្មីជា
ប្រក្រតី នៃព្រះពុទ្ធអង្គនោះ ច្រើនរយកោដិ តែងផ្សាយទៅ
កាន់ទិស ទាំង ១០ ទាំងខាងលើ ទាំងខាងក្រោម ចម្ងាយ
មួយយោជន៍ សព្វ ៗ កាល ។ ម្យ៉ាងទៀត ព្រះពុទ្ធអង្គនោះ
ប្រសើរជាងជន ខ្ពង់ខ្ពស់ជាងសត្វទាំងពួង ជាអ្នកប្រាជ្ញមាន
បញ្ញាចក្ខុ ឋិតនៅក្នុងមនុស្សលោក អស់មួយសែនឆ្នាំ ។

អតុលំ ទស្សេត្វា ឱភាសំ វិរោចេត្វា សទេវកេ

សោបិ អនិច្ចតំ បត្តោ យថគ្គុបាទានសង្ខយា ។

អត្ថទស្សី ជិនវរោ អនោមារាមម្ហិ និព្វុតោ

ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោ ។

អត្ថទស្សីពុទ្ធវំសោ ចុទ្ទសមោ ។

# បណ្ណរសមោ ធម្មទស្សីពុទ្ធវំសោ

(១៦) តត្ថេវ មណ្ឌកប្បម្ហិ ធម្មទស្សី មហាយសោ

តមន្ធការំ វិធមិត្វា អតិរោចតិ សទេវកេ ។

តស្សាបិ អតុលតេជស្ស ធម្មចក្កប្បវត្តនេ

កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។

ព្រះពុទ្ធនោះ ទ្រង់សម្ដែងពន្លឺថ្លឹងពុំបាន ញ៉ាំងមនុស្សលោក ព្រមទាំងទេវលោក ឲ្យរុងរឿង ហើយទ្រង់ដល់នូវអនិច្ចតាធម៌ ដូចជាភ្លើងអស់កំញម ។ ព្រះអត្ថទស្សីជិនស្រីដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអនោមារាម មានការសាយកាយទៅនៃព្រះធាតុ ក្នុងប្រទេសទាំងឡាយនោះ ៗ ។

ចប់ អត្ថទស្សីពុទ្ធវង្ស ទី ១៤ ។

## ធម្មទស្សីពុទ្ធវង្ស ទី ១៥

[១៦] ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធ ព្រះនាមធម្មទស្សី មានយសធំ ទ្រង់កំចាត់បង់ងងឹតអន្ធការ ហើយញ៉ាំងមនុស្សលោក ព្រមទាំងទេវលោក ឲ្យរុងរឿង ។ ការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ក្នុងការញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ នៃព្រះធម្មទស្សីនោះ ទ្រង់មានតេជះថ្លឹងពុំបាន ។

យទា ពុទ្ធោ ធម្មទស្សី វិនេសិ សញ្ជយំ ឥសិំ

តទា នវុតិកោដីនំ ទុតិយាភិសមយោ អហុ ។

យទា សក្កោ ឧបគញ្ឆិ សបរិសោ វិនាយកំ

តទា អសីតិកោដីនំ តតិយាភិសមយោ អហុ ។

តស្សាបិ ទេវទេវស្ស សន្និបាតា តយោ អាសុំ

ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

យទា ពុទ្ធោ ធម្មទស្សី សរណេ វស្សំ ឧបាគមិ

តទា កោដិសហស្សានំ បឋមោ អាសិ សមាគមោ ។

បុនាបរំ យទា ពុទ្ធោ ទេវតោ ឯតិ មានុសំ

តទាបិ សតកោដីនំ ទុតិយោ អាសិ សមាគមោ ។

បុនាបរំ យទា ពុទ្ធោ បកាសេសិ ធុតេ គុណេ

តទា អសីតិកោដីនំ តតិយោ អាសិ សមាគមោ ។

ការត្រាស់ដឹងលើកទី ២ មានសត្វចំនួន ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធ ព្រះនាមធម្មទស្សី ទ្រង់ទូន្មានឥសី ឈ្មោះសញ្ជយៈ ។ ការត្រាស់ដឹងលើកទី ៣ មានសត្វចំនួន ៨០ កោដិ ក្នុងកាលដែលសក្កទេវរាជ ព្រមទាំងបរិស័ទ ចូលទៅគាល់ព្រះធម្មទស្សី ទ្រង់ជានាយក ។ ព្រះធម្មទស្សីនោះជាទេវតាក្រៃលែងជាងទេវតា មានសាវកសន្និបាត ៣ លើកសុទ្ធតែជាព្រះខីណាស្រព មានមន្ទិលទៅប្រាសហើយ មានព្រះទ័យស្ងប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រព មួយពាន់កោដិ ក្នុងវេលាដែលព្រះពុទ្ធព្រះនាមធម្មទស្សី ទ្រង់ចូលទៅកាន់វស្សា ក្នុងអារាម ឈ្មោះសរណៈ ។ សន្និបាតលើកទី ២ មានព្រះខីណាស្រពចំនួន ១០០ កោដិ ក្នុងវេលាដែលព្រះពុទ្ធជាម្ចាស់ ស្ដេចចុះចាកទេវលោក មកកាន់មនុស្សលោក ។ មួយទៀត សន្និបាតលើកទី ៣ មានព្រះខីណាស្រព ចំនួន ៨០ កោដិ ក្នុងវេលាដែលព្រះពុទ្ធ ទ្រង់ប្រកាសនូវធុតង្គគុណទាំងឡាយ ។

## បណ្ណរសមោ ធម្មទស្សិពុទ្ធវំសោ

អហន្តេន សមយេន សក្កោ អាសឹ បុរិន្ទទោ
ទិព្វគន្ធេន មាលេន តុរិយេន អភិបូជយឹ ។
សោបិ មំ តទា(១) ព្យាកាសិ ទេវមជ្ឈេ និសីទិយ
អដ្ឋារសកប្បសតេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

---

១ ឱ.ម. ពុទ្ធោ ។

ធម្មទស្សីពុទ្ធវង្ស ទី ១៥

ក្នុងសម័យនោះ តថាគតកើតជាព្រះឥន្ទ្រ ឈ្មោះបុរិន្ទទៈ បានបូជាព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងក្រអូប ផ្កាកម្រង និងតូរ្យតន្ត្រីទិព្វ ៗ ព្រះពុទ្ធអង្គនោះ ទ្រង់គង់ចំកណ្ដាលពួកទេវតា ហើយព្យាករតថាគតថា ក្នុងកប្បទី ១.៨០០ ទៅពីនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ៗ សត្វនេះ នឹងចេញពីបុរីជាទីគួរត្រេកអរឈ្មោះកបិលពស្តុ ទៅតំកល់ព្យាយាម ធ្វើទុក្ករកិរិយា ៗ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹងនេរញ្ជរា ៗ ព្រះពុទ្ធជិនស្រីអង្គនោះបានឆាន់បាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយនឹងត្រឡប់ទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ៗ លំដាប់នោះ ព្រះជិនស្រីមានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ៗ

ឥមស្ស ជនិកា មាតា    មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម    អយំ ហេស្សតិ គោតមោ ។

កោលិតោ ឧបតិស្សោ ច    អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា    សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ    ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច    អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា    សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ    អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ    អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា    អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស    គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ    អសមស្ស មហេសិនោ
អាមោទិតា នរមរូ    ពុទ្ធវីជង្កុរោ អយំ ។

ព្រះជនទី នៃព្រះតថាគតនេះ ព្រះនាមមាយាទេវី ព្រះបិតា ព្រះនាមសុទ្ធោទនៈ ទេវពជនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ នឹងជាអគ្គសាវ័ក ជាអ្នកមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតំកល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ ព្រះខេមាថេរី ១ ព្រះឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា ជាអ្នកមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថាអស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ឈ្មោះហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្ស និងទេវតា លុះបានស្ដាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ក៏រីករាយថា ព្រះឥន្ទ្រនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។

## បណ្ណរសមោ ធម្មទស្សិពុទ្ធវំសោ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច

កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ

ហេដ្ឋាតិត្ថេ គហេត្វាន ឧត្តរន្តិ មហានទឹ ។

ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

តស្សាបិ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ

ឧត្តរឹ វតមធិដ្ឋាសឹ ទសបារមិបូរិយា ។

សរណំ នាម នគរំ សរណោ នាម ខត្តិយោ

សុនន្ទា នាម ជនិកា ធម្មទស្សិស្ស សត្ថុនោ ។

សម្ដេចហោ៎ ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ។ ពួកមនុស្ស កាលនឹងឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ។ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រ នៃព្រះគោតម ក្នុងកាលជាអនាគតមិនខាន យ៉ាងនោះឯង ។ តថាគត លុះបានស្ដាប់ភាសិតនៃព្រះជិនស្រីអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តទៅ ដើម្បីបំពេញបារមីទាំង ១០ ។ ព្រះសាស្ដាព្រះនាមធម្មទស្សី មានទីក្រុងឈ្មោះសរណៈ មានមហាក្សត្រព្រះនាមសរណៈ ជាព្រះបិតា មានព្រះជននី ព្រះនាមសុនន្ទា ។

អដ្ឋវស្សសហស្សានិ   អគារំ អជ្ឈាវសិ សោ
អរជោ វិរជោ សុទស្សនោ   តយោ បាសាទមុត្តមា ។
ចត្តាឡីស សហស្សានិ   នារិយោ សមលង្កតា
វិចិកោលី នាម នារី   អត្រជោ បុញ្ញវឌ្ឍនោ ។
និមិត្តេ ចតុរោ ទិស្វា   បាសាទេនាភិនិក្ខមិ
សត្តាហំ បធានចារំ   អចរិ បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ   ធម្មទស្សី នរាសភោ
វត្តចក្កោ មហាវីរោ   មិគទាយេ នរុត្តមោ ។
បទុមោ ផុស្សទេវោ ច   អហេសុំ អគ្គសាវកា
សុនេត្តា(១) នាមុបដ្ឋាកោ   ធម្មទស្សិស្ស សត្ថុនោ ។
ខេមា ច សច្ចនាមា ច   អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ   ពិម្ពជាលោតិ(២) វុច្ចតិ ។

---

១ ឱ. ម. សុនេត្តោ ។ ២ ឱ. ពិម្ពជាលោតី ។ ម. ពិម្ពិជាលោតិ ។

ព្រះធម្មទស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហស្ថាន អស់៨ពាន់ឆ្នាំ ទ្រង់មានប្រាសាទ ៣ខ្នង គឺប្រាសាទឈ្មោះអរជៈ ១ ប្រាសាទឈ្មោះវិរជៈ ១ ប្រាសាទឈ្មោះសុទស្សនៈ ១ ។ ពួកនារីចំនួន ៤០ពាន់ សឹងប្រដាប់ខ្លួនយ៉ាងសមសួន នារី (ជាអគ្គមហេសី) ឈ្មោះវិចិកោលី ព្រះរាជបុត្រ ឈ្មោះបុញ្ញវឌ្ឍនៈ ។ ព្រះធម្មទស្សី ជាបុរសដ៏ប្រសើរ ទ្រង់ឃើញនូវនិមិត្ត ៤ ហើយទ្រង់ចេញទៅកាន់ប្រាសាទ ទៅប្រព្រឹត្តព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះពុទ្ធព្រះនាមធម្មទស្សី ប្រសើរជាងពួកជន មានព្យាយាមធំ ឧត្តមជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះសាស្តា ព្រះនាមធម្មទស្សី មានព្រះបទុមត្ថេរ ១ ព្រះបុស្សទេវត្ថេរ ១ ជាអគ្គសាវ័ក ព្រះសុទត្តត្ថេរ ជាឧបដ្ឋាក ។ មានព្រះខេមាថេរី ១ ព្រះសច្ចនាមាថេរី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគនោះ គេហៅថា តិម្ពជាលព្រឹក្ស ។

## បណ្ណរសមោ ធម្មទស្សិពុទ្ធវំសោ

សុភទ្ទោ កដិស្សហោ ចេវ   អហេសុំ អគ្គុបដ្ឋកា
សាឡិសា(១) ច កឡិស្សា(២) ច   អហេសុំ អគ្គុបដ្ឋិកា ។
សោបិ ពុទ្ធោ អសមសមោ   អសីតិហត្ថមុគ្គតោ
អតិរោចតិ តេជេន   ទសសហស្សិម្ហិ ធាតុយា ។
សុផុល្លោ សាលរាជាវ   វិជ្ជុវ គគនេ យថា
មជ្ឈន្តិកេវ សុរិយោ   ឯវំ សោ ឧបសោភថ ។
តស្សាបិ អតុលតេជស្ស   សមកំ អាសិ ជីវិតំ
វស្សសតសហស្សានិ   លោកេ អដ្ឋាសិ ចក្ខុមា ។
ឱភាសំ ទស្សយិត្វាន   វិមលំ កត្វាន សាសនំ
ចវិ(៣) ចន្ទោវ គគនេ   និព្វុតោ សោ សសាវកោតិ ។

---

១ ឱ. ម. សាឡិយា ។ ២ ឱ. វឡិយា ។ ម. កឡិយា ។ ៣ ឱ. វិរោចយិ ។ ។ ម. រវិ ។

## ធម្មទស្សីពុទ្ធវង្ស ទី ១៨

សុភទ្ទគហបតី ១ កដិស្សហគហបតី ១ ជាអគ្គឧបដ្ឋាក នាងសាឡិសា ១ នាងកឡិស្សា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធនោះ ទ្រង់ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ទ្រង់មានកំពស់ ៨០ ហត្ថ ទ្រង់រុងរឿងក្រៃលែង ដោយតេជះក្នុងមួយហ្មឺនលោកធាតុ ។ ដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយល្អ ផ្ទេកបន្ទោរលើអាកាស ព្រះអាទិត្យនាថ្ងៃត្រង់ រុងរឿងល្អ យ៉ាងណាមិញ ព្រះពុទ្ធអង្គនោះ ទ្រង់រុងរឿងល្អ យ៉ាងនោះ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានតេជះថ្លឹងពុំបាន មានជីវិតដ៏ស្មើល្អ ព្រះពុទ្ធមានបញ្ញាចក្ខុ ទ្រង់ឋិតនៅក្នុងលោក អស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សម្តែងស្មើ ធ្វើសាសនាមិនឲ្យមានមន្ទិលដូចព្រះចន្ទ្រ កាលរុងរឿងឰដ៏អាកាស ហើយបរិនិព្វាន ។

ធម្មទស្សី មហាវីរោ  កេសារាមម្ហិ(១) និព្វុតោ
តត្ថេវ សោ ថូបវរោ  តីណិ យោជនមុគ្គតោតិ ។

ធម្មទស្សិពុទ្ធវំសោ បណ្ណរសមោ ។

# សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

(១៧) ធម្មទស្សិស្ស អបរេន  សិទ្ធត្ថោ លោកនាយកោ
និហន្ត្វាន តមំ សព្វំ  សុរិយោ អព្ភុគ្គតោ យថា ។
សោបិ បត្វាន សម្ពោធឹ  សន្តារេន្តោ សទេវកំ
អភិវស្សិ ធម្មមេឃេន  និព្វាបេន្តោ សទេវកំ ។
តស្សាបិ អតុលតេជស្ស អហោសិ អភិសមយា តយោ
កោដិសតសហស្សានំ  បឋមាភិសមយោ អហុ ។

---

១ ម. សាលារាម្ហិ ។

ព្រះធម្មទស្សី ទ្រង់មានព្យាយាមធំ ទ្រង់បរិនិព្វានក្នុងអារាម ឈ្មោះកេសៈ ព្រះស្តូបដ៏ប្រសើរនោះ របស់ព្រះពុទ្ធអង្គនោះឯង មានកំពស់ ៣ យោជន៍ ។

ចប់ ធម្មទស្សីពុទ្ធវង្ស ទី ១៥ ។

# សិទ្ធត្ថពុទ្ធវង្ស ទី ១៦

(១៧) ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ទ្រង់កំចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះឡើង ។ ព្រះសិទ្ធត្ថៈអង្គនោះ ទ្រង់ដល់នូវសម្ពោធិញ្ញាណ ហើយចម្លងមនុស្សព្រមទាំងទេវតា បង្អុរភ្លៀងគឺធម៌ ហើយញុំាងមនុស្ស ព្រមទាំងទេវតា ឲ្យរលត់ទុក្ខ ។ ព្រះអង្គមានតេជៈថ្លឹងពុំបាន ទ្រង់មានការត្រាស់ដឹង ៣ លើក គឺ ការត្រាស់ដឹងលើកទី ១ មានពួកសត្វមួយសែនកោដិ ។

## សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

បុនាបរំ ភីមរដ្ឋេ យថា(១) អាហនិ ទុន្ទុភឹ(២)
តទា នវុតិកោដីនំ ទុតិយាភិសមយោ អហុ ។
យទា ពុទ្ធោ ធម្មំ ទេសេសិ វេភារេ សោ នរុត្តមោ
តទា នវុតិកោដីនំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ សិទ្ធត្ថស្ស មហេសិនោ(៣)
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
កោដិសតានំ នវុតិយា អសីតិយាបិ ច កោដិនំ
ឯតេ អាសុំ តយោ ឋានា វិមលានំ សមាគមេ ។
អហន្តេន សមយេន មង្គលោ នាម តាបសោ
ឧគ្គតេជោ ទុប្បសហោ អភិញ្ញាពលសមាហិតោ ។
ជម្ពុតោ ផលមាហត្វា សិទ្ធត្ថស្ស អទាសហំ
បដិគ្គហេត្វាន សម្ពុទ្ធោ ឥទំ វចនមព្រវិ ។

---

១ ឱ. យទិ ។ ម. យទា ។ ២ ឱ. ទុទ្រភឹ ។ ៣ ឱ. ម. តស្មឹបិ ទីបទុត្តមេតិ ទិស្សតិ ។
ម. តស្សាបិ ទ្វិបទុត្តមេ ។

## សិទ្ធត្ថពុទ្ធវង្ស ទី ១៦

តមក ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ក្នុងកាលព្រះសម្ពុទ្ធ ទ្រង់ទូងស្គរគឺធម៌ ក្នុងដែនឈ្មោះភីមៈ ។ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៩០ កោដិ ក្នុងកាលដែលព្រះពុទ្ធប្រសើរជាងជនអគ្គនោះ ទ្រង់សម្ដែងធម៌ ទៀបភ្នំឈ្មោះវេភារៈ ។ ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ ឋានៈគឺសន្និបាតទាំង ៣ ក្នុងសមាគមនៃព្រះខីណាស្រព ដែលមិនមានមន្ទិលទុះ មានចំនួន ១០០ កោដិម្តង ៩០ កោដិម្តង ៨០ កោដិម្តង ។ សម័យនោះ តថាគតជាតាបស ឈ្មោះមង្គលៈ មានតេជៈខ្ពង់ខ្ពស់ គេគ្របសង្កត់មិនបាន ជាអ្នកប្រកបដោយកម្លាំង នៃអភិញ្ញា ។ តថាគតបាននាំផ្លែព្រីងមកថ្វាយព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈ ព្រះសម្ពុទ្ធទ្រង់ទទួលយកហើយ ទ្រង់បានត្រាស់ព្រះតម្រាស់នេះថា

បស្សថ ឥមំ តាបសំ   ជដិលំ ឧគ្គតាបនំ
ចតុន្នវុតេ ឥតោ កប្បេ   អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា   និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន   កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មិំ   និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ   នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ   បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន   ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា   ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ   ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា   មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម   អយំ ហេស្សតិ គោតមោ ។

អ្នកទាំងឡាយ ចូរមើលជដិលតាបស ដែលមានតបៈខ្ពង់-ខ្ពស់នេះចុះ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ៩៤ អំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញពីបុរីឈ្មោះកបិលពស្តុ ជាទីរីករាយ ទៅតំកល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចត្រឡប់ចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវប្រសើរ ដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះជិនស្រី ទ្រង់មានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់នៃអស្សត្ថព្រឹក្ស ។ ព្រះជននីនៃព្រះគោតមនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។

## សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា

អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។

## សិទ្ធត្ថពុទ្ធវគ្គ ទី ១៦

ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ទឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទឹងបម្រើព្រះជិនស្រីអង្គនេះ ៗ ខេមាថេរី ១ ឧប្បលវណ្ណាថេរី ១ ទឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ មានរាគៈអស់ហើយ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ៗ ដើមឈើជាទីត្រាស់ដឹងនៃព្រះមានជោគនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទឹងជាអគ្គឧបដ្ឋាក ៗ នាងនន្ទមាតា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ព្រះគោតមទ្រង់យសអង្គនោះ មានព្រះជន្មាយុ មួយរយឆ្នាំ ៗ មនុស្សនិងទេវតាបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ក៏រីករាយថា តាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថេ គហេត្វាន ឧត្តរន្តិ មហានទឹ ។

ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

តស្សាហំ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ ទសបារមិបូរិយា ។

វេភារំ នាម នគរំ ឧទេនោ នាម ខត្តិយោ
សុផស្សា នាម ជនិកា សិទ្ធត្ថស្ស មហេសិនោ ។

សម្តេងហើយក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ ពួកយើងគង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ៗ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់ទៅកាន់កំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ៗ ពួកយើងទាំងអស់ បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេចចំពោះព្រះភក្ត្រព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខានយ៉ាងនោះដែរ ៗ តថាគត លុះស្តាប់ភាសិតនៃព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈនោះហើយ ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្រៃលែង បានអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ៗ ព្រះមហេសីព្រះនាមសិទ្ធត្ថៈ មានទីក្រុងឈ្មោះវេភារៈ ព្រះមហាក្សត្រព្រះនាមឧទេនៈ ជាព្រះបិតា ព្រះជននីព្រះនាមសុផស្សា ៗ

## សោឡសមោ សិទ្ធត្ថពុទ្ធវំសោ

ទស វស្សសហស្សានិ   អគារំ អជ្ឈាវសិ សោ
កោកា សុប្បលកោកនុទា   តយោ បាសាទមុត្តមា ។
តិសោឡសសហស្សានិ   នារិយោ សមលង្កតា
សុមនា នាម សា នារី   អនុបមោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា   សិវិកាយាភិនិក្ខមិ
អនូនទសមាសានិ   បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ   សិទ្ធត្ថោ លោកនាយកោ
វត្តចក្កោ មហាវីរោ   មិគទាយេ នរុត្តមោ ។
សម្ពលោ ច សុមិត្តោ ច   អហេសុំ អគ្គសាវកា
រេវតោ នាមុបដ្ឋាកោ   សិទ្ធត្ថស្ស មហេសិនោ ។
សីវលា ច សុរាមា ច   អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ   កណ្ណិការោតិ វុច្ចតិ ។

## សិទ្ធត្ថពុទ្ធវង្ស ទី ១៦

ព្រះសិទ្ធត្ថៈនោះ គ្រប់គ្រងគេហដ្ឋាន អស់មួយហ៊ឺនឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺកោកាសប្រាសាទ ១ ឧប្បលប្រាសាទ ១ កោកនុទប្រាសាទ ១ ៗ នារី ៤៨.០០០ រូប ស៊ឹងមានខ្លួនតាក់តែងល្អ នារីជាអគ្គមហេសី ព្រះនាមសុមនា មានព្រះរាជបុត្រ ព្រះនាមអនុបមៈ ៗ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ យ៉ាង ក៏ចេញទៅដោយវ តម្កល់ព្យាយាម អស់ ១០ ខែគត់ ៗ ព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ៗ ព្រះមហេសី ព្រះនាមសិទ្ធត្ថៈ មានព្រះសម្ពលត្ថេរ ១ ព្រះសុមិត្តត្ថេរ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះរេវតៈ ជាឧបដ្ឋាក ៗ ព្រះសីវលាថេរី ១ ព្រះសុរាមាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថាកណ្ណិការព្រឹក្ស ៗ

សុប្បិយោ ច សមុទ្ទោ ច អហេសុំ អគ្គុបដ្ឋកា
រម្មា ចេវ សុរម្មា ច អហេសុំ អគ្គុបដ្ឋិកា ។
សោ ពុទ្ធោ សដ្ឋិរតនំ(១) អហោសិ នភមុគ្គតោ
កញ្ចនគ្ឃិកសង្កាសោ ទសសហស្សី វិរោចតិ ។
សោបិ ពុទ្ធោ អសមសមោ អតុលោ អប្បដិបុគ្គលោ
វស្សសតសហស្សានិ លោកេ អដ្ឋាសិ ចក្ខុមា ។
វិបុលប្បភំ ទស្សយិត្វា បុប្ផាបេត្វាន សាវកេ
វិលាសេត្វា វរសមាបត្តិយា និព្វុតោ សោ សសាវកោ ។
សិទ្ធត្ថោ មុនិវរោ ពុទ្ធោ អនោមារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ថូបវរោ ចតុយោជនមុគ្គតោតិ ។

សិទ្ធត្ថពុទ្ធវំសោ សោឡសមោ ។

---

១ សដ្ឋិរតនោតិ យុត្តតរំ ។

សុប្បិយគហបតី ១ សមុទ្ទគហបតី ១ ជាអ្នកបម្រើដ៏ប្រសើរ រម្មាឧបាសិកា ១ សុរម្មាឧបាសិកា ១ ជាស្រីបម្រើប្រសើរ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកំពស់ ៦០ ហត្ថ ទ្រង់ខ្ពស់ដល់អាកាស ប្រាកដស្មើដោយគ្រឿងបូជាមាស ទ្រង់រុងរឿងអស់មួយហ្មឺនលោកធាតុ ។ ព្រះពុទ្ធអង្គនោះ ទ្រង់ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ឥតមានបុគ្គលថ្លឹងបាន ឥតមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់មានចក្ខុ បិតនៅក្នុងលោកអស់មួយសែនឆ្នាំ ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សម្ដែងពន្លឺភ្លឺត្រចះ ហើយញុំាងសាវ័ក ឲ្យសាយភាយទៅ ទ្រង់ក្រសាលដោយសមាបត្តិដ៏ប្រសើរ ហើយបរិនិព្វាន ។ ព្រះពុទ្ធព្រះនាមសិទ្ធត្ថៈ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វានក្នុងអនោមារាម ព្រះស្តូបដ៏ប្រសើរ នៃព្រះអង្គនោះ មានកំពស់ ៤ យោជន៍ ប្រតិស្ឋាននៅ ក្នុងអនោមារាមនោះឯង ។

ចប់ សិទ្ធត្ថពុទ្ធវង្ស ទី ១៦ ។

# អដ្ឋារសមោ តិស្សពុទ្ធវំសោ

(១៨) សិទ្ធត្ថស្ស អបរេន អសមោ អប្បដិបុគ្គលោ
អនន្តសីលោ[១] អមិតយសោ តិស្សោ លោកគ្គ-
នាយកោ ។

តមន្ធការំ វិធមិត្វា ឱភាសេត្វា សទេវកំ
អនុកម្បកោ មហាវីរោ លោកេ ឧប្បជ្ជិ ចក្ខុមា ។
តស្សាបិ អតុលា ឥទ្ធិ អតុលា សីលសមាធិយោ
សព្វត្ថ បារមឹ គន្ត្វា ធម្មចក្កំ បវត្តយិ ។
សោ ពុទ្ធោ ទសសហស្សិម្ហិ វិញ្ញាបេសិ គិរំ សុចឹ
កោដិសតានិ អភិសមឹសុ បឋមេ ធម្មទេសនេ ។
ទុតិយោ នវុតិកោដីនំ តតិយេ សដ្ឋិកោដិយោ
ពន្ធនា សោ បមោចេសិ សម្បត្តេ នរមរូ តទា ។

---

១ ម. អនន្តតេជោ ។

# តិស្សពុទ្ធវង្ស ទី ១៧

(១៨) ក្រោយពីព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធ ព្រះនាមតិស្សៈ ជានាយកដ៏ប្រសើរ ក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់ពុំបាន ទ្រង់មានសេចក្ដីអាណិតអាសូរ មានព្យាយាមធំ មានចក្ខុ ទ្រង់កើតឡើងក្នុងលោក កំចាត់បង់ងងឹតអន្ធការ ញុំាងលោកនេះ ព្រមទាំងទេវលោក ឲ្យភ្លឺស្វាងហើយ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានឫទ្ធិថ្លឹងពុំបាន មានសីលសមាធិថ្លឹងពុំបាន ព្រះអង្គសម្រេចនូវបារមី ក្នុងធម៌ទាំងពួង ហើយទ្រង់ញុំាងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះពុទ្ធនោះ ទ្រង់បញ្ចេញព្រះសូរសៀងដ៏ជ្រះស្អាតល្អ ក្នុងលោកធាតុមួយហ្មឺន ពួកសត្វទាំងមួយរយកោដិ សឹងបានត្រាស់ដឹង ក្នុងការសម្ដែងធម៌លើកទី ១ ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ កោដិ ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៦០ កោដិ ពេលនោះ ព្រះសម្ពុទ្ធនោះទ្រង់ដោះមនុស្សនិងទេវតា ដែលមកដល់ឲ្យរួចចាកចំណងគឺមារ ។

សន្និបាតា តយោ អាសុំ តិស្សស្ស ច មហេសិនោ(១)
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

ខីណាសវសតសហស្សានំ បឋមោ អាសិ សមាគមោ
នវុតិសតសហស្សានំ ទុតិយោ អាសិ សមាគមោ ។

អសីតិសតសហស្សានំ តតិយោ អាសិ សមាគមោ
ខីណាសវានំ វិមលានំ បុប្ផិតានំ វិមុត្តិយា ។

អហំ តេន សមយេន សុជាតោ នាម ខត្តិយោ
មហាភោគំ ឆឌ្ឌយិត្វា បព្វជឹ ឥសិបព្វជ្ជំ ។

មយិ បព្វជិតេ សន្តេ ឧប្បជ្ជិ លោកនាយកោ
ពុទ្ធោតិ សទ្ទំ សុត្វាន បីតិ មេ ឧបបជ្ជថ ។

ទិព្វំ មន្ទារវំ បុប្ផំ បទុមំ បារិជត្តកំ
ឧភោ ហត្ថេហិ បគ្គយ្ហ ធុនមានោ ឧបាគមឹ ។

---

១ ឱ. ម. តិស្សេ លោកគ្គនាយកេតិ ទិស្សតិ ។

ព្រះតិស្សមហេសី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធសឹងតែជាពួកព្រះខីណាស្រព មិនមានមន្ទិលគឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រពមួយសែនអង្គ សន្និបាតលើកទី ២ មានព្រះខីណាស្រព៩០សែនអង្គ ។ សន្និបាតលើកទី ៣ មានព្រះខីណាស្រព៨០សែនអង្គ សុទ្ធតែជាអ្នកអស់អាសវៈ ឥតមានមន្ទិលគឺកិលេស រីកហើយដោយវិមុត្តិ ។ គ្រានោះ តថាគតជាក្សត្រនាមសុជាតៈ លះបោលភោគៈដ៏ច្រើន ហើយទៅបួសជាឥសី ។ កាលដែលតថាគត បួសស្រេចហើយ ព្រះលោកនាយកទ្រង់កើតឡើង តថាគតកើតមានបីតិ ព្រោះបានស្ដាប់សម្លេងថាព្រះពុទ្ធ ។ តថាគតបានកាន់យកផ្កាមន្ទារវព្រឹក្ស ផ្កាឈូក និងផ្កាបារិច្ឆត្តកព្រឹក្ស ជាទិព្វ ដោយដៃទាំងពីរ ផ្ទុះរលាស់ ហើយចូលទៅគាល់ ។

## សត្តរសមោ តិស្សពុទ្ធវំសោ

បាតុវណ្ណបរិវុត្តំ(១) តិស្សំ លោកគ្គនាយកំ
តមហំ បុប្ផំ គហេត្វាន មត្ថកេ ធារយេ ជិនំ ។
សោបិ មំ តទា(២) ព្យាកាសិ ជនមជ្ឈេ និសីទិយ
ទ្វានវុតេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

---

១ ឱ.ម. បតុវណ្ណបរិវុតំ ។ ២ ឱ. ពុទ្ធោ ។

## តិស្សពុទ្ធវង្ស ទី ១៧

តថាគតកាន់ផ្កានោះ បាំងលើព្រះសិរ្ស នៃព្រះជិនស្រីព្រះនាមតិស្សៈ ជាលោកគ្គនាយក ដែលមានបរិស័ទ ៤[១] ហោមរោម ។ ព្រះពុទ្ធអង្គនោះ ទ្រង់គង់កណ្ដាលប្រជុំជន ហើយព្យាករតថាគតកាលនោះថា ក្នុងកប្បទី ៩២ អំពីមណ្ឌកប្បនេះទៅ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះនឹងចេញពីបុរី ឈ្មោះកបិលពស្តុ ជាទីត្រេកអរ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសត្រង់ទីនោះ ហើយនឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅទៀបគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ។ លំដាប់នោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយត្រាស់ដឹងទៀបគល់អស្សត្ថព្រឹក្ស ។

---

១ បានដល់ខត្តិយបរិស័ទ ១ ព្រាហ្មណបរិស័ទ ១ គហបតិបរិស័ទ ១ សមណបរិស័ទ ១ ។ អដ្ឋកថា ។

ឥមស្ស ជនិកា មាតា   មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម   អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច   អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ   ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច   អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ   អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ   អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា   អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស   គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ   អសមស្ស មហេសិនោ
អាមោទិតា នរមរូ   ពុទ្ធពីជង្កុរោ អយំ ។

ព្រះជននី នៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតាព្រះនាម សុទ្ធោទនៈ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ នឹងជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ។ នាងខេមាថេរី ១ នាងឧប្បលវណ្ណាថេរី ១ នឹងជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ជាអគ្គឧបដ្ឋាក ។ នន្ទមាតាឧបាសិកា ១ ឧត្តរាឧបាសិកា ១ ជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ ទ្រង់មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់នូវព្រះពុទ្ធដីកានេះ នៃព្រះមហេសី ទ្រង់ឥតមានបុគ្គលស្មើ ហើយរីករាយថា តាបសនេះ ជាពូជពន្លក នៃព្រះពុទ្ធ ។

## សត្តរសមោ តិស្សពុទ្ធវំសោ

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ ទសបារមិបូរិយា ។
ខេមកំ នាម នគរំ ជនសន្ធោ នាម ខត្តិយោ
បទុមា នាម ជនិកា តិស្សស្សច មហេសិនោ ។

## តិស្សពុទ្ធវង្ស ទី ១៧

សម្ដេចនោះ ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃ អបអរសាទរ ធ្វើអញ្ជលីនមស្ការថា បើយើងឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថអង្គនេះ គង់យើងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងកាលជាអនាគតមិនខាន ៗ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងអនាគត យ៉ាងនោះដែរ ៗ តថាគត លុះបានស្ដាប់នូវព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះហើយ ធ្វើចិត្តឲ្យរីករាយតែដ្រេះថ្លាថែមទៀត ទំអធិដ្ឋានវត្តទៅ ដើម្បីបំពេញបារមីទាំង ១០ ៗ ព្រះមហេសីព្រះនាមតិស្ស: មានទីក្រុងឈ្មោះខេមកៈ មានព្រះមហាក្សត្រ ព្រះនាមជនសន្ធ: ជាព្រះបិតា មានព្រះជននី ព្រះនាមបទុមា ៗ

សត្តវស្សសហស្សានិ អគារំ អជ្ឈាវសិ សោ
គុហាសេលានារិយនិសភោ(១) តយោ បាសាទមុត្តមា
សមត្តឹសសហស្សានិ នារិយោ សមលង្កតា
សុភទ្ទា នាម សា នារី អានន្ទោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា អស្សយានេន និក្ខមិ
អនូនកំ អដ្ឋមាសំ បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ តិស្សោ លោកគ្គនាយកោ
វត្តចក្កោ មហាវីរោ យសវតីនាយេមុត្តមេ ។
ព្រហ្មទេវោ ច ឧទយោ ច អហេសុំ អគ្គសាវកា
សមនោ(២) នាមុបដ្ឋាកោ តិស្សស្ស ច មហេសិនោ ។
ផុស្សា ចេវ សុទត្តា ច អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ អសនោតិ បវុច្ចតិ ។

---

១ ឱ. គូហាសេលនារីនិសភា ។ ម. កុមុទោ នាឡិយោ បទុមោតិ ទិស្សន្តិ ។ ២ ឱ. ម. សមង្គោ ។

ព្រះតិស្សៈនោះ ទ្រង់គ្រប់គ្រងព្រះរាជគេហស្ថាន អស់ ៧ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះ គុណសេលៈ ១ ប្រាសាទឈ្មោះ អនាទិយៈ ១ ប្រាសាទ ឈ្មោះនិសភៈ ១ ។ ពួកនារី ចំនួន ៣ ហ្មឺននាក់ សុទ្ធសឹងតែ តាក់តែងខ្លួនល្អ ឯនាងនារី ជាអគ្គមហេសីនោះ ព្រះនាម សុភទ្រា ព្រះរាជបុត្រ ព្រះនាមអានន្ទ ។ ព្រះជិនស្រីទ្រង់ ឃើញនិមិត្តទាំង ៤ ក៏យាងចេញទៅ ដោយយានសេះ ទៅតម្កល់ព្យាយាម អស់កាលកន្លះខែគត់ ។ ព្រះលោក-នាយក ព្រះនាមតិស្សៈ ប្រសើរក្នុងលោក មានព្យាយាមធំ ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្រគឺធម៌ឲ្យប្រព្រឹត្ត ទៅ ក្នុងយសវតីទាយវ័នដ៏ឧត្តម ។ ព្រះព្រហ្មទេវត្ថេរ ១ ព្រះ ឧទយត្ថេរ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសមគៈ ជាឧបដ្ឋាក នៃព្រះមហេសី ព្រះនាមតិស្សៈ ។ នាងផុស្សាថេរី ១ នាង សុទត្តាថេរី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃ ព្រះមានជោគអង្គនោះ ហៅថា អសនព្រឹក្ស (ដើមធ្នង់) ។

## សត្តរសមោ តិស្សពុទ្ធវំសោ

សម្ពលោ ច សិរី(១) ចេវ អហេសុំ អគ្គុបដ្ឋកា
កីសាគោតមី ឧបសេនា អហេសុំ អគ្គុបដ្ឋិកា ។
សោបិ ពុទ្ធោ សដ្ឋិរតនោ អហុ ឧច្ចត្តនេ ជិនោ
អនុបមោ អសទិសោ ហិមវាវិយ ទិស្សតិ ។
តស្សាបិ អតុលតេជស្ស អាយុ អាសិ អនុត្តរោ
វស្សសតសហស្សានិ លោកេ អដ្ឋាសិ ចក្ខុមា ។
ឧត្តមំ បវរំ សេដ្ឋំ អនុភោត្វា មហាយសំ
ជលិត្វា អគ្គិក្ខន្ធោវ និព្វុតោ សោ សសាវកោ ។
វលាហកោវ អនិលេន សុរិយេន វិយ ឧស្សវោ
អន្ធការោវ ទីបេន និព្វុតោ សោ សសាវកោ ។
តិស្សោ ជិនវរោ ពុទ្ធោ ឆន្ទារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ជិនថូបោ តីណិ យោជនសមុស្សិតោតិ(២) ។

តិស្សពុទ្ធវំសោ សត្តរសមោ ។

---

១ ម. សិរិមា ។ ២.ម. យោជនមុគ្គតោតិ ។

## តិស្សពុទ្ធវង្ស ទី ១៧

សម្ពលគហបតី ១ សិរិគហបតី ១ ជាអគ្គឧបដ្ឋាក កីសាគោតមីឧបាសិកា ១ ឧបសេនាឧបាសិកា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះជិនស្រីសម្ពុទ្ធនោះឯង ទ្រង់មានកំពស់ ៦០ ហត្ថ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ឥតមានបុគ្គលស្មើបាន ប្រាកដដូចភ្នំហិមពាន្ត ។ ព្រះជិនស្រីអង្គនោះ ទ្រង់មានតេជះថ្លឹងពុំបាន ទ្រង់មានព្រះជន្ម មួយសែនឆ្នាំ ព្រះអង្គមិនមានបុគ្គលក្រៃលែងជាង ទ្រង់មានចក្ខុ បិតនៅក្នុងលោក ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់សោយនូវយសធំដ៏ឧត្តម ប្រសើរ រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។ ព្រះជិនស្រីអង្គនោះ ព្រមទាំងសាវ័ក ទ្រង់បរិនិព្វានហើយ ដូចជាភ្លើង (ដែលបាត់ទៅ) ព្រោះខ្យល់ ឬដូចទឹកសន្សើម (អស់ទៅ) ព្រោះព្រះអាទិត្យ ឬដូចងងឹត (បាត់ទៅ) ព្រោះប្រទីប ។ ព្រះពុទ្ធព្រះនាមតិស្សៈ ជាព្រះជិនស្រីដ៏ប្រសើរ បរិនិព្វានក្នុងនន្ទារាម ព្រះស្តូបព្រះជិនស្រីអង្គនោះ ពួកមហាជនសាងទុក កំពស់ ៣ យោជន៍ ក្នុងនន្ទារាមនោះ ។

ចប់ តិស្សពុទ្ធវង្ស ទី ១៧ ។

# អដ្ឋារសមោ ផុស្សពុទ្ធវំសោ

(១៩) តត្ថេវ មណ្ឌកប្បម្ហិ អាហុ សត្ថា អនុត្តរោ
អនូបមោ អសមសមោ ផុស្សោ លោកគ្គនាយកោ ។
សោបិ សព្វំ តមំ ហន្ត្វា វិជដេត្វា មហាជដំ
សទេវកំ តប្បយន្តោ អភិវស្សិ អមតម្ពុនា ។
ធម្មចក្កំ បវត្តេន្តេ ផុស្សេ នក្ខត្តមង្គលេ
អសីតិសតសហស្សានំ បឋមាភិសមយោ អហុ ។
នវុតិសតសហស្សានំ ទុតិយាភិសមយោ អហុ
អសីតិសតសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ ផុស្សស្ស ច មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
សដ្ឋិសតសហស្សានំ បឋមោ អាសិ សមាគមោ
បញ្ញាសសតសហស្សានំ ទុតិយោ អាសិ សមាគមោ ។

# បុស្សពុទ្ធវង្ស ទី ១៨

(១៩) ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តា ព្រះនាមបុស្សៈ ទ្រង់មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរ ក្នុងលោក ។ ព្រះពុទ្ធអង្គនោះ ទ្រង់កំចាត់បង់ងងឹតទាំងអស់ ហើយត្រដោះគ្រឿងចាក់ស្រែះធំ (កិលេស) ទ្រង់ញ៉ាំងមនុស្សព្រមទាំងទេវតា ឲ្យឆ្អែតស្កប់ស្កល់ ទ្រង់បង្អុរភ្លៀងទឹកអម្រឹតចុះមក ។ កាលព្រះពុទ្ធ ព្រះនាមបុស្សៈ ញ៉ាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ ៨០ សែន ក្នុងមណ្ឌលនៃថ្ងៃនក្ខត្តឫក្ស ។ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ៩០ សែន ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ សែន ។ ព្រះមហេសី ព្រះនាមបុស្សៈ មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិលគឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានព្រះខីណាស្រព ៦០ សែន សន្និបាតលើកទី ២ មានព្រះខីណាស្រព ចំនួន ៥០ សែន ។

អដ្ឋារសមោ បុស្សវំសោ

ចត្តាឡីសសតសហស្សានំ តតិយោ អាសិ សមាគមោ
អនុបាទា វិមុត្តានំ វោច្ឆិន្នបដិសន្ធិនំ ។
អហន្តេន សមយេន វិជិតោ នាម(១) ខត្តិយោ
ឆឌ្ឌយិត្វា មហារជ្ជំ បព្វជឹ តស្ស សន្តិកេ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ ផុស្សោ លោកគ្គនាយកោ
ទ្វេនវុតេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។

---

១ ឱ. ម. វិជិតាវី នាម ។

## បុស្សពុទ្ធវង្ស ទី ១៨

សន្និបាតលើកទី ៣ មានពួកព្រះខីណាស្រព ៥០ សែន លោកផុតស្រឡះហើយ ព្រោះមិនប្រកាន់ មានដំណាគីជាតិ កាត់ផ្តាច់ហើយ ៗ សម័យនោះ តថាគតជាក្សត្រ ព្រះនាមវិជិតៈ លះបោលរាជសម្បត្តិដ៏ធំ ទៅបួសក្នុងសំណាក់ព្រះពុទ្ធនោះ ៗ ព្រះពុទ្ធជាម្ចាស់ ព្រះនាមបុស្សៈ ជាលោក-គ្គនាយកនោះ បានទ្រង់ព្យាករតថាគតថា ក្នុងកប្បទី ៩២ អំពីកប្បនេះទៅ ភិក្ខុនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ៗ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីរីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ៗ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ៗ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចទៅឯគល់នៃពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ៗ

តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈ ដ៏ប្រសើរ ហើយត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជននី នៃព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ភិក្ខុនេះ ទ្រង់បានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ឧបតិស្សៈ ១ ទ្រង់ជាអគ្គសាវក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទ្រង់បម្រើព្រះជិនស្រីអង្គនេះ ។ ខេមាភិក្ខុនី ១ ឧប្បលវណ្ណាភិក្ខុនី ១ ទ្រង់ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទ្រង់ជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ទ្រង់ជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។

## អដ្ឋារសមោ បុស្សពុទ្ធវំសោ

ឥទំ សុត្វាន វចនំ  អសមស្ស មហេសិនោ
អាមោទិតា នរមរូ  ពុទ្ធពីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ  អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ  ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស  វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា  ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វតមធិដ្ឋាសឹ  ទសបារមិបូរិយា ។
សុត្តន្តំ វិនយញ្ចាបិ  នវង្គំ សត្ថុសាសនំ
សព្វំ បរិយាបុណិត្វាន  សោភយឹ ជិនសាសនំ ។
តត្ថប្បមត្តោ វិហរន្តោ  ព្រហ្មំ ភាវេត្វា ភាវនំ
អភិញ្ញាសុ បារមឹ គន្ត្វា  ព្រហ្មលោកមគញ្ឆហំ ។

## បុស្សពុទ្ធវង្ស ទី ១៨

ពួកមនុស្សនិងទេវតា លុះឮព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើហើយ ក៏រីករាយថា ភិក្ខុនេះ ជាពូជពន្ធក នៃព្រះពុទ្ធ ៗ សម្លេងហ៊ោក៏ប្រព្រឹត្តទៅ ពួកមនុស្សនិងទេវតា ទាំងមួយម៉ឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថ អង្គនេះ គង់នឹងសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតម នេះ ក្នុងកាលអនាគតមិនខាន ៗ ចំណែកខាងតថាគត បាន ស្ដាប់ព្រះពុទ្ធដីកា នៃព្រះបុស្សសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឲ្យ រឹងរឹតតែជ្រះថ្លា ហើយខំអធិដ្ឋានវត្តទៅទៀត ដើម្បីបំពេញ បារមីទាំង ១០ ប្រការ ៗ តថាគត រៀនយកនូវព្រះសូត្រផង ព្រះវិន័យផង ពាក្យប្រៀនប្រដៅព្រះសាស្ដា ប្រកបដោយអង្គ ៩ ទាំងអស់ផង ហើយញុំាងសាសនាព្រះជិនស្រីឲ្យរុងរឿង ៗ តថាគតមិនប្រមាទ សម្រេចសម្រាន្តនៅក្នុងសាសនានោះ ខំ ចម្រើនភាវនា ដែលប្រកបដោយព្រហ្មវិហារ ហើយដល់នូវ បារមីក្នុងអភិញ្ញាទាំងឡាយ ហើយទៅកើតក្នុងព្រហ្មលោក ៗ

កាសិកំ នាម នគរំ   ជយសេនោ នាម ខត្តិយោ
សិរិមា នាម ជនិកា   បុស្សស្ស ច មហេសិនោ ។
ឆវស្សសហស្សានិ   អគារំ អជ្ឈាវសិ សោ
គរុឡហំសសុវណ្ណតារា   តយោ បាសាទមុត្តមា ។
តេវីសតិសហស្សានិ   នារិយោ សមលង្កតា
កីសាគោតមី នាមាបិ   អានន្ទោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា   ហត្ថិយានេន និក្ខមិ
សត្តាហំ បធានចារំ   អចរិ បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ   បុស្សោ លោកគ្គ-
នាយកោ
វត្តចក្កោ មហាវីរេ   មិគទាយេ នរុត្តមោ ។
សុរក្ខិតោ ចន្ទសេនោ   អហេសុំ អគ្គសាវកា
សភិយោ នាមុបដ្ឋាកោ   បុស្សស្ស ច មហេសិនោ ។

ព្រះមហេសី ព្រះនាមបុស្សៈ មានទីក្រុង ឈ្មោះកាសិកៈ មានមហាក្សត្រ ព្រះនាមជយសេន ជាព្រះបិតា មានព្រះជននី ព្រះនាមសិរិមា ។ ព្រះបុស្សៈនោះ ទ្រង់គ្រប់គ្រងគេហដ្ឋាន អស់ ៩ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះគរុឡ ១ ប្រាសាទឈ្មោះហំសៈ ១ ប្រាសាទឈ្មោះសុវណ្ណតារៈ ១ ។ ពួកនារី ៦៣ ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនារី ជាអគ្គមហេសី ឈ្មោះកីសាគោតមី ព្រះរាជបុត្រឈ្មោះអានន្ទ ។ ព្រះជិនស្រី ជាបុរសដ៏ប្រសើរ ទ្រង់ទតឃើញនិមិត្តទាំង ៤ យ៉ាង ហើយចេញទៅដោយយានដំរី បានប្រព្រឹត្តធ្វើព្យាយាម អស់ ៧ ថ្ងៃ ។ ព្រះលោកនាយក ព្រះនាមបុស្សៈ មានព្យាយាមធំ ទ្រង់ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញ៉ាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ នាព្រៃមិគទាយវ័ន ។ ព្រះសុរក្ខិតភិក្ខុ ១ ព្រះធម្មសេនភិក្ខុ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះសភិយៈ ជាឧបដ្ឋាក នៃព្រះមហេសី ព្រះនាមបុស្សៈ ។

## អដ្ឋារសមោ បុស្សពុទ្ធវំសោ

ចាលា ច ឧបចាលា ច   អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ   អាមលកោតិ វុច្ចតិ ។
អនញ្ជយោ វិសាខោ ច   អហេសុំ អគ្គុបដ្ឋកា
បទុមា សិរិនាគា ច   អហេសុំ អគ្គុបដ្ឋិកា ។
អដ្ឋបណ្ណាសរតនំ   សោបិ អច្ចុគ្គតោ មុនិ
សោភតិ សតរំសីវ   ឧឡុរាជាវ បូរិតោ ។
នវុតិវស្សសហស្សានិ   អាយុ វិជ្ជតិ តាវទេ
តាវតា តិដ្ឋមានោ សោ   តារេសិ ជនតំ ពហុំ ។
ឱវទិត្វា ពហូ សត្តេ   សន្តារេត្វា ពហូ ជនេ
សោបិ សត្ថា អតុលយសោ និព្វុតោ សោ សសាវកោ ។
បុស្សោ ជិនវរោ សត្ថា   សេណារាមម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ   តេសុ តេសុ បទេសតោតិ ។

បុស្សពុទ្ធវំសោ អដ្ឋារសមោ ។

## បុស្សពុទ្ធវង្ស ទី ១៨

នាងចាលាភិក្ខុនី ១ នាងឧបចាលាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា អាមលកព្រឹក្ស (ដើមកន្ទួតព្រៃ) ។ អនញ្ញគហបតី ១ វិសាខគហបតី១ ជាអគ្គឧបដ្ឋាក នាងបទុមា ១ នាងសិរិនាគា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមុនីអង្គនោះ មានកំពស់ ៥៨ ហត្ថ ទ្រង់រុងរឿងដូចព្រះអាទិត្យ ឬដូចព្រះចន្ទ្រពេញវង់ ។ ទ្រង់មានព្រះជន្ម ៩០ ពាន់ឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានចម្លងប្រជុំជនជាច្រើន ។ ព្រះសាស្ដាអង្គនោះព្រមទាំងសាវ័ក ទ្រង់មានយសថ្លឹងពុំបាន ទ្រង់ទូន្មានពួកសត្វជាច្រើន ហើយចម្លងពួកសត្វជាច្រើន រួចបរិនិព្វាន ។ ព្រះជិនស្រីដ៏ប្រសើរ ព្រះនាមបុស្សៈ ទ្រង់ជាសាស្ដា បរិ-ព្វានហើយក្នុងសេនារាម ការផ្សាយចេញទៅ នៃព្រះធាតុមានក្នុងប្រទេសទាំងឡាយនោះ ៗ ។

ចប់ បុស្សពុទ្ធវង្ស ទី ១៨ ។

# ឯកូនវីសតិមោ វិបស្សីពុទ្ធវំសោ

(២០) ផុស្សស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
វិបស្សី នាម នាមេន លោកេ ឧប្បជ្ជិ ចក្ខុមា ។
អវិជ្ជណ្ឌំ បទាលេត្វា បត្តោ សម្ពោធិមុត្តមំ
ធម្មចក្កំ បវត្តេតុំ បក្កាមិ ពន្ធុមតីបុរំ ។
ធម្មចក្កំ បវត្តេត្វា ឧភោ ពោធេសិ នាយកោ
គណនាយ ន វត្តព្វោ បឋមាភិសមយោ អហុ ។
បុនាបរំ អមិតយសោ តត្ថ សច្ចំ បកាសយិ
ចតុរាសីតិសហស្សានំ ទុតិយាភិសមយោ អហុ ។
ចតុរាសីតិសហស្សានិ សម្ពុទ្ធមនុបព្វជុំ
តេសមារាមបត្តានំ ធម្មំ ទេសេសិ ចក្ខុមា ។

# វិបស្សីពុទ្ធវង្ស ទី ១៩

(២០) ក្រោយអំពីព្រះពុទ្ធ ព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ដ៏ឧត្តមជាងសត្វជើងពីរ ទ្រង់មានចក្ខុ កើតឡើង ក្នុងលោក ។ ព្រះអង្គទ្រង់រំលាយស៊ុត គឺអវិជ្ជាចេញ ហើយដល់សម្ពោធិញ្ញាណដ៏ឧត្តម ទ្រង់ចៀសចេញទៅកាន់ពន្ធុមតីបុរី ដើម្បីញុាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ ។ ព្រះនាយក ទ្រង់ញុាំងចក្រគឺធម៌ ឲ្យប្រព្រឹត្តទៅ រួចហើយញុាំងខណ្ឌរាជកុមារនិងតិស្សកុមារទាំងពីរ ឲ្យត្រាស់ដឹង ការត្រាស់ដឹងលើកទី ១ មានចំនួនសត្វ គេមិនគប្បីរាប់ដោយការរាប់ឡើយ ។ តមកទៀត ព្រះពុទ្ធជាម្ចាស់ មានយសរាប់មិនបាន ប្រកាសសច្ចៈទាំង ៤ ក្នុងបុរីនោះ ការត្រាស់ដឹងលើកទី ២ មានពួកសត្វ ចំនួន ៨ ហ្មឺន ៤ ពាន់ ។ មានមនុស្ស ៨ ហ្មឺន ៤ ពាន់ បួសតាមព្រះពុទ្ធ ព្រះពុទ្ធមានចក្ខុ ទ្រង់សម្តែងធម៌ដល់បព្វជិតទាំងនោះ ដែលមកដល់អារាម ។

## ឯកូនវីសតិមោ វិបស្សិពុទ្ធវំសោ

សព្វាការេន ភាសតោ ឋត្វា(១) ឧបនិស្សា ជិនោ
តេបិ ជម្ពុវំ កត្វា តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ វិបស្សិស្ស មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
អដ្ឋសដ្ឋិសតសហស្សានំ(២) បឋមោ អាសិ សមាគមោ
ភិក្ខុសតសហស្សានំ ទុតិយោ អាសិ សមាគមោ ។
អសីតិភិក្ខុសហស្សានំ តតិយោ អាសិ សមាគមោ
ឥត្ថ ភិក្ខុគណមជ្ឈេ សម្ពុទ្ធោ អតិរោចតិ ។
មហាន្តេន សមយេន នាគរាជា មហិទ្ធិកោ
អតុលោ នាម នាមេន បុញ្ញវន្តោ ជុតិន្ធរោ ។
នេកានំ នាគកោដីនំ បរិវារេត្វានហំ តទា
វជ្ជន្តោ ទិព្វតុរិយេហិ លោកជេដ្ឋំ ឧបាគមឹ ។

---

១ ឱ. ម. សុត្វា ។ ២ ឱ. អដ្ឋសដ្ឋិសហស្សានំ ។

## វិបស្សិពុទ្ធវង្ស ទី ១៩

ភិក្ខុទាំងនោះ អាស្រ័យព្រះជិនស្រី កាលទ្រង់សម្តែងដោយ អាការទាំងពួង ក៏បានសម្រេចនូវធម៌ដ៏ប្រសើរ នេះជាការត្រាស់ដឹងលើកទី ៣ ។ ព្រះមហេសី ព្រះនាមវិបស្សី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែពួកព្រះខីណាស្រព ឥតមានមន្ទិលគឺកិលេស មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ គឺសន្និបាតលើកទី ១ មានពួកព្រះខីណាស្រព ចំនួន ៦៨ សែន សន្និបាតលើកទី ២ មានពួកព្រះខីណាស្រព ចំនួនមួយសែន ។ សន្និបាតលើកទី ៣ មានភិក្ខុចំនួន ៨ ហ្មឺន ព្រះសម្ពុទ្ធរុងរឿងក្នុងកណ្តាលពួកភិក្ខុនោះ ។ សម័យនោះ តថាគតកើតជាស្តេចនាគ ឈ្មោះអតុល: មានឫទ្ធិច្រើន មានបុណ្យ ទ្រទ្រង់ពន្លឺ ។ ក្នុងកាលនោះ តថាគត មានពួកនាគច្រើនកោដិ ហោមរោម ប្រគំតូរ្យតន្ត្រីដ៏ជាទិព្វ ហើយចូលទៅជិតព្រះលោកជេដ្ឋ: ។

ឧបសង្កមិត្វាន សម្ពុទ្ធំ  វន្ទិស្សំ លោកនាយកំ
មណិមុត្តារតនខចិតំ  សព្វាភរណវិភូសិតំ
និម្មេត្វា ធម្មរាជស្ស  សុវណ្ណបីឋមទាសហំ ។
សោបិ មំ ពុទ្ធោ ព្យាកាសិ សង្ឃមជ្ឈេ និសីទិយ
ឯកនវុតិ ឥតោ កប្បេ  អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា  និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន  កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ  និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ  នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ  បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន  ពោធិមូលម្ហិ ឯហិតិ ។

លុះចូលទៅដល់ហើយ ក៏និមន្តព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ហើយថ្វាយតាំងមាស ដែលដាំដោយកែវ-មណី និងកែវមុក្តា ដ៏ស្អិតស្អាងហើយដោយអាភរណៈគ្រប់យ៉ាង ដល់ព្រះអង្គជាធម្មរាជ ។ ព្រះពុទ្ធជាម្ចាស់នោះ ទ្រង់គង់នៅក្នុងកណ្តាលសង្ឃ ហើយព្យាករតថាគតថា ក្នុងកប្បទី ៩១ អំពីមណ្ឌកប្បនេះ ស្តេចនាគនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីកបិលពស្តុបុរី ជាទីត្រេក-អរ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះនឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ។

## ឯកូនវីសតិមោ វិបស្សីពុទ្ធវំសោ

តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថមូលេ សម្ពោធឹ ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

## វិបស្សីពុទ្ធវង្ស ទី ១៩

លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈ ដ៏ប្រសើរ ហើយត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់នៃ អស្សត្ថព្រឹក្ស ៗ ព្រះជននី នៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ នាគរាជនេះ ទឹងបានត្រាស់ ជាព្រះពុទ្ធ ព្រះនាមគោតម ៗ ព្រះកោលិតៈ ១ ព្រះឧប-តិស្សៈ ១ ទឹងជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាស ចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទឹងបម្រើព្រះជិនស្រីអង្គនេះ ៗ នាងខេមាភិក្ខុនី ១ នាងឧប្បលវណ្ណាភិក្ខុនី ១ ទឹងជាអគ្គសាវិកា សុទ្ធតែមិនមាន អាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ៗ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានជោគអង្គនោះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទឹងជាអគ្គ-ឧបដ្ឋាក ៗ នាងនន្ទមាតា ១ នាងឧត្តរា ១ ទឹងជាអគ្គឧបដ្ឋា-យិកា ព្រះមហេសីព្រះនាមគោតមនោះ មានជន្មាយុ ១០០ ឆ្នាំ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

ឥទំ សុត្វាន វចនំ　　អសមស្ស មហេសិនោ
អាមោទិតា នរមរូ　　ពុទ្ធពីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ　　អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ　　ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស　　វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ　　ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទី តរន្តា　　បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន　　ឧត្តរន្តិ មហានទី ។
ឯវមេវ មយំ សព្វេ　　យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ　　ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា　　ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ　　ទសបារមិបូរិយា ។

ពួកមនុស្សទាំងទេវតា លុះបានស្តាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ហើយរីករាយថា នាគរាជនេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ សម្លេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថអង្គនេះ គង់នឹងសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក្នុងអនាគតកាល ជាមិនខាន ៗ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ៗ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់បានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ក្នុងអនាគតកាល យ៉ាងនោះដែរ ៗ តថាគតបានស្តាប់ព្រះពុទ្ធដីកា នៃព្រះជិនស្រីអង្គនោះ ហើយញុំាងចិត្តឲ្យរឹងរឹតតែជ្រះថ្លា បានខំអធិដ្ឋានវត្តទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ៗ

## ឯកូនវីសតិមោ វិបស្សីពុទ្ធវំសោ

នគរំ ពន្ធុមតី នាម    ពន្ធុមោ នាម ខត្តិយោ
មាតា ពន្ធុមតី នាម    វិបស្សិស្ស មហេសិនោ ។
អដ្ឋវស្សសហស្សានិ    អគារំ អជ្ឈាវសិ សោ
នន្ទោ សុនន្ទោ សិរិមា    តយោ បាសាទមុត្តមា ។
តិចត្តារីសហស្សានិ    នារិយោ សមលង្កតា
សុទស្សនា នាម នារី    សមវត្តក្ខន្ធោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា    រថយានេន និក្ខមិ
អនូនអដ្ឋមាសានិ    បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ    វិបស្សី លោកនាយកោ
វត្តចក្កោ មហាវីរោ    មិគទាយេ នរុត្តមោ ។
ខណ្ឌោ ច តិស្សនាមោ ច    អហេសុំ អគ្គសាវកា
អសោកោ នាមុបដ្ឋាកោ    វិបស្សិស្ស មហេសិនោ ។

## វិបស្សីពុទ្ធវង្ស ទី ១៩

ព្រះមហេសីព្រះនាមវិបស្សី មានទីក្រុងឈ្មោះពន្ធុមតី មានមហាក្សត្រ ព្រះនាមពន្ធុមៈ ជាព្រះបិតា មានព្រះមាតា ព្រះនាមពន្ធុមតី ៗ ព្រះវិបស្សីអង្គនោះ ទ្រង់គ្រប់គ្រងគេហដ្ឋានអស់ ៨ ពាន់ឆ្នាំ មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះនន្ទៈ១ ប្រាសាទឈ្មោះសុនន្ទៈ ១ ប្រាសាទឈ្មោះសិរិមៈ ១ ៗ ពួកនារី ចំនួន ៤ ហ្មឺន ៣ ពាន់ សឹងមានខ្លួនគាត់តែងល្អ ឯនារីជាអគ្គមហេសី ព្រះនាមសុទស្សនា ព្រះរាជបុត្រ ព្រះនាមសមវត្តក្ខន្ធ ៗ ព្រះជិនស្រីទ្រង់ឃើញនិមិត្ត ៤ ហើយចេញទៅដោយយានរថ តម្កល់ព្យាយាម អស់ ៨ ខែគត់ ៗ ព្រះវិបស្សីជាលោកនាយក ទ្រង់មានព្យាយាមធំប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ៗ ព្រះរាជកុមារនាមខណ្ឌៈ ១ បុត្រនៃបុរោហិតនាមតិស្សៈ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះអសោក ជាឧបដ្ឋាក នៃព្រះមហេសី ព្រះនាមវិបស្សី ៗ

ចន្ទា ច ចន្ទមិត្តា ច    អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ    ចាដលីតិ បវុច្ចតិ ។

បុនព្វសុមិត្តោ នាគោ ច    អហេសុំ អគ្គុបដ្ឋកា
សិរិមា ឧត្តរា ចេវ    អហេសុំ អគ្គុបដ្ឋិកា ។

អសីតិហត្ថមុព្វេធោ    វិបស្សី លោកនាយកោ
បភា និទ្ធាវតី តស្ស    សមន្តា សត្តយោជនេ ។

អសីតិវស្សសហស្សានិ    អាយុ ពុទ្ធស្ស តាវទេ
តាវតា តិដ្ឋមានោ សោ    តារេសិ ជនតំ ពហុំ ។

ពហុទេវមនុស្សានំ    ពន្ធនំ បរិមោចយិ
មគ្គាមគ្គញ្ច អាចិក្ខិ    អវសេសបុថុជ្ជនេ ។

អាលោកំ ទស្សយិត្វាន    ទស្សេត្វា អមតំ បទំ
ជលិត្វា អគ្គិក្ខន្ធោវ    និព្វុតោ សោ សសាវកោ ។

នាងបទុមាភិក្ខុនី ១ នាងបទុមមិត្តាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ ហៅថា បាដលិព្រឹក្ស ។ បុទុមសុមិត្តគហបតី ១ នាគគហបតី ១ ជាអគ្គឧបដ្ឋាក នាងសិរិមា ១ នាងឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះវរបស្ស លោកនាយក មានកំពស់ ៨០ ហត្ថ ពន្លឺព្រះអង្គផ្សាយចេញទៅជុំវិញ ៧ យោជន៍ ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានព្រះជន្ម ៨ ម៉ឺនឆ្នាំ ព្រះអង្គកាលទ្រង់ធរមាននៅឡើយ បានបម្លងប្រជុំជនច្រើន ចាកសំសារវដ្ត ។ ព្រះអង្គទ្រង់ដោះស្រាយនូវចំណងនៃទេវតានិងមនុស្សជាច្រើន ទាំងប្រាប់ផ្លូវត្រូវផ្លូវខុសចំពោះពួកបុថុជ្ជនដ៏សេសទៀតផង ។ ព្រះអង្គព្រមទាំងសាវ័កទ្រង់សម្តែងពន្លឺ ហើយបង្ហាញឧបាយ ជាទីទៅកាន់ព្រះនិព្វានឈ្មោះអមតៈ ទ្រង់រុងរឿងដូចគំនរភ្លើង ហើយបរិនិព្វាន ។

ឥទ្ធិវរំ បុញ្ញវរំ លក្ខណញ្ចកុសុមិតំ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ ។
វិបស្សី នរវរោ វីរោ សុមិត្តារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ថូបវរោ សត្តយោជនមុស្សិតោតិ ។

វិបស្សិពុទ្ធវំសោ ឯកូនវីសតិមោ ។

# វីសតិមោ សិខិពុទ្ធវំសោ

(២១) វិបស្សិស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
សិខិវ្ហយោ នាម ជិនោ អសមោ អប្បដិបុគ្គលោ ។
មារសេនំ បមទ្ទិត្វា បត្តោ សម្ពោធិមុត្តមំ
ធម្មចក្កំ បវត្តេសិ អនុកម្បាយ បាណិនំ ។
ធម្មចក្កំ បវត្តេន្តេ សិខិម្ហិ ជិនបុង្គវេ
កោដិសតសហស្សានំ បឋមាភិសមយោ អហុ ។

ព្រះសរីរៈ ដែលមានឫទ្ធិដ៏ខ្ពង់ខ្ពស់ មានបុណ្យដ៏ប្រសើរ ប្រដាប់ហើយដោយលក្ខណៈគឺចក្រ គង់បាត់បង់អស់ទៅបាន ឱហ្ន៎ ! សង្ខារទាំងអស់ សោះសូន្យ ទទេតើ ! ព្រះវិបស្សី ជានរៈដ៏ប្រសើរ ទ្រង់មានព្យាយាម បរិនិព្វានហើយ ក្នុងសុមិត្តារាម ព្រះស្តូបដ៏ប្រសើរ របស់ព្រះអង្គនោះ គេបាន សាងទុក កំពស់ ៧ យោជន៍ ក្នុងអារាមនោះ ។

ចប់ វិបស្សីពុទ្ធវង្ស ទី ១៩ ។

# សិខិពុទ្ធវង្ស ទី ២០

(២១) ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាម សិខីជិនស្រី ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ។ ព្រះអង្គកំចាត់បង់សេនានៃមារ ហើយដល់សម្ពោធិញ្ញាណដ៏ប្រសើរ ញុំាងចក្រគឺធម៌ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីអនុគ្រោះដល់ពួកសត្វ ។ កាលព្រះសិខីជិនស្រីដ៏ប្រសើរ ទ្រង់ញុំាងធម្មចក្រ ឲ្យប្រព្រឹត្តទៅ ការត្រាស់ដឹងលើកទី ១ មានពួកសត្វ ចំនួនមួយសែនកោដិ ។

អបរម្បិ ធម្មំ ទេសេន្តេ គណសេដ្ឋេ នរុត្តមេ
នវុតិកោដិសហស្សានំ ទុតិយាភិសមយោ អហុ ។
យមកប្បាដិហារិយំ ទស្សយន្តេ សទេវកេ
អសីតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ សិខិស្សាបិ មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
ភិក្ខុសតសហស្សានំ បឋមោ អាសិ សមាគមោ
អសីតិភិក្ខុសហស្សានំ ទុតិយោ អាសិ សមាគមោ ។
សត្តតិភិក្ខុសហស្សានំ តតិយោ អាសិ សមាគមោ
អនុបលិត្តោ បទុមំវ តោយម្ហិ សម្បវឌ្ឍិតំ ។
អហន្តេន សមយេន អរិន្ទមោ នាម ខត្តិយោ
សម្ពុទ្ធប្បមុខំ សង្ឃំ អន្នបានេន តប្បយឹ ។

កាលព្រះសិខី ប្រសើរជាងគណៈ ឧត្តមជាងជន ទ្រង់សម្ដែងធម៌ដទៃទៀត ការត្រាស់ដឹងលើកទី ២ មានពួកសត្វចំនួន ៩០ ពាន់កោដិ ។ កាលព្រះសិខី ទ្រង់សម្ដែងយមកបាដិហារ្យក្នុងមនុស្សលោក ព្រមទាំងទេវលោក ការត្រាស់ដឹងលើកទី ៣ មានពួកសត្វ ៨០ ពាន់កោដិ ។ ព្រះមហេសីព្រះនាមសិខី មានសាវកសន្និបាត ៣ លើក ដែលសុទ្ធតែជាពួកព្រះខីណាស្រព ឥតមានមន្ទិល មានចិត្តស្ងប់រម្ងាប់ ប្រកបដោយតាទិគុណ ។ សន្និបាតលើកទី ១ មានភិក្ខុចំនួនមួយសែនរូប សន្និបាតលើកទី ២ មានពួកភិក្ខុចំនួន ៨ ហ្មឺនរូប ។ សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៧ ហ្មឺនរូប ជាសមាគមមិនប្រឡាក់ (ដោយពួកបុថុជ្ជន) ដូចបទុមជាតិដែលលូតលាស់នៅក្នុងទឹក ។ សម័យនោះ តថាគតជាក្សត្រ នាមអរិន្ទមៈ បានញុំាងព្រះសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

## វីសតិមោ សិទីពុទ្ធំសោ

ពហុទុស្សរំ ទត្វា ទុស្សកោដី អនប្បកំ
អលង្កតំ ហត្ថិយានំ សត្ថុទ្ទស្ស អធាសហំ ។
ហត្ថិយានំ និម្មិនិត្វា កប្បិយំ ឧបនាមយឹ
បូរយឹ មានសំ មយ្ហំ និច្ចំ ទឡ្ហមុបដ្ឋិតំ ។
សោបិមំ ពុទ្ធោ ព្យាកាសិ សិទ្ធី លោកគ្គនាយកោ
ឯកត្តឹសេ ឥតោ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។

តថាគត បានប្រគេនសំពត់ជាច្រើន គឺកោដិនៃសំពត់មិនតិច ហើយថ្វាយយានដំរីដ៏ប្រដាប់ហើយ ដល់ព្រះសម្ពុទ្ធ ។ តថាគត សាងយានដំរី ហើយបង្អោនចូលទៅជិតឲ្យជារបស់គួរ បំពេញចិត្តរបស់តថាគត ឲ្យតម្កល់នៅមាំ អស់កាលជានិច្ច ។ ព្រះពុទ្ធ ព្រះនាមសិខី ជាលោកគ្គនាយកនោះ ទ្រង់ព្យាករតថាគតថា ក្នុងកប្បទី ៣១ អំពីមណ្ឌកប្បនេះ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញអំពីកបិលពស្តុបុរី ជាទីរីករាយ ទៅតម្កល់ព្យាយាម ធ្វើទុក្ករកិរិយា សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលយកបាយាសនៅទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានសោយបាយាស ទៀបច្នេរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ។

តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

អនាសវា វីតមលា សន្តចិត្តា សមាហិតា
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតមលា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណនោធិមណ្ឌ: ដ៏ប្រសើរ ហើយទ្រង់ត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះពុទ្ធនេះ ទ្រង់មានព្រះជននី ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ ព្រះរាជាអង្គនេះ ទ្រង់បានជាព្រះពុទ្ធ ព្រះនាមគោតម ។ ព្រះកោលិតៈ ១ ព្រះឧបតិស្សៈ ១ ទ្រង់ជាអគ្គសាវ័ក សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ ភិក្ខុជាឧបដ្ឋាក ឈ្មោះអានន្ទ ទ្រង់បំរើព្រះជិនស្រីអង្គនេះ ។ នាងខេមាភិក្ខុនី ១ ឧប្បលវណ្ណាភិក្ខុនី ១ ជាអគ្គសាវិកា សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ ។ ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនេះ ហៅថា អស្សត្ថព្រឹក្ស ចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទ្រង់ជាអគ្គឧបដ្ឋាក ។ នាងនន្ទមាតា ១ នាងឧត្តរា ១ ទ្រង់ជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ មានព្រះជន្ម ១០០ ឆ្នាំ ។

## វីសតិមោ សិខិពុទ្ធវំសោ

ឥទំ សុត្វាន វចនំ  អសមស្ស មហេសិនោ
អាមោទិតា នរមរូ  ពុទ្ធវីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ  អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ  ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស  វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទីតរន្តា  បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន  ឧត្តរន្តិ មហានទី ។
ឯវមេវ មយំ សព្វេ  យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា  ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ  ទសបារមិបូរិយា ។

## សិរីពុទ្ធវង្ស ទី ២០

ពួកមនុស្សនិងទេវតា លុះបានស្ដាប់ព្រះពុទ្ធដីកានេះ នៃព្រះមហេសី ឥតមានបុគ្គលស្មើ ហើយកែរាយថា ព្រះរាជាអង្គនេះ ជាពូជពន្លកនៃព្រះពុទ្ធ ៗ សម្លេងហ៊ោ ក៏ប្រព្រឹត្តទៅ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ នាំគ្នាទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផលក្នុងសាសនា នៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ ក្នុងអនាគតកាលមិនខាន ៗ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ខាងលើ គង់ទៅកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងបាន យ៉ាង·ណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមអង្គនេះ យ៉ាងនោះដែរ ៗ ឯតថាគត លុះបានស្ដាប់ព្រះពុទ្ធ-ដីកានៃព្រះអង្គនោះហើយ រឹងរឹតតែធ្វើចិត្តឲ្យជ្រះថ្លា ហើយបានចំអធិដ្ឋានវត្តតទៅ ដើម្បីបំពេញបារមីទាំង ១០ ប្រការ ៗ

នគរំ អរុណាវតី នាម អរុណោ នាម ខត្តិយោ
បភាវតី នាម ជនិកា សិខិស្ស ច មហេសិនោ ។
សត្តវស្សសហស្សានិ អគារំ អជ្ឈាវសិ សោ
សុវឌ្ឍកោ គិរិ នារីវាហនោ(១) តយោ បាសាទមុត្តមា ។
ចតុវីសតិសហស្សានិ នារិយោ សមលង្កតា
សព្វកាមា នាម សា នារី អតុលោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា ហត្ថិយានេន និក្ខមិ
អដ្ឋមាសំ បធានចារំ អចរិ បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ សិខី លោកគ្គនាយកោ
វត្តចក្កោ មហាវីរោ មិគទាយេ នរុត្តមោ ។
អភិភូ សម្ភវោ នាម អហេសុំ អគ្គសាវកា
ខេមង្ករោ នាមុបដ្ឋាកោ សិខិស្ស ច មហេសិនោ ។

---

១ ឱ. សុចន្ទោ គិរិវាហនោតិ ទិស្សតិ ។ ម. សុចន្ទកោ សិរិនាមវាសភ ភាតិ ទិស្សតិ ។

ព្រះមហេសី ព្រះនាមសិខី មានទីក្រុងឈ្មោះអរុណវតី មានព្រះមហាក្សត្រ ព្រះនាមអរុណៈ ជាព្រះបិតា មានព្រះជននី ព្រះនាមបភាវតី ។ ព្រះអង្គទ្រង់គ្រប់គ្រងគេហស្ថាន អស់ ៧ ពាន់ឆ្នាំ ទ្រង់មានប្រាសាទដ៏ប្រសើរ ៣ ខ្នង គឺប្រាសាទឈ្មោះសុវឌ្ឍកៈ ១ ប្រាសាទឈ្មោះគិរី ១ ប្រាសាទឈ្មោះនារីវាហនៈ ១ ។ ពួកនារីចំនួន ២ ហ្មឺន ៤ ពាន់ សឹងមានខ្លួនតាក់តែងល្អហើយ ឯនាងនារីជាអគ្គមហេសីនោះ ព្រះនាមសព្វកាមា ព្រះរាជបុត្រ ព្រះនាមអតុលៈ ។ (ព្រះតថាគត) ជាបុរសដ៏ឧត្តម ទ្រង់ឃើញនិមិត្តទាំង ៤ ហើយចេញទៅដោយយានដំរី បានប្រព្រឹត្តធ្វើព្យាយាម អស់ ៨ ខែគត់ ។ ព្រះសិខីលោកនាយក មានព្យាយាមដ៏ធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនាហើយ ទើបញ៉ាំងធម្មចក្រ ឲ្យប្រព្រឹត្តទៅក្នុងមិគទាយវ័ន ។ ព្រះមហេសី ព្រះនាមសិខី មានអភិភូភិក្ខុ ១ សម្ភវភិក្ខុ ១ ជាអគ្គសាវ័ក ភិក្ខុឈ្មោះខេមង្ករៈ ជាឧបដ្ឋាក ។

## វីសតិមោ សិខិពុទ្ធវំសោ

មខិណា ច(១) បទុមា ច    អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ    បុណ្ឌរីកោតិ វុច្ចតិ ។
សិរិវឌ្ឍោ ច នន្ទោ ច    អហេសុំ អគ្គុបដ្ឋកា
ចិត្តា ចេវ សុចិត្តា ច    អហេសុំ អគ្គុបដ្ឋិកា ។
ឧច្ចត្តនេន សោ ពុទ្ធោ    សត្តតិហត្ថមុគ្គតោ
កញ្ចនគ្ឃិកសង្កាសោ    ទ្វត្តឹសវរលក្ខណោ ។
តស្សាបិ ព្យាមប្បភា កាយា    និច្ឆរន្តិ(២) និរន្តរំ
ទិសោទិសំ និច្ឆរន្តិ    តីណិ យោជនានិ(៣) សោ បភា ។
សត្តតិំសសហស្សានិ    អាយុ តស្ស មហេសិនោ
តាវតា តិដ្ឋមានោ សោ    តារេសិ ជនតំ ពហុំ ។
ធម្មមេឃំ វស្សេត្វាន    តេមយិត្វា សទេវកេ
ខេមន្តំ បាបយិត្វាន    និព្ពុតោ សោ សសាវកោ ។

---

១ ឱ. អខិណា ចេវ ។ ម. សខិណា ច ។ ២ និច្ឆរតិ ។ ៣ យោជនសោ បភាតិ អដ្ឋកថាយំ ទិស្សន្តិ ។

## សិខីពុទ្ធវង្ស ទី ២០

នាងមខិលាភិក្ខុនី ១ នាងបទុមាភិក្ខុនី ១ ជាអគ្គសាវិកា ដើមឈើជាទីត្រាស់ដឹង នៃព្រះមានព្រះភាគអង្គនោះ គេហៅថា បុណ្ឌរីកព្រឹក្ស (ដើមស្វាយស) ។ សិរិវឌ្ឍគហបតី ១ នន្ទគហបតី ១ ជាអគ្គឧបដ្ឋាក នាងចិត្តា ១ នាងសុចិត្តា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះពុទ្ធអង្គនោះ ទ្រង់មានកំពស់ ៧០ ហត្ថ ប្រាកដស្មើដោយគ្រឿងមាស មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានពន្លឺប្រមាណមួយព្យាម ផ្សាយចេញអំពីព្រះកាយជានិច្ច ផ្សាយចេញទៅកាន់ទិសតូចនិងទិសធំ ក៏ចេញទៅចម្ងាយ ៣ យោជន៍ ។ ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ៧ ហ្មឺនឆ្នាំ ព្រះអង្គកាលទ្រង់គង់ធរមាននៅឡើយ បានញុំាងប្រជុំជនជាច្រើនឲ្យឆ្លង (ត្រើយសំសារវដ្ត) ។ ព្រះពុទ្ធនោះ ព្រមទាំងសាវ័កបង្ហូរភ្លៀងគឺធម៌ ស្រោចស្រប់ផ្សើមពួកមនុស្ស ព្រមទាំងទេវតា ធ្វើឲ្យដល់នូវសភាពក្សេមក្សាន្ត ហើយបរិនិព្វាន ។

អនុព្យញ្ជនសម្បន្នំ ទ្វត្តឹសវរលក្ខណំ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ ។
សិខី មុនិវរោ ពុទ្ធោ អស្សារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ថូបវរោ តិយោជនមុគ្គតោតិ ។

សិខិពុទ្ធវំសោ វីសតិមោ ។

# ឯកវីសតិមោ វេស្សភូពុទ្ធវំសោ

(២៦) តត្ថេវ មណ្ឌកប្បម្ហិ អសមោ អប្បដិបុគ្គលោ
វេស្សភូ នាម នាមេន លោកេ ឧប្បជ្ជិ សោ ជិនោ ។
អាទិត្តំ វត(១) រាគគ្គិ តណ្ហានំ វិជិតំ តទា(២)
នាគោវ ពន្ធនំ ឆេត្វា បត្តោ សម្ពោធិមុត្តមំ ។

---

១ ឱ. អាទិត្តំ តិប ។ ម. អាទិត្តំ វត ។ ២ ឱ. សទា ។ ម. តទា ។

ព្រះសរីរៈបរិបូណ៌ដោយអនុព្យញ្ជនៈ មានលក្ខណៈដ៏ប្រសើរ ៣២ ប្រការ គង់បាត់បង់សូន្យទាំងអស់ ទៅ ។ សង្ខារទាំងពួង ជារបស់ទទេ ទទេតែ ។ ព្រះសិរីសម្ពុទ្ធ ជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់បរិនិព្វាន ក្នុងអស្សារាម ព្រះស្តូបដ៏ប្រសើរ នៃព្រះអង្គនោះ គេបានសាងទុក កំពស់ ៣ យោជន៍ ក្នុងទីនោះឯង ។

ចប់ សិរិពុទ្ធវង្ស ទី ២០ ។

## វេស្សភូពុទ្ធវង្ស ទី ២១

[២២] ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រី ព្រះនាមវេស្សភូ ព្រះអង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើងក្នុងលោក ។ ព្រះជិនស្រីនោះ កាលជ្រាបច្បាស់ នូវលោកទាំង ៣ នេះ ដែលឆេះសព្វ ដោយភ្លើងគឺរាគៈផង នូវដែននៃតណ្ហាទាំងឡាយផង ទ្រង់កាត់នូវបំណងដូចដំរីដ៏ប្រសើរ ដល់នូវសម្ពោធិញាណដ៏ឧត្តម ។

## ឯកវីសតិមោ វេស្សភូពុទ្ធវំសោ

ធម្មចក្កំ បវត្តេសិ(១) វេស្សភូ លោកនាយកោ(២)
អសីតិកោដិសហស្សានំ បឋមាភិសមយោ អហុ ។
បក្កន្តេ ចារិកំ រដ្ឋេ លោកជេដ្ឋេ នរាសភេ
សត្តតិកោដិសហស្សានំ ទុតិយាភិសមយោ អហុ ។
មហាទិដ្ឋី វិនោទេន្តោ បាដិហេរំ ករោតិ សោ
សមាគតា នរមរូ ទសសហស្សី សទេវកេ ។
មហាអច្ឆរិយំ ទិស្វា អព្ភុតំ លោមហំសនំ
ទេវា ចេវ មនុស្សា ច ពុជ្ឈរេ សដ្ឋិកោដិយោ ។
សន្និបាតា តយោ អាសុំ វេស្សភុស្ស មហេសិនោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។
អសីតិកោដិសហស្សានំ បឋមោ អាសិ សមាគមោ
សត្តតិភិក្ខុសហស្សានំ ទុតិយោ អាសិ សមាគមោ ។

---

១ ឱ.ម. បវត្តេត្តេ ។ ២ ម. លោកនាយកេ ។

## វេស្សភូពុទ្ធវង្ស ទី ២១

ព្រះវេស្សភូ ជាលោកនាយក ទ្រង់សម្តែងធម្មចក្រ មានពួកបរិស័ទ ចំនួន ៨០ ពាន់កោដិ បានត្រាស់ដឹង ក្នុងគ្រាជាដំបូង ៗ កាលដែលព្រះលោកជេដ្ឋ ប្រសើរជាងពួកនរជនចៀសចេញទៅកាន់ចារិកក្នុងដែន មានពួកបរិស័ទ ចំនួន ៧០ ពាន់កោដិ បានត្រាស់ដឹង ក្នុងគ្រាទី ២ ៗ ព្រះជិនស្រីអង្គនោះ ទ្រង់បន្ទោបង់នូវមហាទិដ្ឋ ហើយធ្វើនូវបាដិហារ្យ ពួកមនុស្សនិងទេវតា ក្នុងមួយហ្មឺនលោកធាតុ ព្រមទាំងទេវលោក ក៏បានមកប្រជុំគ្នា ៗ ពួកទេវតានិងមនុស្ស ចំនួន ៦០ កោដិ ឃើញហេតុអស្ចារ្យ ដំចំឡែក ជាទីព្រឺរោមហើយក៏បានត្រាស់ដឹង (ក្នុងគ្រាទី ៣) ៗ ព្រះពុទ្ធព្រះនាមវេស្សភូស្វែងរកគុណដ៏ធំ មានសាវកសន្និបាត ៣ លើក សុទ្ធតែព្រះខីណាស្រព ប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ៗ គឺសន្និបាតលើកទី ១ មានភិក្ខុចំនួន ៨០ ពាន់កោដិ សន្និបាតលើកទី ២ មានភិក្ខុចំនួន ៧០ ពាន់កោដិ ៗ

សដ្ឋិភិក្ខុសហស្សានំ តតិយោ អាសិ សមាគមោ
ជកឌិកយភីតានំ ឱរសានំ មហេសិនោ ។
តស្ស ពុទ្ធស្ស អសមស្ស ចក្កំ វត្តិតមុត្តមំ
សុត្វាន បណីតំ ធម្មំ បព្វជ្ជមភិរោចយឹ ។
អហន្តេន សមយេន សុទស្សនោ នាម ខត្តិយោ(១)
អន្នបានេន វត្ថេន សសង្ឃំ ជិនមបូជយឹ ។
មហាទានំ បវត្តេត្វា រត្តិន្ទិវមតន្ទិតោ
បព្វជ្ជំ គុណសម្បន្នំ បព្វជឹ ជិនសន្តិកេ ។
អាចារគុណសម្បន្នោ វត្តសីលសមាហិតោ
សព្វញ្ញុតំ គវេសន្តោ រមាមិ ជិនសាសនេ ។
សទ្ធាបីតី ឧប្បាទេត្វា(២) ពុទ្ធំ វន្ទាមិ សត្ថារំ
បីតិ ឧប្បជ្ជតិ មយ្ហំ ពោធិយាយេវ ការណា ។

---

១ ម. ឥតោ បរំ និមន្តេត្វា មហាវីរំ ទានំ ទត្វា មហារហំ ឥតិ ទិស្សតិ ។ ២ ឱ. ម. ឧបគន្ត្វា ។ អដ្ឋកថាយំ ឦទិសោយេវ ។

សន្និបាតលើកទី ៣ មានពួកភិក្ខុចំនួន ៦០ ពាន់កោដិ ដែលភ័យតក់ស្លុតអំពីទុក្ខ មានជាដើម ជាឱរសរបស់ព្រះពុទ្ធ ស្វែងរកនូវគុណដ៏ធំ ៗ កាលព្រះសម្ពុទ្ធ មិនមានបុគ្គលស្មើ អង្គនោះ ទ្រង់សម្តែងធម្មចក្រដ៏ឧត្តម សម័យនោះ តថាគតជាក្សត្រ ឈ្មោះសុទស្សនៈ បានស្តាប់នូវធម៌ដ៏ប្រសើរហើយ ក៏ពេញចិត្តនឹងផ្នួស យ៉ាងក្រៃលែង បានបូជានូវព្រះជិនស្រី ព្រមទាំងព្រះសង្ឃ ដោយបាយទឹកនិងសំពត់ ៗ តថាគតញុំាងមហាទាន ឲ្យប្រព្រឹត្តទៅ ជាអ្នកមិនខ្ជិល ទាំងយប់ទាំងថ្ងៃ ហើយចូលទៅកាន់ផ្នួស ដែលបរិបូណ៌ដោយគុណក្នុងសំណាក់ព្រះជិនស្រី ៗ តថាគតបរិបូណ៌ដោយអាចារគុណ មានចិត្តតម្កល់ខ្ជាប់ក្នុងវត្តនិងសីល ស្វែងរកនូវសព្វញ្ញុតញ្ញាណ ត្រេកអរក្នុងសាសនានៃព្រះជិនស្រី ៗ តថាគតញុំាងសទ្ធានិងបីតិ ឲ្យកើតឡើង ហើយថ្វាយបង្គំព្រះសម្ពុទ្ធជាសាស្តា បីតិរបស់តថាគត ក៏កើតឡើង ព្រោះហេតុនៃការត្រាស់ដឹង ៗ

## ឯកវីសតិមោ វេស្សភូពុទ្ធវំសោ

អនិវត្តមានសំ ញត្វា  សម្ពុទ្ធោ ឯតទព្រវិ
ឯកត្តឹស ឥតោ កប្បេ  អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា  និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន  កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ  និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ  នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ  បាយាសំ អទ សោ ជិនោ
បដិយត្តវរមគ្គេន  ពោធិមូលមុបេហិតិ ។
តតោ បទក្ខិណំ កត្វា  ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ  ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា  មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម  អយំ ហេស្សតិ គោតមោ ។

## វេស្សភូពុទ្ធវង្ស ទី ២១

ព្រះសម្ពុទ្ធ ទ្រង់ជ្រាបចិត្តមិនវិលត្រឡប់ ហើយទ្រង់ត្រាស់ថា ក្នុងកប្បទី ៣១ អំពីកប្បនេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញពីក្រុងកបិលពស្តុ ជាទីរីក-រាយ ហើយតាំងសេចក្តីព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីអង្គនោះ បានឆាន់បាយាស ក្បែរស្ទឹងនេរញ្ជរា ហើយចូលទៅឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ។ លំដាប់នោះ ព្រះសម្ពុទ្ធមានយសធំ ធ្វើប្រទក្សិណនូវពោធិមណ្ឌ ដ៏ប្រសើរ ហើយនឹងត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះមាតាព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតាព្រះនាមសុទ្ធោទនៈ ស្តេចនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ។

កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។
នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

ព្រះថេរៈ ២ អង្គ គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទឹងជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ ទឹងជាឧបដ្ឋាក បម្រើព្រះជិនស្រីអង្គនេះ ។ ព្រះថេរី ឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ទឹងជាអគ្គសាវិកា ។ ដើមឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តគហបតី ១ ហត្ថាឡវកគហបតី ១ ទឹងបានជាអគ្គ-ឧបដ្ឋាក ។ ឧបាសិកា ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ទឹងជាអគ្គឧបដ្ឋាយិកា ព្រះសម្ពុទ្ធ ព្រះនាមគោតម មានយសអង្គនោះ មានព្រះជន្មមួយរយឆ្នាំ ។ ពួកទេវតានិងមនុស្ស បានស្តាប់នូវព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធ ទ្រង់រកបុគ្គលស្មើគ្មាន ស្វែងរកគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្សព្រមទាំងទេវតា ទាំងមួយហ្មឺនលោកធាតុ មានសម្រែងហ៊ោ ទះដៃ អបអរសាទរ ធ្វើអញ្ជលីនមស្ការថា

## ឯកវីសតិមោ វេស្សភូពុទ្ធវំសោ

យទិមស្ស លោកនាថស្ស  វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា  បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថំ គហេត្វាន  ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ  យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ  ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា  ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ  ទសបារមិបូរិយា ។
អនោមំ នាម នគរំ  សុប្បតិតោ នាម ខត្តិយោ
មាតា យសវតី នាម  វេស្សភុស្ស មហេសិនោ ។
ឆព្វស្សសហស្សានិ  អគារំ អជ្ឈាវសិ សោ
រុចិសុរតិវឌ្ឍកា  តយោ បាសាទមុត្តមា ។

## វេស្សភូពុទ្ធវង្ស ទី ២១

បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនានៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគតមិនខាន ៗ មនុស្សទាំងឡាយកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណាមិញ ៗ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះ ក៏គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ៗ តថាគតបានស្តាប់នូវព្រះពុទ្ធ-ដីកា នៃព្រះសាស្តានោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែងបានខំអធិដ្ឋានវត្តទៅ ដោយការបំពេញបារមីទាំង ១០ ៗ ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំ មាននគរឈ្មោះអនោម: មានព្រះមហាក្សត្រ ព្រះនាមសុប្បតិត: ជាព្រះបិតាមានព្រះមាតា ព្រះនាមយសវតី ព្រះអង្គគង់នៅគ្រប់គ្រងព្រះដំណាក់ អស់ ៦ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ គឺរុចិប្រាសាទ ១ សុរតិប្រាសាទ ១ វឌ្ឍកប្រាសាទ ១ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

អដ្ឋចត្តីសសហស្សានិ នារិយោ សមលង្កតា
សុចិត្តា នាម សា នារី សុប្បពុទ្ធោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា សិវិកាយាភិនិក្ខមិ
ឆម្មាសំ បធានចារំ អចរិ បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ វេស្សភូ លោកនាយកោ
វត្តចក្កោ(១) មហាវីរេ អរុណោបិ នរុត្តមោ(២) ។
សោណោ ច ឧត្តរោ ចេវ អហេសុំ អគ្គសាវកា
ឧបសន្តោ នាមុបដ្ឋាកោ វេស្សភុស្ស មហេសិនោ ។
រាមា(៣) ចេវ សមាលា នាម(៤) អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ មហាសាលោតិ វុច្ចតិ ។
សោត្ថិកោ ចេវ រម្មោ(៥) ច អហេសុំ អគ្គុបដ្ឋកា
គោតមី ច សិរិមា ច អហេសុំ អគ្គុបដ្ឋិកា ។

---

១ ខ. ម. វត្តិ បក្កំ ។ ២ ខ. អរុណាភវេ នរុត្តមេតិ ទិស្សតិ ។ ម. អរុណាភវេ នរុត្ត-មោតិ ទិស្សតិ ។ ៣ ខ. ទាមា ចេវ ។ ៤ ខ. ម. សមាលា ច ។ ៥ ម. រម្ភោ ។

ពួកនារីមិនខ្វះពី ៣០ ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមសុចិត្តា ព្រះរាជបុត្រ ព្រះនាមសុប្បពុទ្ធ ។ ព្រះសម្ពុទ្ធជាបុរសដ៏ឧត្តម បានឃើញនូវនិមិត្ត ៤ យ៉ាង ស្ដេចចេញដោយរថ បានប្រព្រឹត្តព្យាយាម អស់ ៦ ខែ ។ ព្រះវេស្សភូ ជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ មានចក្រគឺធម៌ប្រព្រឹត្តទៅ មានព្យាយាមធំ ឧត្តមជាងពួកជន ត្រូវមហាព្រហ្មអារាធនាហើយ ក្នុងអរុណារាម ។ ព្រះវេស្សភូសម្ពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈឈ្មោះសោណៈ ១ ឧត្តរៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះឧបសន្តៈ ជាឧបដ្ឋាក ។ ព្រះថេរីឈ្មោះពាមា ១ សមានា ១ ជាអគ្គសាវិកា ឯឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគអង្គនោះ គេតែងហៅថា មហាសាលព្រឹក្ស ។ ឧបាសក ឈ្មោះសោត្ថិកៈ ១ រម្មៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះគោតមី ១ សិរិមា ១ ជាអគ្គឧបដ្ឋាយិកា ។

## ឯកវីសតិមោ វេស្សភូពុទ្ធវំសោ

សដ្ឋិរតនមុព្វេធោ ហេមយូបសមូបមោ
កាយា និច្ឆរតិ រំសិ រត្តឹ បព្វតេ សិខី ។
សដ្ឋិវស្សសហស្សានិ អាយុ តស្ស មហេសិនោ(១)
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
ធម្មំ វិត្ថារិកំ កត្វា វិភជិត្វា មហាជនំ
ធម្មនាវំ ឋបេត្វាន និព្វុតោ សោ សសាវកោ ។
ទស្សនេយ្យំ សព្វជនំ វិហារំ ឥរិយាបថំ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ ។
វេស្សភូ ជិនវរោ សត្ថា ខេមារាមម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោតិ ។

វេស្សភូពុទ្ធវំសោ ឯកវីសតិមោ ។

---

១ ឱ. អាយុ វិជ្ជតិ តាវទេតិ ទិស្សតិ ។

## វេស្សភូពុទ្ធវង្ស ទី ២១

ស្មើមានកំពស់ ៦០ ហត្ថ មានរូបមាស្មើដោយប្រាសាទមាស ផ្សាយចេញពីព្រះកាយ ដូចអណ្តាតភ្លើងលើកំពូលភ្នំក្នុងវេលាយប់ ។ ព្រះសម្ពុទ្ធ ទ្រង់ស្វែងរកគុណដ៏ធំអង្គនោះ មានព្រះជន្មាយុ ៦ មុឺនឆ្នាំ ព្រះអង្គឋិតនៅអស់កាលត្រឹមនោះ ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង (ចាកសង្សារ) ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ញែកធម៌ធ្វើឲ្យពិស្តារ តម្កល់មហាជនក្នុងសំពៅគឺធម៌ ហើយបរិនិព្វាន ។ ជនទាំងអស់នោះ វិហារ និងឥរិយាបថ ជារបស់ដែលគេគប្បីរមិលមើល របស់ទាំងអស់នេះ វិនាសសាបសូន្យអស់ទៅ ឬ ! សង្ខារទាំងពួង ជារបស់ទទេ ទទេតែ ។ ព្រះជិនស្រីដ៏ប្រសើរ ព្រះនាម វេស្សភូ ជាសាស្តា បរិនិព្វានក្នុងខេមារាម ព្រះធាតុផ្សាយទៅ ក្នុងប្រទេសនោះៗ ។

ចប់ វេស្សភូពុទ្ធវង្ស ទី ២១ ។

# ទ្វាវីសតិមោ កកុសន្ធពុទ្ធវំសោ

(២៣) វេស្សភុស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
កកុសន្ធោ នាម នាមេន អប្បមេយ្យោ ទុរាសទោ ។
ឧគ្ឃាដេត្វា សព្វភវំ ចរិយាយ បារមិំ គតោ
សីហោវ បញ្ជរំ ភេត្វា បត្តោ សម្ពោធិមុត្តមំ ។
ធម្មចក្កំ បវត្តេន្តេ កកុសន្ធេ លោកនាយកេ
ចត្តាឡីសកោដិសហស្សានំ បឋមាភិសមយោ អហុ ។
អន្តលិក្ខម្ហិ អាកាសេ យមកំ កត្វា វិកុព្វនំ
តីសកោដិសហស្សានំ ពោធេសិ សទេវមានុសេ ។
នរទេវស្ស យក្ខស្ស ចតុសច្ចប្បកាសនេ
ធម្មាភិសមយោ តស្ស គណនាតោ អសង្ខិយោ ។
កកុសន្ធស្ស ភគវតោ ឯកោ អាសិ សមាគមោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ ។

# កកុសន្ធពុទ្ធវង្ស ទី ២២

(២៣) ក្នុងកាលជាក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មាន ព្រះសម្ពុទ្ធ ព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណរាប់មិនបាន គេគ្របសង្កត់បានដោយកម្រ ព្រះអង្គ រំលើងនូវភពទាំងពួង ដល់នូវបារមីដោយចរិយា ហើយសម្រេច នូវពោធិញាណដ៏ឧត្តម ដូចសីហៈទំលាយនូវទ្រុង ។ កាលព្រះ កកុសន្ធៈ ជាលោកនាយក ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ មាន ពួកបរិស័ទ ចំនួន ៤ ម៉ឺនកោដិ បានត្រាស់ដឹង ក្នុងគ្រាដំបូង ។ ព្រះកកុសន្ធៈ ទ្រង់ធ្វើនូវវិកុព្វនបាដិហារ្យ ជាគូ ៗ ឰដ៏អាកាស ញុំាងទេវតានិងមនុស្ស ៣ ម៉ឺនកោដិ ឲ្យត្រាស់ដឹង (នេះជាការ ត្រាស់ដឹងទី ២) ។ ក្នុងការប្រកាសនូវចតុសច្ចធម៌ នៃព្រះពុទ្ធ នោះ មានមនុស្សទេវតានិងយក្ស ត្រាស់ដឹងនូវធម៌ គេមិនអាច រាប់បាន (នេះជាការត្រាស់ដឹងទី ៣) ។ ព្រះមានជោគព្រះនាម កកុសន្ធៈ មានសាវកសន្និបាតតែមួយដង សុទ្ធតែជាព្រះខីណា- ស្រព មិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។

## ទ្វាវីសតិមោ កក្កុសន្ធពុទ្ធវំសោ

ចត្តាឡីសសហស្សានិ តទា អាសិ សមាគមោ
ទន្តភូមិមនុប្បត្តានំ អាសវារិគណក្ខយា ។

អហំ តេន សមយេន ខេមោ នាមាសិ ខត្តិយោ
តថាគតេ ជិនបុត្តេ ទានំ ទត្វា អនប្បកំ ។

បត្តញ្ច ចីវរំ ទត្វា អញ្ជនំ មធុលដ្ឋិកំ
ឥមេតំ បត្ថិតំ សព្វំ បដិយាទេមិ វរំ វរំ ។

សោបិ មំ មុនិ ព្យាកាសិ កក្កុសន្ធោ វិនាយកោ
ឥមម្ហិ ភទ្ទកេ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។

អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។

## កក្កុសន្ធពុទ្ធវង្ស ទី ២២

សាវកសមាគមក្នុងកាលនោះ មានពួកព្រះខីណាស្រព ៤ ម៉ឺន ដែលដល់នូវទន្តភូមិ ( ភូមិនៃបុគ្គលអ្នកមានខ្លួនទូន្មានហើយ ) ព្រោះអស់ទៅនៃកិលេសមានអាសវៈជាដើម ។ សម័យនោះ តថាគតជាក្សត្រ ឈ្មោះខេមៈ បានថ្វាយទានដ៏ច្រើន ចំពោះព្រះតថាគតនិងព្រះសង្ឃជាជិនបុត្ត ។ តថាគតបានចាត់ចែងថ្វាយបាត្រ ចីវរ ថ្នាំបន្តក់ និងដើមឈើអែម ទាំងអស់នេះជារបស់ប្រសើរក្រៃពេក ដែលតថាគតប្រាថ្នាហើយ ។ ព្រះមុនីកកុសន្ធៈ ជានាយកអគ្គនោះ ទ្រង់ព្យាករតថាគតថា ក្នុងភទ្ទកប្បនេះ ក្សត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ សត្វនេះ នឹងចេញចាកក្រុងកបិលពស្តុ ជាទីរីករាយ ហើយតម្កល់នូវព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ នឹងអង្គុយទៀបគល់នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ។

នេរញ្ជរាយ តីរម្ហិ បាយាសំ អទិ សោ ជិនោ

បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឧបេហិតិ ។

តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ

អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ

បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។

កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា

អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា

អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

ព្រះជិនស្រីនោះ ទ្រង់សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចសំដៅទៅ ឯគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែង ៗ លំដាប់នោះ ព្រះពុទ្ធមានយសធំ ធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយទ្រង់ត្រាស់ដឹងទៀប គល់អស្សត្ថព្រឹក្ស ៗ ព្រះមាតានៃព្រះពុទ្ធនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈ ក្សត្រនេះ ជាព្រះពុទ្ធ ព្រះនាមគោតម ៗ ព្រះថេរៈឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះអានន្ទ ជាឧបដ្ឋាកបម្រើព្រះជិនស្រីនេះ ៗ ព្រះថេរីឈ្មោះខេមា ១ ឧប្បល-វណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាអគ្គសាវិកា ៗ ឈើជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ៗ

## ទ្វាវីសតិមោ កកុសន្ធពុទ្ធវំសោ

នន្ទមាតា ច ឧត្តរា    អគ្គា ហេស្សន្តុបដ្ឋិកា
អាយុ វស្សសតំ តស្ស    គោតមស្ស យសស្សិនោ ។
ឥទំ សុត្វាន វចនំ    អសមស្ស មហេសិនោ ។
អាមោទិតា នរមរូ    ពុទ្ធវីជង្កុរោ អយំ ។
ឧក្កុដ្ឋិសទ្ទា វត្តន្តិ    អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ    ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស    វិរជ្ជិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
យថា មនុស្សា នទឹ តរន្តា    បដិតិត្ថំ វិរជ្ជិយ
ហេដ្ឋាតិត្ថេ គហេត្វាន    ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ    យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។

## កក្កុសន្ធពុទ្ធវង្ស ទី ២២

ឧបាសិកា ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ទឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតម មានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ៗ ពួកមនុស្សទិងទេវតា បានស្ដាប់ព្រះពុទ្ធដីកានេះ របស់ព្រះសម្ពុទ្ធទ្រង់មិនមានបុគ្គលស្មើ ស្វែងរកនូវគុណដ៏ធំហើយ ក៏រីករាយថា ក្សត្រអង្គនេះ ជាពូជពន្ធុកនៃព្រះពុទ្ធ ៗ ពួកមនុស្ស ព្រមទាំងទេវតា ទាំងមួយមុឺនលោកធាតុ មានសម្លេងហ៊ោ ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើយើងទឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ យើងគង់ទឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្ដាអង្គនេះ ក្នុងកាលជាអនាគត មិនខាន ៗ មនុស្សទាំងឡាយ កាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ គង់ទឹងកាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងនូវស្ទឹងធំបានដែរ យ៉ាងណាមិញ ៗ យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីអង្គនេះហើយ គង់តែទឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះសាស្ដាអង្គនេះ ក្នុងកាលជាអនាគតពុំខាន ក៏យ៉ាងនោះដែរ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ពុទ្ធវំសោ

តស្សាបិ វចនំ សុត្វា    ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ    ទសបារមិបូរិយា ។
នគរំ ខេមវតី នាម    ខេមោ នាមាសហំ តទា
សព្វញ្ញុតំ គវេសន្តោ    បព្វជឹ តស្ស សន្តិកេ ។
ព្រាហ្មណោ អគ្គិទត្តោ ច    អាសិ ពុទ្ធស្ស សោ បិតា
វិសាខា នាម ជនិកា    កកុសន្ធស្ស មហេសិនោ ។
វសតិ តត្ថ ខេមបុរេ    សម្ពុទ្ធស្ស មហាកុលំ
នរានំ បវរំ សេដ្ឋំ    ជាតិមន្តំ មហាយសំ ។
ចតុវស្សសហស្សានិ    អគារំ អជ្ឈាវសិ សោ
កាមវឌ្ឍកាមសុទ្ធិរតិវឌ្ឍនោ    តយោ បាសាទ-
មុត្តមា ។
សមត្តឹសសហស្សានិ    នារិយោ សមលង្កតា
រោចិនី នាម សា នារី    ឧត្តរោ នាម អត្រជោ ។

តថាគតស្តាប់ព្រះពុទ្ធដីកា របស់ព្រះពុទ្ធនោះហើយ ក៏ញ៉ាំងចិត្តឲ្យជ្រះថ្លាដោយក្រៃលែង បានអធិដ្ឋានវត្តទៅ ដោយការបំពេញបារមីទាំង ១០ ។ កាលនោះ នគរឈ្មោះខេមវតី ឯតថាគត ជាបុរសឈ្មោះខេមៈ ស្វែងរកនូវសព្វញ្ញុតញ្ញាណ បានបួសក្នុងសំណាក់នៃព្រះពុទ្ធអង្គនោះ ។ ព្រះពុទ្ធព្រះនាមកកុសន្ធៈ ទ្រង់ស្វែងរកនូវគុណដ៏ធំ មានអគ្គិទត្តព្រាហ្មណ៍ជាព្រះបិតា ព្រះមាតា ព្រះនាមវិសាខា ។ មហាត្រកូលរបស់ព្រះសម្ពុទ្ធ នៅក្នុងខេមបុរីនោះ ជាត្រកូលប្រសើរបំផុត មានជាតិខ្ពង់ខ្ពស់ មានយសធំ ជាងមនុស្សទាំងឡាយ ។ ព្រះកកុសន្ធៈអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងឃរាវាស អស់ ៤ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ គឺកាមវឌ្ឍប្រាសាទ ១ កាមសុទ្ធិប្រាសាទ ១ រតិវឌ្ឍនប្រាសាទ ១ ។ មាននារី ៣ ម៉ឺននាក់ មានខ្លួនប្រដាប់សមរម្យ ឯនារី ជាមហេសីនោះ ព្រះនាមរោចិនី ព្រះរាជបុត្រ ព្រះនាមឧត្តរៈ ។

## ទ្វាវីសតិមោ កក្កុសន្ធពុទ្ធវំសោ

និមិត្តេ ចតុរោ ទិស្វា　　រថយានេន និក្ខមិ
អនូនកំ អដ្ឋមាសំ　　បធានំ បទហី ជិនោ ។
ព្រហ្មុនា យាចិតោ សន្តោ　　កក្កុសន្ធោ លោក-
នាយកោ
វត្តចក្កោ មហាវីរោ　　មិគទាយេ នរុត្តមោ ។
វិធុរោ សញ្ជីវនាមោ ច　　អហេសុំ អគ្គសាវកា
ពុទ្ធិជោ នាមុបដ្ឋាកោ　　កក្កុសន្ធស្ស មហេសិនោ ។
សាមា ច ចម្បនាមា ច　　អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ　　សិរីសោតិ បវុច្ចតិ ។
អច្ចុគ្គតោ ច សុមនោ　　អហេសុំ អគ្គុបដ្ឋកា
នន្ទា ចេវ សុនន្ទា ច　　អហេសុំ អគ្គុបដ្ឋិកា ។
ចត្តាលីសរតនានិ　　អច្ចុគ្គតោ មហាមុនិ
កនកប្បភា និច្ឆរតិ　　សមន្តា ទសយោជនំ ។

## កក្កុសន្ធពុទ្ធវង្ស ទី ២២

ព្រះជិនស្រី ឃើញនូវនិមិត្តទាំង ៤ ទ្រង់ចេញទៅដោយរថយាន តម្កល់ទុកនូវព្យាយាម មិនលើសពី ៨ ខែ ។ ព្រះកកុសន្ធៈ ជាលោកនាយក មានព្រះទ័យស្ងប់រម្ងាប់ មានព្យាយាមធំ ទ្រង់ឧត្តមជាងពួកជន ត្រូវព្រហ្មអារាធនាហើយ ទើបញុំាងចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះកកុសន្ធៈ ស្វែងរកនូវគុណដ៏ធំ មានព្រះថេរៈ ឈ្មោះវិធុរៈ ១ សញ្ជីវៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះពុទ្ធិជៈ ជាឧបដ្ឋាក ។ ព្រះថេរី ឈ្មោះសាមា ១ ឈ្មោះចម្បា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថា សិរីសព្រឹក្ស (ដើមប្រេស) ។ ឧបាសកឈ្មោះអច្ចុគតៈ ១ សុមនៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះនន្ទា ១ សុនន្ទា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះមហាមុនីមានកំពស់ ៤០ ហត្ថ រស្មីដូចជាមាស ផ្សាយចេញទៅកាន់ទី ចម្ងាយ ១០ យោជន៍ ដោយជុំវិញ ។

ចត្តារីសវស្សសហស្សានិ អាយុ តស្ស មហេសិនោ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
ធម្មាបណំ បសារេត្វា នរនារីនំ សទេវកេ
នទិត្វា សីហនាទំវ និព្វុតោ សោ សសាវកោ ។
អដ្ឋង្គវចនសម្បន្នោ អច្ឆិទ្ទានិ និរន្តរំ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារា ។
កក្កុសន្ធោ ជិនវរោ ខេមារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ថូបវរោ គាវុតំ នភមុគ្គតោតិ ។

កក្កុសន្ធពុទ្ធវំសោ ទ្វាវីសតិមោ ។

# តេវីសតិមោ កោណាគមនពុទ្ធវំសោ

(២៤) កក្កុសន្ធស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
កោណាគមនោ នាម ជិនោ លោកជេដ្ឋោ នរាសភោ ។

ព្រះមហេសីនោះ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ព្រះអង្គគង់នៅ កំណត់ប៉ុណ្ណោះ ទ្រង់ញ៉ាំងប្រជុំជនដ៏ច្រើនឲ្យឆ្លង (ពាក-សង្សារ) ។ ព្រះសម្ពុទ្ធនោះ ព្រមទាំងសាវ័ក តាំងពនផ្សារ គឺព្រះសទ្ធម្ម បន្លឺឡើងដូចជាសីហនាទ បំពោះនរៈនិងនារីទាំងឡាយ ក្នុងមនុស្សលោក ព្រមទាំងទេវលោក ហើយនិព្វាន ។ ព្រះសម្ពុទ្ធបរិបូណ៌ដោយពាក្យ ប្រកបដោយអង្គ ៨ សីលទាំងឡាយមិនធ្លុះធ្លាយ ដាច់មិនដាច់ របស់ទាំងអស់វិនាសសូន្យទៅ ឱ! សង្ខារទាំងពួង ជារបស់មិនទៀង ទេតើ ។ ព្រះកកុសន្ធៈ ជាព្រះជិនស្រីដ៏ប្រសើរ និព្វានក្នុងខេមារាម ព្រះស្តូបដ៏ប្រសើររបស់ព្រះពុទ្ធនោះ មានកំពស់ទៅក្នុងអាកាសមួយគាវុត ក្នុងទីនោះឯង ។

ចប់ កកុសន្ធពុទ្ធវំស ទី ២២ ។

# កោនាគមនពុទ្ធវំស ទី ២៣

[២៤] កាលជាខាងក្រោយ អំពីព្រះកកុសន្ធៈមក មានព្រះជិនស្រីសម្ពុទ្ធ ព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ។

## តេវីសតិមោ កោណាគមនពុទ្ធវំសោ

ទសធម្មេ បូរយិត្វាន  កន្តារំ សមតិក្កមិ
បវាហាយ(១) មលំ សព្វំ  បត្តោ សម្ពោធិមុត្តមំ ។
ធម្មចក្កំ បវត្តេន្តេ  កោណាគមននាយកេ
តឹសកោដិសហស្សានំ  បឋមាភិសមយោ អហុ ។
បាដិហីរំ ករោន្តេ ច  បរវាទប្បមទ្ទនេ
វីសតិកោដិសហស្សានំ  ទុតិយាភិសមយោ អហុ ។
តតោ វិកុព្វនំ កត្វា  ជិនោ ទេវបុរំ គតោ
វសតិ តត្ថ សម្ពុទ្ធោ  សិលាយ បណ្ឌុកម្ពលេ ។
បករណេ សត្ត ទេសេន្តោ  វស្សំ វសតិ សោ មុនិ
ទសកោដិសហស្សានំ  តតិយាភិសមយោ អហុ ។
តស្សាបិ ទេវទេវស្ស  ឯកោ អាសិ សមាគមោ
ខីណាសវានំ វិមលានំ  សន្តចិត្តាន តាទិនំ ។

---

១ ឱ. ម. បវាហិយ ។

## កោនាគមនពុទ្ធវង្ស ទី ២៣

ព្រះសម្ពុទ្ធអង្គនោះ បានបំពេញបារមីធម៌ទាំង ១០ កន្លងផុតឆ្ងាយគឺជាតិ លះបង់មន្ទិលទាំងអស់ ដល់នូវសម្ពោធិញាណដ៏ឧត្តម ។ ព្រះកោនាគមនសម្ពុទ្ធ ជានាយក ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកសត្វចំនួន ៣ ម៉ឺនកោដិ បានត្រាស់ដឹងដំបូង ។ កាលទ្រង់ធ្វើបាដិហារិយ៍ ញុំាញីពាក្យត្មះតិះដៀលនៃជនដទៃ ពួកសត្វចំនួន ២ ម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ២ ។ លំដាប់ពីនោះ ព្រះជិនស្រីធ្វើនូវវិកុព្វនបាដិហារិយ៍ ហើយទ្រង់យាងទៅកាន់ទេវបុរី ព្រះសម្ពុទ្ធគង់នៅលើបណ្ឌុកម្ពលសិលា ក្នុងទេវលោកនោះ ។ ព្រះមុនីនោះកាលសម្តែងសត្តបករណាភិធម្ម គង់ចាំវស្សា (ក្នុងទេវលោក) ពួកសត្វចំនួនមួយម៉ឺនកោដិ បានត្រាស់ដឹងជាលើកទី ៣ ។ ព្រះពុទ្ធជាទេវតា ទ្រង់ប្រសើរជាងទេវតាអង្គនោះ ទ្រង់មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាពួកព្រះខីណាស្រពប្រាសចាកមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។

តឹសភិក្ខុសហស្សានំ តទា អាសិ សមាគមោ
ឱឃានមតិក្កន្តានំ(១) ភិជ្ជិតានញ្ច មច្ចុយា ។
អហន្តេន សមយេន បព្វតោ នាម ខត្តិយោ
មិត្តាមច្ចេហិ សម្បន្នោ ពលពាហនមប្បកំ(២) ។
សម្ពុទ្ធទស្សនំ គន្ត្វា សុត្វា ធម្មមនុត្តរំ
និមន្តេត្វា សជិនំ សង្ឃំ ទានំ ទត្វា យទិច្ឆកំ ។
បត្តុណ្ណំ(៣) ចីនបដញ្ច កោសេយ្យំ កម្ពលំបិ ច
សោវណ្ណបាទុកញ្ចេវ អទាសិំ សត្ថុ សាវកេ ។
សោបិ មំ មុនិ ព្យាកាសិ សង្ឃមជ្ឈេ និសីទិយ
ឥមស្មឹ ភទ្ទកេ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

---

១ ឱ. អតិក្កន្តចតុរោឃានន្តិ ទិស្សតិ ។ ២ ពលពាហនមនប្បកន្តិ អដ្ឋកថាយំ ទិស្សតិ ។
៣ បតុណ្ណន្តិ អដ្ឋកថាយំ ទិស្សតិ ។

សាវកសមាគមក្នុងកាលនោះ មានភិក្ខុ ៣ ម៉ឺន ដែលកន្លងឱឃៈ ផ្ដាច់បង់មច្ចុ ៗ សម័យនោះ តថាគតជាក្សត្រ ឈ្មោះបព្វតៈ បរិបូណ៌ដោយមិត្តនិងអាមាត្យ មានពលនិងពាហនៈច្រើន ៗ តថាគតទៅគាល់ព្រះសម្ពុទ្ធ ស្ដាប់ធម៌ដ៏ប្រសើរ ហើយនិមន្ត ព្រះសង្ឃព្រមទាំងព្រះជិនស្រី ថ្វាយទានតាមសេចក្ដីប្រាថ្នា ។ តថាគតបានថ្វាយវត្ថុ ៤ មុខ គឺសំពត់ចីនប្រទេស ១ សំពត់សូត្រ ១ សំពត់កម្ពល ១ ស្បែកជើងមាស ១ ចំពោះព្រះសាស្ដា ព្រមទាំងសាវ័ក ៗ ព្រះមុនីនោះ ទ្រង់គង់នៅក្នុងកណ្ដាលសង្ឃ ទ្រង់ព្យាករតថាគតថា មហាបុរសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកប្បនេះ ៗ សត្វនេះ នឹងចេញពីនគរកបិលពស្តុ ជាទីត្រេកអរ តាំងនូវព្យាយាម ធ្វើទុក្ករកិរិយា ៗ

## តេវីសតិមោ កោនាគមពុទ្ធវំសោ

អជបាលរុក្ខមូលស្មឹ   និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ   នេរញ្ជរមុបេហិតិ ។
នេរញ្ជរាយ តីរម្ហិ   បាយាសំ អទិ សោ ជិនោ
បដិយត្តវរមគ្គេន   ពោធិមណ្ឌម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា   ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ   ពុជ្ឈិស្សតិ មហាយសោ ។
ឥមស្ស ជនិកា មាតា   មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម   អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច   អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ   ឧបដ្ឋិស្សតិមំ ជិនំ ។
ខេមា ឧប្បលវណ្ណា ច   អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា ។

សត្វនេះ នឹងអង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាស ក្នុងទីនោះ ហើយចូលទៅកាន់ស្ទឹងនេរញ្ជរា ៗ ព្រះជិនស្រីអង្គនោះ បានឆាន់បាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយស្តេចសំដៅទៅឯពោធិមណ្ឌៈ តាមផ្លូវដ៏ប្រសើរ ដែលគេតាក់តែងហើយ ៗ លំដាប់នោះ មហាបុរស មានយសធំ នឹងធ្វើប្រទក្សិណពោធិមណ្ឌៈដ៏ប្រសើរ ហើយបានត្រាស់ដឹង ទៀបគល់អស្សត្ថព្រឹក្ស ៗ ព្រះមាតាបង្កើត របស់ព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទនៈក្សត្រអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ៗ ព្រះថេរៈ ឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវ័ក ព្រះថេរៈ ឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីអង្គនេះ ៗ ព្រះថេរី ឈ្មោះខេមា ១ ឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ នឹងជាអគ្គសាវិកា ៗ

បោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា នរមរូ ពុទ្ធពីជង្កុរោ អយំ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច

កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

យថា មនុស្សា នទី តរន្តា បដិតិត្ថំ វិរជ្ឈិយ

ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទី ។

ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឧបាសក ឈ្មោះបិត្តៈ ១ ហត្ថាឡវកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកា ឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធ រកបុគ្គលស្មើគ្មាន ស្វែងរកគុណដ៏ធំហើយ ក៏មានចិត្តរីករាយថា មហាបុរសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្សនិងទេវតា ទាំងមួយហ្មឺនលោកធាតុ មានសម្រែងហ៊ោឡើង ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថនេះ គង់នឹងសម្រេចចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលអនាគតមិនខាន ។ មនុស្សទាំង-ឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់កាន់យកនូវកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបាន យ៉ាងណា ។

## តេវីសតិមោ កោនាគមនពុទ្ធវំសោ

ឯវមេវ មយំ សព្វេ    យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ    ហេស្សាម សម្មុខា ឥមំ ។
តស្សាបិ វចនំ សុត្វា    ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ    ទសបារមិបូរិយា ។
សព្វញ្ញុតំ គវេសន្តោ    ទានំ ទត្វា នរុត្តមេ
ឱហាយាហំ មហារជ្ជំ    បព្វជឹ ជិនសន្តិកេ ។
នគរំ សោភវតី នាម    សោភោ នាមាសិ ខត្តិយោ
វសតិ តត្ថ នគរេ    សម្ពុទ្ធស្ស មហាកុលំ ។
ព្រាហ្មណោ យញ្ញទត្តោ ច    អាសិ ពុទ្ធស្ស សោ បិតា
ឧត្តរា នាម ជនិកា    កោនាគមនស្ស សត្ថុនោ ។
តីណិ វស្សសហស្សានិ    អគារំ អជ្ឈាវសិ សោ
តុសិតសន្តុសិតសន្តុដ្ឋា    តយោ បាសាទមុត្តមា ។

## កោនាគមនពុទ្ធវង្ស ទី ២៣

យើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងអនាគតកាល ក៏យ៉ាងនោះដែរ ។ តថាគតស្តាប់ព្រះពុទ្ធដីកា នៃព្រះសម្ពុទ្ធនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លា ដោយក្រៃលែង បានទំអធិដ្ឋានវត្តតទៅ ដោយការបំពេញនូវបារមីទាំង ១០ ។ តថាគតប្រសើរជាងជន កាលស្វែងរកសព្វញ្ញុតញ្ញាណ បានឲ្យទាន លះបង់រាជសម្បត្តិដ៏ធំ ហើយបួសក្នុងសំណាក់ព្រះជិនស្រី ។ មាននគរឈ្មោះសោភវតី ក្សត្រព្រះនាមសោភៈ ត្រកូលធំរបស់ព្រះពុទ្ធ នៅក្នុងនគរនោះ ។ ព្រាហ្មណ៍ ឈ្មោះយញ្ញទត្ត ( ជាព្រះបិតា ) នាងឧត្តរា ជាព្រះមាតា របស់ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនៈ ជាសាស្តានោះ ។ ព្រះសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅគ្រប់គ្រងព្រះដំណាក់ អស់ ៣ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ គឺ តុសិតប្រាសាទ ១ សន្តុសិតប្រាសាទ ១ សន្តុដ្ឋប្រាសាទ ១ ។

អឌ្ឍសោឡសសហស្សានិ នារិយោ សមលង្កតា
រុចិគត្តា នាម នារី សព្វកាមោ នាម អត្រជោ ។

និមិត្តេ ចតុរោ ទិស្វា ហត្ថិយានេន និក្ខមិ
ឆម្មាសំ បធានចារំ អចរិ បុរិសុត្តមោ ។

ព្រហ្មុនា យាចិតោ សន្តោ កោនាគមនោ លោក-
នាយកោ
វត្តចក្កោ មហាវីរោ មិគទាយេ នរុត្តមោ ។

ភិយ្យោសោ ឧត្តរោ នាម អហេសុំ អគ្គសាវកា
សោត្ថិជោ នាមុបដ្ឋាកោ កោនាគមនស្ស យស-
ស្សិនោ ។

សមុទ្ទា ឧត្តរា ចេវ អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ ឧទុម្ពរោតិ វុច្ចតិ ។

ឧគ្គោ ច សោមទេវោ ច អហេសុំ អគ្គុបដ្ឋកា
សីវលា ចេវ សាមា ច អហេសុំ អគ្គុបដ្ឋិកា ។

មាននារីមិនខ្វះពីមួយម៉ឺន ៦ ពាន់នាក់ មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសី ព្រះនាមរុចិគត្តា ព្រះរាជបុត្រ ព្រះនាម សត្ថវាហៈ ៗ បុរសដ៏ឧត្តមឃើញ នូវនិមិត្តទាំង ៤ យ៉ាង ហើយចេញទៅដោយយានដំរី បានប្រព្រឹត្តព្យាយាម អស់ ៦ ខែ ៗ ព្រះកោនាគមនៈ ជាលោកនាយក មានព្រះទ័យស្ងប់ រម្ងាប់ មានព្យាយាមធំ ប្រសើរជាងជន ត្រូវព្រហ្មអារាធនា ហើយ ទើបទ្រង់ញុំាងចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ៗ ព្រះពុទ្ធ ព្រះនាមកោនាគមនៈ ដ៏មានយស មានព្រះថេរៈ ឈ្មោះភិយ្យោសៈ ១ ឧត្តរៈ ១ ជាអគ្គសាវ័ក ព្រះថេរៈ ឈ្មោះ សោត្ថិជៈ ជាឧបដ្ឋាក ៗ ព្រះថេរី ឈ្មោះសមុទ្ទា ១ ឧត្តរា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង នៃព្រះមានព្រះភាគ អង្គនោះ គេហៅថា ឧទុម្ពរព្រឹក្ស (ដើមល្វា) ៗ ឧបាសក ឈ្មោះឧគ្គៈ ១ ឈ្មោះសោមទេវៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកា ឈ្មោះសីវលា ១ ឈ្មោះសាមា ១ ជាអគ្គឧបដ្ឋាយិកា ៗ

## តេវីសតិមោ កោនាគមនពុទ្ធវំសោ

ឧច្ចត្តនេន សោ ពុទ្ធោ តឹសហត្ថសមុគ្គតោ
ឧក្កាមុខេ យថា តម្ពំ(១) ឯវំ រំសីហិ មណ្ឌិតោ ។

តឹសវស្សសហស្សានិ អាយុ ពុទ្ធស្ស តាវទេ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។

ធម្មចេតិយំ សមុស្សេត្វា ធម្មទុស្សវិភូសិតំ
ធម្មបុប្ផគុឡំ កត្វា និព្វុតោ សោ សសាវកោ ។

មហាវិលាសោ តស្ស ជនោ សិរិធម្មប្បកាសនោ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារា ។

កោនាគមនោ សម្ពុទ្ធោ បព្វតារាមម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ តេសុ តេសុ បទេសតោ ។

កោនាគមនពុទ្ធវំសោ តេវីសតិមោ ។

---

១ ម. កម្ពុ ។

## កោនាគមនពុទ្ធវង្ស ទី ២៣

ព្រះពុទ្ធនោះ មានកំពស់ ៣០ ហត្ថ ប្រដាប់ដោយរស្មីយ៉ាងនេះ ដូចជាមាសក្នុងមាត់នៃបាវ ។ ព្រះពុទ្ធមានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ជាកំណត់ ព្រះអង្គឋិតនៅ កំណត់ត្រឹមនោះ ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង (ចាកសង្សារ) ។ ព្រះពុទ្ធអង្គនោះ ព្រមទាំងសាវ័ក លើកឡើងនូវធម្មចេតិយ ស្អិតស្អាងដោយសំពត់គឺធម៌ ធ្វើទៅកម្រងផ្កាគឺធម៌ ហើយបរិនិព្វាន ។ ជនជាសាវ័ក របស់ព្រះពុទ្ធនោះ សម្តែងនូវធម៌ដ៏មានសិរីដល់នូវឫទ្ធិដ៏ធំទូលាយ របស់ទាំងអស់នេះ វិនាសសូន្យទៅឱ ! សង្ខារទាំងពួង ជារបស់ទទេ ទទេតើ ។ ព្រះសម្ពុទ្ធ ព្រះនាមកោនាគមនៈ និព្វានក្នុងបព្វតារាម ព្រះធាតុផ្សាយទៅក្នុងទីនោះ ៗ តាមចំណែក ។

ចប់ កោនាគមនពុទ្ធវង្ស ទី ២៣ ។

# ចតុវីសតិមោ កស្សបពុទ្ធវំសោ

(២៥) កោណាគមនស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
កស្សបោ នាម នាមេន ធម្មរាជា បភង្ករោ ។
ស ឆឌ្ឌិតំ កុលមូលំ ពហ្វន្នំ ចាណារុជិតំ(១)
ទត្វាន យាចកេ(២) ទានំ បូរយិត្វាន មានសំ
ឧសភោវាឡ្ហកំ ភេត្វា បត្តោ សម្ពោធិមុត្តមំ ។
ធម្មចក្កំ បវត្តេន្តេ កស្សបេ លោកនាយកេ
វីសតិកោដិសហស្សានំ បឋមាភិសមយោ អហុ ។
ចតុម្មាសំ យទា ពុទ្ធោ លោកេ ចរតិ ចារិកំ
ទសកោដិសហស្សានំ ទុតិយាភិសមយោ អហុ ។
យមកំ វិកុព្វនំ កត្វា ញាណធាតុំ បកិត្តយិ
បញ្ចកោដិសហស្សានំ តតិយាភិសមយោ អហុ ។

---

១ ឱ.ម. បានភោជនំ ។ ២ យាចកេតិ អដ្ឋកថាយ ទិស្សតិ ។ យាចកេតិ យាចកានំ
ទត្វាតិ អត្ថោ ។

# កស្សបពុទ្ធវង្ស ទី ២៤

[៦៥] កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមកោនាគមនៈមក មានព្រះសម្ពុទ្ធ ព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ ជាធម្មរាជ ទ្រង់ធ្វើពន្លឺ ។ ផុះជាឫសនៃត្រកូលព្រះពុទ្ធ ទ្រង់លះបង់ហើយ ព្រះពុទ្ធនោះទ្រង់ឲ្យទាន គឺបាយនិងទឹកច្រើន ដល់យាចកទាំងឡាយ ហើយញុំាងព្រះទ័យឲ្យពេញ ដល់សម្ពោធិញ្ញាណដ៏ឧត្តម ដូចជាគោឧសភទំលាយនូវក្រោល ។ កាលព្រះកស្សបៈ ជាលោកនាយក ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកបរិស័ទ ចំនួន ៦ ម៉ឺនកោដិ បានត្រាស់ដឹងជាគ្រាដំបូង ។ កាលព្រះសម្ពុទ្ធយាងទៅកាន់ចារិក ក្នុងទេវលោក អស់ ៤ ខែ ពួកបរិស័ទមួយម៉ឺនកោដិ បានត្រាស់ដឹង ជាគ្រាទី ២ ។ ព្រះសាស្តាធ្វើយមកបាដិហារ្យ និងវិកុព្វនឫទ្ធិ សម្តែងនូវញាណធាតុ ពួកបរិស័ទ ៥ ពាន់កោដិ បានត្រាស់ដឹង ជាគ្រាទី ៣ ។

## ចតុព្វីសតិមោ កស្សបពុទ្ធវំសោ

សុធម្មទេវបុរេ រម្មេ តត្ថ ធម្មំ បកាសយិ
តិណ្ណំ កោដិសហស្សានំ ទេវានំ ពោធយី ជិនោ។
នរទេវស្ស យក្ខស្ស អបរេ ធម្មទេសនេ
ឯតេសានំ អភិសមយោ គណនាតោ អសង្ខិយោ។
តស្សាបិ ទេវទេវស្ស ឯកោ អាសិ សមាគមោ
ខីណាសវានំ វិមលានំ សន្តចិត្តាន តាទិនំ។
វីសតិភិក្ខុសហស្សានំ តទា អាសិ សមាគមោ
អតិក្កន្តភវន្តានំ ហិរិសីលេន តាទិនំ។
អហំ តទា មាណវកោ ជោតិបាលោតិ វិស្សុតោ
អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទាន បារគូ។
លក្ខណេ ឥតិហាសេ ច សទ្ធម្មេ បារមឹ គតោ
ភុម្មន្តលិក្ខកុសលោ កតវិជ្ជោ អនាមយោ។

## កស្សបពុទ្ធវង្ស ទី ២៤

ព្រះជិនស្រីសម្តែងធម៌ ក្នុងសុធម្មទេវបុរី ជាទីរីករាយ ក្នុងទេវលោកនោះ ញុំាងទេវតា ៣ ពាន់កោដិឲ្យត្រាស់ដឹង ។ ក្នុងការសម្តែងធម៌ដទៃទៀត ដល់ទេវតាមនុស្សនិងយក្ស ជនទាំងនោះ បានត្រាស់ដឹងរាប់មិនអស់ ។ ព្រះពុទ្ធជាទេវតាដ៏ប្រសើរនោះ មានសាវកសន្និបាតតែមួយដង ដែលសុទ្ធតែជាពួកព្រះខីណាស្រព មិនមានមន្ទិល មានចិត្តស្ងប់រម្ងាប់ មានចិត្តនឹងធឹង ។ ការប្រជុំក្នុងកាលនោះ មានភិក្ខុ ២ ម៉ឺនរូប ដែលមានភពកន្លងហើយ មានចិត្តនឹងធឹង ដោយហិរិនិងសីល ។ កាលនោះ តថាគត ជាមាណព ឈ្មោះជោតិបាល ជាអ្នករៀនមន្ត ចេះចាំមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ។ តថាគតដល់នូវបារមី ក្នុងគម្ពីរលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងព្រះសទ្ធម្មផង ឈ្លាសវៃក្នុងផែនដី និងអាកាស មានវិជ្ជាធ្វើរួចហើយ ជាអ្នកមិនមានរោគ ។

កស្សបស្ស ភគវតោ ឃដិការោ នាមុបដ្ឋកោ
សក្កតោ សប្បតិស្សោ និព្វុតោ តតិយេ ផលេ ។
អាទាយ មំ ឃដិការោ ឧបគច្ឆិ កស្សបំ ជិនំ
តស្ស ធម្មំ សុណិត្វាន បព្វជឹ តស្ស សន្តិកេ ។
អារទ្ធវីរិយោ ហុត្វា វត្តាវត្តេសុ កោវិទោ
ន ក្វចិ បរិហាយាមិ បូរេមិ ជិនសាសនំ ។
យាវតា ពុទ្ធភណិតំ នវង្គសត្ថុសាសនំ
សព្វំ បរិយាបុណិត្វាន សោភយឹ ជិនសាសនំ ។
មម អច្ឆរិយំ ទិស្វា សោបិ ពុទ្ធោ វិយាករិ
ឥមម្ហិ ភទ្ទកេ កប្បេ អយំ ពុទ្ធោ ភវិស្សតិ ។
អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។

ឧបាសក ឈ្មោះឃដិការ ជាឧបដ្ឋាក របស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ប្រកបដោយសេចក្ដីគោរព ប្រកបដោយសេចក្ដីកោតក្រែង និព្វានក្នុងផលទី ៣ ឃដិការនាំតថាគតចូលទៅគាល់ព្រះជិនស្រី ព្រះនាមកស្សបៈ តថាគតស្ដាប់ធម៌របស់ព្រះពុទ្ធនោះ ក៏បួសក្នុងសំណាក់ នៃព្រះអង្គ ។ តថាគតមានព្យាយាមក្លៀវក្លា ឈ្លាសវៃ ក្នុងវត្តតូចនិងវត្តធំ មិនមានសេចក្ដីសាបសូន្យ ក្នុងសីលនិងសមាធិណាមួយឡើយ ញុំាងសាសនានៃព្រះជិនស្រីឲ្យពេញបរិបូណ៌ ។ សាសនាព្រះសាស្ដាមានអង្គ ៩ ដែលព្រះអង្គសម្ដែងហើយទាំងប៉ុន្មាន តថាគតបានរៀនទូវធម៌ទាំងអស់នោះ ហើយញុំាងសាសនាព្រះជិនស្រី ឲ្យរុងរឿង ។ ព្រះពុទ្ធនោះឃើញហេតុជាអស្ចារ្យ របស់តថាគតក៏ទ្រង់ព្យាករថា ជោតិបាលមាណពនេះ នឹងបានត្រាស់ដឹងជាព្រះពុទ្ធ ក្នុងកប្បនេះឯង ។ សត្វនេះ នឹងចេញអំពីនគរកបិលពស្ដុជាទីរីករាយ តម្កល់សេចក្ដីព្យាយាម ធ្វើទុក្ករកិរិយា ។

## ចតុវីសតិមោ កស្សបពុទ្ធវំសោ

អជបាលរុក្ខមូលម្ហិ   និសីទិត្វា តថាគតោ
តត្ថ បាយាសំ សមាទាយ   នេរញ្ជរមុបេហិតិ ៗ
នេរញ្ជរាយ តីរម្ហិ   បាយាសំ បរិភុញ្ជិយ
បដិយត្តវរមគ្គេន   ពោធិមូលម្ហិ ឯហិតិ ៗ
តតោ បទក្ខិណំ កត្វា   ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថមូលេ សម្ពោធឹ   ពុជ្ឈិស្សតិ មហាយសោ ៗ
ឥមស្ស ជនិកា មាតា   មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម   អយំ ហេស្សតិ គោតមោ ៗ
កោលិតោ ឧបតិស្សោ ច   អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ   ឧបដ្ឋិស្សតិមំ ជិនំ ៗ
ខេមា ឧប្បលវណ្ណា ច   អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា ៗ

សត្វនេះ នឹងអង្គុយនៅទៀបគល់ នៃអជបាលព្រឹក្ស ទទួលបាយាសក្នុងទីនោះ ហើយចូលទៅឯស្ទឹងនេរញ្ជរា ៗ សត្វនេះ សោយបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយចូលសំដៅទៅរកគល់ពោធិព្រឹក្ស តាមផ្លូវដ៏ប្រសើរ ដែលគេចាត់ចែងហើយ ៗ លំដាប់ពីនោះ ព្រះពុទ្ធមានយសធំ ទ្រង់ធ្វើប្រទក្សិណនូវពោធិមណ្ឌ: ដ៏ប្រសើរ ហើយនឹងបានត្រាស់ដឹងនូវសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ៗ ព្រះមាតាបង្កើត របស់ព្រះពុទ្ធអង្គនេះ ព្រះនាមមាយា ព្រះបិតា ព្រះនាមសុទ្ធោទន: មាណពនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ៗ ព្រះថេរ: ឈ្មោះកោលិត: ១ ឧបតិស្ស: ១ មិនមានអាសវ: ប្រាសចាករាគ: មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ នឹងបានជាអគ្គសាវ័ក ព្រះថេរ: ឈ្មោះអានន្ទ ជាឧបដ្ឋាក នឹងបម្រើព្រះជិនស្រីអង្គនេះ ៗ ព្រះថេរី ឈ្មោះនាងខេមា ១ នាងឧប្បលវណ្ណា ១ សុទ្ធតែមិនមានអាសវ: ប្រាសចាករាគ: មានចិត្តស្ងប់រម្ងាប់ មានចិត្តតាំងមាំ ៗ

ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ

ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

នន្ទមាតា ច ឧត្តរា អគ្គា ហេស្សន្តុបដ្ឋិកា

អាយុ វស្សសតំ តស្ស គោតមស្ស យសស្សិនោ ។

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ

អាមោទិតា នរមរូ ពុទ្ធវីជង្កុរោ អយំ ។

ឧក្កុដ្ឋិសទ្ទា វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច

កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។

យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ

អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ

ហេដ្ឋាតិត្ថំ គហេត្វាន ឧត្តរន្តិ មហានទឹ ។

ឈើជាទីត្រាស់ដឹង របស់ព្រះមានជោគអង្គនោះ គេហៅថា អស្សត្ថព្រឹក្ស ឧបាសកឈ្មោះបិត្តៈ ១ ហត្ថាឡ្វកៈ ១ នឹងជាអគ្គឧបដ្ឋាក ។ ឧបាសិកា ឈ្មោះនន្ទមាតា ១ ឧត្តរា ១ នឹងជាអគ្គឧបដ្ឋាយិកា ព្រះគោតមមានយសអង្គនោះ មានព្រះជន្មាយុ ១០០ ឆ្នាំ ។ ពួកមនុស្សនិងទេវតា បានស្តាប់ព្រះពុទ្ធដីកានេះ របស់ព្រះពុទ្ធរកបុគ្គលស្មើគ្មាន ស្វែងរកគុណធំហើយ ក៏រីករាយថា មាណពនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ ពួកមនុស្សនិងទេវតា ទាំងមួយម៉ឺនលោកធាតុ មានសម្លេងហ៊ោឡើង ទះដៃអបអរ ធ្វើអញ្ជលីនមស្ការថា បើពួកយើងនឹងឃ្លាងមគ្គផល ក្នុងសាសនា នៃព្រះលោកនាថអង្គនេះ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រ នៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត មិនខាន ។ មនុស្សទាំងឡាយ កាលឆ្លងនូវស្ទឹង បើឃ្លាងកំពង់ចំពោះមុខ គង់នឹងកាន់យកកំពង់ខាងក្រោម ហើយឆ្លងស្ទឹងធំបានដែរ យ៉ាងណាមិញ ។

## ចតុព្វីសតិមោ កស្សបពុទ្ធវំសោ

ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ។
តស្សាបិ វចនំ សុត្វា ភិយ្យោ ចិត្តំ បសាទយឹ
ឧត្តរឹ វត្តមធិដ្ឋាសឹ ទសបារមិបូរិយា ។
ឯវមហំ សំសរិត្វា បរិវជ្ជេន្តោ អនាចរំ
ទុក្ការំ បកតំ មយ្ហំ ពោធិយាយេវ ការណា។
នគរំ ពារាណសី នាម កិកី នាមាសិ ខត្តិយោ
វសតិ តត្ថ នគរេ សម្ពុទ្ធស្ស មហាកុលំ។
ព្រាហ្មណោ ព្រហ្មទត្តោ ច អាសិ ពុទ្ធស្ស សោ បិតា
មាតា ធនវតី នាម កស្សបស្ស មហេសិនោ។
ទុវេ វស្សសហស្សានិ អគារំ អជ្ឈាវសិ សោ
ហំសោ យសោ សិរិចន្ទោ តយោ បាសាទមុត្តមា ។
តិសោឡសសហស្សានិ នារិយោ សមលង្កតា
សុនន្ទា នាម សា នារី វិជិតសេនោ នាម អត្រជោ។

ពួកយើងទាំងអស់ បើឃ្លាតព្រះជិនស្រីអង្គនេះហើយ គង់នឹងបានសម្រេច ចំពោះព្រះភក្ត្រនៃព្រះសាស្តាអង្គនេះ ក្នុងកាលជាអនាគត ក៏យ៉ាងនោះដែរ ។ តថាគតបានស្តាប់ព្រះពុទ្ធដីការបស់ព្រះពុទ្ធអង្គនោះហើយ ក៏ញុំាងចិត្តឲ្យជ្រះថ្លាក្រៃលែង បានទំអធិដ្ឋានវត្តតទៅទៀត ដោយការបំពេញបារមី ទាំង ១០ ។ តថាគត កាលបំពេញបារមីយ៉ាងនេះ តថាគតតែងអន្ទោលទៅវៀរនូវមារយាទអាក្រក់ អំពើដែលបុគ្គលធ្វើដោយកម្រ តថាគតបានធ្វើហើយ ព្រោះហេតុពោធិញាណ ។ នគរឈ្មោះពារាណសី ក្សត្រព្រះនាមកិកី ត្រកូលធំរបស់ព្រះសម្ពុទ្ធ នៅក្នុងនគរនោះ ។ ព្រះពុទ្ធ ព្រះនាមកស្សបៈ ទ្រង់ស្វែងរកគុណដ៏ធំ មានព្រហ្មទត្តព្រាហ្មណ៍ ជាព្រះបិតា ព្រះមាតាព្រះនាមធនវតី ។ ព្រះអង្គគង់គ្រប់គ្រងព្រះដំណាក់ អស់ ២ ពាន់ឆ្នាំ ប្រាសាទដ៏ប្រសើរ មាន ៣ គឺ ហំសប្រាសាទ ១ យសប្រាសាទ ១ សិរិចន្ទប្រាសាទ ១ ។ នារី ១៦ ពាន់ ៣ ដង មានខ្លួនប្រដាប់សមរម្យ ឯនារីជាអគ្គមហេសីនោះ ព្រះនាមសុនន្ទា ព្រះរាជបុត្រ ព្រះនាមវិជិតសេន ។

និមិត្តេ ចតុរោ ទិស្វា　　បាសាទេនាភិនិក្ខមិ
សត្តាហំ បធានចារំ　　អចរិ បុរិសុត្តមោ ។
ព្រហ្មុនា យាចិតោ សន្តោ　　កស្សបោ លោក-
នាយកោ
វត្តចក្កោ មហាវីរោ　　មិគទាយេ នរុត្តមោ ។
តិស្សោ ច ភារទ្វាជោ ច　　អហេសុំ អគ្គសាវកា
សព្វមិត្តោ នាមុបដ្ឋាកោ　　កស្សបស្ស មហេសិនោ ។
អនុឡា ច ឧរុវេឡា ច　　អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ　　និគ្រោធោតិ បវុច្ចតិ ។
សុមង្គលោ ឃដិការោ ច　　អហេសុំ អគ្គុបដ្ឋាកា
វិជិតសេនា ច ភទ្ទា ច　　អហេសុំ អគ្គុបដ្ឋិកា ។
ឧច្ចត្តនេន សោ ពុទ្ធោ　　វីសតិរតនមុគ្គតោ
វិជ្ជុលដ្ឋីវ អាកាសេ　　ចន្ទោវ គហបូរិតោ ។

ព្រះពុទ្ធជាបុរសដ៏ឧត្តម ឃើញនូវនិមិត្តទាំង ៤ ក៏បានចេញទៅដោយប្រាសាទ ទ្រង់ប្រព្រឹត្តសេចក្តីព្យាយាម អស់ ៧ ថ្ងៃ (បានត្រាស់ជាព្រះពុទ្ធ) ។ ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ជាលោកនាយក មានព្រះហឫទ័យស្ងប់រម្ងាប់ មានព្យាយាមច្រើន ទ្រង់ឧត្តមជាងនរជន ត្រូវព្រហ្មអារាធនាហើយ ទើបទ្រង់ញុំាងចក្រឲ្យប្រព្រឹត្តទៅ ក្នុងមិគទាយវ័ន ។ ព្រះថេរៈឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះសព្វមិត្ត ជាឧបដ្ឋាក របស់ព្រះសម្ពុទ្ធ ព្រះនាមកស្សបៈ ស្វែងរកគុណដ៏ធំ ។ ព្រះថេរី ឈ្មោះអនុឡា ១ ឧរុវេលា ១ ជាអគ្គសាវិកា ឈើសម្រាប់ត្រាស់ដឹង របស់ព្រះមានជោគនោះ ហៅថា និគ្រោធព្រឹក្ស (ដើមជ្រៃ) ។ ឧបាសកឈ្មោះសុមង្គលៈ ១ ឃដិការៈ ១ ជាអគ្គឧបដ្ឋាក ឧបាសិកាឈ្មោះវិជិតសេនា ១ ភទ្រា ១ ជាអគ្គឧបដ្ឋាយិកា ។ ព្រះសម្ពុទ្ធនោះ មានកំពស់ ២០ ហត្ថ ដូចជាឆ្នូតនៃផ្លេកបន្ទោរឰដ៏អាកាស ឬដូចជាព្រះចន្ទដែលផ្កាយហោមរោមហើយ ។

## បញ្ចវីសតិមោ កស្សបពុទ្ធវំសោ

វីសតិវស្សសហស្សានិ អាយុ តស្ស មហេសិនោ
តាវតា តិដ្ឋមានោ សោ តារេសិ ជនតំ ពហុំ ។
ធម្មតឡាកំ មាបយិត្វា សីលំ ទត្វា វិលេបនំ
ធម្មទុស្សំ និវាសេត្វា ធម្មមាលំ វិភជ្ជិយ ។
ធម្មវិមលមាទាសំ ឋបយិត្វា មហាជនេ
កេចិ និព្វានំ បត្ថេន្តា បស្សន្តុ មេ អលង្ករំ ។
សីលកញ្ចុកំ ទត្វាន ឈានកវចវម្មិតំ
ធម្មចម្មំ បារុបិត្វា ទត្វា សន្នាហមុត្តមំ ។
សតិផលកំ ទត្វាន តិខិណញាណកុន្តិមំ
ធម្មខគ្គវរំ ទត្វា សីលសត្តុប្បមទ្ទនំ ។
តេវិជ្ជាភូសំ ទត្វាន អាវេឡំ ចតុរោ ផលេ
ឆឡភិញ្ញាភរណំ ទត្វា ធម្មបុប្ផបិឡន្ធនំ ។

## កស្សបពុទ្ធវង្ស ទី ២៤

ព្រះមហេសីអង្គនោះ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ព្រះអង្គបិត
ទៅត្រឹមណោះ ទ្រង់ញ៉ាំងប្រជុំជនដ៏ច្រើន ឲ្យឆ្លង (ចាក
សង្សារ) ។ ព្រះអង្គនិម្មិតស្រះ គឺព្រះសទ្ធម្ម ទ្រង់ប្រទាន
គ្រឿងលាប គឺសីល ទ្រង់ញ៉ាំងសត្វឲ្យស្លៀកសំពត់ គឺព្រះ
ធម៌ ទ្រង់បែកកម្រងផ្កា គឺព្រះធម៌ ទ្រង់តម្កល់ទុកកញ្ចក់
មិនមានមន្ទិល គឺព្រះសទ្ធម្ម បំពោះពួកមហាជនថា ពួកជន
ណាមួយ កាលប្រាថ្នានិព្វាន ចូរមិលមើលគ្រឿងប្រដាប់
របស់តថាគតចុះ ។ ព្រះសម្ពុទ្ធនោះ ឲ្យអាវគឺសីល ឲ្យស្បែក
គ្រោះ គឺឈាន ឲ្យជណ្តប់ស្បែក គឺព្រះធម៌ ឲ្យកាំបិត
ស្នៀតដ៏ឧត្តម គឺព្យាយាម ។ ឲ្យខែល គឺសតិ ឲ្យកាំបិតគឺ
ញាណដ៏មុត ឲ្យព្រះខ័នដ៏ប្រសើរគឺធម៌ ឲ្យប្រដាប់សម្រាប់
ញាំញីសត្រូវ គឺសីល ។ ឲ្យគ្រឿងស្អិតស្អាង គឺវិជ្ជា ៣
ឲ្យគ្រឿងពាក់ត្រចៀក គឺផល ៤ ឲ្យគ្រឿងអាភរណៈ គឺ
អភិញ្ញា ៦ ឲ្យគ្រឿងប្រដាប់ជាវិការៈនៃផ្កា គឺព្រះសទ្ធម្ម ។

សទ្ធម្មបណ្ឌរច្ឆត្តំ ធត្វា ចាបនិភរណំ
មាបយិត្វា អភយំ បុរំ និព្វុតោ សោ សសាវកោ ។
ឯសោ ហិ សម្មាសម្ពុទ្ធោ អប្បមេយ្យោ ទុរាសទោ
ឯសោ ហិ ធម្មរតនោ ស្វាក្ខាតោ ឯហិបស្សិកោ ។
ឯសោ ហិ សង្ឃរតនោ សុបដិបន្នោ អនុត្តរោ
សព្វំ សមន្តរហិតំ ននុ រិត្តា សព្វសង្ខារាតិ ។
មហាកស្សបោ ជិនោ សត្ថា សេតព្យារាមម្ហិ និព្វុតោ
តត្ថេវ តស្ស ជិនថូបោ យោជនុព្វេធមុគ្គតោតិ ។

កស្សបពុទ្ធវំសោ ចតុវីសតិមោ ។

# បញ្ចវីសតិមោ គោតមពុទ្ធវំសោ

(២៦) អហមេតរហិ សម្ពុទ្ធោ គោតមោ សក្យវឌ្ឍនោ
បធានំ បទហិត្វាន បត្តោ សម្ពោធិមុត្តមំ ។

ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក ឡើងត្រាស់គឺព្រះសទ្ធម្ម ជាគ្រឿងឃាត់នូវបាប និម្មិតនូវផ្លូវមិនមានភ័យ ហើយទើបនិព្វាន ។ ព្រះសម្មាសម្ពុទ្ធអង្គនុ៎ះ ប្រមាណមិនបាន បុគ្គលគ្របសង្កត់បានដោយកម្រ ព្រះធម្មរតនៈនុ៎ះ ដែលព្រះអង្គសម្ដែងហើយដោយប្រពៃ ជាធម៌គួរហៅអ្នកផងឲ្យចូលមកមើលបាន ។ ព្រះសង្ឃរតនៈនុ៎ះ លោកប្រតិបត្តិហើយដោយប្រពៃ ជាព្រះសង្ឃដ៏ប្រសើរ របស់ទាំងអស់នេះ វិនាសសោះសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេ ទេតើ ។ ព្រះជិនស្រីជាសាស្ដា ព្រះនាមមហាកស្សបៈ ទ្រង់និព្វានក្នុងសេតព្យារាម ព្រះស្តូបរបស់ព្រះជិនស្រីអង្គនោះ មានកំពស់មួយយោជន៍ ក្នុងទីនោះ ។

ចប់ កស្សបពុទ្ធវង្ស ទី ២៤ ។

# គោតមពុទ្ធវង្ស ទី ២៥

(២៦) ក្នុងកាលឥឡូវនេះ តថាគតជាព្រះសម្ពុទ្ធ ព្រះនាមគោតម បម្រើនក្នុងត្រកូលសក្យៈ តាំងព្យាយាម ដល់សម្ពោធិញាណឧត្តម ។

## បញ្ចវីសតិមោ គោតមពុទ្ធវំសោ

ព្រហ្មុនា យាចិតោ សន្តោ ធម្មចក្កំ បវត្តយឹ
អដ្ឋារសន្នំ កោដីនំ បឋមាភិសមយោ អហុ ។
តតោ បរញ្ច ទេសេន្តេ នរទេវសមាគមេ
គណនាយ ន វត្តព្វោ ទុតិយាភិសមយោ អហុ ។
ឥធេវាហំ ឯតរហិ ឱវទឹ មម អត្រជំ
គណនាយ ន វត្តព្វោ តតិយាភិសមយោ អហុ ។
ឯកោសិ សន្និបាតោ មេ សាវកានំ មហេសិនំ
អឌ្ឍតេឡសសតានំ មេ ភិក្ខូនាសិ សមាគមោ ។
វិរោចមានោ វិមលោ ភិក្ខុសង្ឃស្ស មជ្ឈតោ(១)
ទទាមិ បត្ថិតំ សព្វំ មណីវ សព្វកាមទោ ។
ផលមាកង្ខមានានំ ភវច្ឆន្ទជហេសិនំ
ចតុសច្ចំ បកាសេសិ(២) អនុកម្បាយ បាណិនំ ។

---

១ ម. មជ្ឈគោ ។ ២ ម. បកាសេមិ ។

## គោតមពុទ្ធវង្ស ទី ២៥

តថាគតមានចិត្តស្ងប់ស្ងាប់ ត្រូវព្រហ្មអារាធនាហើយ ក៏ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ពួកបរិស័ទ ១៨ កោដិ បានត្រាស់ដឹងគ្រាដំបូង ៗ លំដាប់តទៅ កាលតថាគត សម្ដែងធម៌ដទៃទៀត ក្នុងការប្រជុំ នៃពួកមនុស្សនិងទេវតា ការត្រាស់ដឹងគ្រាទី ២ គេមិនគប្បីពោល ដោយការរាប់បានឡើយ ៗ ឥឡូវនេះ តថាគត បានទូន្មានកូនរបស់តថាគត ក្នុងទីនេះ ការត្រាស់ដឹងគ្រាទី ៣ បុគ្គលមិនគប្បីពោល ដោយការរាប់បានឡើយ ៗ ការប្រជុំសាវ័ក របស់តថាគត អ្នកស្វែងរកគុណដ៏ប្រសើរ មានតែមួយដង គឺប្រជុំពួកភិក្ខុ ១.២៥០ របស់តថាគត ៗ តថាគតរុងរឿង មិនមានមន្ទិល នៅក្នុងកណ្ដាលនៃសង្ឃ ឲ្យសេចក្ដីប្រាថ្នាទាំងពួង គឺបុគ្គលប្រាថ្នាហើយ ដូចជាកែវមណី ដែលអាចឲ្យសម្រេចសេចក្ដីប្រាថ្នាគ្រប់យ៉ាង ៗ តថាគតប្រកាសសច្ចៈទាំង ៤ ដើម្បីអនុគ្រោះដល់ពួកសត្វ ដែលប្រាថ្នានូវផល លះបង់នូវឆន្ទៈក្នុងភព ៗ

នសវីសសហស្សានំ   ធម្មាភិសមយោ អហុ
ឯកទ្វិន្នំ អភិសមយោ   គណនាតោ អសង្ខិយោ ។
វិត្ថារិកំ ពហុជញ្ញំ   ឥទ្ធំ ផីតំ សុផុល្លិតំ
ឥធ មយ្ហំ សក្យមុនិនោ   សាសនំ សុវិសោធិតំ ។
អនាសវា វីតរាគា   សន្តចិត្តា សមាហិតា
ភិក្ខូ នេកសតា សព្វេ   បរិវារេន្តិ មំ សទា ។
ឥទានិ យេ ឯតរហិ   ជហន្តិ មានុសំ ភវំ
អប្បត្តមានសា សេក្ខា   តេ ភិក្ខូ វិញ្ញុគរហិតា ។
អរិយញ្ជសំ ថោមយន្តា   សទា ធម្មរតា ជនា
ពុជ្ឈិស្សន្តិ ជុតិមន្តោ   សំសារសរិតា គតា(១) ។
នគរំ កបិលវត្ថុ មេ   រាជា សុទ្ធោទនោ បិតា
មយ្ហំ ជនេត្តិកា មាតា   មាយាទេវីតិ វុច្ចតិ ។

---

១ ម. សំសារសរិតំ គតាតិ ទិស្សន្តិ ។

មានពួកសត្វ ២ សែន បានត្រាស់ដឹងធម៌ ការត្រាស់ដឹងរបស់បុគ្គលមួយនាក់ ឬក៏ ២ នាក់ គេមិនអាចរាប់បានឡើយ ។ សម័យនេះ សាសនានៃតថាគត ជាសក្យមុនី បានផ្សាយទៅជាសាសនា ដែលទេវតានិងមនុស្សដ៏ច្រើន ជាសាសនាស្តុកស្តម្ភ មាំមួន រីកសាយភាយ តថាគតបានពិសោធហើយដោយប្រពៃ ។ ពួកភិក្ខុជាច្រើនរយ មិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់ស្ងាប់ មានចិត្តតម្កល់មាំ គ្រប់រូប តែងតែចោមរោមតថាគត សព្វ ៗ កាល ។ ក្នុងកាលឥឡូវនេះឯង ពួកភិក្ខុណា លះបង់ភពជារបស់មនុស្ស តែភិក្ខុទាំងនោះ មិនទាន់បានអរហត្តផល នៅជាសេក្ខបុគ្គល ពួកភិក្ខុទាំងនោះ ត្រូវអ្នកប្រាជ្ញតិះដៀលបាន ។ នរជនទាំងឡាយ កាលសរសើរផ្លូវដ៏ប្រសើរ (អដ្ឋង្គិកមគ្គ) ត្រេកអរក្នុងធម៌សព្វកាល មានសេចក្តីរុងរឿង អន្ទោលទៅក្នុងសង្សារ នឹងបានត្រាស់ដឹង ៗ នគររបស់តថាគត ឈ្មោះកបិលពស្តុ ស្តេចជាព្រះបិតា ព្រះនាមសុទ្ធោទនៈ ព្រះមាតាបង្កើតរបស់តថាគត ព្រះនាមមាយាទេវី ។

## បញ្ចវីសតិមោ គោតមពុទ្ធវំសោ

ឯកូនត្តឹសវស្សានិ អគារំ អជ្ឈាវសិហំ
សុចន្ទោ កោកនុទោ កោញ្ចោ(១) តយោ បាសាទ-
មុត្តមា ។

ចត្តាឡីសសហស្សានិ នារិយោ សមលង្កតា
យសោធរា នាម(២) នារី រាហុលោ នាម អត្រជោ ។

និមិត្តេ ចតុរោ ទិស្វា អស្សយានេន និក្ខមឹ
ឆព្វស្សំ បធានចារំ អចរឹ ទុក្ករំ អហំ ។

ពារាណសី ឥសិបតនេ ជិនោ ចក្កំ បវត្តយឹ
អហំ គោតមសម្ពុទ្ធោ សរណំ សព្វបាណិនំ ។

កោលិតោ ឧបតិស្សោ ច ទ្វេ ភិក្ខូ អគ្គសាវកា
អានន្ទោ នាមុបដ្ឋាកោ សន្តិកាវចរោ មម ។

ខេមា ឧប្បលវណ្ណា ច ភិក្ខុនី អគ្គសាវិកា
ចិត្តោ ច ហត្ថាឡវកោ អគ្គុបដ្ឋាកុបាសកា ។

---

១ ឱ. ម. ភមោ សុភមោ សុភគោតិ ទិស្សន្តិ ។ ២ ឱ. ម. ភទ្ទកច្ចា នាម ។

## គោតមពុទ្ធវង្ស ទី ២៥

តថាគតនៅគ្រប់គ្រងព្រះដំណាក់ អស់ ២៩ ឆ្នាំ មានប្រាសាទ ដ៏ប្រសើរ ៣ គឺសុចន្ទប្រាសាទ ១ កោកនុទប្រាសាទ ១ កោញ្ចប្រាសាទ ១ ៗ មាននារី ៤ ម៉ឺននាក់ មានខ្លួនប្រដាប់ សមរម្យ នារីជាអគ្គមហេសី ព្រះនាមយសោធរា ព្រះរាជបុត្រ ព្រះនាមរាហុល ៗ តថាគតឃើញនិមិត្ត ៤ យ៉ាង ហើយក៏ ចេញទៅ ដោយយានសេះ ប្រព្រឹត្តព្យាយាម ធ្វើទុក្ករកិរិយា អស់ ៦ ឆ្នាំ ៗ តថាគត ជាព្រះជិនស្រី បានញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅ ក្នុងព្រៃឥសិបតនៈ ទៀបក្រុងពារាណសី តថាគត ជាគោតមសម្ពុទ្ធ ជាទីពឹងនៃសត្វទាំងពួង ៗ ភិក្ខុ ២ រូប ឈ្មោះកោលិតៈ ១ ឧបតិស្សៈ ១ ជាអគ្គសាវក ភិក្ខុ ឈ្មោះអានន្ទ ជាឧបដ្ឋាក អ្នកបម្រើផ្ទាល់ របស់តថាគត ៗ ភិក្ខុនី ឈ្មោះខេមា ១ ឧប្បលវណ្ណា ១ ជាអគ្គសាវិកា ឧបាសក ឈ្មោះចិត្តៈ ១ ហត្ថាឡវកៈ ១ ជាអគ្គឧបដ្ឋាក ៗ

នន្ទមាតា ច ឧត្តរា អគ្គុបដ្ឋាកុបាសិកា
អហំ អស្សត្ថមូលម្ហិ បត្តោ សម្ពោធិមុត្តមំ ។
ព្យាមប្បភា សទា មយ្ហំ សោឡសហត្ថមុគ្គតោ
អប្បំ វស្សសតំ អាយុ មមេតរហិ វិជ្ជតិ ។
តាវតា តិដ្ឋមានោហំ តារេសឹ ជនតំ ពហុំ
ឋបយិត្វាន ធម្មោក្កំ(១) បច្ឆិមជនពោធនំ ។
អហំបិ នចិរស្សេវ សទ្ធឹ សាវកសង្ឃតោ
ឥធេវ បរិនិព្វិស្សំ អគ្គិវហារសង្ខយា ។
តានិ អតុលតេជានិ ឥមានិ ច យសពលានិ ឥទ្ធិយោ
អហំ គុណធារណោ ទេហោ(២) ទ្វត្តឹសវរលក្ខណ-
វិចិត្តោ ។

ទសទិសា បភាសេត្វា សតរំសីវ នប្បភា
សព្វា សមន្តរហោស្សន្តិ ននុ រិត្តា សព្វសង្ខារាតិ ។

គោតមពុទ្ធវំសោ បញ្ចវីសតិមោ ។

---

១ ម. ធម្មុក្កំ ។ ២ ឱ. អយញ្ច គុណវរទេហោតិ ទិស្សតិ ។

ឧបាសិកា ឈ្មោះនន្ទមាតា ១ ឧត្តរា ១ ជាអគ្គឧបដ្ឋាយិកា តថាគតបានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តម ទៀបគល់អស្សត្ថព្រឹក្ស ។ តថាគតមានរស្មីមួយព្យាម សព្វ ៗ កាល មានកំពស់ ១៦ ហត្ថ ក្នុងកាលឥឡូវនេះ តថាគតមានអាយុតិចបានតែ ១០០ ឆ្នាំ ។ តថាគត កាលឋិតនៅ អស់កាលត្រឹមនោះ បានញុំាងប្រជុំជនដ៏ច្រើន ឲ្យឆ្លងចាកសង្សារ ហើយតម្កល់ទុកគប់ភ្លើង គឺធម៌ ដើម្បីញុំាងជនតាងក្រោយឲ្យបានត្រាស់ដឹងផង ។ មិនយូរប៉ុន្មានទេ តថាគតព្រមទាំងសង្ឃជាសាវ័ក នឹងនិព្វានក្នុងទីនេះ ដូចជាភ្លើងរលត់ ព្រោះអស់អាហារគឺឧស ។ អគ្គសាវ័កទាំងគូនេះឯង មានតេជះប្រឹងពុំបានផង មានយសនិងកម្លាំងឫទ្ធិផង តថាគត មានរាងកាយទ្រទ្រង់នូវគុណ វិចិត្រដោយលក្ខណៈ ដ៏ប្រសើរ ៣២ ប្រការ ។ រស្មី ៦ ពណ៌ ភ្លឺទៅក្នុងទិសទាំង ១០ ដូចព្រះអាទិត្យ របស់ទាំងអស់នេះ នឹងវិនាសសូន្យទៅ ឱ ! សង្ខារទាំងពួង ជារបស់ទទេ ទទេតែ ។

ចប់ គោតមពុទ្ធវង្ស ទី ២៥ ។

# ពុទ្ធប្បកិណ្ណកកណ្ឌោ

(២៧) អបរិមេយ្យេ ឥតោ កប្បេ ចតុរោ អាសុំ
វិនាយកា

តណ្ហង្ករោ មេធង្ករោ អថោបិ សរណង្ករោ
ទីបង្ករោ ច សម្ពុទ្ធោ ឯកកប្បម្ហិ តេ ជិនា ។
ទីបង្ករស្ស អបរេន កោណ្ឌញ្ញោ នាម នាយកោ
ឯកោវ ឯកកប្បម្ហិ តារេសិ ជនតំ ពហុំ ។
ទីបង្ករស្ស ភគវតោ កោណ្ឌញ្ញស្ស ច សត្ថុនោ
ឯតេសំ អន្តរា កប្បា គណនាតោ អសង្ខេយ្យា ។
កោណ្ឌញ្ញស្ស អបរេន មង្គលោ នាម នាយកោ
តេសំបិ អន្តរា កប្បា គណនាតោ អសង្ខេយ្យា ។
មង្គលោ ច សុមនោ ច រេវតោ សោភិតោ មុនិ
តេបិ ពុទ្ធា ឯកកប្បេ ចក្ខុមន្តោ បភង្ករា ។

# ពុទ្ធប្បកិណ្ណកកណ្ឌ

(២៧) ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះ មានព្រះពុទ្ធជានាយក ៤ ព្រះអង្គ គឺព្រះសម្ពុទ្ធ ព្រះនាមតណ្ហង្ករ: ១ មេធង្ករ: ១ សរណង្ករ: ១ ទីបង្ករ: ១ ព្រះជិនស្រីទាំងនោះ ត្រាស់ក្នុងកប្បជាមួយគ្នា ៗ ខាងក្រោយ អំពីព្រះពុទ្ធទីបង្ករ: មក ព្រះពុទ្ធជានាយក ព្រះនាមកោណ្ឌញ្ញ: បានត្រាស់តែមួយព្រះអង្គ ក្នុងកប្បមួយ ញុំាងប្រជុំជនជាច្រើន ឲ្យឆ្លង (ពាកសង្សារ) ៗ កប្បជាបន្ទោះនៃព្រះពុទ្ធ ២ ព្រះអង្គនុះ គឺព្រះពុទ្ធទីបង្ករ: មានព្រះភាគ និងព្រះសាស្តា ព្រះនាមកោណ្ឌញ្ញ: ជាកប្បគេមិនអាចរាប់បានឡើយ ៗ ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមកោណ្ឌញ្ញ:មក មានព្រះពុទ្ធជានាយក ព្រះនាមមង្គល: (ទ្រង់ត្រាស់ឡើង) កប្បជាបន្ទោះ នៃព្រះពុទ្ធទាំង ២ ព្រះអង្គនោះ បុគ្គលមិនអាចរាប់បានឡើយ ៗ ព្រះពុទ្ធ ព្រះនាមមង្គល: ១ ព្រះសុមន: ១ ព្រះរេវត: ១ និងព្រះមុនី ព្រះនាមសោភិត: ១ ព្រះសម្ពុទ្ធទាំងនោះ មានចក្ខុ ធ្វើនូវពន្លឺ (បានត្រាស់ឡើង) ក្នុងកប្បជាមួយគ្នា ៗ

សោភិតស្ស អបរេន    អនោមទស្សី មហាមុនិ(១)
តេសំបិ អន្តរា កប្បា    គណនាតោ អសង្ខិយា ។
អនោមទស្សី បទុមោ    នារទោ ចាបិ នាយកោ
តេបិ ពុទ្ធា ឯកកប្បេ    តមន្តការណា(២) មុនី ។
នារទស្ស អបរេន    បទុមុត្តរោ នាម នាយកោ
ឯកកប្បម្ហិ ឧប្បន្នោ    តារេសិ ជនតំ ពហុំ ។
នារទស្ស ភគវតោ    បទុមុត្តរស្ស សត្ថុនោ
តេសំបិ អន្តរា កប្បា    គណនាតោ អសង្ខិយា ។
កប្បសតសហស្សម្ហិ    ឯកោ អាសិ មហាមុនិ
បទុមុត្តរោ លោកវិទូ    អាហុតីនំ បដិគ្គហោ ។
តឹសកប្បសហស្សម្ហិ    ទុវេ អាសឹសុ នាយកា
សុមេធោ ច សុជាតោ ច    ឱរតោ បទុមុត្តរោ ។
អដ្ឋារសកប្បសតេ    តយោ អាសឹសុ នាយកា
បិយទស្សី អត្ថទស្សី    ធម្មទស្សី ច នាយកា ។

---

១ ឱ.ម. មហាយសោ ។ ២ ម. តមន្តការកា ។

ខាងក្រោយនៃព្រះសម្ពុទ្ធ ព្រះនាមសោភិតៈមក មានព្រះពុទ្ធ ព្រះនាមអនោមទស្សី ជាមហាមុនី ត្រាស់ឡើងក្នុងលោក កប្ប ជាបន្លោះ នៃព្រះពុទ្ធទាំង ២ អង្គនោះ គេមិនអាចរាប់បានឡើយ ។ ព្រះនាយក ព្រះនាមអនោមទស្សី ១ ព្រះនាមបទុមៈ ១ ព្រះនាមនារទៈ ១ ព្រះពុទ្ធ ជាមហាមុនីទាំងនោះ ទ្រង់ធ្វើនូវទីបំផុតនៃងងឹត (ត្រាស់ឡើង) ក្នុងកប្បជាមួយគ្នា ។ ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមនារទៈមក មានព្រះនាយក ព្រះនាមបទុមុត្តរៈ កើតឡើងក្នុងកប្បមួយ ញុំាងប្រជុំជនជាច្រើនឲ្យឆ្លង ចាកសង្សារ ។ កប្បជាបន្លោះនៃព្រះពុទ្ធទាំងពីរព្រះអង្គនោះ គឺព្រះមានជោគព្រះនាមនារទៈ និងព្រះសាស្តា ព្រះនាមបទុមុត្តរៈ គេមិនអាចរាប់បានឡើយ ។ ក្នុងកប្បទីមួយសែន មានតែព្រះមហាមុនីមួយព្រះអង្គ ព្រះនាមបទុមុត្តរៈ ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជាដែលគេនាំមកបូជា ។ ក្នុងកប្បទី ៣ ម៉ឺន ខាងអាយព្រះពុទ្ធបទុមុត្តរៈមក មានព្រះនាយក ២ អង្គ ព្រះនាមសុមេធៈ ១ សុជាតៈ ១ ត្រាស់ឡើងក្នុងលោក ។ ក្នុងកប្បទីមួយពាន់ ៨ រយ ខាងអាយព្រះពុទ្ធព្រះនាមសុជាតៈមក មានព្រះនាយក ៣ អង្គព្រះនាមបិយទស្សី ១ អត្ថទស្សី ១ ព្រះនាយក ធម្មទស្សី ១ ត្រាស់ឡើងក្នុងលោក ។

## ពុទ្ធប្បកិណ្ណកកណ្ឌោ

ឱរតោ(១) ច សុជាតស្ស សម្ពុទ្ធា ទិបទុត្តមា
ឯកកប្បម្ហិ សម្ពុទ្ធា លោកេ អប្បដិបុគ្គលា ។
ចតុន្នវុតេ ឥតោ កប្បេ ឯកោ អាសិ មហាមុនិ
សិទ្ធត្ថោ សោ លោកវិទូ សល្លក្តោ(២) អនុត្តរោ ។
ទ្វេនវុតេ ឥតោ កប្បេ ទុវេ អាសឹសុ នាយកា
តិស្សោ ផុស្សោ ច សម្ពុទ្ធោ អសមោ អប្បដិបុគ្គលោ ។
ឯកនវុតេ ឥតោ កប្បេ វិបស្សី លោកនាយកោ
សោបិ ពុទ្ធោ ការុណិកោ សត្តេ មោចេសិ ពន្ធនា ។
ឯកត្តឹសេ ឥតោ កប្បេ ទុវេ អាសឹសុ នាយកា
សិខី ច វេស្សភូ ចេវ អសមា អប្បដិបុគ្គលា ។
ឥមម្ហិ ភទ្ទកេ កប្បេ តយោ អាសឹសុ នាយកា
កកុសន្ធោ កោណាគមនោ កស្សបោ ចាបិ នាយកោ ។

---

១ ឱ. ឱរសោ ។ ២ ឱ. សល្លគត្តោ ។ ម. សល្លកត្តោ ។

## ពុទ្ធប្បកិណ្ណកកណ្ឌ

ព្រះសម្ពុទ្ធទាំងនោះ ឧត្តមជាងសត្វជើងពីរ ជាព្រះសម្ពុទ្ធរកបុគ្គលប្រៀបផ្ទឹមគ្មាន កន្លងលោក បានត្រាស់ដឹងក្នុងកប្បជាមួយគ្នា ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ មានព្រះមហាមុនីព្រះនាមសិទ្ធត្ថៈតែមួយអង្គ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ជាពេទ្យដ៏ប្រសើរ បានត្រាស់ឡើង ក្នុងលោក ។ ក្នុងកប្បទី ៩២ អំពីភទ្ទកប្បនេះ ព្រះសម្ពុទ្ធជានាយក ២ ព្រះអង្គ ព្រះនាមតិស្សៈ ១ ផុស្សៈ ១ រកបុគ្គលស្មើគ្មាន រកបុគ្គលប្រៀបផ្ទឹមគ្មាន បានត្រាស់ឡើងក្នុងលោក ។ ក្នុងកប្បទី ៩១ អំពីភទ្ទកប្បនេះ ព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ជាលោកនាយក ព្រះអង្គប្រកបដោយសេចក្តីករុណា ទ្រង់ដោះសត្វទាំងឡាយឲ្យរួចចាកចំណង (បានត្រាស់ឡើង ក្នុងលោក) ។ ក្នុងកប្បទី ៣១ អំពីភទ្ទកប្បនេះ ព្រះនាយក ២ អង្គ ព្រះនាមសិខី ១ វេស្សភូ ១ រកបុគ្គលស្មើគ្មាន រកបុគ្គលប្រៀបផ្ទឹមគ្មាន (បានត្រាស់ឡើងក្នុងលោក) ។ ក្នុងភទ្ទកប្បនេះ ព្រះនាយក ៣ ព្រះអង្គ ព្រះនាមកកុសន្ធៈ ១ កោនាគមនៈ ១ និងព្រះនាយក ព្រះនាមកស្សបៈ ១ (បានត្រាស់ឡើងក្នុងលោក) ។

អហមេតរហិ សម្ពុទ្ធោ   មេត្តេយ្យោ ចាបិ ហេស្សតិ
ឯតេបិមេ បញ្ច ពុទ្ធា   ធីរា លោកានុកម្បកា ។
ឯតេសំ ធម្មរាជូនំ   អញ្ញេសំ នេកកោដិនំ
អាចិក្ខិត្វាន តំ មគ្គំ   និព្វុតោ សោ សសាវកោតិ ។

ពុទ្ធប្បកិណ្ណកកណ្ឌោ និដ្ឋិតោ ។

# ធាតុភាជនីយកថា

(២៨) មហាគោតមោ ជិនវរោ   កុសិនារម្ហិ និព្វុតោ
ធាតុវិត្ថារិកំ អាសិ   តេសុ តេសុ បទេសតោ ។
ឯកោ អជាតសត្តុស្ស   ឯកោ វេសាលិយា បុរេ
ឯកោ កបិលវត្ថុស្មឹ   ឯកោ ច អល្លកប្បកេ ។
ឯកោ ច រាមគាមម្ហិ   ឯកោ ច វេដ្ឋទីបកេ
ឯកោ បាវេយ្យកេ មល្លេ   ឯកោ ច កោសិនារកេ ។

ក្នុងកាលឥឡូវនេះ មានតថាគតនេះ ជាព្រះសម្ពុទ្ធ ទៅក្នុងអនាគតកាល នឹងមានព្រះសម្ពុទ្ធព្រះនាមមេត្តេយ្យ ព្រះសម្ពុទ្ធទាំង ៥ អង្គនេះ ជាអ្នកប្រាជ្ញ អនុគ្រោះស្រង់សត្វលោក ។ ព្រះសម្ពុទ្ធអង្គនោះ ព្រមទាំងសាវ័ក លុះប្រាប់ផ្លូវ របស់ព្រះពុទ្ធ ជាធម្មកដទាំងនុ៎ះ ដល់ពួកសត្វដទៃជាច្រើនកោដិហើយ ក៏បរិនិព្វាន ។

ចប់ពុទ្ធកិណ្ណកកណ្ឌ ។

# ធាតុភាជនីយកថា

(២៨) ព្រះមហាគោតម ជាព្រះជិនស្រីប្រសើរ ទ្រង់និព្វាន ក្នុងនគរកុសិនារា ព្រះធាតុផ្សាយទៅក្នុងប្រទេសនោះៗ តាមចំណែក គឺ ព្រះធាតុមួយចំណែក បានទៅព្រះបាទអជាតសត្តុ មួយចំណែក បានទៅក្រុងវេសាលី មួយចំណែក បានទៅក្រុងកបិលព័ស្តុ មួយចំណែក បានទៅដែនអល្លកប្បកៈ មួយចំណែក បានទៅក្រុងរាមគ្រាម មួយចំណែក បានទៅក្រុងវេដ្ឋទីបកៈ មួយចំណែក បានទៅក្រុងបាវេយ្យកមល្លៈ ឯព្រះធាតុមួយចំណែកទៀត បានទៅអ្នកក្រុងកុសិនារា ។

# ធាតុភាជនីយកថា

តុម្ពស្ស(១) ថូបំ ការេសិ ព្រាហ្មណោ ទោណសវ្ហយោ
អង្គារថូបំ ការេសុំ មោរិយា តុដ្ឋមានសា ។
អដ្ឋ សារីរិកា ថូបា នវមោ តុម្ពចេតិយោ
អង្គារថូបោ ទសមោ តទាយេវ បតិដ្ឋិតោ(២) ។
ឯកា ទាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារវិសយេ ឯកា កាលិង្គរាជិនោ ។
ចត្តាលីសសមា ទន្តា កេសា លោមា ច សព្វសោ
ទេវា ហរឹសុំ ឯកេកំ ចក្កវាឡបរម្បរា ។

---

១ ឱ. ម. កុម្ភស្ស ។ ២ ម. ឥតោ បរំ

ឧណ្ហិសំ ចតស្សោ ទាឋា អក្ខកា ទ្វេ ច ធាតុយោ
អសម្ភិន្នា ឥមា សត្ត សេសា ភិន្នា វ ធាតុយោ ។
មហន្តា មុគ្គមត្តា វ មជ្ឈិមា ភិន្នតណ្ឌុលា
ខុទ្ទកា សាសបមត្តា ច នានាវណ្ណា ច ធាតុយោ ។
មហន្តា សុវណ្ណវណ្ណា ច មុត្តវណ្ណា ច មជ្ឈិមា
ខុទ្ទកា មកុលវណ្ណា ច សោឡស ទោណមត្តកា ។
មហន្តា បញ្ច នាឡិយោ នាឡិយោ បញ្ច មជ្ឈិមា
ខុទ្ទកា ឆ នាឡិ ចេវ ឯតា សព្វាបិ ធាតុយោ ។
ឧណ្ហិសំ សីហឡេ ទីបេ ព្រហ្មលោកេ ច វាមកំ
សីហឡេ ទក្ខិណក្ខកំ សព្វាបេតា បតិដ្ឋិតា ឥមេ ពហ ទិស្សន្តិ ។

## ធាតុភាជនីយកថា

ព្រាហ្មណ៍ឈ្មោះទោណៈ បានធ្វើស្តូបបញ្ចុះតុម្ព (នាឡិ) ពួកមោរិយជន មានចិត្តជ្រះថ្លា បានធ្វើស្តូបបញ្ចុះព្រះអង្គារ (ធ្យូង) ។ ព្រះស្តូបបញ្ចុះព្រះសារីរិកធាតុ មាន ៨ បើរាប់តុម្ពចេតិយមួយផង ជា ៩ បើគិតទាំងព្រះស្តូបបញ្ចុះព្រះអង្គារមួយទៀត ត្រូវជា ១០ ដែលមហាជនស្ថាបនាទុក ក្នុងកាលនោះ ។ ព្រះចង្កូម ១ តម្កល់ក្នុងឋានត្រៃត្រឹង្ស ព្រះចង្កូម ១ តម្កល់ក្នុងនាគបុរី ព្រះចង្កូម ១ នៅក្នុងដែនគន្ធារៈ ព្រះចង្កូម ១ នៅក្នុងដែនកាលិង្គរាជ ។ ព្រះទន្ត ទាំង ៤០ គត់ ព្រះកេសា និងព្រះលោមាទាំងអស់ ពួកទេវតាវៀងខ្លួន បាននាំទៅមួយ ៗ កាន់ចក្រវាឡទីទៃ ៗ

វជិរាយំ ភគវតោ បត្តោ ទណ្ឌោ ច ចីវរំ
និវាសនំ កុលឃរេ បច្ចត្ថរណំ សិលវ្ហយេ ។
បាដលិបុត្តនគរេ ករកំ កាយពន្ធនំ
ចម្បាយំ ឧទកសាដកា ឧណ្ណាលោមញ្ច កោសលេ ។
កាសាវកំ ព្រហ្មលោកេ វេឋនំ តិទសេ បុរេ
បាសាណកេ បទំ សេដ្ឋំ យថាបិ កប្បតំ បុរំ
និសីទនំ អវន្តីសុ ទេវរដ្ឋេ អត្ថរណំ តទា ។
អរណី ច មិថិលាយំ វិទេហេ បរិសាវនំ
វាសី សូចិឃរញ្ចាបិ ឥន្ទបត្ថបុរេ តទា ។
បរិក្ខារា អវសេសា ជនបទន្តេ តទា
បរិភុត្តានិ មុនិនា ហោស្សន្តិ មនុជា តទា ។
ធាតុវិត្ថារិកំ អាសិ គោតមស្ស មហេសិនោ
បាណីនំ អនុកម្បាយ អហុ ពោរាណកំ តទាតិ ។

ធាតុភាជនីយកថា និដ្ឋិតា ។

ពុទ្ធវំសោ និដ្ឋិតោ ។

បាត្រ ឈើច្រត់ និងចីវររបស់ព្រះមានព្រះភាគ តម្កល់ទុកនៅក្នុងដែនវជិរ ស្បង់ តម្កល់ទុកនៅក្នុងផ្ទះនៃត្រកូល គ្រឿងកម្រាល តម្កល់ទុកនៅក្នុងក្រុង ឈ្មោះសិលៈ ។ ធម្មក្រកនិងកាយពន្ធ (វត្ថពន្ធបង្កេះ) តម្កល់ទុកនៅក្នុងក្រុងបាដលិបុត្ត ទឹកសាដក តម្កល់ទុកនៅក្រុងចម្បា ព្រះឧណ្ណាលោម (រោមចិញ្ចើម) តម្កល់ទុកនៅក្នុងដែនកោសល ។ សំពត់កាសាវៈ តម្កល់ទុកក្នុងព្រហ្មលោក ឆត្រតម្កល់ទុកក្នុងឋាននៃត្រៃត្រិង្ស ស្នាមព្រះបាទដ៏ប្រសើរ ដែលមិនបាត់ទៅ តម្កល់ទុកលើថ្ម សំពត់និសីទនៈ តម្កល់ទុកក្នុងអវន្តិជនបទ គ្រឿងកម្រាល តម្កល់ទុកក្នុងដែនឈ្មោះទេវៈ ក្នុងកាលនោះ ។ កាលនោះ ដែកភ្លើង តម្កល់ទុកក្នុងក្រុងមិថិលា តម្រងទឹក តម្កល់ទុកក្នុងដែនវិទេហៈ កាំបិតកោរ និងបំពង់ម្ជុល តម្កល់ទុកនៅក្នុងឥន្ទបត្ថបុរី ។ កាលនោះ គ្រឿងបរិក្ខារដ៏សេសទាំងឡាយ តម្កល់ទុកក្នុងជនបទជាទីបំផុត ពួកមនុស្ស តែងបូជាចំពោះគ្រឿងបរិក្ខារទាំងឡាយ ដែលព្រះមុនីទ្រង់ប្រើប្រាស់ ។ ការផ្សាយទៅនៃព្រះធាតុ របស់ព្រះមហេសី ព្រះនាមគោតម ក្នុងកាលនោះ ជាប្រពៃណីពីបូរាណ (នៃព្រះពុទ្ធទាំងឡាយ) សម្រាប់ទុកអនុគ្រោះ ស្រោចស្រង់សត្វទាំងឡាយ ជាខាងក្រោយ ។

ចប់ ធាតុភាជនីយកថា ។

ចប់ ពុទ្ធវង្ស ។

# ព្រះ

# សុត្តន្តបិដក ខុទ្ទកនិកាយ

# ចរិយាបិដក

# សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស

# ចរិយាបិដកំ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ទានបារមិតា

## បឋមំ អកិត្តិចរិយំ

(១) កប្បេ ច សតសហស្សេ ចតុរោ ច អសង្ខិយេ
អន្តរេ យំ ចរិតំ សព្វំ តំ ពោធិបាចនំ ។
អតីតកប្បេ ចរិតំ ឋបយិត្វា ភវាភវេ
ឥមម្ហិ កប្បេ ចរិតំ បវក្ខិស្សំ សុណោហិ មេ ។
យទា អហំ ព្រហារញ្ញេ សុញ្ញេ វិបិនកាននេ
អជ្ឈោគាហេត្វា វិហរាមិ អកិត្តិ នាម តាបសោ ។

# សុត្តន្តបិដក

# ខុទ្ទកនិកាយ ចរិយាបិដក

---

សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## ទានបារមិតា

## អកិត្តិចរិយា ទី ១

(១) អំពើ(១)ណា ដែលតថាគត បានប្រព្រឹត្តហើយ ក្នុងរវាងនេះ អស់ ៤ អសង្ខេយ្យ កំរៃមួយសែនកប្ប អំពើទាំងអស់នោះ ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច ។ តថាគត លើកទុកនូវអំពើ ដែលតថាគតបានប្រព្រឹត្ត ក្នុងភពតូចនិងភពធំ ក្នុងកប្បដែលកន្លងទៅហើយ នឹងសំដែងតែអំពើដែលតថាគតបានប្រព្រឹត្តហើយក្នុងភទ្ទកប្បនេះ អ្នកចូរស្តាប់តថាគតចុះ ។ កាលដែលតថាគត ជាតាបស ឈ្មោះអកិត្តិ ចូលទៅនៅក្នុងព្រៃធំនិងព្រៃតូច ជាព្រៃស្ងាត់សូន្យឈឹង ។

---

១ ពាក្យថា អំពើ ក្នុងទីនេះ បានដល់សេចក្តីប្រតិបត្តិ មានទាននិងសីលជាដើម ដែលសង្គ្រោះចូលក្នុងបារមីទាំង ៣០ ។ អដ្ឋកថា ។

## បឋមំ អកិត្តិចរិយំ

តទា មំ តបតេជេន សន្តត្តោ តិទិវាភិភូ
ធារេន្តោ ព្រាហ្មណវណ្ណំ ភិក្ខាយ មំ ឧបាគមិ ។
បវនា អាភតំ បណ្ណំ អតេលញ្ច អលោណិកំ
មម ទ្វារេ ឋិតំ ទិស្វា សកដាហេន អាកិរឹ ។
តស្ស ទត្វានហំ បណ្ណំ និក្កុជ្ជិត្វាន ភាជនំ
បុនេសនំ ជហិត្វាន បាវិសឹ បណ្ណសាលកំ ។
ទុតិយំ ទិវសំ តតិយំបិ(១) ឧបគច្ឆិ មមន្តិកេ
អកម្បិតោ អនោលគ្គោ ឯវមេវមទាសហំ ។
ន មេ តប្បច្ចយា អត្ថិ សរីរស្មឹ វិវណ្ណិយំ
បីតិសុខេន រតិយា វីតិនាមេមិ តំ ទិវំ ។
យទិ មាសំបិ ទិមាសំ ទក្ខិណេយ្យំ វរំ លភេ
អកម្បិតោ អនោលីនោ ទទេយ្យំ ទានមុត្តមំ ។

---

១ ឱ. ម. ទុតិយម្បិ តតិយម្បីតំ ទិស្សតិ ។

# អកិត្តិចរិយា ទី ១

កាលនោះ ព្រះឥន្ទ្រ អ្នកគ្រប់សង្កត់ទេវលោក ទ្រង់ក្ដៅ ដោយតេជះ គឺតបធម៌នៃតថាគត ក៏ក្លែងភេទជាព្រាហ្មណ៍ ចូលមករកតថាគតដើម្បីសូមភិក្ខា ។ តថាគតឃើញព្រាហ្មណ៍ ឈរទៀបទ្វារបណ្ណសាលា របស់តថាគត ក៏ឲ្យស្លឹកជន្លៀប ក្ដាមទាំងអស់ ដែលតថាគតនាំមកពីព្រៃ ជាស្លឹកមិនមានប្រេង មិនមានរសប្រៃ ព្រមទាំងកាជន៍ ។ លុះតថាគត ឲ្យស្លឹក ជន្លៀបក្ដាមដល់ព្រាហ្មណ៍ហើយ ក៏ផ្កាប់កាជន៍លះបង់នូវការ ស្វែងរកទៀត ហើយចូលទៅក្នុងបណ្ណសាលា ។ ក្នុងថ្ងៃទី២ និងថ្ងៃទី ៣ ព្រាហ្មណ៍ចូលមកក្នុងសំណាក់តថាគតទៀត តែ តថាគតមិនញាប់ញ័រ មិនជាប់ចំពាក់ បានឲ្យយ៉ាងនុះទៀត សរីរៈរបស់តថាគត មិនមានផ្លែកភេទ ព្រោះហេតុទាននោះ តថាគតញុំាងកាលឲ្យប្រព្រឹត្តកន្លងទៅ អស់ថ្ងៃនោះ ព្រោះ សេចក្ដីត្រេកអរ ដោយសុខដែលកើតអំពីបីតិ ។ បើតថាគត បានទក្ខិណេយ្យបុគ្គលដ៏ប្រសើរ អស់ ១ ខែ ឬ ២ ខែទៀត តថាគតមិនញាប់ញ័រ មិនរួញរា នឹងឲ្យទានដ៏ឧត្ដមឡើយ ។

ន តស្ស ទានំ ទទមានោ យសំ លាភញ្ច បត្ថយឹ
សព្វញ្ញុតំ បត្ថយានោ តានិ កម្មានិ អាចរិន្តិ ។

អកិត្តិចរិយំ បឋមំ ។

# ទុតិយំ សង្ខព្រាហ្មណចរិយំ

(២) បុនាបរំ យទា ហោមិ ព្រាហ្មណោ សង្ខសវ្ហយោ
មហាសមុទ្ទំ តរិតុកាមោ ឧបគច្ឆាមិ បដ្ដនំ ។
តត្ថទ្ទសាមិ បដិបថេ សយម្ភុំ អបរាជិតំ
កន្តារទ្ធានំ(១) បដិបន្នំ តត្តាយ កឋិនភូមិយា ។
តមហំ បដិបថេ ទិស្វា ឥមមត្ថំ វិចិន្តយឹ
ឥទំ ខេត្តំ អនុប្បត្តំ បុញ្ញកាមស្ស ជន្តុនោ ។
យថាបិ កស្សកោ បុរិសោ ខេត្តំ ទិស្វា មហាគមំ(២)
ន តត្ថ ពីជំ រោបេតិ ន សោ ធញ្ញេន អត្ថិកោ ។

---

១ ឱ. ម. កន្តារទ្ធានំ ។ ២ ឱ. ម. មហាគាមំ ។

តថាគត កាលឲ្យទានដល់ឥន្ទព្រាហ្មណ៍នោះ ទាំងបានប្រព្រឹត្តនូវអំពើទាំងឡាយនោះ មិនប្រាថ្នានូវយសនិងលាភទេ តថាគតប្រាថ្នាចំពោះសព្វញ្ញុតញ្ញាណតែម្យ៉ាង ។

ចប់ អកិត្តិចរិយា ទី ១ ។

## សង្ខព្រាហ្មណចរិយា ទី ២

(២) មានចរិយាដទៃទៀត កាលដែលតថាគត កើតជាព្រាហ្មណ៍ ឈ្មោះសង្ខៈ មានប្រាថ្នាដើម្បីឆ្លងមហាសមុទ្រ សំដៅទៅកាន់កំពង់ (តម្ពលិត្តិ) ។ កាលនោះ តថាគតបាន ឃើញព្រះបច្ចេកពុទ្ធដែលត្រាស់ដឹងឯង ទ្រង់ឈ្មោះមារ កំពុងនិមន្តទៅកាន់ផ្លូវលំបាក លើផែនដីរដិបរដុបដ៏ក្តៅ ត្រង់ផ្លូវជួបគ្នានោះ ។ លុះតថាគត ឃើញព្រះបច្ចេកពុទ្ធ ត្រង់ផ្លូវជួបគ្នានោះ ក៏គិតនូវសេចក្តីនេះថា ស្រែបុណ្យនេះ រមែងសម្រេចដល់សត្វអ្នកប្រាថ្នានូវបុណ្យ ប្រៀបដូចបុរសអ្នកភ្ជួរ ឃើញស្រែ ឬសួនច្បារធំ មិនព្រោះពូជក្នុងស្រែនោះទេ បុរសនោះឈ្មោះថាជាអ្នកមិនត្រូវការដោយស្រូវ យ៉ាងណាមិញ ។

## ទុតិយំ សង្ខព្រាហ្មណចរិយំ

ឯវមេវាហំ បុញ្ញកាមោ ទិស្វា ខេត្តំ វរុត្តមំ
យទិ(១) ការំ ន ការេមិ នាហំ បុញ្ញេន អត្ថិកោ ។
យថា អមច្ចោ មុទ្ទកាមោ(២) រញ្ញោ អន្តេបុរេ ជនេ
ន ទេតិ តេសំ ធនធញ្ញំ មុទ្ទតោ បរិហាយតិ ។
ឯវមេវាហំ បុញ្ញកាមោ វិបុលំ ទិស្វាន ទក្ខិណំ
យទិ តត្ថ ទានំ ន ទទាមិ បរិហាយិស្សាមិ បុញ្ញតោ ។
ឯវាហំ ចិន្តយិត្វាន ឱរោហិត្វា ឧបាហនា
តស្ស បាទានិ វន្ទិត្វា អទាសិំ ឆត្តុបាហនំ ។
តេនាហំ សតគុណតោ សុខុមាលោ សុខេធិតោ
អបិច ទានំ បរិបូរេន្តោ ឯវំ តស្ស អទាសហន្តិ ។

សង្ខព្រាហ្មណចរិយំ ទុតិយំ ។

---

១ ឱ. ម. ឯត្ថន្តរេ ឥត្ថាតិ ទិស្សតិ ។ ២ ឱ. ម. មុទ្ទិកាមោ ។

## សង្ខព្រាហ្មណចរិយា ទី ២

តថាគត ជាអ្នកបង់បានបុណ្យ បើឃើញស្រែបុណ្យដ៏ប្រសើរថៃថ្លាហើយ មិនធ្វើសក្ការៈទេ តថាគត ឈ្មោះថាជាអ្នកមិនត្រូវការដោយបុណ្យ យ៉ាងនោះឯង ។ ម្យ៉ាងទៀត ប្រៀបដូចអាមាត្យ មានប្រាថ្នាជាធំក្នុងក្រសួងត្រា (ហើយបណ្តេញ) ពួកជនក្នុងវាំងរបស់ស្តេច មិនឲ្យទ្រព្យនិងស្រូវដល់ជនទាំងនោះ អាមាត្យនោះ រមែងសាបសូន្យចាកត្រា យ៉ាងណាមិញ តថាគត ជាអ្នកប្រាថ្នាបុណ្យ បានឃើញទក្ខិណេយ្យបុគ្គលដ៏ធំទូលាយ ហើយមិនឲ្យទាន ដល់ទក្ខិណេយ្យបុគ្គលនោះ តថាគត រមែងសាបសូន្យចាកបុណ្យ ក៏យ៉ាងនោះដែរ ។ តថាគត លុះគិតឃើញយ៉ាងនេះហើយ ក៏ដោះស្បែកជើង ថ្វាយបង្គំព្រះបាទា នៃព្រះបច្ចេកពុទ្ធនោះ រួចប្រគេនឆ័ត្រនិងស្បែកជើង ។ ហេតុនោះ បានជាតថាគត ចម្រើនដោយសេចក្តីសុខ ដល់នូវសេចក្តីសុខ ដោយរយគុណ ម្យ៉ាងទៀត តថាគតកាលបំពេញទាន ក៏បានឲ្យទាន ដល់ព្រះបច្ចេកពុទ្ធ យ៉ាងនេះឯង ។

ចប់ សង្ខព្រាហ្មណចរិយា ទី ២ ។

## តតិយំ កុរុធម្មចរិយំ

(៣) បុនាបរំ យទា ហោមិ ឥន្ទបត្តេ បុរុត្តមេ
រាជា ធនញ្ចយោ នាម កុសលេ ទសហុបាគតោ ។
កាលិង្គរដ្ឋវិសយា ព្រាហ្មណា ឧបគច្ឆុ មំ
អាយាចុំ មំ ហត្ថិនាគំ ធញ្ញំ មង្គលសម្មតំ ។
អវុដ្ឋិកោ ជនបទោ ទុព្ភិក្ខោ ឆាតកោ មហា
ទទាហិ បវរំ នាគំ នីលំ អញ្ជនសវ្ហយំ ។
ន មេ យាចកមនុប្បត្តេ បដិក្ខេបោ អនុច្ឆវោ
មា មេ ភិជ្ជិ សមាទានំ ទស្សាមិ វិបុលំ គជំ ។
នាគំ គហេត្វា សោណ្ឌាយ ភិង្ការេ រតនាមយេ
ជលំ ហត្ថេ អាកិរិត្វា ព្រាហ្មណានំ អទំ គជំ ។
តស្ស(១) នាគេ បទិន្នម្ហិ អមច្ចា ឯតទព្រវុំ
កឹ នុ តុយ្ហំ វរំ នាគំ យាចកានំ បទស្សសិ ។

---
១ ឱ. តស្មឹ ។

# កុរុធម្មចរិយា ទី ៣

(៣) ចរិយាដទៃទៀត កាលតថាគតជាស្តេច ឈ្មោះធនញ្ជ័យ នៅក្នុងឥន្ទបត្តបុរី ដ៏ឧត្តម ប្រកបដោយកុសលធម៌ ១០ ។ ព្រាហ្មណ៍ទាំងឡាយ នៅក្នុងដែនកាលិង្គៈ ចូលទៅរកតថាគត សូមដំរីដ៏ប្រសើររបស់តថាគត ជាដំរីនាំឲ្យបានទ្រព្យ ដែលគេសន្មតថាជាសត្វមង្គល ដោយពាក្យថា ជនបទ (នៃយើងខ្ញុំ ព្រះអង្គ) មិនមានភ្លៀង ទុរ្ភិក្សអត់ឃ្លានខ្លាំងណាស់ សូមព្រះអង្គប្រទានដំរីប្រសើរ ដែលមានសម្បុរខ្មៅ ឈ្មោះអញ្ជន ។ បើសូមមកដល់ហើយ តថាគតមិនគួរប្រកែក ការសមាទានរបស់តថាគត កុំបែកធ្លាយឡើយ ដូច្នេះ តថាគត នឹងឲ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ ស្រួចទឹកកុណ្ឌី ជាវិការៈនៃកែវលើដៃព្រាហ្មណ៍ ហើយឲ្យដំរីដល់ព្រាហ្មណ៍ ។ កាលតថាគត បានឲ្យដំរី ដល់ពួកព្រាហ្មណ៍ហើយ មានពួកអាមាត្យក្រាបទូលពាក្យនេះថា ហេតុដូចម្តេច បានជាព្រះអង្គ

ធញ្ញំ មង្គលសម្បន្នំ សង្គាមវិជយុត្តមំ
តស្ស(១) នាគេ បទិន្នម្ហិ កិន្តេ រជ្ជំ ករិស្សតិ ។
រជ្ជម្បិ មេ ទទេ សព្វំ សរីរំ ទជ្ជមត្តនោ
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា នាគំ អទាសហន្តិ ។

កុរុធម្មចរិយំ តតិយំ ។

# ចតុត្ថំ មហាសុទស្សនចរិយំ

(៤) កុសាវតិម្ហិ នគរេ យទា អាសឹ មហីបតិ
មហាសុទស្សនោ នាម ចក្កវត្តិ មហព្វលោ ។
តត្ថាហំ ទិវសេ តិក្ខត្តុំ ឃោសាបេមិ តហឹ តហឹ
កោ កឹ ឥច្ឆតិ បត្ថេតិ កស្ស កឹ ទិយ្យតុ ធនំ ។

---

១ ឱ. ម. តស្មឹ ។

ប្រទានដំរីដ៏ប្រសើរ របស់ព្រះអង្គ ដែលជាដំរីនាំឲ្យបានទ្រព្យ ប្រកបដោយមង្គល ជាដំរីឧត្តមក្នុងសង្គ្រាមជ័យ ដល់ពួកស្មូម កាលបើព្រះអង្គ ប្រទានដំរីដ៏ប្រសើរ ដល់ពួកស្មូមនោះហើយ ព្រះអង្គសោយរាជ្យធ្វើអ្វី ។ តថាគតតបថា តថាគតអាចនឹងឲ្យរាជ្យទាំងអស់ របស់តថាគត ដល់ស្មូមក៏បាន ឬនឹងឲ្យសិរៈរបស់ខ្លួន ដល់ពួកស្មូមក៏បាន ដ្បិតសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់ របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យដំរីដ៏ប្រសើរ ។

ចប់ កុរុធម្មចរិយា ទី ៣ ។

# មហាសុទស្សនចរិយា ទី ៤

(៤) កាលតថាគត ជាក្សត្រចក្រពត្តិ ឈ្មោះមហាសុទស្សនៈ មានពលច្រើន នៅក្នុងនគរកុសាវតី ។ ក្នុងនគរនោះ តថា-គត បានឲ្យគេឃោសនា ក្នុងមួយថ្ងៃ ៣ ដង ក្នុងទីនោះ ៗ ថា អ្នកណាប្រាថ្នាចង់បានអ្វី ចូរឲ្យនូវទ្រព្យអ្វី ដល់អ្នកណា ៗ

កោ ឆាតកោ កោ តសិតោ　កោ មាលំ កោ
វិលេបនំ

នានារត្តានិ វត្ថានិ　កោ នគ្គោ បរិទហិស្សតិ
កោ បថេ ឆត្តមាទេតិ　កោ ឧបាហនា មុទូ សុភា(១) ។
ឥតិ សាយញ្ច បាតោ ច　ឃោសាបេតិ តហឹ តហឹ
ន តំ ទសសុ ឋានេសុ　ន បិ(២) ឋានសតេសុ វា ។
អនេកសតឋានេសុ　បដិយត្តំ យាចកេ ធនំ
ទិវា វា យទិ វា រត្តឹ　យទិ ឯតិ វណិព្វកោ ។
លទ្ធា យទិច្ឆកំ ភោគំ　បូរហត្ថោវ គច្ឆតិ
ឯវរូបំ មហាទានំ　អទាសិ យាវជីវិកំ ។
ន ចាហំ ទេស្សំ ធនំ ទម្មិ　នបិ នត្ថិ និចយោ មយិ
យថាបិ អាតុរោ នាម　រោគតោ បរិមុត្តិយា ។
ធនេន វេជ្ជំ តប្បេត្វា　រោគតោ បរិមុច្ចតិ
តថេវាហំ ជានមានោ　បរិបូរេតុំ អសេសតោ ។

---

១ ឱ. សភា ។ ២ ឱ. ម. បិសទ្ទោ ទិស្សតិ ។

អ្នកណាឃ្លាន អ្នកណាស្រេក អ្នកណា (ប្រាថ្នា) នូវកម្រងផ្កា អ្នកណា (ប្រាថ្នា) នូវគ្រឿងលាប អ្នកណា អាក្រាត នឹងស្លៀកដណ្តប់នូវសំពត់ទាំងឡាយ ដែលជ្រលក់ដោយពណ៌ផ្សេង ៗ អ្នកណាយកឆត្រ (ដើម្បីបាំង) ក្នុងផ្លូវ អ្នកណា យកស្បែកជើងដ៏ទន់ល្អ (ដើម្បីពាក់ក្នុងផ្លូវ) ៗ តថាគតឲ្យគេឃោសនា ក្នុងវេលាព្រឹក (ថ្ងៃត្រង់) ល្ងាច ក្នុងទីនោះ ៗ ដូចបានពោលហើយ ក្នុងខាងលើ ទាននោះ តថាគត មិនមែនចាត់ចែងតែក្នុងទី ១០ កន្លែង មិនមែនចាត់ចែងតែក្នុងទី មួយរយកន្លែងទេ ៗ ទ្រព្យដែលតថាគតចាត់ចែងចំពោះស្មូម ក្នុងទីច្រើនរយកន្លែង សម្រាប់ពួកវណិព្វកៈដែលមកក្នុងវេលាថ្ងៃ ឬមកក្នុងវេលាយប់ ៗ ពួកស្មូមលុះតែបានភោគៈគួរតាមសេចក្តីប្រាថ្នា ពេញក្នុងដៃហើយ ទើបបានដើរចេញទៅ តថាគតបានឲ្យមហាទានបែបនេះ ដរាបដល់អស់ជីវិត ៗ តថាគតមិនឲ្យទ្រព្យ ដែលមិនជាទីគាប់ចិត្តទេ ម្យ៉ាងទៀត តថាគតមិនមែនជាអ្នកមិនសន្សំទ្រព្យទុកទេ ដូចបុរសកើតរោគក្តៅក្រហាយ ចង់ជារោគ ញុំាងពេទ្យឲ្យស្កប់ស្កល់ដោយទ្រព្យ រមែងរួចចាករោគយ៉ាងណាមិញ តថាគតកាលដឹងច្បាស់ថា (ការឲ្យទានជាឧបាយ) ដើម្បីបំពេញអធ្យាស្រ័យ របស់សត្វ ដោយមិនមានសេសសល់

ឩនមនំ(១) បូរយិតុំ ទេមិ ទានំ វណិព្វកេ

និរាលយោ អបច្ចាសោ(២) សម្ពោធិមនុបត្តិយាតិ ។

មហាសុទស្សនចរិយំ ចតុត្ថំ ។

## បញ្ចមំ មហាគោវិន្ទចរិយំ

(៥) បុនាបរំ យទា ហោមិ សត្តរជបុរោហិតោ

បូជិតោ នរទេវេហិ មហាគោវិន្ទព្រាហ្មណោ ។

តទាហំ សត្តរជ្ជេសុ យំ មេ អាសិ ឧបាយនំ

តេន ទេមិ មហាទានំ អក្ខោភំ សាគរូបមំ ។

ន មេ ទេស្សំ ធនធញ្ញំ នបិ នត្ថិ និចយោ មយិ

សព្វញ្ញុតំ បិយំ មយ្ហំ តស្មា ទេមិ វរំ ធនន្តិ ។

មហាគោវិន្ទចរិយំ បញ្ចមំ ។

---

១ ឱ. ឧនមនំ ។ ២ ឱ. អបច្ចាសេក ។

តថាគតឲ្យទាន ចំពោះសម្ពុទ្ធ ដើម្បីបំពេញចិត្តសម្ពុទ្ធ ដែលខ្ពស់កន្ទុះ តថាគតជាអ្នកមិនមានអាល័យ មិនមានសេចក្តីប្រុងប្រឹង (ចំពោះផលនៃទាននោះទេ តថាគតឲ្យទាន) ដើម្បីបាន ត្រាស់ដឹង នូវសព្វញ្ញុតញ្ញាណ យ៉ាងនេះឯង ។

ចប់ មហាសុទស្សនចរិយា ទី ៤ ។

# មហាគោវិន្ទចរិយា ទី ៥

[៥] ចរិយាដទៃទៀត កាលតថាគតកើតជាមហាគោវិន្ទព្រាហ្មណ៍ បានជាបុរោហិតនៃស្តេច ៧ អង្គ ជាបុរោហិតដែលមនុស្សនិងទេវតាបូជាហើយ ។ សួយសារអាករណា ដែលកើតដល់តថាគត ក្នុងរាជ្យនៃស្តេចទាំង ៧ អង្គ ក្នុងកាលនោះ តថាគតបានឲ្យនូវមហាទាន ជាទានមិនកម្រើក ដូចជាសាគរ ដោយសួយសារអាករនោះ ។ ទ្រព្យនិងស្រូវ មិនមែនជាទីស្អប់ខ្ពើមរបស់តថាគតទេ ទាំងការសន្សំទ្រព្យនៃតថាគត មិនមែនជាមិនមានទេ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យទ្រព្យដ៏ប្រសើរ ។

ចប់ មហាគោវិន្ទចរិយា ទី ៥ ។

# ឆដ្ឋមំ នេមិរាជចរិយំ

(៦) បុនាបរំ យទា ហោមិ មិថិលាយំ បុរុត្តមេ
និមិ នាម មហារាជា បណ្ឌិតោ កុសលត្ថិកោ ។
តទាហំ មាបយិត្វាន ចតុស្សាលំ ចតុម្មុខំ
តត្ថ ទានំ បវត្តេសឹ មិគបក្ខិនរាទិនំ ។
អច្ឆាទនំ សយនញ្ច អន្នំ បានញ្ច ភោជនំ
អព្វោច្ឆិន្នំ ករិត្វាន មហាទានំ បវត្តយឹ ។
យថាបិ សេវកោ សាមឹ ធនហេតុមុបាគតោ
កាយេន វាចាមនសា អារាធនីយមេសតិ ។
តថេវាហំ សព្វភវេ បរិយេសិស្សាមិ ពោធិជំ
ទានេន សត្តេ តប្បេត្វា ឥច្ឆាមិ ពោធិមុត្តមំ ។

នេមិរាជចរិយំ ឆដ្ឋមំ ។

# នេមិរាជចរិយា ទី ៦

(៦) ចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចធំ ឈ្មោះនេមិ ជាបណ្ឌិត អ្នកត្រូវការដោយកុសល នៅក្នុងក្រុងដ៏ប្រសើរ ឈ្មោះមិថិលា ។ កាលនោះ តថាគតបានឲ្យគេស្ថាបនាសាលាបួនខ្នង មានមុខ ៤ ហើយញុំាងទានឲ្យប្រព្រឹត្តទៅ ដល់ពួកម្រឹគ បក្សីនិងមនុស្សជាដើម ក្នុងសាលានោះ ។ តថាគតបានធ្វើ នូវសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក បាយ ទឹកនិងភោជន ឲ្យជារបស់ប្រព្រឹត្តទៅមិនដាច់ ហើយញុំាងមហាទាន ឲ្យប្រព្រឹត្តទៅ ។ សេវកាមាត្យ ចូលទៅរកចៅហ្វាយនាយ ព្រោះហេតុចង់បានទ្រព្យ ហើយស្វែងរកហេតុដែលគួររីករាយ ដោយកាយ ឬដោយវាចាចិត្ត (ផ្គាប់ចិត្តចៅហ្វាយនាយ) យ៉ាងណា ។ តថាគតនឹងស្វែងរក នូវពូជនៃពោធិញ្ញាណក្នុងភពទាំងពួង ញុំាងសត្វឲ្យស្កប់ស្កល់ ដោយទាន ហើយប្រាថ្នានូវពោធិញ្ញាណដ៏ឧត្តម យ៉ាងនេះឯង ។

ចប់ នេមិរាជចរិយា ទី ៦ ។

# សត្តមំ ចន្ទកុមារចរិយំ

(៧) បុនាបរំ យទា ហោមិ ឯករាជស្ស អត្រជោ
នគរេ បុប្ផវតិយា កុមារោ ចន្ទសវ្ហយោ ។
តទាហំ យជនា មុត្តោ និក្ខន្តោ យញ្ញវាដតោ
សំវេគំ ជនយិត្វាន មហាទានំ បវត្តយឹ ។
នាហំ បិវាមិ ខាទាមិ នបិ ភុញ្ជាមិ ភោជនំ
ទក្ខិណេយ្យេ អទត្វាន អបិ ឆប្បញ្ចរត្តិយោ ។
យថាបិ វាណិជោ នាម កត្វាន ភណ្ឌសញ្ចយំ
យត្ថ លាភោ មហា ហោតិ តត្ថ តំ ហរតិ ភណ្ឌកំ ។
តថេវ សកភុត្តម្បិ បរេ ទិន្នំ មហប្ផលំ
តស្មា បរស្ស ទាតព្វំ សតភាគោ ភវិស្សតិ ។
ឯតមត្ថវសំ ញត្វា ទេមិ ទានំ ភវាភវេ
ន បដិក្កមាមិ ទានតោ សម្ពោធិមនុបត្តិយា ។

ចន្ទកុមារចរិយំ សត្តមំ ។

# ចន្ទកុមារចរិយា ទី ៧

(៧) មានចរិយាដទៃទៀត កាលដែលតថាគត ជាឱរស ឈ្មោះចន្ទកុមារ របស់ស្តេច ព្រះនាមឯករាជ នៅក្នុងក្រុងបុប្ផវតី ។ កាលនោះ តថាគតរួចអំពីការដែលគេត្រូវសម្លាប់ ចេញផុតពីទីយញ្ញនោះហើយ ក៏កើតសេចក្តីសង្វេគ បានញុំាងមហាទាន ឲ្យប្រព្រឹត្តទៅ ។ តថាគត បើមិនទាន់បានឲ្យទេយ្យធម៌ ចំពោះទក្ខិណេយ្យបុគ្គលទេ តថាគតក៏មិនផឹក មិនទំពាស៊ី មិនបរិភោគភោជន អស់ចំនួន ៥ ឬ ៦ រាត្រី ។ ពាណិជ ធ្វើការសន្សំទ្រព្យ (បើដឹងថា) ទីណា មានលាភច្រើន ក៏នាំកណ្ឌៈទៅក្នុងទីនោះ យ៉ាងណា ។ វត្ថុដែលត្រូវបរិភោគខ្លួនឯង បើឲ្យដល់បដិគ្គាហកដទៃ ជាវត្ថុមានផលច្រើន ហេតុនោះ ត្រូវតែឲ្យដល់បុគ្គលដទៃវិញ ទឹងមានផល ១០០ ភាគ ក៏យ៉ាងនោះដែរ ។ តថាគតដឹងនូវអំណាចនៃហេតុនុះហើយ ទើបឲ្យទានក្នុងភពតូចនិងភពធំ មិនគេចចេញចាកទាន ដើម្បីបានត្រាស់ដឹងនូវសម្ពោធិញ្ញាណ ។

ចប់ ចន្ទកុមារចរិយា ទី ៧ ។

# អដ្ឋមំ សិវិរាជចរិយំ

(៨) អរិដ្ឋសវ្ហយេ នគរេ សិវិនាមាសិ ខត្តិយោ
និសជ្ជ បាសាទវរេ ឯវំ ចិន្តេសហំ តទា ។
យំ កិញ្ចិ មានុសំ ទានំ អទិន្នំ មេ ន វិជ្ជតិ
យោបិ យាចេយ្យ មំ ចក្ខុំ ទទេយ្យំ អវិកម្បិតោ ។
មម សង្កប្បមញ្ញាយ សក្កោ ទេវានមិស្សរោ
និសិន្នោ ទេវបរិសាយ ឥទំ វចនមព្រវិ
និសជ្ជ បាសាទវរេ សិវិរាជា មហិទ្ធិកោ
ចិន្តេន្តោ វិវិធំ ទានំ អទេយ្យំ សោ ន បស្សតិ ។
តថំ នុ វិតថំ នេតំ ហន្ទ វីមំសយាមិ តំ
មុហុត្តំ អាគមេយ្យាថ យាវ ជានាមិ តំ មនំ ។
បវេធមានោ បលិតសិរោ វលិតគត្តោ ជរាតុរោ
អន្ធវណ្ណោវ ហុត្វាន រាជានំ ឧបសង្កមិ ។

# សិវិរាជចរិយា ទី ៨

[៨] កាលតថាគត ជាក្សត្រឈ្មោះសិវិ សោយរាជ្យក្នុងនគរអរិដ្ឋៈ អង្គុយក្នុងប្រាសាទដ៏ប្រសើរ តថាគតគិតយ៉ាងនេះថា ទានណាមួយ ជារបស់មនុស្ស ទាននោះ គឺអញមិនដែលឲ្យហើយ មិនមានឡើយ បើមានយាចកណាមកសូមភ្នែកអញ អញនឹងមិនញាប់ញ័រ ត្រូវតែឲ្យ (ដល់យាចកនោះ) ។ សក្កៈជាធំជាងពួកទេវតា បានដឹងនូវសេចក្តីត្រិះរិះរបស់តថាគត អង្គុយនៅក្នុងទេវបរិស័ទ ក៏ពោលនូវពាក្យនេះថា ស្តេចសិវិមានឫទ្ធិច្រើន គង់ក្នុងប្រាសាទដ៏ប្រសើរ កំពុងពិចារណានូវទានផ្សេងៗ (ដែលខ្លួនឲ្យហើយ) ស្តេចនោះមិនឃើញនូវវត្ថុ ដែលខ្លួនមិនធ្លាប់ឲ្យសោះឡើយ ។ ការណ៍នុ៎ះពិត ឬមិនពិតអេះ បើដូច្នេះ អញនឹងល្បងស្តេចនោះមើល អ្នកទាំងឡាយ ចូររង់ចាំមួយរំពេច ទំរាំយើងបានដឹងនូវព្រះរាជហឫទ័យនៃស្តេចនោះ (ព្រះឥន្ទ្រក៏ក្លែងខ្លួនជាព្រាហ្មណ៍) មានសក់ស្កូវ មានខ្លួនជ្រួញជ្រីវ ទ្រទ្រង់ដោយជរា ព្រមទាំងមានសម្បុរអាក្រក់ ដើរញញាក់ញញ័រ ចូលទៅរកព្រះរាជា ។

## អដ្ឋមំ សិវិរាជចរិយំ

សោ តទា បគ្គហេត្វាន    វាមំ ទក្ខិណពាហុញ្ច
សិរស្មឹ អញ្ជលឹ កត្វា    ឥទំ វចនមព្រវិ
យាចាមិ តំ មហារាជ    ធម្មិក រដ្ឋវឌ្ឍន
តវ ទានរតា កិត្តិ    ឧគ្គតា ទេវមានុសេ ។
ឧភោបិ នេត្តា នយនា    អន្ធា ឧបហតា មម
ឯកំ មេ នយនំ ទេហិ    ត្វម្បិ ឯកេន យាបយ ។
តស្សាហំ វចនំ សុត្វា    ហដ្ឋោ សំវិគ្គមានសោ
កតញ្ជលី វេទជាតោ    ឥទំ វចនមព្រវឹ ។
ឥទានាហំ ចិន្តយិត្វាន    បាសាទតោ ឥធាគតោ
ត្វំ មម ចិត្តមញ្ញាយ    នេត្តំ យាចិតុមាគតោ ។
អហោ មេ មានសំ សិទ្ធំ    សង្កប្បោ មេ បរិបូរិតោ
អទិន្នបុព្វំ ទានវរំ    អជ្ជ ទស្សាមិ យាចកេ ។

## សិរីភាងពរិយោ ទី ៨

គ្រានោះ ព្រាហ្មណ៍នោះ ផ្គងដៃឆ្វេងនិងដៃស្តាំ ហើយធ្វើអញ្ជលីលើសិរ្សៈ ពោលពាក្យនេះថា បពិត្រធម្មិកមហារាជ ជាអ្នកញ៉ាំងដែនឲ្យចម្រើន ខ្ញុំព្រះអង្គសូមអង្វរព្រះអង្គ កិត្តិ-ស័ព្ទរបស់ព្រះអង្គ ថាត្រេកអរក្នុងទាន ល្បីខ្ទ័រទៅក្នុងទេវ-លោកនិងមនុស្សលោក ។ ភ្នែកទាំងពីរនៃទូលព្រះបង្គំ ត្រូវងងឹតបៀតបៀនហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រមួយដល់ទូលព្រះបង្គំ ចំណែកព្រះអង្គ សូមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយព្រះនេត្រម្ខាងចុះ ។ តថាគតឮពាក្យនៃព្រាហ្មណ៍នោះហើយ ក៏រីករាយ មានចិត្តសង្វេគ ធ្វើអញ្ជលី មានសេចក្តីត្រេកអរ ហើយពោលថា ខ្ញុំទើបនឹងគិតឃើញអម្បាញ់មិញនេះ ហើយចុះអំពីប្រាសាទមកក្នុងទីនេះ អ្នកទំនងជាដឹងចិត្តខ្ញុំ ទើបមកសូមភ្នែកខ្ញុំ ឱហ្ន៎ ! សេចក្តីប្រាថ្នាក្នុងចិត្តនៃខ្ញុំ សម្រេចហើយ សេចក្តីត្រិះរិះនៃខ្ញុំ ពេញហើយ ទានដ៏ប្រសើរដែលខ្ញុំមិនធ្លាប់ឲ្យ ខ្ញុំនឹងឲ្យដល់ស្មូមក្នុងថ្ងៃនេះ ។

ឯហិ សិវក ឧដ្ឋេហិ មា ទន្ធយិ មា បវេធយិ
ឧភោបិ នយនំ ទេហិ ឧប្បាដេត្វា វណិព្វកេ ។
តតោ សោ ចោទិតោ មយ្ហំ សិវកោ វចនង្ករោ
ឧទ្ធរិត្វាន បាទាសិ តាលមិញ្ជំវ យាចកេ ។
ទទមានស្ស ទេន្តស្ស ទិន្នទានស្ស មេ សតោ
ចិត្តស្ស អញ្ញថា នត្ថិ ពោធិយាយេវ ការណា ។
ន មេ ទេស្សា ឧភោ ចក្ខុ អត្តាបិ មេ ន ទេស្សិយោ
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា ចក្ខុំ អទាសហំ ។

សិវិរាជចរិយំ អដ្ឋមំ ។

ម្នាលពេទ្យឈ្មោះសិវកៈ អ្នកចូរមក ចូរក្រោកឡើង កុំបង្អង់ឲ្យយឺតយូរឡើយ កុំញាប់ញ័រ ចូរឆ្កៀលភ្នែកទាំងពីរ (របស់អញ) ហើយឲ្យដល់សួម ៗ លំដាប់នោះ ពេទ្យសិវកៈនោះដែលតថាគតដាស់តឿនហើយ ក៏ធ្វើតាមពាក្យតថាគត បានខ្វេះឆ្កៀល (ភ្នែកតថាគត) ហើយប្រគល់ឲ្យដល់សួម ដូចជាឲ្យសាប់ស្នាត ៗ ក្នុងកាលមុនឲ្យក្តី កំពង់ឲ្យក្តី ឲ្យរួចហើយក្តី ចិត្តរបស់តថាគត ឥតមានការពាយមាយឡើយ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ៗ ភ្នែកទាំងពីរ មិនមែនជាទីស្អប់ របស់តថាគតទេ ទាំងខ្លួនសោតទៀត ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតឲ្យចក្ខុ ៗ

ចប់ សិវិរាជចរិយា ទី ៨ ។

# ទសមំ វេស្សន្តរចរិយំ

(៩) យា មេ អហោសិ ជនិកា ផុស្សតី នាម ខត្តិយា
សា អតីតាសុ ជាតីសុ សក្កស្ស មហេសី សិយា(១)។
តស្សា អាយុក្ខយំ ញត្វា(២) ទេវិន្ទោ ឯតទព្រវិ
ទទាមិ តេ ទសវរេ   វរភទ្ទេ យទិច្ឆសិ ។
ឯវំ វុត្តា ច សា ទេវី   សក្កំ បុនិទមព្រវិ
កឹ នុ មេ អបរាធត្ថិ   កឹ នុ ទេស្សា អហំ តវ
រម្មា ឋានា ចាវេសិ មំ   វាតោវ ធរណីរុហំ ។
ឯវំ វុត្តាយ(៣) សោ សក្កោ   បុន តស្សិទមព្រវិ
ន ចេវ តេ កតំ បាបំ   ន ច មេ ត្វំសិ អប្បិយា ។
ឯត្តកំយេវ តេ អាយុ   ចវនកាលោ ភវិស្សតិ
បដិគ្គណ្ហ មយា ទិន្នេ   វរេ ទស វរុត្តមេ ។

---

១ ឱ. ប. មហេសិយា ។ ម. មហេសី បិយា ។ ២ ម. ញត្វា ។ ៣ ឱ. វុត្តេ ច ។

# វេស្សន្តរបរិយា ទី ៩

(៩) ព្រះនាងផុស្សតី ខត្តិយកញ្ញា ជាព្រះជននីរបស់តថាគត ព្រះនាងផុស្សតីនោះ ជាព្រះមហេសីនៃសក្កទេវរាជ ក្នុងអតីតជាតិទាំងឡាយ ។ ព្រះឥន្ទ្រទ្រង់ជ្រាប នូវការអស់ទៅនៃអាយុ របស់ព្រះនាងហើយ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលនាងដ៏ចំរើន យើងនឹងឲ្យនូវពរ ១០ ប្រការ ដល់នាង បើនាងប្រាថ្នានូវពរណា ចូរទទួលយក នូវពរនោះចុះ ។ ព្រះនាងទេវីនោះ កាលបើព្រះឥន្ទ្រពោលយ៉ាងនេះហើយ ក៏ពោលពាក្យនេះ តបនឹងព្រះឥន្ទ្រវិញថា ខ្ញុំមានទោសកំហុសដូចម្តេច ខ្ញុំជាទីស្អប់របស់ព្រះអង្គ យ៉ាងណាទៅ បានជាព្រះអង្គញុំាងខ្ញុំឲ្យឃ្លាតចាកមរណីយដ្ឋាន ដូចជាខ្យល់បក់បោករំលំនូវរុក្ខជាតិ ដែលដុះលើផែនដីដូច្នោះ ។ សក្កទេវរាជនោះ លុះឮព្រះនាងផុស្សតី ពោលយ៉ាងនេះហើយ ក៏ត្រាស់ពាក្យនេះ តបនឹងព្រះនាងវិញថា អំពើដ៏លាមក នាងមិនបានធ្វើទេ នាងមិនមែនជាទីស្អប់នៃយើងទេ ។ អាយុរបស់នាងត្រឹមតែប៉ុណ្ណោះ កាលជាទីច្យុតនឹងមាន ( ដល់នាង ) ចូរនាង ទទួលយកពរ ដ៏ប្រសើរ ឧត្តម ១០ ប្រការ ដែលយើងឲ្យនេះចុះ ។

សក្កេន សា ទិន្នវរា តុដ្ឋហដ្ឋា បមោទិតា
មមំ អព្ភន្តរំ កត្វា ផុស្សតី ទស វរេ វរិ ។
តតោ ចុតា សា ផុស្សតី ខត្តិយេ ឧបបជ្ជថ
ជេតុត្តរម្ហិ នគរេ សញ្ជយេន សមាគមិ ។
យទាហំ ផុស្សតិយា កុច្ឆឹ ឱក្កន្តោ បិយមាតុយា
មម តេជេន មេ មាតា សទា ទានរតា អហុ ។
អធនេ អាតុរេ ជិណ្ណេ យាចកេ អទ្ធិកេ ជនេ
សមណេ ព្រាហ្មណេ ខីណេ ទេតិ ទានំ អកិញ្ចនេ ។
ទស មាសេ ធារយិត្វា ករោន្តេ បុរំ បទក្ខិណំ
វេស្សានំ វីថិយា មជ្ឈេ ជនេសិ ផុស្សតី មមំ ។
ន មយ្ហំ មត្តិកំ(១) នាមំ នបិ បេត្តិកសម្ភវំ
ជាតេត្ថ(២) វេស្សវីថិយំ តស្មា វេស្សន្តរោ អហុ ។

---

១ ឱ. មេត្តិកំ ។ ២ ឱ. ម. ជាតោម្ហីតិ ទិស្សតិ ។

ព្រះនាងផុស្សតីនោះ បានទទួលពរដែលសក្កទេវរាជឲ្យហើយ ក៏មានព្រះហឫទ័យ ត្រេកអររីករាយ ធ្វើតថាគតឲ្យនៅខាងក្នុង (ពរទាំងនោះ) ហើយទទួលយកពរទាំង ១០ ប្រការ ។ ព្រះនាងផុស្សតីនោះ លុះច្យុតចាកឋានទេវលោកនោះហើយ មកកើតក្នុងត្រកូលក្សត្រ ហើយមកគប់ប្រសព្វនឹងសញ្ជយរាជកុមារ ក្នុងជេតុត្តរនគរ ។ កាលណា តថាគតចុះមកកាន់ផ្ទៃ នៃនាងផុស្សតីជារាជមាតា ដែលជាទីស្រឡាញ់ ក្នុងកាលនោះ ដោយតេជានុភាពរបស់តថាគត មាតានៃតថាគត ក៏ត្រេកអរក្នុងទានសព្វ ៗ កាល ។ ព្រះនាងផុស្សតីនោះ ទ្រង់បរិច្ចាគទាន ដល់ពួកជនអ្នកឥតទ្រព្យ ពួកជនឈឺជាទិច្ច ពួកជនចាស់ជរា ពួកយាចក ពួកអ្នកដំណើរនិងពួកសមណព្រាហ្មណ៍ ដែលមានអាសវៈអស់ហើយ មិនមានកិលេសជាគ្រឿងកង្វល់ ។ កាលព្រះនាងផុស្សតីទេវីនោះ ទ្រង់គភ៌គ្រប់ ១០ ខែហើយ ព្រះបាទសញ្ជយមហារាជ ទ្រង់នាំព្រះនាងទៅធ្វើប្រទក្សិណបុរី ព្រះនាងប្រសូតតថាគត ត្រង់កណ្ដាលថ្នល់នៃអ្នកដំនួញ ។ ឈ្មោះរបស់តថាគត មិនមែនជាប់មកអំពីមាតា មិនមែនជាប់មកអំពីបិតាទេ គឺព្រោះតែតថាគត កើតត្រង់កណ្ដាលថ្នល់អ្នកដំនួញ ហេតុនោះបានជាឈ្មោះថាវេស្សន្តរ ។

## នវមំ វេស្សន្តរចរិយំ

យទាហំ ទារកោ ហោមិ ជាតិយា អដ្ឋវស្សិកោ
តទា និសជ្ជ បាសាទេ ទានំ ទាតុំ វិចិន្តយឹ ។
ហទយំ ទទេយ្យំ ចក្ខុំ មំសំបិ រុធិរំបិ ច
ទទេយ្យំ កាយំ សាវេត្វា យទិ កោចិ យាចយេ មមំ ។
សភាវំ ចិន្តយន្តស្ស អកម្បិតមសណ្ឋិតំ
អកម្បិ តត្ថ បថវី សិនេរុវនវដំសកា ។
អន្វឌ្ឍមាសេ បន្នរសេ បុណ្ណមាសេ ឧបោសថេ
បច្ចយំ នាគមារុយ្ហ ទានំ ទាតុំ ឧបាគមឹ ។
កាលិង្គរដ្ឋវិសយា ព្រាហ្មណា ឧបគច្ឆុ មំ
អយាចុំ មំ ហត្ថិនាគំ ធញ្ញំ មង្គលសម្មតំ ។
អវុដ្ឋិកោ ជនបទោ ទុព្ភិក្ខោ ឆាតកោ មហា
ទទាហិ បវរំ នាគំ សព្វសេតំ គជុត្តមំ ។

## វេស្សន្តរចរិយា ទី ៩

កាលណា តថាគតជាទារក មានអាយុ ៨ ឆ្នាំ អំពីកំណើត ក្នុងកាលនោះ តថាគតអង្គុយក្នុងប្រាសាទ ត្រិះរិះដើម្បីឲ្យនូវអជ្ឈត្តិកទានថា បើអ្នកណា មកសូមតថាគត តថាគតគប្បីឲ្យបេះដូង ឲ្យភ្នែក ឲ្យសាច់និងឈាម ឬក៏គេញុំាងតថាគតឲ្យដឹងឮថា (អ្នកចូរធ្វើជាទាសៈរបស់ខ្ញុំ) តថាគតនឹងព្រមប្រគល់កាយ (ដល់អ្នកនោះ) ។ កាលតថាគត កំពុងគិតនូវភាពដែលមិនញាប់ញ័រ ដែលមិនរួញរា មហាប្រថពីមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រក្នុងទីនោះ ។ តថាគតឡើងជិះដំរីឈ្មោះបច្ច័យ ចូលទៅ (កាន់សាលាទាន) ដើម្បីឲ្យទានក្នុងថ្ងៃឧបោសថ ខែពេញបូណ៌មី ទី ១៥ ក្នុងកន្លះខែជាលំដាប់ ។ ព្រាហ្មណ៍ទាំងឡាយ ដែលនៅក្នុងដែនកាលិង្គៈចូលទៅរកតថាគត សូមដំរីដ៏ប្រសើរ របស់តថាគត ជាដំរីនាំឲ្យបានទ្រព្យ ដែលគេសន្មតជាសត្វមង្គលថា ជនបទ (របស់យើងខ្ញុំព្រះអង្គ) មិនមានភ្លៀង ទុរ្ភិក្សអត់ឃ្លានខ្លាំង សូមព្រះអង្គព្រះរាជទានដំរីប្រសើរ មានអវយវៈសព្វជាដំរីឧត្តម ។

ទទាមិ ន វិកម្បាមិ    យំ មំ យាចន្តិ ព្រាហ្មណា
សន្តំ នប្បដិគុយ្ហាមិ    ទានេ មេ រមតី មនោ ។
ន មេ យាចកមនុប្បត្តេ    បដិក្ខេបោ អនុច្ឆវោ
មា មេ ភិជ្ជិ សមាទានំ    ទស្សាមិ វិបុលំ គជំ ។
នាគំ គហេត្វា សោណ្ឌាយ    ភិង្គារេ រតនាមយេ
ជលំ ហត្ថេ អាកិរិត្វា    ព្រាហ្មណានំ អទំ គជំ ។
បុនាបរំ ទទន្តស្ស    សព្វសេតំ គជុត្តមំ
តទាបិ បថវី កម្បិ    សិនេរុវនវដំសកា ។
តស្ស នាគស្ស ទានេន    សិវយោ កុទ្ធា សមាគតា
បព្វាជេសុំ សកា រដ្ឋា    វង្កំ គច្ឆតុ បព្វតំ ។
តេសំ និច្ឆុភមានានំ    អកម្បិតមសណ្ឋិតំ
មហាទានំ បវត្តេតុំ    ឯកវរមយាចិហំ ។

ព្រាហ្មណ៍ទាំងឡាយ សូមដំរីណា ចំពោះតថាគត តថាគតឲ្យដំរីនោះ ឥតញាប់ញ័រឡើយ តថាគតមិនលាក់លៀម នូវទេយ្យធម៌ដែលមាន ព្រោះចិត្តរបស់តថាគត ត្រេកអរក្នុងទាន ។ កាលបើយាចកមកដល់ហើយ ការប្រកែកក៏មិនសមគួរដល់តថាគត ការសមាទានរបស់តថាគត កុំបីបែកធ្លាយឡើយ ដូច្នេះ តថាគតនឹងឲ្យដំរីប្រសើរ ។ តថាគតចាប់ដំរីត្រង់ប្រមោយ រួចជ្រួចទឹកក្នុងកុណ្ឌី ជាវិការៈនៃកែវ ដាក់លើដៃព្រាហ្មណ៍ ហើយឲ្យដំរីដល់ព្រាហ្មណ៍ ។ កាលតថាគតឲ្យដំរីដ៏ឧត្តមសសុទ្ធ ដទៃទៀត ក្នុងកាលនោះ មហាប្រថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។ ព្រោះតែការឲ្យនូវដំរីនោះ ជាហេតុឲ្យពួកអ្នកដែនសិវិ ខឹងខ្លាំង ក៏មកប្រជុំគ្នា ហើយបណ្ដេញតថាគតចាកដែនរបស់ខ្លួនដោយពាក្យថា សូមព្រះអង្គទៅនៅវង្កតបព៌តទៅ ។ កាលពួកអ្នកដែនសិវិនោះ បណ្ដេញតថាគតឲ្យចេញចាកដែន ចិត្តរបស់តថាគតមិនញាប់ញ័រ មិនតក់ស្លុតទេ តថាគតបានសូមពរមួយដ៏ប្រសើរ នឹងជនទាំងនោះ ដើម្បីញុំាងមហាទានឲ្យប្រព្រឹត្តទៅ ។

## ទសមំ វេស្សន្តរចរិយំ

យាចិតា សិវិយោ សព្វេ  ឯកំ វរមទំសុ មេ
សាវយិត្វា(១) កណ្ណភេរឹ  មហាទានំ ទទាមហំ ។
អថេត្ថ វត្តតី សទ្ទោ  តុមុលោ(២) ភេរវោ មហា
ទានេនិមំ នីហរន្តិ  បុន ទានំ ទទាតយំ(៣) ។
ហត្ថី អស្សេ រថេ ទត្វា  ទាសី ទាសំ គវំ ធនំ
មហាទានំ ទទិត្វាន  នគរា និក្ខមឹ តទា ។
និក្ខមិត្វាន នគរា  និវត្តិត្វា វិលោកិតេ
តទាបិ បថវី កម្បិ  សិនេរុវនវដំសកា ។
ចតុវាហិំ រថំ ទត្វា  ឋត្វា ចតុម្មហាបថេ
ឯកាកិកោ អទុតិយោ  មទ្ទឹ ទេវីមព្រវី ។
ត្វំ មទ្ទិ កណ្ហំ គណ្ហាហិ  លហុកា ឯសា កនិដ្ឋកា
អហំ ជាលឹ គហេស្សាមិ  គរុកោ ភាតិកោ ហិ សោ ។

---

១ ឱ. អាឃោបយិត្វា ។ ២ ឱ. ម. តុម្មុលោ ។ ៣ ឱ. ទទាមហំ ។ ម. ទទាថ យំ ។

## វេស្សន្តរចរិយា ទី ៩

ពួកអ្នកដែនសិវិទាំងអស់ ដែលតថាគតសូមពរហើយ ក៏ឲ្យនូវពរមួយដ៏ប្រសើរ ដល់តថាគត ៗ ញុំាងគេឲ្យដឹងឮដោយស្គរមានត្រចៀកហើយឲ្យមហាទាន ៗ គ្រានោះ សម្លេងកោលាហល ដែលនាំឲ្យភ័យធំ ក៏ប្រព្រឹត្តទៅក្នុងពេលទាននុ៎ះថា (ពួកអ្នកដែនសិវិ) បណ្តេញព្រះបាទវេស្សន្តរនេះ ព្រោះតែទាន ឥឡូវព្រះបាទវេស្សន្តរនេះ នៅតែឲ្យទានទៀត ៗ កាលនោះ តថាគតឲ្យដំរី សេះ រថ ខ្ញុំស្រី ខ្ញុំប្រុស មេគោ និងទ្រព្យ លុះឲ្យមហាទានហើយ ក៏ចេញអំពីនគរ ៗ លុះតថាគតចេញចាកនគរហើយ ក៏ងាកមើលទៅព្រះនគរវិញ កាលនោះមហាប្រថពី ដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ៗ តថាគត ឲ្យនូវរថដែលទឹម ដោយសេះសិន្ធព ៤ ហើយឋិតនៅក្នុងផ្លូវធំ ៤ ជាបុគ្គលតែម្នាក់ឯង មិនមានបុគ្គលជាគំរប់ពីរ និយាយនូវពាក្យនេះ នឹងនាងមទ្រីទេវីថា ម្នាល នាងមទ្រី នាងចូរពកណ្ហាជិនាចុះ ព្រោះកណ្ហាជិនាជាប្អូននេះស្រាល បងនឹងពជាលីកុមារ ព្រោះជាលីកុមារជាបងធ្ងន់ ៗ

បទុមំ បុណ្ឌរីកំវ　　មទ្ទី កណ្ហាជិនំ គហិ
អហំ សុវណ្ណពិម្ពំវ　　ជាលឹ ខត្តិយមគ្គហឹ ។
អភិជាតា សុខុមាលា　　ខត្តិយា ចតុរោ ជនា
វិសមសមំ អក្កមន្តា　　វង្កំ គច្ឆាម បព្វតំ ។
យេ កេចិ មនុជា ឯន្តិ　　អនុមគ្គេ បដិបថេ
មគ្គន្តេ បដិបុច្ឆាម　　កុហឹ វង្កតបព្វតោ ។
តេ តត្ថ អម្ហេ បស្សិត្វា　　ការុណំ គិរមុទីរយុំ(១)
ទុក្ខន្តេ បដិវេទេន្តិ　　ទូរេ វង្កតបព្វតោ ។
យទិ បស្សន្តិ បវនេ　　ទារកា ផលិតេ ទុមេ
តេសំ ផលានំ ហេតុម្ហិ　　ឧបរោទន្តិ ទារកា ។
រោទន្តេ ទារកេ ទិស្វា　　ឧព្ភិទ្ធា វិបុលា ទុមា
សយមេវោនមិត្វាន　　ឧបគច្ឆន្តិ ទារកេ ។

---

១ ស. គិរមុទីរយុំ ។

នាងមទ្រីទេវី ពកណ្ហាជិនា ដូចជាផ្កាឈូកស តបាគតព ក្សត្រជាលី ដូចជារូបភាព ជាវិការៈនៃមាស ៗ ខត្តិយជនទាំង ៤ អង្គ ធ្លាប់ចំរើនដោយសេចក្តីសុខ មានជាតិខ្ពង់ខ្ពស់ កាលស្តេចទៅក្នុងផ្លូវ មិនរាបស្មើខ្លះ រាបស្មើខ្លះ (ដោយគិតថា) យើងនឹងទៅកាន់វង្កតបពិត ៗ បើមនុស្សណាមួយដើរមកក្នុងផ្លូវបណ្តោយគ្នា ឬផ្លូវចួបគ្នា យើងនឹងសាកសួរផ្លូវនឹងមនុស្សទាំងនោះថា វង្កតបពិតនៅក្នុងទីណា ៗ មនុស្សទាំងនោះ ឃើញយើងក្នុងទីនោះ នឹងប្រាប់ (នូវផ្លូវដែលទៅ) កាន់ភ្នំ ដោយសេចក្តីករុណា មនុស្សទាំងនោះ ដឹងនូវទុក្ខ (របស់យើង នឹងប្រាប់ថា) វង្កតបពិត នៅក្នុងទីឆ្ងាយអំពីទីនេះ ៗ បើទារកទាំងពីរ ឃើញឈើមានផ្លែក្នុងព្រៃធំ ព្រោះហេតុនៃផ្លែឈើទាំងនោះ ទារកទាំងពីរនឹងយំទារ ៗ ដើមឈើធំខ្ពស់ទាំងឡាយ ព្រោះឃើញទារកទាំងពីរយំ ក៏ទោរទន់ ចូលមកជិតទារកដោយខ្លួនឯង ៗ

## នវមំ វេស្សន្តរចរិយំ

ឥទំ អច្ឆរិយំ ទិស្វា    អព្ភុតំ លោមហំសនំ
សាធុការំ បវត្តេសិ    មទ្ទី សព្ពង្គសោភណា ។
អច្ឆេរំ វត លោកស្មឹ    អព្ភុតំ លោមហំសនំ
វេស្សន្តរស្ស តេជេន    សយមេវោនតា ទុមា ។
សង្ខិបឹសុ បថំ យក្ខា    អនុកម្បាយ ទារកេ
និក្ខន្តទិវសេនេវ    ចេតរដ្ឋមុបាគមុំ ។
សដ្ឋិរាជសហស្សានិ    តទា វសន្តិ មាតុលា(១)
សព្ពេ បញ្ជលិកា ហុត្វា    រោទមានា ឧបាគមុំ ។
តត្ថ វត្តេត្វា សល្លាបំ    ចេតេហិ ចេតបុត្តេហិ
តេ តតោ និក្ខមិត្វាន    វង្កំ អគមុ បព្វតំ ។
អាមន្តយិត្វា ទេវិន្ទោ    វិស្សុកម្មំ មហិទ្ធិកំ
អស្សមំ សុកតំ រម្មំ    បណ្ណសាលំ សុមាបយ ។

---

១ មាតុលេតិ អដ្ឋកថាយំ ទិស្សតិ ។

## វេស្សន្តរបរិយាយ ទី ៩

នាងមទ្រីមានអវយវៈទាំងអស់ល្អ ឃើញនូវហេតុគួរអស្ចារ្យ បំព្លែកគួរព្រឺរោម ក៏ញុំាងសាធុការឲ្យប្រព្រឹត្តទៅថា ឱហ្ន៎! ហេតុអស្ចារ្យបំព្លែក គួរព្រឺរោមកើតឡើងហើយ ក្នុងលោកនេះ ដោយតេជះនៃព្រះវេស្សន្តរ ដើមឈើទាំងឡាយ ក៏ទោរ-ទន់ចុះមកដោយខ្លួនឯង ៗ ពួកទេវតាបានបម្រួញផ្លូវ ដោយសេចក្ដីអនុគ្រោះចំពោះទារក ញុំាងជនទាំងនោះឲ្យដល់ដែនចេតៈ ក្នុងថ្ងៃដែលខ្លួនចេញទៅ ៗ កាលនោះ ស្ដេចទាំងអស់ ៦០.០០០ អង្គ ដែលនៅក្នុងមាតុលនគរ ក៏ប្រណម្យអញ្ជលីទួញយំ ដើរចូលមកជិត ៗ ក្សត្រទាំង ៤ ព្រះអង្គនោះ និយាយចរចាជាមួយ នឹងស្ដេចចេតៈទាំងឡាយនឹងពួកបុត្ររបស់ស្ដេចចេតៈ ក្នុងទីនោះ ហើយលាចេញពីទីនោះទៅថា យើងនឹងទៅកាន់វង្កតបព៌ត ៗ ព្រះឥន្ទ្រទ្រង់ហៅ នូវវិស្សុកម្មទេវបុត្រ ដែលមានឫទ្ធិច្រើនមកប្រាប់ថា អ្នកចូរនិម្មិតអាស្រម និងបណ្ណសាលាដ៏ល្អ ជាទីរីករាយ ថ្វាយព្រះបាទវេស្សន្តរ ព្រមទាំងភរិយានិងបុត្រ ៗ

## សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ចរិយាបិដកំ

សក្កស្ស វចនំ សុត្វា   វិស្សុកម្មោ មហិទ្ធិកោ
អស្សមំ សុកតំ រម្មំ   បណ្ណសាលំ សុមាបយិ ។
អជ្ឈោគាហេត្វា បវនំ   អប្បសទ្ទំ និរាកុលំ
ចតុរោ ជនា មយំ តត្ថ   វសាម បព្វតន្តរេ ។
អហញ្ច មទ្ទី ទេវី ច   ជាលី កណ្ហាជិនា ចុភោ
អញ្ញមញ្ញំ សោកនុទា   វសាម អស្សមេ តទា ។
ទារកេ អនុរក្ខន្តោ   អសុញ្ញោ ហោមិ អស្សមេ
មទ្ទី ផលំ អាហរតិ   បោសេតិ សា តយោ ជនេ ។
បវនេ វសមានស្ស   អត្ថិកោ(១) មំ ឧបាគមិ
អយាចិ បុត្តកេ មយ្ហំ   ជាលឹ កណ្ហាជិនំ(២) ចុភោ ។
យាចកំ ឧបគតំ ទិស្វា   ហាសោ មេ ឧបបជ្ជថ
ឧភោ បុត្តេ គហេត្វាន   អទាសឹ ព្រាហ្មណេ តទា ។

---

១ អទ្ធិកោតិ អដ្ឋកថាយំ ទិស្សតិ ។ ២ ឱ. ជាលឹកណ្ហាជិនេ ។

វិស្សកម្មទេវបុត្ត ដែលមានឫទ្ធិច្រើន លុះបានស្តាប់ពាក្យរបស់សក្កទេវរាជហើយ ក៏ចុះមកនិម្មិតអាស្រមនិងបណ្ណសាលាដ៏ល្អជាទីរីករាយ ។ ក្សត្រ ៤ ព្រះអង្គ បានចូលទៅកាន់ព្រៃធំ ដែលមិនមានសម្លេង មិនមានសេចក្តីវិកវរ ហើយ (និយាយគ្នាថា) យើងទាំងនៅក្នុងចន្លោះនៃភ្នំនោះ កាលនោះ តថាគត នាងមទ្រីទេវី កូនទាំងពីរ គឺជាលីនិងកណ្ហាជិនា បានបន្ទាបង់សេចក្តីសោក ដល់គ្នានិងគ្នា ហើយនៅក្នុងអាស្រម កាលនោះ តថាគត រក្សាទារកក្នុងអាស្រម មិនសូន្យស្ងាត់ នាងមទ្រីនោះ តែងនាំផ្លែឈើមកចិញ្ចឹមជនទាំង ៣ នាក់ ។ កាលតថាគតនៅក្នុងព្រៃធំ មានអ្នកដំណើរម្នាក់ ចូលមករកតថាគត សូមកូនទាំងពីរនៃតថាគត គឺជាលីនិងកណ្ហាជិនា ។ កាលនោះ តថាគតកើតសេចក្តីរីករាយ ព្រោះបានឃើញយាចកដើរចូលមក បានយកកូនទាំងពីរឲ្យដល់ព្រាហ្មណ៍ ។

## នវមំ វេស្សន្តរចរិយំ

សកេ បុត្តេ ចជន្តស្ស ជូជកេ ព្រាហ្មណេ យទា
តទាបិ បថវី កម្បិ សិនេរុវនវដំសកា ។
បុនទេវ សក្កោ ឱរុយ្ហ ហុត្វា ព្រាហ្មណសន្និភោ
អយាចិ មំ មទ្ទឹ ទេវឹ សីលវតឹ បតិព្វតំ ។
មទ្ទឹ ហត្ថេ គហេត្វាន ឧទកញ្ជលិ បូរយ
បសន្នមនសង្កប្បោ តស្ស មទ្ទឹ អទាសហំ ។
មទ្ទិយា ទីយមានាយ គគនេ ទេវា បមោទិតា
តទាបិ បថវី កម្បិ សិនេរុវនវដំសកា ។
ជាលឹ កណ្ហាជិនំ ធីតុំ មទ្ទឹ ទេវឹ បតិព្វតំ
ចជមានោ ន ចិន្តេសឹ ពោធិយាយេវ ការណា ។
ន មេ ទេស្សា ឧភោ បុត្តា មទ្ទី ទេវី ន ទេស្សិយា
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា បិយេ អទាសហំ ។

## វេស្សន្តរបរិយា ទី ៩

កាលតថាគតបរិច្ចាគបុត្តទាំងពីររបស់ខ្លួន ដល់ជូជកព្រាហ្មណ៍ កាលនោះ ប្រថពី ដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ។ ព្រះឥន្ទ្របានក្លែងភេទ ជាព្រាហ្មណ៍ម្តងទៀត ចុះមកសូមនាងមទ្រីទេវី ដែលមានសីល មានវត្តចំពោះប្តី និងតថាគត ។ តថាគត មានសេចក្តីត្រិះរិះក្នុងចិត្ត ដោយជ្រះថ្លា ចាប់នាងមទ្រីទេវីត្រង់ដើមដៃ ហើយច្រួចទឹក ដាក់លើអញ្ជលីនៃព្រាហ្មណ៍ ឲ្យនាងមទ្រីដល់ព្រាហ្មណ៍ ។ កាលដែលតថាគតឲ្យនាងមទ្រី ទេវតាឮដ៏អាកាស ក៏ត្រេកអររីករាយ ប្រថពីដែលមានភ្នំសិនេរុ និងព្រៃជាគ្រឿងប្រដាប់ ក៏ញាប់ញ័រ ក្នុងកាលនោះ ។ កាលតថាគត បរិច្ចាគជាលីកុមារ កណ្ហាជិនាធីតា និងនាងមទ្រីទេវី ដែលមានវត្តចំពោះប្តី ឥតគិតក្តៅក្រហាយសោះឡើយ ក៏ព្រោះហេតុនៃពោធិញ្ញាណតែម្យ៉ាង ។ បុត្រទាំងពីរមិនមែនជាទីស្អប់ របស់តថាគតទេ ទាំងនាងមទ្រីទេវី ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត បានជាតថាគតឲ្យបុត្តនិងភរិយាជាទីស្រឡាញ់ ។

បុនាបរំ ព្រហារញ្ញេ  មាតាបិតុ សមាគមេ

ករុណំ បរិទេវន្តេ  សល្លបន្តេ សុខំ ទុក្ខំ ។

ហិរោត្តប្បេន គរូនំ  ឧភិន្នំ ឧបសង្កមិ

តទាបិ បថវី កម្បិ  សិនេរុវនវដំសកា ។

បុនាបរំ ព្រហារញ្ញា  និក្ខមិត្វា សញ្ញាតិភិ

បវិសាមិ បុរំ រម្មំ  ជេតុត្តរំ បុរុត្តមំ ។

រតនានិ សត្ត វស្សិំសុ  មហាមេឃោ បវស្សថ

តទាបិ បថវី កម្បិ  សិនេរុវនវដំសកា ។

អចេតនាយំ បថវី  អវិញ្ញាយ សុខំ ទុក្ខំ

សាបិ ទានពលា មយ្ហំ  សត្តក្ខត្តុំ បកម្បថាតិ ។

វេស្សន្តរចរិយំ នវមំ ។

កាលពួកជនមកជួបជុំគ្នា ក្នុងសំណាក់នៃមាតានិងបិតា ក្នុងព្រៃធំ ក៏ខ្សឹកខ្សួល ដោយសេចក្តីករុណា ចរចាសួរសុខនិងទុក្ខគ្នា ។ កាលមហាជនចូលទៅរកជនទាំងពីរ ជាអ្នកធ្ងន់ដោយហិរិនិងឱត្តប្បៈ កាលនោះ ប្រថពីដែលមានភ្នំសិនេរុនិងព្រៃជាគ្រឿងប្រដាប់ ក៏កម្រើកញាប់ញ័រ ។ ម្យ៉ាងទៀត តថាគតចេញអំពីព្រៃធំ ជាមួយនឹងពួកញាតិ ចូលទៅកាន់បុរី គួរជាទីសប្បាយ ឈ្មោះជេតុត្តរ ដែលជានគរដ៏ឧត្តម ក្នុងកាលនោះ មហាមេឃក៏បង្អុរចុះ នូវភ្លៀងជាវិការៈនៃកែវ ៧ ប្រការ ប្រថពីដែលមានភ្នំសិនេរុនិងព្រៃ ជាគ្រឿងប្រដាប់ ក៏កម្រើក ។ ប្រថពី មិនមានចេតនាទេ មិនដឹងសុខនិងទុក្ខទេ តែមហាប្រថពីនោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទានរបស់តថាគត ។

ចប់ វេស្សន្តរចរិយា ទី ៩ ។

# ទសមំ សសបណ្ឌិតចរិយំ

(១០) បុនាបរំ យទា ហោមិ សសកោ បវនចារកោ
តិណបណ្ណសាកផលភក្ខោ បរហេឋនវិវជ្ជិតោ ។
មក្កដោ ច សិង្គាលោ ច សុត្តបោតោ(១) ចហំ តទា
វសាម ឯកសមន្តា(២) សាយំ បាតោ ច ទិស្សរេ ។
អហំ តេ អនុសាសាមិ កិរិយេ កល្យាណបាបកេ
បាបានិ បរិវជ្ជេថ កល្យាណេ អភិនិវិស្សថ ។
ឧបោសថម្ហិ ទិវសេ ចន្ទំ ទិស្វាន បូរិតំ
ឯតេសំ តត្ថ អាចិក្ខឹ ទិវសោ អជ្ជុបោសថោ ។
ទានានិ បដិយាទេថ ទក្ខិណេយ្យស្ស ទាតវេ
ទត្វា ទានំ ទក្ខិណេយ្យេ ឧបវស្សថុបោសថំ ។

---

១ ឱ. ម. ឧទ្ទបោតោ ។ ២ ឱ. ម. ឯកសាមន្តា ។

# សសបណ្ឌិតចរិយា ទី ១០

(១០) ចរិយាដទៃទៀត កាលតថាគត កើតជាទន្សាយ ត្រាច់ទៅក្នុងព្រៃ មានស្មៅ ស្លឹកឈើ បន្លែនិងផ្លែឈើជាអាហារ វៀរចាកការបៀតបៀនសត្វដទៃ ៗ កាលនោះស្វា ចចក កេ និងតថាគត ព្រមព្រៀងនៅជាមួយគ្នា ទាំងព្រឹកទាំងល្ងាច ៗ តថាគតប្រៀនប្រដៅសំឡាញ់ទាំង ៣ នោះ ដែលមានកិរិយាល្អ និងកិរិយាអាក្រក់ថា អ្នកទាំងឡាយ ចូរវៀរនូវអំពើអាក្រក់ ហើយចូរតម្កល់ខ្ជាប់ក្នុងអំពើល្អ ៗ តថាគតឃើញព្រះចន្ទ្រពេញវង់ ក្នុងថ្ងៃឧបោសថ ក៏ប្រាប់ដល់សម្លាញ់នុ៎ះ ក្នុងទីនោះថា ថ្ងៃនេះជាថ្ងៃឧបោសថ ៗ អ្នកទាំងឡាយ ចូរចាត់ចែងទាន ដើម្បីឲ្យដល់ទក្ខិណេយ្យបុគ្គល លុះបានឲ្យទានដល់ទក្ខិណេយ្យបុគ្គលរួចហើយ ចូររក្សាឧបោសថ ៗ

តេ មេ សាធូតិ វត្វាន យថាសត្តិ យថាពលំ
ទានានិ បដិយាទេត្វា ទក្ខិណេយ្យំ គវេសិសុំ ។
អហំ និបជ្ជ ចិន្តេសឹ ទានំ ទក្ខិណានុច្ឆវិំ
យទិហំ លភេ ទក្ខិណេយ្យំ កឹ មេ ទានំ ភវិស្សតិ ។
ន មេ អត្ថិ តិលមុគ្គា(១) ន មាសា តណ្ឌុលា ឃតំ
អហំ តិណេន យាបេមិ ន សក្កា តិណទាតវេ ។
យទិ កោចិ ឯតិ ទក្ខិណេយ្យោ ភិក្ខាយ មម សន្តិកេ
ទជ្ជាហំ សកមត្តានំ ន សោ តុច្ឆោ គមិស្សតិ ។
មម សង្កប្បមញ្ញាយ សក្កោ ព្រាហ្មណវណ្ណិនា
អាសយំ មេ ឧបគច្ឆិ ទានំ វីមំសនាយ មេ ។
តមហំ ទិស្វាន សន្តុដ្ឋោ ឥទំ វចនមព្រវឹ
សាធុ ខោសិ អនុប្បត្តោ ឃាសហេតុ មមន្តិកេ ។

---

១ ឱ. ម. តិលាមុគ្គា ។

សត្វជាសំឡាញ់នោះ បានទទួលពាក្យតថាគតថាសាធុ ហើយកាត់បែងទាន តាមសេចក្តីអង់អាច តាមកម្លាំង ហើយស្វែងរកទក្ខិណេយ្យបុគ្គល ៗ ឯតថាគត ដេកគិតនូវទានដែលសមគួរដល់ទក្ខិណេយ្យបុគ្គលថា បើអញបានទក្ខិណេយ្យបុគ្គល តើអញនឹងឲ្យទានដូចម្តេច ៗ ល្ងនិងសណ្តែកបាយនៃអញគ្មានទេ សណ្តែកពជមាស អង្ករនិងខ្លាញ់នៃអញ ក៏គ្មានដែរ អញញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយស្មៅ អញមិនអាចនឹងឲ្យស្មៅបានទេ ដូច្នេះ បើមានទក្ខិណេយ្យបុគ្គលណាមួយ ដើរមកក្នុងសំណាក់អញដើម្បីភិក្ខា អញនឹងឲ្យខ្លួនជារបស់ខ្លួន នឹងមិនឲ្យទក្ខិណេយ្យ-បុគ្គលនោះ មានដៃទទេ ទៅវិញឡើយ ព្រះឥន្ទ្រដឹងនូវសេចក្តីត្រិះរិះរបស់តថាគត ហើយក្លែងភេទជាព្រាហ្មណ៍ ចូលមកកាន់លំនៅតថាគត ដើម្បីល្បងទានរបស់តថាគត ៗ តថាគតឃើញឥន្ទព្រាហ្មណ៍នោះ ហើយក៏ត្រេកអរ បានពោលពាក្យនេះថា ពេញជាល្អមែនអ្នកមកក្នុងសំណាក់ខ្ញុំ ព្រោះហេតុតែអាហារ ៗ

## ទសមំ សសបណ្ឌិតចរិយំ

អទិន្នបុព្វំ ទានវរំ   អជ្ជ ទស្សាមិ តេ អហំ
តុវំ សីលគុណូបេតោ   អយុត្តន្តេ បរហេឋនំ ។
ឯហិ អគ្គឹ បទីបេហិ   នានាកដ្ឋេ សមានយ
អហំ បចិស្សាមត្តានំ   បក្កំ តុវំ ភក្ខយិស្សសិ ។
សាធូតិ សោ ហដ្ឋមនោ   នានាកដ្ឋេ សមានយិ
មហន្តំ អកាសិ ចិតកំ   កត្វានង្គារគព្ភកំ ។
អគ្គឹ តត្ថ បទីបេសិ   យថា សោ ខិប្បំ មហា ភវេ
ផោដេត្វា រជគតេ គត្តេ   ឯកមន្តំ ឧបាវិសឹ ។
យទា មហាកដ្ឋបុញ្ជោ   អាទិត្តោ ធមធមាយតិ[១]
តទុប្បតិត្វា បបតិ   មជ្ឈេ ជាលសិខន្តរេ ។
យថា សីតោទកំ នាម   បវិដ្ឋំ យស្ស កស្សចិ
សមេតិ ទរថបរិឡាហំ   អស្សាទំ ទេតិ បីតិ ច ។

---

១ ឱ. ម. ធូមមាយតិ ។

## សសបណ្ឌិតចរិយា ទី ១០

ក្នុងថ្ងៃនេះ ខ្ញុំនឹងឲ្យនូវទានដ៏ប្រសើរដល់អ្នក ជាទានដែលខ្ញុំ មិនធ្លាប់ឲ្យឡើយ អ្នកប្រកបដោយគុណ គឺសីល ការបៀតបៀនសត្វដទៃ មិនគួរដល់អ្នកឡើយ អ្នកចូរមក ចូរទៅនាំយកឧសផ្សេង ៗ មកបង្កាត់ភ្លើងឲ្យឆេះឡើង ខ្ញុំនឹងដុតខ្លួន អ្នកនឹងបានបរិភោគសាច់ឆ្អិន ។ ឥន្ទព្រាហ្មណ៍នោះ មានចិត្តត្រេកអរ ទទួលថា សាធុ ហើយទៅនាំឧសផ្សេងៗ យកមកធ្វើជើងថ្ករយ៉ាងធំ ហើយធ្វើឲ្យមានផ្ទៃពេញដោយរងើកភ្លើង ៗ គំនរភ្លើងធំនោះឆេះឆាប យ៉ាងណា ឥន្ទព្រាហ្មណ៍នោះ ក៏ដុតភ្លើងឆេះសន្ធោក្នុងទីនោះ យ៉ាងនោះ តថាគតរលាស់ខ្លួន ដែលប្រឡាក់ដោយធូលី ហើយអង្គុយក្នុងទីដ៏សមគួរនោះ ។ កាលណា គំនរឧសធំត្រូវភ្លើងឆេះ ឮសូរសម្លេងផុំ ផុំ កាលនោះ តថាគតលោតទម្លាក់ខ្លួន ទៅក្នុងកណ្ដាលចន្លោះអណ្ដាតភ្លើង ធម្មតាទឹកត្រជាក់ ដែលបុគ្គលណាមួយចុះទៅហើយ រមែងញ៉ាំងសេចក្ដីក្រវល់ក្រវាយ ក្ដៅក្រហាយ ឲ្យស្ងប់រម្ងាប់ បានញ៉ាំងសេចក្ដីត្រេកអរ និងបីតិឲ្យកើតឡើង យ៉ាងណា ៗ

តថេវ ជលិតំ អគ្គឹ បវិដ្ឋស្ស មមំ តទា

សព្វំ សមេតិ ទរថំ យថា សីតោទកំ វិយ ។

ឆវិ ចម្មញ្ច មំសញ្ច ន្ហារុំ អដ្ឋិំ ហទយពន្ធនំ

កេវលំ សកលំ កាយំ ព្រាហ្មណស្ស អទាសហំ ។

សសបណ្ឌិតចរិយំ ទសមំ ។

## ឧទ្ទានំ

អកិត្តិ ព្រាហ្មណោ សង្ខោ កុរុរាជា ធនញ្ចយោ

មហាសុទស្សនោ រាជា មហាគោវិន្ទព្រាហ្មណោ ។

នេមិ ចន្ទកុមារោ ច សិវិ វេស្សន្តរោ សសោ

អហមេវ តទា អាសឹ យោ តេ ទានវរេ អទា ។

ឥមេ ទានបរិក្ខារា ឥមេ ទានស្ស បារមី

ជីវិតំ យាចកេ ទត្វា ឥមំ បារមិ បូរយឹ ។

កាលតថាគត ចូលទៅក្នុងភ្លើង ដែលកំពុងឆេះសន្ធោសន្ធៅ ក៏ញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងអស់ ឲ្យស្ងប់រម្ងាប់ ដូចជាទឹកត្រជាក់ ដូច្នោះឯង ។ តថាគតបានឲ្យសម្បុរថ្ងៃ ស្បែក សាច់ សរសៃ ឆ្អឹង បេះដូង និងកាយទាំងមូល មិនឲ្យមានសេសសល់ ដល់ព្រាហ្មណ៍ ។

ចប់ សសបណ្ឌិតចរិយា ទី ១០ ។

## ឧទ្ទាននៃចរិយានោះ

អកិត្តិចរិយា ១ សង្ខព្រាហ្មណចរិយា ១ ស្តេចក្នុងដែនកុរុព្រះនាមធនញ្ជ័យ (កុរុធម្មចរិយា) ១ មហាសុទស្សនរាជ (សុទស្សនចរិយា) ១ មហាគោវិន្ទចរិយា ១ នេមិរាជចរិយា ១ ចន្ទកុមារចរិយា ១ សិវិរាជចរិយា ១ វេស្សន្តរចរិយា ១ សសបណ្ឌិតចរិយា ១ បុគ្គលណា បានឲ្យទានដ៏ប្រសើរទាំងឡាយនោះ ក្នុងកាលនោះ បុគ្គលនោះ គឺតថាគតហ្នឹងឯង ។ ការបរិច្ចាគនូវទេយ្យធម៌ទាំងឡាយនុ៎ះ ជាបរិក្ខារនៃទាន ការបរិច្ចាគនូវទានដ៏ប្រសើរទាំងឡាយនុ៎ះ ជាបារមីនៃទាន (ហេតុនោះ) បានជាតថាគត ឲ្យនូវជីវិតដល់យាចក ហើយបំពេញនូវបារមីនេះ ។

បឋមំ សីលវនាគចរិយំ

ភិក្ខាយ ឧបគតំ ទិស្វា សកត្តានំ បរិច្ចជឹ
ទានេន មេ សមោ នត្ថិ ឯសា មេ ទានបារមីតិ ។

ទានបារមិតា និដ្ឋិតា ។

# សីលបារមិតា

## បឋមំ សីលវនាគចរិយំ

[១១] យទា អហោសឹ បព្វតេ កុញ្ជរោ មាតុបោសកោ
ន តទា អត្ថិ មហិយា គុណេន មម សាទិសោ ។
បវនេ ទិស្វា វនចរោ រញ្ញោ មំ បដិវេទយិ
តវានុច្ឆវោ មហារាជ គជោ វសតិ កាននេ ។
ន តស្ស បរិក្ខាយត្ថោ នបិ អាឡ្ហកកាសុយា(១)
សមាគហិតេ សោណ្ឌាយ សយមេវ ឥធេហិតិ ។
តស្ស តំ វចនំ សុត្វា រាជាបិ តុដ្ឋមានសោ
បេសេសិ ហត្ថិទមកំ ឆេកាចរិយំ សុសិក្ខិតំ ។

១ ឱ. ម. អាឡកកាសុយា ។

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន ជារបស់ខ្លួន បុគ្គលអ្នកឲ្យទាន ស្មើដោយទានរបស់តថាគត មិនមានឡើយ នេះជាទានបារមី របស់តថាគត ។

ចប់ ទានបារមី ។

# សីលបារមិតា

## សីលវិភាគបរិយា ទី ១

(១១) កាលដែលតថាគតកើតជាដំរី ជាសត្វចិញ្ចឹមមាតា នៅក្នុងព្រៃធំ កាលនោះ ទីរកអ្នកណា លើផែនដីនេះ ឲ្យស្មើនឹងតថាគត ដោយសីលគុណ មិនមានឡើយ ។ មានព្រានព្រៃម្នាក់ ឃើញតថាគតក្នុងព្រៃ ក៏ក្រាបទូលដល់ស្តេចពារាណសីថា បពិត្រមហារាជ គជសារមួយ នៅក្នុងព្រៃធំ ជាសត្វមានសភាពសមគួរ ដល់ព្រះអង្គ ដំរីនោះ មិនមានសេចក្តីត្រូវការដោយស្ទាមភ្ជោះទេ មិនមានសេចក្តីត្រូវការដោយខ្សែប្រកាំទិសណាទេ ដំរីនោះគ្រាន់តែបុគ្គលចាប់ទាញប្រមោយនាំមកក្នុងទីនេះ ដោយខ្លួនឯង ។ ចំណែកខាងព្រះរាជា ទ្រង់បានព្រះសណ្ដាប់នូវពាក្យ របស់ព្រានព្រៃនោះហើយ ក៏មានព្រះរាជហឫទ័យត្រេកអរ ទើបទ្រង់ប្រើហ្មដំរី ដែលជាហត្ថាចារ្យឈ្លាសវាងវៃ បានសិក្សាវិជ្ជាចាប់ដំរីចេះល្អិតល្អ ។

គន្ត្វា សោ ហត្ថិទមកោ អទ្ទស បទុមស្សរេ
ភិសមុឡាលំ ឧទ្ធរន្តំ យាបនត្ថាយ មាតុយា ។
វិញ្ញាយ មេ សីលគុណំ លក្ខណំ ឧបធារយិ
ឯហិ បុត្តាតិ វត្វាន សោណ្ឌាយ មម អគ្គហិ ។
យំ មេ តទា បាកតិកំ សរីរានុគតំ ពលំ
អជ្ជ នាគសហស្សានំ ពលេន សមសាទិសំ ។
យទិហំ តេសំ បកុប្បេយ្យំ ឧបេតំ គហណាយ មំ
បដិពលោ ភវេ តេសំ យាវ រជ្ជម្បិ មានុសំ ។
អបិចាហំ សីលរក្ខាយ សីលបារមិបូរិយា
ន ករោមិ ចិត្តេ អញ្ញថត្តំ បក្ខិបន្តំ មមាឡ្ហកេ(១) ។
យទិ តេ មំ តត្ថ កោដេយ្យុំ ផរសូហិ តោមរេហិ ច
នេវ តេសំ បកុប្បេយ្យំ សីលខណ្ឌភយា មមាតិ ។

សីលវនាគចរិយំ បឋមំ ។

---

១ ឱ. ម. មមាលកេ ។

ហ្វូងដំរីនោះលុះទៅដល់ ក៏ឃើញតថាគត កំពុងដកមើមឈូក ក្រអៅឈូកក្នុងបទុមស្រះ ដើម្បីចិញ្ចឹមមាតា ។ នាយហត្ថាចារ្យនោះ លុះដឹងច្បាស់សីលគុណនៃតថាគត ក៏ពិចារណាឃើញលក្ខណៈ (នៃតថាគត) ហើយពោលថា ម្នាលកូនអ្នកចូរមក ហើយចាប់ដឹកតថាគតត្រង់ប្រមោយ ។ កាលនោះ កម្លាំងណា ប្រព្រឹត្តទៅក្នុងសរីរៈនៃតថាគត ដែលតាំងនៅដោយប្រក្រតី កម្លាំងនោះ ប្រាកដស្មើដោយកម្លាំងនៃដំរីច្រើនពាន់ ក្នុងថ្ងៃនេះ ។ បើតថាគត ខឹងចំពោះជនទាំងឡាយនោះ ដែលចូលមកចាប់តថាគត តថាគតអាច (នឹងញុំាញីនូវជីវិត) នៃមនុស្សនោះ រហូតដល់ពង្ស ជារបស់មនុស្សក៏បាន ។ តែតថាគតរក្សាសីល (សូម្បីឃើញ) នូវជនកាលដាក់តថាគត ក្នុងរោង ក៏មិនធ្វើចិត្តឲ្យរាយមាយ ដើម្បីបំពេញនូវសីលបារមី ។ ប្រសិនបើជនទាំងឡាយនោះ កាប់ចាក់តថាគត ដោយប៉ូវថៅ និងលំពែងស្នងក្របី ក្នុងទីនោះ ក៏តថាគត មិនក្រោធខឹងចំពោះជនទាំងនោះ ព្រោះតថាគតខ្លាចដាច់សីល ។

ចប់ សីលវនាគចរិយា ទី ១ ។

# ទុតិយំ ភូរិទត្តចរិយំ

(១២) បុនាបរំ យទា ហោមិ ភូរិទត្តោ មហិទ្ធិកោ

វិរូបក្ខេន មហារញ្ញា ទេវលោកមគញ្ឆហំ ។
តត្ថ បស្សិត្វាហំ ទេវេ ឯកន្តំ សុខសមប្បិតេ
តំ សគ្គគមនត្ថាយ សីលព្វតំ សមាទិយឹ ។
សរីរកិច្ចំ កត្វាន ភុត្វា(១) យាបនមត្តកំ

ចតុរោ អង្គេ អធិដ្ឋាយ សេមិ វម្មិកមុទ្ធនិ ។
ឆវិយា ចម្មេន មំសេន ន្ហារុហិ អដ្ឋិកេហិ វា
យស្ស ឯតេន ករណីយំ ទិន្នំយេវ ហរាតុ សោ ។
សំសិតោ អកតញ្ញុនា អាលម្ពានោ មមគ្គហិ
បេឡាយ បក្ខិបិត្វាន កីឡេតិ មំ តហឹ តហឹ ។

---

១ ម. សុត្វា ។

# ភូរិទត្តចរិយា ទី ២

[១២] មានរឿងដទៃទៀត កាលដែលតថាគត កើតជានាគ ឈ្មោះភូរិទត្ត មានឫទ្ធិច្រើន កាលនោះ តថាគតបានទៅកាន់ឋានតាវត្តឹង្សទេវលោក ជាមួយនឹងមហារាជ ព្រះនាមវិរូបក្ខៈ ។ តថាគត បានឃើញទេវតាទាំងឡាយ ដែលឆ្អែតស្កប់ស្កល់ ដោយសេចក្តីសុខ យ៉ាងក្រៃលែង ក្នុងតាវត្តឹង្សទេវលោកនោះ បានជាតថាគតសមាទាន នូវសីលនិងវត្តដើម្បីទៅកាន់ឋានសួគ៌នោះ ។ តថាគតធ្វើនូវកិច្ចថែទាំសរីរៈ បរិភោគគ្រាន់តែញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ អធិដ្ឋាននូវអង្គ ៤ ហើយដេកលើក្បាលដំបូក ។ កិច្ចដែលបុគ្គលណា គួរធ្វើដោយសម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយកនូវសម្បុរថ្ងៃ ស្បែក ដែលតថាគតឲ្យហើយនោះចុះ ។

អាលម្ពានព្រាហ្មណ៍ លុះនេសាទព្រាហ្មណ៍ ជាអកតញ្ញូប្រាប់កន្លែងហើយ ក៏ទៅចាប់យកតថាគត ដាក់ក្នុងកំប្រោង ហើយប្រើតថាគតឲ្យលេង ក្នុងស្រុក និគម ជនបទនោះៗ ។

បេឡាយ បក្ខិបន្តេបិ មំ មទ្ទន្តេបិ(១) បាណិនា
អាលម្ពានេ ន កុប្បាមិ សីលខណ្ឌភយា មម ។
សកជីវិតបរិច្ចាគោ តិណាតោបិ លហុកោ មយិ
សីលវីតិក្កមោ មយ្ហំ បថវី ឧព្វត្តនា វិយ ។
និរន្តរំ ជាតិសតំ ចជេយ្យំ មម ជីវិតំ
នេវ សីលំ បភិន្ទេយ្យំ ចតុន្នំ ទីបាន ហេតុបិ ។
អបិចាហំ សីលរក្ខាយ សីលបារមិបូរិយា
ន ករោមិ ចិត្តេ អញ្ញថត្តំ បក្ខិបន្តំបិ បេឡកេតិ ។

ភូរិទត្តចរិយំ ទុតិយំ ។

# តតិយំ ចម្បេយ្យចរិយំ

(១៣) បុនាបរំ យទា ហោមិ ចម្បេយ្យកោ មហិទ្ធិកោ
តទាបិ ធម្មិកោ អាសិ សីលព្វតសមប្បិតោ ។

---

១ ឱ. ម. សម្មទ្ទន្តេបិ ។

កាលអាលម្ពានព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោងក្តី ញាំញីតថាគតដោយដៃក្តី តថាគតមិនខឹងនឹងអាលម្ពានព្រាហ្មណ៍ ព្រោះតថាគតខ្ជាប់ជាប់សីល ។ ការបរិច្ចាគជីវិតនៃខ្លួន របស់តថាគត ជាធម្មជាតិស្រាលជាងចាប់ស្មៅទៅទៀត ឯការប្រព្រឹត្តិកន្លងសីលនៃតថាគត ធ្ងន់ដូចជាការប្រែត្រឡប់ផែនដី ។ តថាគតលះបង់ជីវិត នៃតថាគត អស់រយជាតិមិនមានចន្លោះ តថាគតមិនដែលទំលាយសីល ព្រោះហេតុតែបានជាស្តេចចក្រពត្តិ ក្នុងទ្វីបទាំង ៤ ទេ ។ បំណែកខាងតថាគតរក្សាសីល (សូម្បីឃើញ) នូវអាលម្ពានព្រាហ្មណ៍ ដាក់តថាគតក្នុងកំប្រោង ក៏មិនធ្វើចិត្តឲ្យរកយមាយ ដើម្បីបំពេញនូវសីលបារមី ។

ចប់ ភូរិទត្តចរិយា ទី ២ ។

## ចម្បេយ្យចរិយា ទី ៣

(១៣) ចរិយាដទៃទៀត កាលដែលតថាគត កើតជាស្តេចនាគ ឈ្មោះចម្បេយ្យ(១) មានឫទ្ធិច្រើន កាលនោះតថាគតជាអ្នកប្រកបដោយធម៌ ជាអ្នកឆ្អែតស្កប់ស្កល់ ដោយសីលទិនវ័ត ។

---

១ មានស្ទឹងមួយឈ្មោះចម្បា នៅត្រង់ចន្លោះដែនអង្គៈ និងដែនមគធៈ នៅខាងក្រោមស្ទឹងនោះ មានភពនាគមួយ ឈ្មោះចម្បា ស្តេចនាគដែលកើតក្នុងភពនោះ ឈ្មោះចម្បេយ្យ ។ អដ្ឋកថា ។

## តតិយំ ចម្បេយ្យចរិយំ

តទាបិ មំ ធម្មចារឹ ឧបវុដ្ឋំ ឧបោសថំ
អហិតុណ្ឌិកោ គហេត្វាន រាជទ្វារម្ហិ កីឡតិ ។
យំ សោ វណ្ណំ ចិន្តយតិ នីលំវ បីតលោហិតំ
តស្ស ចិត្តានុវត្តេន្តោ ហោមិ ចិន្តិតសន្និភោ ។
ថលំ ករេយ្យំ ឧទកំ ឧទកម្បិ ថលំ ករេ
យទិ ហន្តស្ស កុប្បេយ្យំ ខណេន ឆារិកំ ករេ ។
យទិ ចិត្តវសី ហេស្សំ បរិហាយិស្សាមិ សីលតោ
សីលេន បរិហីនស្ស ឧត្តមត្ថោ ន សិជ្ឈតិ ។
កាមំ ភិជ្ជតុយំ កាយោ ឥធេវ វិកិរីយតុ
នេវ សីលំ បភិន្ទេយ្យំ វិកិរន្តេ ភុសំ វិយាតិ ។

ចម្បេយ្យចរិយំ[១] តតិយំ ។

---

១ ឱ. ម. ចម្បេយ្យនាគចរិយំ ។

## ចម្បេយ្យចរិយា ទី ៣

កាលនោះ ហ្មពស់ចាប់តថាគត ដែលជាអ្នកប្រព្រឹត្តធម៌រក្សា ឧបោសថ យកទៅឲ្យលេងល្បែង ទៀបទ្វារក្រុងនៃស្តេច ៗ ហ្មពស់នោះ គិតឲ្យមានពណ៌ខៀវ លឿង ក្រហម តថាគត ធ្វើតាមចិត្តហ្មពស់ ឲ្យសម្រេចដូចគំនិតដែលគិត ៗ តថាគត អាចនឹងធ្វើទីទួលឲ្យជាទឹក ធ្វើទឹកឲ្យជាទីទួល បើតថាគត ខឹងចំពោះហ្មពស់នោះ តថាគតធ្វើឲ្យខ្ទេចជាផេះមួយរំពេច ៗ បើតថាគត បណ្តោយតាមអំណាចចិត្ត តថាគត នឹងសាប សូន្យបាកសីល ប្រយោជន៍ដ៏ឧត្តម គឺភាពជាព្រះពុទ្ធ នឹងមិន សម្រេចដល់តថាគត ដែលសាបសូន្យបាកសីលឡើយ ៗ កាយនេះ ទោះបែកធ្លាយរោយរាយលើផែនដីនេះ ឲ្យដូចជា បុគ្គលរោយនូវសំដីស្រូវ ក៏តថាគតមិនទំលាយសីលឡើយ ៗ

ចប់ ចម្បេយ្យចរិយា ទី ៣ ។

## ចតុត្ថំ ចូឡពោធិចរិយំ

(១៤) បុនាបរំ យទា ហោមិ ចូឡពោធិ សុសីលវា
ភវំ ទិស្វាន ភយតោ នេក្ខម្មំ អភិនិក្ខមឹ ។
យា មេ ទុតិយិកា អាសិ ព្រាហ្មណី កនកសន្និភា
សាបិ វដ្ដេ អនបេក្ខា នេក្ខម្មំ អភិនិក្ខមិ ។
និរាលយា ឆិន្នពន្ធុ អនបេក្ខា កុលេ គណេ
ចរន្តា គាមនិគមំ ពារាណសឹ ឧបាគមុំ ។
តត្ថ វសាម និបកា អសំសដ្ឋា កុលេ គណេ
និរាកុលេ អប្បសទ្ទេ រាជុយ្យានេ វសាមុភោ ។
ឧយ្យានទស្សនំ គន្ត្វា រាជា អទ្ទស ព្រាហ្មណឹ
ឧបសង្កម្ម មំ(១) បុច្ឆិ តុយ្ហេសា កា(២) កស្ស ភរិយា ។

---

១ ឱ. ម. ឧបគម្ម មមំ ។ ២ ឱ. ម. កាតិ បទំ នត្ថិ ។

# ចូឡពោធិចរិយា ទី ៤

(១៤) ចរិយាដទៃទៀត កាលដែលតថាគត ជាបរិញ្វាជក ឈ្មោះចូឡពោធិ ជាអ្នកមានសីលល្អ ឃើញនូវភពថាជារបស់គួរខ្លាចហើយ ក៏ចេញទៅសាងអភិនេស្រ្កម ។ នាងព្រាហ្មណីមានសម្បុរដូចមាស នាងជាភរិយារបស់តថាគត នាងមិនមានអាល័យក្នុងវដ្តៈ ក៏បានចេញទៅសាងអភិនេស្រ្កមដែរ នាងមិនមានអាល័យ លះបង់នូវផៅពង្ស មិនជាប់នឹងពួកត្រកូល តថាគតនិងព្រាហ្មណីនោះ ដើរទៅកាន់ស្រុកនិងនិគម ក៏បានចូលទៅកាន់ក្រុងពារាណសី ។ យើងទាំងពីរនាក់ ជាអ្នកមានបញ្ញា នៅជិតក្រុងពារាណសីនោះ មិននៅប្រឡូកប្រឡំក្នុងពួកត្រកូលទេ នៅក្នុងឧទ្យានស្ងប់ ជាទីមិនមានសំឡេង មិនមានវិការ ។ ព្រះរាជាទ្រង់ស្តេចទៅទតឧទ្យាន បានឃើញព្រាហ្មណី ទ្រង់ចូលទៅសួរតថាគតថា ស្រីនេះ ជាភរិយារបស់លោក ឬជាភរិយារបស់អ្នកណា ។

## ចតុត្ថំ ចូឡពោធិចរិយំ

ឯវំ វុត្តេ អហន្តស្ស ឥទំ វចនមព្រវឹ
ន មយ្ហំ ភរិយា ឯសា សហធម្មា(១) ឯកសាសនី ។
តស្សា សារត្តគធិតោ គាហាបេត្វាន ចេដកេ
និប្បីឡយន្តោ ពលសា អន្តេបុរំ បវេសយិ ។
ឱទបត្តិកិយា មយ្ហំ សហជាតា(២) ឯកសាសនី
អាកឌ្ឍិត្វា នយន្តិយា កោបោ មេ ឧបបជ្ជថ ។
សហ កោបេ សមុប្បន្នេ សីលព្វតមនុស្សរឹ
តត្ថេវ កោបំ និគ្គណ្ហឹ នាទាសឹ វឌ្ឍិតូបរិ ។
យទិ នំ ព្រាហ្មណឹ កោចិ កោដ្ដេយ្យ តិណ្ហសត្តិយា
នេវ សីលំ បភិន្ទេយ្យំ ពោធិយាយេវ ការណា ។
ន មេសា ព្រាហ្មណី ទេស្សា នបិ មេ ពលំ ន វិជ្ជតិ
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា សីលានុរក្ខិស្សន្តិ ។

ចូឡពោធិចរិយំ ចតុត្ថំ ។

---

១ ម. សហជា ។ ២ ឱ. ម. សហជា ។

## ចូឡពោធិចរិយា ទី ៤

កាលព្រះរាជា ទ្រង់ត្រាស់សួរយ៉ាងនេះហើយ តថាគតបាន ទូលព្រះរាជាថា ស្រីនេះ មិនមែនជាភរិយារបស់អាត្មាភាពទេ គ្រាន់តែជាស្រីមានធម៌ត្រូវគ្នា មានសាសនាត្រូវគ្នាប៉ុណ្ណោះ ។ ព្រះរាជា មានព្រះទ័យប្រតិព័ទ្ធ ចំពោះបរិព្វាជិកានោះ ក៏ប្រើរាជបុរសឲ្យចាប់ សង្កត់សង្កិនដោយកម្លាំង យកចូលទៅខាងក្នុងព្រះរាជវាំង ។ កាលភរិយា មានជាតិជាមួយគ្នា មានសាសនាត្រូវគ្នា របស់តថាគត ដែលរាជបុរសទាញអូសនាំទៅនោះ សេចក្តីក្រោធ ក៏កើតឡើងដល់តថាគត ។ កាលសេចក្តីក្រោធកើតឡើង តថាគតពិចារណា នូវសីលតែ ផ្ចាញ់ផ្ចាល់នូវសេចក្តីក្រោធក្នុងទីនោះ មិនឲ្យចំរើនឡើងបាន បើប្រសិនជាអ្នកណាមួយ ចាក់ព្រាហ្មណីនោះ ដោយលំពែងដ៏មុត តថាគតក៏មិនទំលាយសីល ព្រោះហេតុនៃពោធិញ្ញាណ ព្រាហ្មណីនោះ មិនមែនជាទីស្អប់របស់តថាគតទេ ទាំងកម្លាំងតថាគត ក៏មិនមែនជាមិនមានឡើយ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគត រក្សាសីលតែម្យ៉ាង ។

ចប់ ចូឡពោធិចរិយា ទី ៤ ។

# បញ្ចមំ មហិសរាជចរិយំ

(១៨) បុនាបរំ យទា ហោមិ មហិសោ(១) បវនចារកោ
បវឌ្ឍកាយោ ពលវា មហន្តោ ភីមទស្សនោ ។
បព្ភារេ គិរិទុគ្គេ ច រុក្ខមូលេ ទកាសយេ
ហោតេត្ថ ឋានំ មហិសានំ កោចិ កោចិ តហឹ តហឹ ។
វិចរន្តោ ព្រហារញ្ញេ ឋានមទ្ទស ភទ្ទកំ
តំ ឋានំ ឧបគន្ត្វាន តិដ្ឋាមិ ច សយាមិ ច ។
អថេត្ថ កបិមាគន្ត្វា បាបោ អនរិយោ លហុ
ខន្ធេ នលាដេ ភមុកេ មុត្តេតិ ឱហទេតិ តំ ។
សកឹបិ ទិវសំ ទុតិយំ តតិយំ ចតុត្ថំបិ ច
ទូសេតិ មំ សព្វកាលំ តេន ហោមិ ឧបទ្ទុតោ ។
មមំ ឧបទ្ទុតំ ទិស្វា យក្ខោ មំ ឥទមព្រវិ
នាសេហេតំ ឆវំ បាបំ សិង្គេហិ ច ខុរេហិ ច ។

---

១ ឱ. ម. មហិំសោ វនចារកោ ។ ម. មហឹសោ បវនចារកោ ។

# មហិសរាជចរិយា ទី ៥

(១៩) មានចរិយាដទៃទៀត កាលតថាគតកើតជាក្របីព្រៃ ត្រាច់ទៅក្នុងព្រៃធំ មានកាយចំរើន មានកម្លាំងច្រើន មានសរីរៈធំធាត់ បើគេឃើញហើយគួរតែខ្លាច ៗ ទីនៅនៃក្របីទាំងឡាយមានក្នុងទីនោះ គឺញកភ្នំ ផ្លូវជិតភ្នំដែលបុគ្គលទៅបានដោយកម្រ គល់ឈើនិងបឹង សត្វនីមួយ ៗ កាលត្រាច់ទៅក្នុងទីនោះ ៗ តែងបានឃើញទីដ៏ល្អក្នុងព្រៃធំ ឯតថាគតក៏ចូលទៅកាន់ទីនោះ ឈរផងដេកផង ៗ គ្រានោះ មានស្វាមួយក្នុងព្រៃធំនោះ ជាសត្វលាមកថោកទាប ខ្សេះខ្សោះ មកកាន់ទីនោះ នោម ជុះ ដាក់តថាគតត្រង់ក ថ្ងាស និងចិញ្ចើម ៗ ពានរនោះ ប្រទូស្តនឹងតថាគត អស់មួយថ្ងៃ ពីរថ្ងៃ បីថ្ងៃ បួនថ្ងៃ តថាគតត្រូវពានរនោះ បៀតបៀនសព្វ ៗ កាល ៗ ទេវតាឃើញតថាគត ដែលត្រូវស្វានោះបៀតបៀនហើយ ក៏ពោលពាក្យនេះនឹងតថាគតថា (ម្នាលក្របី) អ្នកចូរញុំាងស្វាលាមកអាក្រក់នេះ ឲ្យវិនាសដោយស្នែងនិងក្រចកទៅ ៗ

ឯវំ វុត្តោ តទា យក្ខោ    អហំ តំ ឥទមព្រវឹ
កឹ ត្វំ មក្ខេសិ កុណបេន    បាបេន អនរិយេន មំ ។
យទិហន្តស្ស បកុប្បេយ្យំ    តតោ ហីនតរោ ភវេ
សីលញ្ច មេ បភិជ្ជេយ្យ    វិញ្ញូ ច គរហេយ្យុ មំ ។
ហីឡិតា ជីវិតា វាបិ    បរិសុទ្ធេន មតំ វរំ
ក្យាហំ ជីវិតហេតុបិ    កាហាមិ បរហេឋនំ ។
ហីនមជ្ឈិមុក្កដ្ឋេ    សហន្តោ អវមានិតំ
ឯវំ លភតិ សប្បញ្ញោ    មនសា យថា បត្ថិតន្តិ ។

មហិសរាជចរិយំ បញ្ចមំ ។

## ឆដ្ឋមំ រុរុមិគចរិយំ

(១៦) បុនាបរំ យទា ហោមិ    សុតត្តកនកសន្និភោ(១)
មិគរាជា រុរុ នាម    បរមសីលសមាហិតោ ។

---

១ ម. សុវណ្ណកនកសន្និភោ ។

កាលទេវតាពោលយ៉ាងនេះហើយ តថាគតបាននិយាយតបទៅនឹងទេវតានោះវិញថា (ម្នាលទេវតា) បើទុកជាអ្នកប្រឡាក់ខ្ញុំដោយសាកសព លាមក ថោកទាប ដូចម្តេចក៏ដោយ ក៏ខ្ញុំមិនធ្វើតាមពាក្យអ្នកឡើយ ។ ព្រោះថា បើខ្ញុំខឹងនឹងស្វានេះ ខ្ញុំជាបុគ្គលថោកទាប ជាងស្វានោះទៅទៀត សីលរបស់ខ្ញុំនឹងបែកធ្លាយផង វិញ្ញូជនទាំងឡាយ នឹងតិះដៀលដល់ខ្ញុំផង ។ ការស្លាប់ដោយសេចក្តីបរិសុទ្ធ ប្រសើរជាងការរស់នៅ ដែលពួកអ្នកប្រាជ្ញតិះដៀល បើយ៉ាងនេះ ឲ្យខ្ញុំធ្វើនូវការបៀតបៀនអ្នកដទៃ ព្រោះហេតុតែជីវិត (របស់ខ្លួន) ដូចម្តេចកើត ។ បុគ្គលប្រកបដោយប្រាជ្ញា កាលអត់ទ្រាំ ចំពោះសេចក្តីមើលងាយ (របស់ពួកជនដទៃ) ក្នុងហេតុយ៉ាងមុទុ មជ្ឈិម និងឧក្រិដ្ឋ រមែងបានសម្រេច ដូចសេចក្តីប្រាថ្នាក្នុងចិត្ត យ៉ាងនេះឯង ។

ចប់ មហិសរាជចរិយា ទី ៥ ។

## រុរុមិគចរិយា ទី ៦

(១៦) មានចរិយាដទៃទៀត កាលតថាគតកើតជាស្តេចម្រឹគ ឈ្មោះរុរុ សម្បុរស្បែកដូចមាសដែលជាងដុតល្អ ប្រកបដោយសីលដ៏ឧត្តម ។

រម្មេ បទេសេ រម្មណីយេ វិវិត្តេ អមនុស្សកេ
តត្ថ វាសំ ឧបគញ្ឆឹ គង្គាកូលេ មនោរមេ ។
អថ ឧបរិ គង្គាយ ធនិកេហិ បរិបីឡិតោ
បុរិសោ គង្គាយ បតតិ ជីវាមិ វា មរាមិ វា ។
រត្តិន្ទិវំ សោ គង្គាយ វុយ្ហមានោ មហោទកេ
រវន្តោ ករុណំ រវំ មជ្ឈេ គង្គាយ គច្ឆតិ ។
តស្សាហំ សទ្ទំ សុត្វាន ករុណំ បរិទេវតោ
គង្គាយ តីរេ ឋត្វាន អបុច្ឆឹ កោសិ ត្វំ នរោ ។
សោ មេ បុដ្ឋោ ព្យាករាសិ អត្តនោ ការណំ តទា
ធនិកេហិ ភីតោ តសិតោ បក្ខន្ទោហំ មហានទឹ ។
តស្ស កត្វាន ការុញ្ញំ ចជិត្វា មម ជីវិតំ
បវិសិត្វា នីហរិន្តស្ស អន្ធការម្ហិ រត្តិយា ។

កាលនោះ ប្រទេសដែលគួរឲ្យត្រេកអរ គួរឲ្យរីករាយ ជាប្រទេសស្ងាត់ស្ងៀម មិនមានមនុស្ស នៅជិតច្រាំងទន្លេគង្គា គួរជាទីរីករាយនៃចិត្ត តថាគតបានចូលទៅនៅក្នុងទីនោះ ។ កាលនោះ មានបុរសម្នាក់ (ចំពាក់បំណុលគេ) ត្រូវពួកម្ចាស់ទ្រព្យតឹងតារខ្លាំង ក៏លោតទម្លាក់ខ្លួនចុះ ក្នុងទឹកខាងលើខ្សែទឹកទន្លេគង្គា ដោយគិតថា អញរស់ក៏ដោយ ស្លាប់ក៏ដោយ ។ បុរសនោះ ត្រូវខ្សែទឹកទន្លេគង្គា កួចទៅក្នុងទឹកធំ អស់មួយយប់មួយថ្ងៃ ស្រែកនូវសម្រែកគួរអាណិត អណ្តែតទៅក្នុងកណ្តាលទន្លេ ។ តថាគតឮសម្លេងនៃបុរសនោះ កំពុងខ្សឹកខ្សួល គួរអាណិត ឋិតនៅទៀបឆ្នេរនៃស្ទឹង ក៏ស្រែកសួរថា អ្នកជាមនុស្សឬ ។ បុរសនោះ ដែលតថាគតសួរហើយ ក៏ប្រាប់ហេតុរបស់ខ្លួន ក្នុងកាលនោះថា ខ្ញុំភ័យតក់ស្លុតខ្លាំងនឹងពួកម្ចាស់បំណុល ហើយស្ទុះមកក្នុងស្ទឹងធំនេះ ។ តថាគតមានសេចក្តីអាណិត ចំពោះបុរសនោះ ក៏ប្រថុយលះបង់ជីវិតរបស់ខ្លួន ចូលទៅនាំយកបុរសនោះមក ក្នុងរាត្រីដ៏ងងឹត ។

## អដ្ឋមំ រុរុមិគចរិយំ

អស្សត្ថកាលមញ្ញាយ តស្សាហំ ឥទមព្រវិំ
ឯកន្តំ វរំ យាចាមិ មា មំ កស្សចិ បាវទ ។
នគរំ គន្ត្វាន អាចិក្ខិ បុច្ឆិតោ ធនហេតុកោ
រាជានំ សោ គហេត្វាន ឧបគញ្ឆិ មមន្តិកំ ។
យាវតា ការណំ សព្វំ រញ្ញោ អារោចិតំ មយា
រាជា សុត្វាន វចនំ ឧសុំ តស្ស បកប្បយិ ។
ឥធេវ ឃាតយិស្សាមិ មិត្តទុព្ភិំ អនរិយំ
តមហំ អនុរក្ខន្តោ និម្មិនិំ មម អត្តនា ។
តិដ្ឋតេ សោ មហារាជ កាមការោ ភវាមិ តេ
អនុរក្ខិំ មម សីលំ នារក្ខិំ មម ជីវិតំ
សីលវា ហិ តទា អាសិំ ពោធិយាយេវ ការណាតិ ។

រុរុមិគចរិយំ ឆដ្ឋមំ ។

## រុរុមិគចរិយា ទី ៦

តថាគតដឹងនូវកាលនៃបុរសនោះ ផុតសេចក្តីលំបាកហើយ ក៏ពោលពាក្យនេះ នឹងបុរសនោះថា ខ្ញុំសូមពរមួយនឹងអ្នកថា ចូរអ្នកកុំប្រាប់រូបខ្ញុំ ដល់អ្នកណាមួយឡើយ ។ បុរសនោះទៅកាន់នគរវិញ ស្តេចសួរ ហេតុតែចង់បានទ្រព្យ ក៏ក្រាបទូល (ដល់ស្តេច) ហើយនាំស្តេចចូលទៅកាន់សំណាក់តថាគត ។ តថាគត ប្រាប់ហេតុសព្វគ្រប់ដល់ស្តេច ស្តេចលុះបានស្តាប់ពាក្យនោះហើយ ក៏បានសម្រេចព្រះទ័យថា ត្រូវសម្លាប់បុរសនេះ ដោយកូនសរ (ទ្រង់ត្រាស់ថា) អញនឹងសម្លាប់បុរសទ្រុស្តមិត្ត ដ៏អាក្រក់ ក្នុងទីនេះ ។ តថាគតកាលរក្សានូវបុរសនោះ ក៏ស៊ូប្តូរខ្លួនបុរសនោះ ដោយខ្លួនរបស់តថាគត (ក្រាបទូលថា) បពិត្រមហារាជ បុរសនុ៎ះ ចូររស់នៅចុះ សូមព្រះអង្គធ្វើខ្ញុំព្រះអង្គតាមប្រាថ្នាវិញ ។ តថាគតរក្សាសីល របស់តថាគត មិនរក្សាជីវិត របស់តថាគតឡើយ បានជាក្នុងកាលនោះ តថាគតកាន់សីលម៉ត់ចត់ ព្រោះហេតុតែពោធិញ្ញាណ ។

ចប់ រុរុមិគចរិយា ទី ៦ ។

# សត្តមំ មាតង្គចរិយំ

(១៧) បុនាបរំ យទា ហោមិ ជដិលោ ឧគ្គតាបនោ
មាតង្គោ នាម នាមេន សីលវា សុសមាហិតោ ។
អហញ្ច ព្រាហ្មណោ ឯកោ គង្គាកូលេ វសាមុភោ
អហំ វសាមិ ឧបរិ ហេដ្ឋា វសតិ ព្រាហ្មណោ ។
វិចរន្តោ អនុកូលម្ហិ ឧទ្ធម្មេ អស្សមទ្ទស
តត្ថ មំ បរិភាសិត្វា អភិសបិ មុទ្ធផាលនំ ។
យទិ ហន្តស្ស បកុប្បេយ្យំ យទិ សីលំ ន គោបយេ
ឱលោកេត្វានហន្តស្ស ករេយ្យំ ឆារិកំ វិយ ។
យំ សោ តទា មំ អភិសបិ កុបិតោ ទុដ្ឋមានសោ
តស្សេវ មត្ថកេ និបតិ យោគេន តំ បមោចយឹ ។
អនុរក្ខឹ មម សីលំ នារក្ខឹ មម ជីវិតំ
សីលវា ហិ តទា អាសឹ ពោធិយាយេវ ការណាតិ ។

មាតង្គចរិយំ សត្តមំ ។

# មាតង្គចរិយា ទី ៧

(១៧) មានចរិយាដទៃទៀត កាលតថាគត កើតជាជដិលតាបស ឈ្មោះមាតង្គៈ មានតបៈខ្ពង់ខ្ពស់ មានសីលបរិសុទ្ធ មានចិត្តតម្កល់មាំល្អ ។ ជនពីរនាក់ គឺតថាគត និងព្រាហ្មណ៍ នៅជិតឆ្នេរទន្លេគង្គា តថាគតនៅខាងលើខ្សែទឹក ឯព្រាហ្មណ៍នៅខាងក្រោមខ្សែទឹក ។ ព្រាហ្មណ៍ កាលដើរទៅតាមឆ្នេរទន្លេ បានឃើញអាស្រមតថាគត នៅខាងលើខ្សែទឹក ក៏ប្រទេចផ្ដាសាតថាគតក្នុងទីនោះ ហើយដាក់សម្បថថា (ចូរឲ្យក្បាលអ្នក បែកជា ៧ ភាគ ក្នុងថ្ងៃទី ៧) ។ បើតថាគតខឹងនឹងព្រាហ្មណ៍ មានតែតថាគតមិនរក្សាសីល តថាគតនឹងក្រឡេកមើលព្រាហ្មណ៍នោះ ហើយធ្វើឲ្យឆេះទៅជាផេះក៏បាន ។ កាលណោះ ព្រាហ្មណ៍នោះ មានចិត្តប្រទូស្តខឹង ដាក់សម្បថដល់តថាគត ដោយឧបាយណា សម្បថនោះ បែរជាធ្លាក់លើក្បាលព្រាហ្មណ៍នោះវិញ តថាគតដោះព្រាហ្មណ៍នោះ ឲ្យរួចចាកសម្បថ ដោយឧបាយនោះ ។ តថាគតរក្សាសីល របស់តថាគត មិនរក្សាជីវិត របស់តថាគតឡើយ បានជាក្នុងកាលនោះ តថាគតកាន់សីលម៉ត់ចត់ ព្រោះហេតុនៃពោធិញ្ញាណ ។

ចប់ មាតង្គចរិយា ទី ៧ ។

# អដ្ឋមំ ធម្មទេវបុត្តចរិយំ

(១៨) បុនាបរំ យទា ហោមិ មហេសក្ខោ(១) មហិទ្ធិកោ
ធម្មោ នាម មហាយក្ខោ សព្វលោកានុកម្បកោ ។
ទសកុសលកម្មបថេ សមាទបេន្តោ មហាជនំ
ចរាមិ គាមនិគមំ សមិត្តោ សបរិជនោ ។
បាបោ កទរិយោ យក្ខោ ទីបេន្តោ ទស បាបកេ
សោបេត្ថ មហិយា ចរតិ សមិត្តោ សបរិជនោ ។
ធម្មវាទី អធម្មោ ច ឧភោ បច្ចនិកា មយំ
ធុរេ ធុរំ ឃដ្ដយន្តា សមិម្ហា បដិបថេ ឧភោ ។
កលហោ វត្តតី ភេស្មា(២) កល្យាណបាបកស្ស ច
មគ្គា ឧក្កមនត្ថាយ មហាយុទ្ធោ ឧបដ្ឋិតោ ។
យទិហំ តស្ស បកុប្បេយ្យំ យទិ ភិន្ទេ តបោគុណំ
សហ បរិជនស្ស រជភូតំ ការេយ្យហំ ។

១ ឱ. មហាយក្ខោ ។ ម. មហាបក្ខោ ។ ២ ឱ. អស្មា ។

# ធម្មទេវបុត្តបរិយា ទី ៨

(១៨) មានបរិយាយដទៃទៀត កាលតថាគត កើតជាទេវបុត្ត មានអានុភាពធំ ឈ្មោះធម្មៈ មានសក្តិធំ មានឫទ្ធិច្រើន ជាអ្នកអនុគ្រោះដល់សត្វលោកទាំងពួង ៗ កាលនោះ តថាគត ញុំាងមហាជនឲ្យតម្កល់នៅក្នុងកុសលកម្មបថ ១០ ត្រាច់ទៅក្នុងស្រុកនិងនិគម ជាមួយនឹងមិត្រ ជាមួយនឹងជនជាបរិវារ ៗ មានទេវបុត្តមួយអង្គ មានធម៌លាមក កំណាញ់ស្វិតស្វាញ សម្ដែងនូវធម៌លាមក ១០ ប្រការ ទេវបុត្តនោះត្រាច់ទៅលើផែនដីដ៏ធំ ក្នុងជម្ពូទ្វីបនេះ ជាមួយនឹងមិត្ត ជាមួយនឹងជនជាបរិវារ ៗ យើងជាទេវបុត្តទាំងពីរនាក់ គឺទេវបុត្តអ្នកពោលនូវធម៌ និងទេវបុត្តអ្នកពោលនូវអធម៌ ទៅជាសត្រូវនឹងគ្នា យើងទាំងពីរនាក់ ត្រូវបររថប៉ះទឹមដោយទឹម ក្នុងផ្លូវជួបគ្នា ៗ ជម្លោះជាហេតុញុំាងភ័យឲ្យកើត ប្រព្រឹត្តទៅដល់កល្យាណ-ទេវបុត្តនិងបាបទេវបុត្ត មហាសង្គ្រាមក៏តាំងឡើង ដើម្បីប្រ-ដែងផ្លូវគ្នា ៗ បើតថាគតខឹងនឹងអធម្មទេវបុត្ត មានតែតថាគតទំលាយតបោគុណ គឺសីលដ៏ប្រសើរ តថាគតគប្បីធ្វើនូវអធម្ម-ទេវបុត្តនោះ ព្រមទាំងជនជាបរិស័ទឲ្យទៅជាធូលីក៏បាន ៗ

អបិចាហំ សីលរក្ខាយ និព្វាបេត្វាន មានសំ
សហ ជនេនោក្កមិត្វា បថំ បាបស្ស ទាសហំ ។
សហ បថតោ ឱក្កន្តេ កត្វា ចិត្តស្ស និព្វុតឹ
វិវរំ អទាសិ បថវី បាបយក្ខស្ស តាវទេតិ ។

ធម្មទេវបុត្តចរិយំ អដ្ឋមំ ។

## នវមំ ជយទិសចរិយំ

(១៩) បញ្ចាលរដ្ឋេ នគរវរេ កបិលាយំ បុរុត្តមេ
រាជា ជយទិសោ នាម សីលគុណមុបាគតោ ។
តស្ស រញ្ញោ អហំ បុត្តោ សុតធម្មោ សុសីលវា
អនីនសត្តោ គុណវា អនុរក្ខបរិជនោ សទា ។
បិតា មេ មិគវំ គន្ត្វា បោរិសាទំ ឧបាគមិ
សោ មេ បិតុមគ្គហេសិ ភក្ខោសិ មម មា ចលិ ។

ប៉ុន្តែតថាគតរំលត់ចិត្ត ដើម្បីរក្សាសីល តថាគតព្រមទាំងជនជាបរិស័ទក៏បរចៀស បើកផ្លូវឲ្យបាបទេវបុត្ត ។ កាលតថាគតព្រមទាំងជនជាបរិស័ទ រំលត់ចិត្ត បររថ ចៀសអំពីផ្លូវហើយ មហាប្រថពី ក៏ស្រូបបាបទេវបុត្ត ក្នុងខណៈនោះ ។

ចប់ ធម្មទេវបុត្តចរិយា ទី ៨ ។

# ជយទិសចរិយា ទី ៩

(១៩) មានស្តេចមួយអង្គ ព្រះនាមជយទិស ប្រកបដោយសីលគុណ ក្នុងក្រុងដ៏ឧត្តម ឈ្មោះកប្បិលា ជាក្រុងដ៏ប្រសើរ ក្នុងដែនបញ្ចាល ។ តថាគត កើតជាព្រះរាជបុត្ត របស់ស្តេចនោះ ឈ្មោះអលីនសត្តកុមារ ជាអ្នកល្បីល្បាញក្នុងធម៌ មានសីលដ៏ល្អ ប្រកបដោយមហាបុរិសគុណ ជាអ្នករក្សានូវជនជាបរិវារ សព្វកាល ។ បិតារបស់តថាគត បានទៅប្រមាញម្រឹគ (ក្នុងព្រៃ) ជ្រួលចូលទៅកាន់សំណាក់យក្ស ឈ្មោះបោរិសាទ យក្សនោះចាប់ស្តេចជយទិស ជាបិតានៃតថាគត (ហើយនិយាយថា) អ្នកត្រូវជាអាហាររបស់យើងហើយ អ្នកកុំកម្រើកឡើយ ។

## ទសមំ ជយទិសចរិយំ

តស្ស តំ វចនំ សុត្វា　　ភីតោ តសិតវេធិតោ
ឩរុត្ថម្ភោ អហុ តស្ស　　ទិស្វាន បោរិសាទកំ ។
មិគវំ គហេត្វា មុញ្ចស្សុ　　កត្វា អាគមនំ បុន
ព្រាហ្មណស្ស ធនំ ទត្វា　　បិតា អាមន្តយី មមំ ។
រជ្ជំ បុត្ត បដិបជ្ជ　　មា បមជ្ជ បុរំ ឥទំ
កតំ មេ បោរិសាទេន　　មម អាគមនំ បុន ។
មាតុបិតុញ្ច វន្ទិត្វា　　និម្មិនិត្វាន អត្តនំ
និក្ខិបិត្វា ធនុំ ខគ្គំ　　បោរិសាទមុបាគមឹ ។
សសត្ថហត្ថូបគតំ　　កទាចិ សោ តសិស្សតិ
តេន ភិជ្ជិស្សតី សីលំ　　បរិត្តាសំ កតេ មយិ ។
សីលខណ្ឌភយា មយ្ហំ　　តស្ស ទេស្សំ ន ព្យាហរឹ
មេត្តចិត្តោ ហិតវាទី　　ឥទំ វចនមព្រវឹ ។

បិតារបស់តថាគតនោះ លុះឮពាក្យរបស់យក្ខិនីបុត្តនោះ ហើយ ក៏ភ័យ តក់ស្លុត ញ័រន្ធត់ រឹងក្តៅទាំងពីរ បិតានៃតថាគតនោះ ឈរនៅស្ងៀម មិនអាចនឹងរត់ចេញទៅបាន ព្រោះឃើញស្តេចពោរិសាទ ។ ព្រះរាជាទ្រង់អង្វរថា សូមអ្នកយកសាច់ម្រឹគនេះចុះ សូមលែងខ្ញុំ ខ្ញុំនឹងឲ្យទ្រព្យដល់ព្រាហ្មណ៍ រួចហើយនឹងត្រឡប់មកវិញ ។ បិតាហៅតថាគតមកប្រាប់ថា ម្នាលកូន អ្នកចូរគ្រប់គ្រងរាជ្យ ចូរកុំប្រមាទបុរីនេះឡើយ ដែលអញបានត្រឡប់មកវិញនេះ ព្រោះតែអញបានប្តេជ្ញា ជាមួយនឹងយក្សពោរិសាទ ។ តថាគត ថ្វាយបង្គំព្រះមាតានិងព្រះបិតា ហើយនិម្មិតខ្លួនកាន់ធ្នូនិងពះខាន់ ចេញអំពីនគរ ដើរចូលទៅរកពោរិសាទយក្ស ។ ( តថាគតគិតថា យក្សនោះបើឃើញតថាគត ) មានគ្រឿងសាស្ត្រាវុធនៅក្នុងដៃ ក៏នឹងតក់ស្លុត កាលបើតថាគតធ្វើយក្សនោះឲ្យតក់ស្លុត សីលរបស់តថាគត នឹងបែកធ្លាយ ដោយការញុំាងសេចក្តីតក់ស្លុត ឲ្យកើតដល់យក្សនោះ ។ (លុះគិតឃើញយ៉ាងនេះ ) តថាគតមិនពោលពាក្យជាទីស្អប់ ទៅរកយក្សនោះទេ ព្រោះការខ្លាចដាច់សីល នៃតថាគត តថាគតមានមេត្តាចិត្តពោលតែពាក្យមានប្រយោជន៍ ហើយបានពោលនូវពាក្យនេះថា

ឧជ្ជលេហិ មហាអគ្គឹ   បបតិស្សាមិ រុក្ខតោ
សុបក្កកាលសមញ្ញាយ(១)   ភក្ខយ ត្វំ បិតាមហា ។
ឥតិ សីលវតំ ហេតុ   នារក្ខឹ មម ជីវិតំ
បព្វាជេសិ មហាន្តស្ស   សទា បាណាតិបាតិកន្តិ ។

ជយទ្ទិសចរិយំ នវមំ ។

## ទសមំ សង្ខបាលចរិយំ

(២០) បុនាបរំ យទា ហោមិ   សង្ខបាលោ មហិទ្ធិកោ
ទាឍាវុធោ(២) ឃោរវិសោ   ទ្វិជិវ្ហោ ឧរគាភិភូ ។
ចតុប្បថេ មហាមគ្គេ   នានាជនសមាកុលេ
ចតុរោ អង្គេ អធិដ្ឋាយ   តត្ថ វាសមកប្បយឹ ។
ឆវិយា ចម្មេន មំសេន   ន្ហារូហិ អដ្ឋិកេហិ វា
យស្ស ឯតេន ករណីយំ   ទិន្នំយេវ ហរាតុ សោ ។
អទ្ទសំសុ ភោជបុត្តា   ខរា លុទ្ទា អការុណា
ឧបគញ្ឆុំ មមំ តត្ថ   ទណ្ឌមុគ្គរបាណិនោ ។

---

១ ឱ. សម្បត្តកាលមញ្ញេយ ។ ម. សម្បក្កកាលមញ្ញាយ ។ ២ ឱ. ម. ទាឋាវុធោ ។

ចូរលោកតាដុតភ្លើងឲ្យឆេះខ្លាំងឡើង ខ្ញុំនឹងលោតពីដើមឈើនេះទម្លាក់ទៅ (ក្នុងភ្លើងនោះ) បពិត្រជីតា បើលោកតាដឹងនូវកាលនៃសាច់នោះឆ្អិនល្អហើយ ចូរបរិភោគសាច់នោះចុះ ។ ព្រោះហេតុបិតាមានសីល ដូចរៀបរាប់មកនេះ តថាគតមិនរក្សាជីវិត របស់តថាគតទេ តថាគតញុំាងបោរិសាទ ជាអ្នកធ្វើអំពើបាណាតិបាត ឲ្យវៀរបង់អំពើអាក្រក់ សព្វកាល ។

ចប់ ជយទិសបរិយា ទី ៩ ។

# សង្ខបាលបរិយា ទី ១០

(២០) មានបរិយាដទៃទៀត កាលតថាគតកើតជាស្តេចនាគឈ្មោះសង្ខបាល មានឫទ្ធិច្រើន មានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក មានអណ្តាតពីរ ជាសត្វគ្របសង្កត់ឧរគជាតិ ។ តថាគត អធិដ្ឋានអង្គទាំង ៤ ជិតផ្លូវធំ ៤ ជាកន្លែងទៅមកនៃជនផ្សេង ៗ ហើយសម្រេចនូវការនៅក្នុងទីនោះ ។ បុគ្គលណា មានកិច្ចគួរធ្វើដោយអវយវៈនេះ គឺសម្បុរថ្ងៃ ស្បែក សាច់ សរសៃ និងឆ្អឹង បុគ្គលនោះ ចូរនាំយកអវយវៈដែលអញឲ្យហើយចុះ ។ កូនព្រាននៃព្រៃទាំងឡាយ ជាមនុស្សរឹងត្អឹងអាក្រក់ ឥតមានសេចក្តីអាណិតអាសូរ មានដំបង៤ជ្រុងក្នុងដៃ បានឃើញតថាគត ហើយដើរចូលមកក្នុងទីនោះ ៗ

នាសាយ វិនិវិជ្ឈិត្វា នង្គុដ្ឋេ បិដ្ឋិកណ្ឌកេ
កាជេ អារោបយិត្វាន ភោជបុត្តា ហរឹសុ មំ ។
សសាគរន្តំ បថវឹ សកាននំ សបព្វតំ
ឥច្ឆមានោ ចហំ តត្ថ នាសាវាតេន ឈាបយេ ។
សូលេហិ វិជ្ឈិយន្តេបិ កោដ្ដយន្តេបិ សត្តិភិ
ភោជបុត្តេ ន កុប្បាមិ ឯសា មេ សីលបារមីតិ ។

**សង្ខបាលចរិយំ ទសមំ ។**

## តស្សុទ្ទានំ

ហត្ថិនាគោ ភូរិទត្តោ ចម្បេយ្យោ ពោធិ មាហិសោ
រុរុមាតង្គធម្មោ ច អត្រជោ ច ជយទ្ទិសោ ។
ឯតេ សព្វេ សីលពលា បរិក្ខារ បទេសិកា
ជីវិតំ បរិរក្ខិត្វា សីលានិ អនុរក្ខិស្សំ ។
សង្ខបាលស្ស មេ សតោ សព្វកាលម្បិ ជីវិតំ
យស្ស កស្សចិ និយ្យន្តំ តស្មា សា សីលបារមីតិ ។

**សីលបារមីនិទ្ទេសោ និដ្ឋិតោ ។**

កូនព្រានព្រៃទាំងឡាយ បានចោះតថាគតត្រង់ប្រមុះ កន្ទុយ ខ្នង ទិនក ហើយលើកតថាគតដាក់ក្នុងសម្រែក រែកយកទៅ ។ តថាគត បើប្រាថ្នានឹងធ្វើនូវមហាប្រថពី ដែលមានសមុទ្រជាទីបំផុត ព្រមទាំងឈើព្រៃ ព្រមទាំងភ្នំ ឲ្យឆេះខ្ទេចទៅជាផេះ ដោយខ្យល់តាមប្រមុះ ក្នុងទីនោះ ក៏បាន ។ (ប៉ុន្តែ) តថាគត មិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច និងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមីរបស់តថាគត ។

ចប់ សង្ខបាលចរិយា ទី ១០ ។

## ឧទ្ទាននៃចរិយានោះ

សីលវនាគចរិយា ១ ភូរិទត្តចរិយា ១ ចម្បេយ្យចរិយា ១ ចូឡពោធិចរិយា ១ មហិសរាជចរិយា ១ រុរុមិគចរិយា ១ មាតង្គចរិយា ១ ទេវធម្មបុត្តចរិយា ១ ជយទិសចរិយា ១ សង្ខបាលចរិយា ១ ។ ចរិយាទាំងអស់នោះ តថាគតសម្តែងហើយថា មានសីលជាកម្លាំង ជាបរិក្ខារ តថាគតបានគ្រប់គ្រងជីវិត រក្សាសីល ។ កាលតថាគត ជាសង្ខបាលនាគរាជ បានប្រគល់ជីវិតឲ្យដល់បុគ្គលណាមួយ សព្វ ៗ កាល ហេតុនោះ បារមីនោះ ជាសីលបរមត្ថបារមី (នៃតថាគត) ។

ចប់ សីលបារមីនិទ្ទេស ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស ចរិយាបិដកំ

# នេក្ខម្មបារមិតា

## បឋមំ យុធញ្ជយចរិយំ

[២១] យទាហំ អមិតយសោ រាជបុត្តោ យុធញ្ជយោ
ឧស្សាវពិន្ទុំ សុរិយាតបេ បតិតំ ទិស្វាន សំវិជឹ ។
តមេវាធិបតឹ កត្វា សំវេគមនុព្រូហយឹ
មាតាបិតូ ច វន្ទិត្វា បព្វជ្ជមនុយាចហំ ។
យាចន្តិ មំ បញ្ជលិកា សនេគមា សរដ្ឋកា
អជ្ជេវ បុត្ត បដិបជ្ជ ឥទ្ធំ ផីតំ មហាមហឹ ។
សរាជកេ សឱរោធេ(១) សនេគមេ សរដ្ឋកេ
ករុណំ បរិទេវន្តេ អនបេក្ខោ បរិច្ចជឹ ។
កេវលំ បថវឹ រជ្ជំ ញាតិបរិជនំ យសំ
ចជមានោ ន ចិន្តេសឹ ពោធិយាយេវ ការណា ។

---

១ ឱ. សហោរោធេ ។

# នេក្ខម្មបារមី

## យុធញ្ជយចរិយា ទី ១

[២១] កាលដែលតថាគត កើតជារាជបុត្ត (នៃស្តេចសព្វទត្ត) ឈ្មោះយុធញ្ជ័យ ជារាជកុមារមានបរិវារនិងយស រាប់មិនបាន ក្នុងកាលនោះ តថាគតកើតសេចក្តីសង្វេគ ព្រោះឃើញដំណក់ទឹកសន្សើម ដែលរីងហួតដោយកំដៅព្រះអាទិត្យ ។ តថាគតយកដំណក់ទឹកសន្សើមនោះជាអធិបតី បម្រើនូវសេចក្តីសង្វេគ ថ្វាយបង្គំព្រះមាតានិងព្រះបិតា ហើយសូមបព្វជ្ជា ។ ពួករាជបុរស ព្រមទាំងអ្នកនិគម អ្នកនៅក្នុងដែន ផ្គងអញ្ជលីអង្វរតថាគតថា បពិត្រព្រះរាជបុត្ត សូមព្រះអង្គម្ចាស់គ្រប់គ្រងមហាប្រថពី ដែលសម្រេចដោយសម្បត្តិដ៏ស្តុកស្តម្ភ ក្នុងថ្ងៃនេះចុះ ។ តថាគតមិនមានអាល័យ លះបង់រាជបុរស ព្រមទាំងស្តេច ស្រីស្នំ អ្នកនិគម និងអ្នកនៅក្នុងដែន ដែលកំពុងខ្សឹកខ្សួលគួរឲ្យអាណិត ។ តថាគតលះបង់រាជ្យលើដែនដី ញាតិ ជនជាបរិស័ទ និងយសទាំងអស់ ឥតមានគិតដល់ ព្រោះហេតុពោធិញ្ញាណតែម្យ៉ាង ។

មាតា បិតា ន មេ ទេស្សា នបិ មេ ទេស្សា
មហាយសា(១)
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា រជ្ជំ បរិច្ចជិន្តិ ។

យុធញ្ជយចរិយំ បឋមំ ។

# ទុតិយំ សោមនស្សចរិយំ

(២២) បុនាបរំ យទា ហោមិ ឥន្ទបត្ថេ(២) បុរុត្តមេ
កាមិតោ ទយិតោ បុត្តោ សោមនស្សោតិ វិស្សុតោ ។
សីលវា គុណសម្បន្នោ កល្យាណបដិភាណវា
វុឌ្ឍាបចាយី ហិរិមា សង្គហេសុ ច កោវិទោ ។
តស្ស រញ្ញោ បដិករោ អហោសិ កុហកតាបសោ
អារាមំ មាលាវច្ឆញ្ច រោបយិត្វាន ជីវតិ ។
តមហំ ទិស្វាន កុហកំ ថុសរាសីវ អតណ្ឌុលំ
ទុមំវ អន្តោ សុសិរំ កទលិំវ អសារកំ ។

---

១ ឱ. នបិ ទេស្សំ មហាយសំ ។ ម. នបិ មេ ទេស្សំ មហាយសំ ។ ២ ម. ឥន្ទបត្តេ ។

មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិនមែនជាទីស្អប់ របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់ របស់តថាគត ព្រោះហេតុនោះ បានជាតថាគតលះបង់រាជ្យ ។

ចប់ យុធញ្ជយបរិយា ទី ១ ។

## សោមនស្សបរិយា ទី ២

(២២) មានចរិយាដទៃទៀត កាលដែលតថាគត កើតជារាជបុត្ត (នៃស្តេចកុរុរាជ) ក្នុងឥន្ទបត្តបុរដ៏ឧត្តម មានឈ្មោះប្រាកដថា សោមនស្សកុមារ ជារាជបុត្រដែលជនទាំងឡាយមានមាតាបិតាជាដើម ស្រឡាញ់ ពេញចិត្តក្រៃលែង ជាអ្នកមានសីល ប្រកបដោយគុណ មានសំដីពីរោះ គោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យ មានហិរិទាំងមានសេចក្តីឈ្លាសវៃ ក្នុងសង្គហធម៌ (៤យ៉ាង) ។ មានតាបសកុហកម្នាក់ ជាអ្នកស្និទ្ធស្នាលនៃស្តេចកុរុនោះ ដាំសួនច្បារ និងគុម្ពផ្កាចិញ្ចឹមជីវិត ។ តថាគតឃើញកុហកតាបសនោះ ដូចគំនរអង្កាមមិនមានគ្រាប់អង្ករ ដូចឈើមានប្រហោងក្នុង ឬដូចដើមចេកមិនមានខ្លឹម

នត្ថិ មស្ស សតំ ធម្មោ សាមញ្ញាបគតោ អយំ
ហិរិសុក្កធម្មជហិតោ ជីវិតវុត្តិការណា ។
កុបិតោ អាសិ បច្ចន្តោ អដវីហិ បរន្តិហិ
តំ និសេធេតុំ គច្ឆន្តោ អនុសាសិ បិតា មម ។
មា បមជ្ជិ តុវំ តាត ជដិលេ ឧគ្គតាបនេ
យទិច្ឆកំ បវត្តេហិ សព្វកាមទទោ ហិ សោ ។
តមហំ គន្ត្វានុបដ្ឋានំ ឥទំ វចនមព្រវី
កច្ចិ តេ គហបតិ កុសលំ កឹ វា តេ អាហរីយតុ ។
តេន សោ កុបិតោ អាសិ កុហកោ មាននិស្សិតោ
ឃាតាបេមិ តុវំ អជ្ជ រដ្ឋា បព្វាជយាមិ វា ។
និសេធយិត្វា បច្ចន្តំ រាជា កុហកមព្រវិ
កច្ចិ ខមនីយំ តេ(១) សម្មានោ តេ បវត្តិតោ ។

---

១ ឱ. ម. កច្ចិ តេ ភន្តេ ខមនីយន្តិ ទិស្សតិ ។

ក៏ត្រិះរិះថា សប្បុរិសធម៌ មានឈានជាដើម នៃតាបសនេះ មិនមានទេ តាបសនេះ ជាបុគ្គលប្រាសចាកភាពជាសមណៈ លះបង់សុក្កធម៌គឺហិរិនិងឱត្តប្បៈ ព្រោះហេតុតែការចិញ្ចឹមជីវិត ៗ ក្នុងបច្ចន្តប្រទេស មានពួកចោរនៅក្នុងព្រៃធំបះបោរ បិតារបស់តថាគត ទៅបង្ក្រាបបច្ចន្តប្រទេសនោះ បានផ្តាំ (តថាគតថា) ម្នាលកូន ចូរបាកុំធ្វេសប្រហែស ចំពោះជដិលដែលមានតបៈដ៏ខ្ពង់ខ្ពស់ ចូរបាញុំាងជដិលនេះ ឲ្យប្រព្រឹត្តទៅតាមសេចក្តីប្រាថ្នាចុះ ព្រោះតាបសនោះ ជាអ្នកឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ៗ តថាគត ទៅកាន់ទីបំរើតាបសនោះ បានពោលនូវពាក្យនេះថា ម្នាលគហបតី អ្នកសុខសប្បាយទេឬ ពួកអ្នកជំនួញនាំ (មាសនិងប្រាក់) មកឲ្យអ្នកដែរឬ ៗ ព្រោះពាក្យដែលតថាគត ពោលថាគហបតី កុហកតាបសនោះ អាស្រ័យនូវមានះ ក៏ខឹង (និយាយថា) ក្នុងថ្ងៃនេះ អាត្មាភាពនឹងឲ្យស្តេចសម្លាប់ទ្រង់ ឬឲ្យបំបរបង់ទ្រង់ចាកដែន ៗ លុះព្រះរាជាបង្ក្រាបបច្ចន្តប្រទេសរួចហើយ (ត្រឡប់មកនគរវិញ ស្តេចចូលទៅកាន់ឧទ្យាន) ទ្រង់ត្រាស់សួរកុហកតាបសថា (បពិត្រលោកម្ចាស់ដ៏ចម្រើន) ចុះលោកល្មមអត់ទ្រាំបានទេឬ រាជកុមាររាប់អានលោកស្រួលបួលទេឬ ៗ

## ទុតិយំ សោមនស្សចរិយំ

តស្ស អាចិក្ខតី បាបោ    កុមារោ យថា ជាសិយោ(១)
តស្ស តំ វចនំ សុត្វា    អាណាបេសិ មហីបតិ ។
សីសំ តត្ថេវ ឆិន្ទិត្វា    កាត្វាន ចតុខណ្ឌិកំ
រថិយា រថិយំ ទស្សេថ    សា គតិ ជដិលហីឡិតា ។
តត្ថ តេ ការណី(២) គន្ត្វា    ចណ្ឌា លុទ្ធា អការណា
មាតុ អង្កេ និសិន្នស្ស    អាកឌ្ឍិត្វា នយន្តិ មំ ។
តេសាហំ ឯវមវចំ    ពន្ធំ គាឡ្ហពន្ធនំ
រញ្ញោ ទស្សេថ មំ ខិប្បំ    រាជកិរិយានិ អត្ថិ មេ ។
តេ មំ រញ្ញោ ទស្សយិស្សុ    បាបស្ស បាបសេវិនោ
ទិស្វាន តំ អញ្ញាបេសី    មម ច វសមានយី ។

---

១ ឱ. នាសិតោ ។ ២ ឱ. តត្ថ ការុណិកា ។

## សោមនស្សចរិយា ទី ២

តាបសបាបនោះ បានទូលព្រះរាជានោះ តាមដែលខ្លួនអាចឲ្យ
ព្រះរាជកុមារវិនាស ព្រះរាជាជាម្ចាស់ផែនដី ទ្រង់ព្រះសណ្ដាប់
ពាក្យនេះ របស់តាបសនោះ ហើយត្រាស់បង្គាប់ពួកពេជ្ឈ-
ឃាតថា អ្នកទាំងឡាយ (ទៅឃើញកុមារក្នុងទីណា) ចូរកាត់
ក្បាលចិញ្ច្រាំជាបួនកំណាត់ ហើយកប់ក្នុងផ្លូវប្រែក បង្ហាញជន
ដទៃឲ្យដឹងថា នេះជាគតិដែលបៀតបៀនជដិល ៗ ពួកពេជ្ឈ-
ឃាតទាំងនោះ កាច អាក្រក់ មិនមានសេចក្ដីអាណិត ទៅក្នុង
ទីនោះ ហើយទាញតថាគត ដែលអង្គុយលើចង្កេះមាតា នាំយក
ទៅ ៗ តថាគតនិយាយនឹងជនទាំងនោះ ដែលកំពុងចងដោយ
បំណងដ៏មាំថា រាជកិច្ចមានដល់ខ្ញុំ សូមអ្នកទាំងឡាយនាំខ្ញុំទៅ
ជួបនឹងស្ដេច មួយរំពេចសិន ៗ ពួកពេជ្ឈឃាតទាំងនោះ នាំ
តថាគតទៅជួបនឹងស្ដេច ដែលសេពគប់នឹងតាបសលាមក លុះ
តថាគតបានជួប ក៏ញុំាងស្ដេចឲ្យដឹងច្បាស់ នូវការប្រព្រឹត្តនៃ
តាបសនោះ ព្រមទាំងញុំាងស្ដេចឲ្យលុះក្នុងអំណាចតថាគត ៗ

សោ មំ តត្ថ ខមាបេសិ   មហារជ្ជំ អទាសិ មេ
សោហំ តំ ទាលយិត្វា   បព្ពជឹ អនគារិយំ ។
ន មេ ទេស្សំ មហារជ្ជំ   កាមភោគោ ន ទេស្សិយោ
សព្វញ្ញុតំ បិយំ មយ្ហំ   តស្មា រជ្ជំ បរិច្ចជឹ ។

សោមនស្សចរិយំ ទុតិយំ ។

## តតិយំ អយោឃរចរិយំ

(២៣) បុនាបរំ យទា ហោមិ   កាសិរាជស្ស អត្រជោ
អយោឃរម្ហិ សំវឌ្ឍោ   នាមេនាសិ អយោឃរោ ។
ទុក្ខេន ជីវិតោ(១) លទ្ធោ   សម្បីឡេ បតិបោសិតោ
អជ្ជេវ បុត្ត បដិបជ្ជ   កេវលំ វសុធំ(២) ឥមំ ។
សរដ្ឋកំ សនិគមំ   សជនំ វន្ទិត្វា ខត្តិយំ
អញ្ជលឹ បគ្គហេត្វាន   ឥទំ វចនមព្រវឹ ។

---

១ ឱ. ជីវិកោ ។ ២ ឱ. ម. វសុធំ ។

ព្រះរាជាជាបិតារបស់តថាគតនោះ សូមទោសតថាគតក្នុងទីនោះ ហើយប្រទាននូវភាពជាស្តេចធំដល់តថាគត តែតថាគតនោះឯង ទំលាយនូវងងឹត ចូលទៅកាន់ផ្នួសវិញ ។ ភាពនៃខ្លួនជាស្តេចធំ មិនមែនជាទីស្អប់ របស់តថាគតទេ ទាំងការបរិភោគកាម ក៏មិនមែនជាទីស្អប់ នៃតថាគតដែរ តែសព្វញ្ញុតញ្ញាណ ជាទីស្រឡាញ់ របស់តថាគត បានជាតថាគតលះបង់រាជ្យ (ចូលទៅកាន់ផ្នួស) ។

ចប់ សោមនស្សចរិយា ទី ២ ។

## អយោឃរចរិយា ទី ៣

(២៣) មានចរិយាដទៃទៀត កាលដែលតថាគត កើតជារាជកុមារ ឈ្មោះអយោឃរៈ ជាឱរសនៃព្រះបាទកាសិករាជ ចំរើនវ័យវឡ្យនាការក្នុងផ្ទះជាវិការៈនៃដែក ។ ព្រះរាជបិតារបស់តថាគត ទ្រង់ត្រាស់និងតថាគតថា ម្នាលកូន ជីវិត (របស់កូន) រស់នៅបានដោយលំបាក បិតាបិញ្ចឹមថែរក្សាកូនក្នុងផ្ទះជាវិការៈនៃដែក ដ៏ចង្អៀត ចូរកូនគ្រប់គ្រងមហាប្រថពី ទាំងមូលនេះ ព្រមទាំងដែន និគមនិងពួកជន ក្នុងថ្ងៃនេះ ។ តថាគតថ្វាយបង្គំ ប្រណម្យអញ្ជលី នូវព្រះមហាក្សត្រ ហើយពោលនូវពាក្យនេះថា

## តតិយំ អយោឃរចរិយំ

យេ កេចិ មហិយា សត្តា   ហីនុក្កដ្ឋមជ្ឈិមា
និរារក្ខា សកេ គេហេ   វឌ្ឍន្តិ សកញាតិភិ(១)។
ឥទំ លោកេ ឧត្តរិយំ   សម្បីឡេ មម បោសនំ
អយោឃរម្ហិ សំវឌ្ឍោ   អប្បភេ ចន្ទសុរិយេ ។
បូតិកុណបសម្បុណ្ណា   មុញ្ចិត្វា មាតុកុច្ឆិតោ
តតោ ឃោរតរេ ទុក្ខេ   បុន បក្ខិត្តយោឃរេ ។
យទិហំ តាទិសំ បត្វា   ទុក្ខំ បរមទារុណំ
រជ្ជេសុ យទិ រជ្ជាមិ   បាបានំ ឧត្តមោ សិយំ ។
ឧក្កណ្ឋិតោម្ហិ កាយេន   រជ្ជេនម្ហិ អនត្ថិកោ
និព្វុតឹ បរិយេសិស្សំ   យត្ថ មំ មច្ចុ ន មទ្ទិយេ ។
ឯវាហំ ចិន្តយិត្វាន   វិរវន្តេ មហាជនេ
នាគោវ ពន្ធនំ ឆេត្វា   បាវិសឹ កាននំ វនំ ។

---

១ ឱ.ម. សហញាតិភិ ។

ពពួកសត្វណាមួយ លើផែនដី ជាសត្វថោកទាប ឬខ្ពង់ខ្ពស់ និងកណ្តាល សត្វទាំងនោះ ពុំមានការរក្សាឡើយ តែងចម្រើនឡើង ក្នុងផ្ទះរបស់ខ្លួន ជាមួយនឹងពួកញាតិរបស់ខ្លួន ចំឡែកតែខ្ញុំព្រះអង្គ មានការចិញ្ចឹមក្នុងផ្ទះជាវិការៈនៃដែក ដ៏ចង្អៀតនេះ ចាត់ទុកជាការខ្ពង់ខ្ពស់ក្នុងលោក ខ្ញុំចម្រើនវ័យក្នុងផ្ទះជាវិការៈនៃដែក ដែលពុំមានពន្លឺព្រះចន្ទ្រនិងព្រះអាទិត្យ ។ ខ្ញុំប្រសូតចេញចាកផ្ទៃនៃមាតា ដែលពេញដោយសាកសព មានក្លិនស្អុយ ហើយត្រូវគេដាក់ក្នុងផ្ទះជាវិការៈនៃដែកទៀត បានសេចក្តីទុក្ខយ៉ាងខ្លាំង ជាងកាលដែលនៅក្នុងផ្ទៃនៃមាតានោះទៅទៀត ។ ខ្ញុំបានសេចក្តីទុក្ខ អាក្រក់ក្រៃលែង ប្រាកដដូច្នោះ បើខ្ញុំនៅត្រេកអរនឹងរាជ្យ ខ្ញុំជាបុគ្គលថោកទាបបំផុត ជាងបុរសដ៏លាមកៈទៅទៀត ។ ខ្ញុំជាបុគ្គលនឿយណាយ នឹងកាយស្អុយ ពុំត្រូវការដោយរាជ្យឡើយ ខ្ញុំស្វែងរក នូវទីដែលមច្ចុរាជ ញុំាញីមិនបាននោះ ដែលជាទីរំលត់នូវទុក្ខ ។ តថាគត លុះគិតយ៉ាងនេះហើយ ពួកមហាជនក៏យំស្រែក តថាគតកាត់នូវចំណង (គឺតណ្ហា) ហើយចូលកាន់ព្រៃធំ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទឹង ។

មាតា បិតា ន មេ ទេស្សា នបិ ទេស្សា មហាយសា
សព្វញ្ញុតំ បិយំ មយ្ហំ តស្មា រជ្ជំ បរិច្ចជិន្តិ ។

អយោឃរចរិយំ តតិយំ ។

## ចតុត្ថំ ភិសចរិយំ

(២៤) បុនាបរំ យទា ហោមិ កាសីនំ បុរវរុត្តមេ
ភគិនី ច ភាតរោ សត្ត និព្វត្តា សោត្ថិយេ កុលេ ។
ឯតេសំ បុព្វជោ អាសី ហិរិសុក្កមុបាគតោ
ភវំ ទិស្វាន ភយតោ នេក្ខម្មាភិរតោ អហំ ។
មាតាបិតូហិ បហិតា សហាយា ឯកមានសា
កាមេហិ មំ និមន្តេន្តិ កុលវំសំ ធារេហីតិ ។
យំ តេសំ វចនំ វុត្តំ គិហិធម្មេ សុខាវហំ
តំ មេ អហោសិ កឋិនំ តត្តផាលសមំ វិយ ។

មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ ទាំងយសដ៏ធំ ក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់នៃតថាគត ព្រោះហេតុនោះ បានជាតថាគតលះបង់រាជ្យ ។

ចប់ អយោឃរចរិយា ទី ៣ ។

# ភិសចរិយា ទី ៤

[៤៤] មានចរិយាដទៃទៀត កាលដែលតថាគត កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងពារាណសី ដែនកាសី មានបងប្អូនស្រីនិងបងប្អូនប្រុស ៧ នាក់ ។ តថាគតជាច្បងនៃជនទាំង ៧ នាក់នុ៎ះ ប្រកបដោយសុក្កធម៌គឺហិរិ ឃើញនូវកាម (មានកាមគុណជាដើម) ជាគួរខ្លាច ហើយត្រេកអរ ក្នុងនេក្ខម្មៈ ។ ពួកសម្លាញ់មានអធ្យាស្រ័យត្រូវគ្នា ដែលមាតាបិតាប្រើឲ្យទៅអញ្ជើញតថាគត ដោយកាមទាំងឡាយថា អ្នកចូរទ្រទ្រង់វង្សត្រកូលចុះ ។ ពាក្យណា ដែលពួកសម្លាញ់ទាំងនុ៎ះបានពោលហើយ ជាពាក្យនាំមកនូវសេចក្តីសុខ ក្នុងគិហិភាព ពាក្យនោះ ជាពាក្យអាក្រក់ សម្រាប់ខ្ញុំ ដូចជាភាជន៍ដ៏ក្តៅ ។

តេ មំ តទា ឧក្ខិបន្តំ  បុច្ឆឹសុ បត្ថិតំ មម
កឹ ត្វំ បត្ថយសិ សម្ម  យទិ កាមេ ន ភុញ្ជសិ ។
តេសាហំ ឯវមវចំ  អត្ថកាមោ ហិតេសិនំ
នាហំ បត្ថេមិ គិហិភាវំ  នេក្ខម្មាភិរតោ អហំ ។
តេ មយ្ហំ វចនំ សុត្វា  បិតុំ មាតុញ្ច សាវយុំ
មាតា បិតា ឯវមាហុ  សព្វេបិ បព្វជាម ភោ ។
ឧភោ មាតា បិតា មយ្ហំ  ភគិនី សត្ត ភាតរោ
អមិតំ ធនំ ឆឌ្ឌយិត្វា  បាវិសិម្ហា មហាវនន្តិ ។

ភិសចរិយំ[1] ចតុត្ថំ ។

# បញ្ចមំ សោណនន្ទបណ្ឌិតចរិយំ

(២៥) បុនាបរំ យទា ហោមិ នគរេ ព្រហ្មវឌ្ឍនេ
តត្ថ កុលវរេ សេដ្ឋេ  មហាសាលេ អជាយហំ ។

---

១ ឱ. ម. ភីសចរិយំ ។

សោណនន្ទបណ្ឌិតបរិយា ទី ៤

កាលនោះ ពួកសម្លាញ់ទាំងនោះ សួរសេចក្ដីប្រាថ្នារបស់តថាគត និងតថាគត ដែលជាអ្នកលះបង់នូវកាមថា ម្នាលសម្លាញ់ បើអ្នកមិនបរិភោគកាមទេ អ្នកចង់បានអ្វីទៅវិញ ។ តថាគត ជាអ្នកប្រាថ្នាប្រយោជន៍ខ្លួន បានពោលពាក្យនេះប្រាប់ពួកសម្លាញ់ទាំងនោះ ដែលស្វែងរកប្រយោជន៍ (ដល់តថាគត) ថា ខ្ញុំត្រេកអរក្នុងនេក្ខម្មៈ ខ្ញុំមិនប្រាថ្នានូវគិហិ-ភាពទេ ។ សម្លាញ់ទាំងនោះ ស្ដាប់ពាក្យរបស់តថាគតបានហើយ ទៅជំរាបមាតាបិតា (នៃតថាគត) ឯមាតាបិតាបាននិយាយនឹងតថាគត យ៉ាងនេះថា ម្នាលព្រាហ្មណ៍ដ៏ចំរើនយើងទាំងអស់គ្នានឹងបួសដែរ ។ មាតាបិតាទាំងគូ នឹងបងប្អូនប្រុសស្រីទាំង ៧ នាក់ របស់តថាគត លះបង់ទ្រព្យរាប់មិនអស់ ចូលទៅកាន់ព្រៃធំ ជាមួយនឹងតថាគត) ។

ចប់ ភិសបរិយា ទី ៤ ។

## សោណនន្ទបណ្ឌិតបរិយា ទី ៥

(២៥) មានបរិយាដទៃទៀត កាលតថាគតកើតក្នុងត្រកូលព្រាហ្មណមហាសាល ដ៏ប្រសើរថ្លៃថ្លាក្នុងនគរព្រហ្មវឌ្ឍនៈ ។

តទាសឹ(១) លោកំ ទិស្វាន អន្ធភូតំ តមោត្ថតំ
ចិត្តំ ភវតោ បតិកុដតិ តុត្តវេគហតំ វិយ ។
ទិស្វាន វិវិធំ បាបំ ឯវំ ចិន្តេសហំ តទា
កទាហំ គេហា និក្ខម្ម បវិសិស្សាមិ កាននំ ។
តទាបិ មំ និមន្តឹសុ កាមភោគេហិ ញាតយោ
តេសំបិ ឆន្ទមាចិក្ខឹ មា និមន្តេថ តេហិ មំ ។
យោ មេ កនិដ្ឋកោ ភាតា នន្ទោ នាមាសិ បណ្ឌិតោ
សោបិ មំ អនុសិក្ខន្តោ បព្វជ្ជំ សមរោចសិ ។
អហំ សោណោ ច នន្ទោ ច ឧភោ មាតា បិតា មម
តទាបិ ភោគេ ឆឌ្ឌេត្វា បាវិសិម្ហា មហាវនន្តិ ។

សោណនន្ទបណ្ឌិតចរិយំ បញ្ចមំ ។

---

១ ឱ. ម. តទាបិ ។

កាលនោះឯង តថាគតបានឃើញសត្វលោក ដែលដល់នូវអន្ធភាព ត្រូវងងឹតគឺអវិជ្ជាគ្របសង្កត់ ចិត្តរបស់តថាគតក៏ខ្ញុររួញហាកកត ដូចជាហត្ថាជានេយ្យ ដែលគេចាក់ទីងបន្លួញ ដោយកម្លាំង ។ កាលនោះ តថាគតឃើញបាបផ្សេងៗ ក៏គិតយ៉ាងនេះថា កាលណាហ្ន៎ អញនឹងបានចេញចាកផ្ទះ ចូលទៅកាន់ព្រៃ ។ គ្រានោះ ពួកញាតិអញ្ជើញតថាគតដោយភោគៈគឺកាមទាំងឡាយ តថាគតប្រាប់នូវឆន្ទៈ (របស់ខ្លួន) ដល់ពួកញាតិទាំងនោះថា សូមអ្នកទាំងឡាយកុំអញ្ជើញខ្ញុំ ដោយកាមទាំងនោះឡើយ ។ ប្អូនប្រុសណារបស់តថាគត ឈ្មោះនន្ទបណ្ឌិត ប្អូនប្រុសនោះ ក៏សិក្សាតាមតថាគត ពេញចិត្តនឹងបព្វជ្ជា ។ កាលនោះ តថាគតឈ្មោះសោណៈ ប្អូននៃតថាគតឈ្មោះនន្ទៈ និងមាតាបិតានៃតថាគតទាំងពីរ លះបង់ភោគៈទាំងឡាយ ហើយចូលទៅកាន់ព្រៃធំក្នុងកាលនោះ ។

ចប់ សោណនន្ទបណ្ឌិតចរិយា ទី ៤ ។

# ឆដ្ឋមំ មូគផក្ខចរិយំ

(២៦) បុនាបរំ យទា ហោមិ កាសិរាជស្ស អត្រជោ
មូគផក្ខោតិ(១) នាមេន តេមិយោតិ វទន្តិ មំ ។
សោឡសិត្ថីសហស្សានំ ន វិជ្ជតិ បុមោ តទា
អហោរត្តានមច្ចយេន និព្វត្តោ អហមេកកោ ។
កិច្ឆា លទ្ធំ បិយំ បុត្តំ អភិជាតំ ជុតិន្ធរំ
សេតច្ឆត្តំ ធារយិត្វាន សយនេ បោសេសិ មំ បិតា ។
និទ្ទាយមានោ សយនវរេ បពុជ្ឈិត្វានហំ តទា
អទ្ទសំ បណ្ឌរំ ឆត្តំ យេនាហំ និរយំ គតោ ។
សហទិដ្ឋស្ស មេ ឆត្តំ តាសោ ឧប្បជ្ជិ ភេរវោ
វិនិច្ឆយំ សមាបន្នោ កថាហំ ឥមំ មុញ្ចិស្សំ ។

---

១ ឱ. ម. មូគបក្ខោតិ ។

# មូគបក្ខចរិយា ទី ៦

(៦៦) មានចរិយាដទៃទៀត កាលដែលតថាគត កើតជាឱរស នៃព្រះបាទកាសិករាជ ជនទាំងឡាយមានមាតាបិតាជាដើម តែងហៅតថាគតថា មូគបក្ខៈផង ថាតេមិយៈផង ។ កាលនោះ ពួកស្រីស្នំ (របស់ព្រះបាទកាសិករាជ) ចំនួន ១៦.០០០ មិនមានកូនប្រុស អស់កាលកន្លងទៅនៃថ្ងៃនិងយប់ជាច្រើន គឺអស់ច្រើនឆ្នាំ កើតបានតែកូនបុត្រមួយ គឺតថាគត ។ ដោយបិតារបស់តថាគត បានដោយកម្រនូវតថាគតជាកូនជាទីស្រឡាញ់ ជាកូនមានជាតិខ្ពស់ ទ្រទ្រង់សេចក្ដីរុងរឿង ព្រះរាជាក៏យកនូវស្វេតច្ឆត្រ បាំងតថាគត បំពីមឲ្យផ្ទំលើសិរីសយនា ។ កាលនោះ តថាគតដេកលក់លើសយនា ហើយភ្ញាក់ឡើង បានឃើញស្វេតច្ឆត្រ គិតថា អញទៅនរក ព្រោះតែស្វេតច្ឆត្រណា ។ សេចក្ដីភ័យតក់ស្លុតកើតឡើង ដល់តថាគត ជាមួយនឹងការឃើញ នូវស្វេតច្ឆត្រនោះ ពេលនោះ តថាគតពិចារណាមើលថា កង់ កាលណាហ្ន៎ អញនឹងដោះខ្លួន ឲ្យរួចពីស្វេតច្ឆត្រនេះ ។

បុត្តសា លោហិតា មយ្ហំ ទេវតា អត្ថកាមិនី
សា មំ ទិស្វាន ទុក្ខិតំ តីសុ ឋានេសុ យោជយិ ។
មា បណ្ឌិច្ចយំ(១) វិភាវយ ពាលមតោ ភវ សព្ព-
បាណិនំ(២)

សព្វោ តំ ជនោ ឱចិនាយតុ ឯវំ តវ អត្ថោ ភវិស្សតិ ។
ឯវំ វុត្តាយហំ តស្សា ឥទំ វចនមព្រវឹ
ករោមិ តេ តំ វចនំ យំ មំ(៣) ភណសិ ទេវតេ ។
អត្ថកាមាសិ មេ អម្ម ហិតកាមាសិ ទេវតេ
តស្សាហំ វចនំ សុត្វា សាគរេវ ថលំ លភឹ ។
ហដ្ឋោ សំវិគ្គមានសោ តយោ អង្គេ អធិដ្ឋហឹ
មូគោ អហោសឹ ពធិរោ ដក្ខោ(៤) គតិវិវជ្ជិតោ ។
ឯតេ អង្គេ អធិដ្ឋាយ វស្សានិ សោឡសំ វសឹ
តតោ មេ ហត្ថបាទេ ច ជិវ្ហំ សោតញ្ច មទ្ទិយ
អនូនតំ មេ បស្សិត្វា កាឡកណ្ណីតិ និន្ទិសុំ ។

---

១ ឱ. បណ្ឌិច្ចំ ។ ២ ឱ. ពហុមតំ សព្វបាណិនន្តិ ទិស្សតិ ។ ៣ ឱ. ម. ត្វំ ។ ៤ ឱ. ម. បក្ខោ ។

ទេវតាជាសាលោហិតក្នុងកាលមុន ជាអ្នកប្រាថ្នាប្រយោជន៍ដល់តថាគត ទេវតានោះឃើញតថាគតបានទុក្ខ ក៏ឲ្យតថា-គត ប្រកបក្នុងហេតុ ៣ ប្រការ ដូច្នេះថា ចូរអ្នកកុំសម្តែងនូវភាពរបស់ខ្លួនជាបណ្ឌិត ១ ចូរឲ្យសព្វសត្វទាំងឡាយ ដឹងថាអ្នកជាពាលវិញ ១ ឲ្យពួកជនទាំងពួងមើលងាយអ្នកវិញ ១ ប្រយោជន៍នឹងមានដល់អ្នក ដោយវិធីយ៉ាងនេះ ៗ កាលទេវតានោះ ពោលយ៉ាងនេះហើយ តថាគតពោលនូវពាក្យនេះថា ម្នាលទេវតា អ្នកពោលនូវពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យនៃអ្នកនោះ ម្នាលទេវតាជាម៉ែ អ្នកឈ្មោះថាប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ ៗ លុះតថាគតស្តាប់ពាក្យទេវតានោះហើយ ក៏បាននូវទួលគឺទីពឹង ដូចជាបុរស កាលលិចក្នុងសាគរ ហើយបាននូវទួល ៗ តថាគតមានចិត្តត្រេកអរ មានចិត្តសង្វេគ បានអធិដ្ឋាននូវអង្គ ៣ យ៉ាង គឺអធិដ្ឋានជាគ ថ្លង់ និងខ្វិន វៀរចាកដំណើរធម្មតា ៗ តថាគត អធិដ្ឋាននូវអង្គទាំង ៣ នុ៎ះហើយ នៅអស់ ១៦ ឆ្នាំ លំដាប់ពីនោះមក ជនទាំងឡាយប្រចាប់ដៃជើង អណ្តាតនិងត្រចៀករបស់តថាគតមើល ឃើញថាអវយវៈតថាគត មិនខ្វះខាត ហើយតិះដៀលតថាគត ថាជាបុរសកាឡកណ្ណី ៗ

## អដ្ឋមំ មូគបក្ខចរិយំ

តតោ ជានបទា សព្វេ      សេនាបតិបុរោហិតា
សព្វេ ឯកមនា ហុត្វា      ឆឌ្ឌនំ អនុមោទិសុំ ។
សោហំ តេសំ មតឹ សុត្វា      ហដ្ឋោ សំវិគ្គមានសោ
យស្សត្ថាយ តបោចិណ្ណោ សោ មេ អត្ថោ សមិជ្ឈថ ។
ន្ហាបេត្វា អនុលិម្បេត្វា      វេឋេត្វា រាជវេឋនំ
ឆត្តេន អភិសិញ្ចិត្វា      ការេសុំ បុរំ បទក្ខិណំ ។
សត្តាហំ ធារយិត្វាន      ឧគ្គតេ រវិមណ្ឌលេ
រថេន មំ នីហរិត្វា      សារថិ វនមុបាគមិ ។
ឯកោកាសេ រថំ កត្វា      សជ្ជស្សំ ហត្ថមុញ្ចិតោ
សារថិ ខណតិ កាសុំ      និខាតុំ បឋវិយា មមំ ។
អធិដ្ឋិតមធិដ្ឋានំ      តជ្ជេន្តោ វិវិធការណា
ន ភិន្ទឹ តមធិដ្ឋានំ      ពោធិយាយេវ ការណា ។

## មូគបក្ខចរិយា ទី ៦

លំដាប់នោះ ពួកអ្នកជនបទទាំងអស់ មានសេនាបតីនិង
បុរោហិតជាប្រធាន ពួកជនទាំងអស់នោះ ស្រុះចិត្តគ្នាត្រេក-
អរ ក្នុងការលះបង់ចោលតថាគត ៗ លុះតថាគតស្ដាប់នូវ
សេចក្ដីយល់ឃើញ របស់ពួកជនទាំងនោះ ក៏មានចិត្តត្រេកអរ
មានចិត្តសង្វេគ តបៈដែលតថាគតប្រព្រឹត្តហើយ ដើម្បីជា
ប្រយោជន៍ណា ប្រយោជន៍នោះ នឹងសម្រេចដល់តថាគតមិន
ខាន ៗ ជនទាំងឡាយមានមាតាបិតាជាដើម ផ្ងូតទឹកក្រអូប
លាបគ្រឿងក្រអូប ហើយឲ្យពាក់ពជមកុដ អភិសេកដោយ
ស្វេតច្ឆត្រ ធ្វើប្រទក្សិណបុរី ឲ្យតថាគតគ្រងរាជ្យ អស់ ៧
ថ្ងៃ លុះមណ្ឌលព្រះអាទិត្យរះឡើង សារថីនាំតថាគតដោយ
រថ ចេញអំពីនគរ ចូលទៅកាន់ព្រៃ ៗ សារថីបានទុករថ
ក្នុងទីឱកាសមួយ បង់សេះផុតពីដៃតថាគត ហើយជីករណ្ដៅ
ដើម្បីកប់តថាគត ក្នុងផែនដី ៗ តថាគតគ្រាន់តែគម្រាមនូវ
អធិដ្ឋានដែលខ្លួនអធិដ្ឋានហើយ ដោយហេតុផ្សេង ៗ តែមិន
ទំលាយនូវអធិដ្ឋាននោះទេ ព្រោះហេតុនៃពោធិញាណ ៗ

មាតា បិតា ន មេ ទេស្សា   អត្តា មេ ន ច ទេស្សិយោ
សព្វញ្ញុតំ បិយំ មយ្ហំ   តស្មា វតមធិដ្ឋហឹ ។
ឯតេ អង្គេ អធិដ្ឋាយ   វស្សានិ សោឡសំ វសឹ
អធិដ្ឋានេន សមោ នត្ថិ   ឯសា មេ អធិដ្ឋានបារមីតិ ។

មូគផក្ខចរិយំ ទសមំ ។

## សត្តមំ កបិលរាជចរិយំ

(២៧) យទា អហំ កបិ អាសឹ   នទីកូលេ ទរីសយេ
បីឡិតោ សុំសុមារេន   គមនំ ន លភាមហំ ។
យម្ហោកាសេ អហំ ឋត្វា   ឱរា បារំ បតាមហំ
តត្ថច្ឆិ សត្តុវធកោ   កុម្ភីលោ លុទ្ទទស្សនោ ។
សោ មំ អសំសិ ឯហីតិ   អហម្បេមីតិ តំ វទឹ
តស្ស មត្ថកមក្កម្ម   បរកូលេ បតិដ្ឋហឹ ។

មាតាបិតាមិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ ។ តថាគតអធិដ្ឋាននូវអង្គទាំង ៣ នុ៎ះ ហើយនៅអស់ ១៦ ឆ្នាំ អធិដ្ឋានដទៃស្មើដោយអធិដ្ឋាននេះ មិនមានឡើយ នេះជាអធិដ្ឋានបារមីរបស់តថាគត ។

ចប់ មូគបក្ខចរិយា ទី ៦ ។

## កបិលរាជចរិយា ទី ៧

(២៧) កាលដែលតថាគតកើតជាស្តេចស្វា សម្រេចទីលំនៅជិតឆ្នេរនៃស្ទឹងមួយ កាលណោះ តថាគតត្រូវក្រពើបៀតបៀន ហើយមិនបាននូវដំណើរចេញទៅ ។ តថាគតឋិតនៅលើខ្នងថ្មណា ដែលតាំងនៅកណ្តាលស្ទឹង ក៏បានលោតអំពីត្រើយអាយ ទៅកាន់ត្រើយនាយ ហើយទំលើខ្នងថ្មនោះ ដែលមានក្រពើនៅ ជាសត្រូវឃើញគួរខ្លាច ។ ក្រពើនោះនិយាយនឹងតថាគតថា អ្នកចូរមកវិញ តថាគតនិយាយតបនឹងក្រពើនោះថា អើខ្ញុំនឹងមកវិញ ហើយតថាគតលោតជាន់លើក្បាលក្រពើនោះ ទៅឋិតនៅលើត្រើយនាយវិញ ។

ន តស្សាលិកំ ភណិតំ យថា វាចំ អកាសហំ

សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ ។

កបិលរាជចរិយំ សត្តមំ ។

## អដ្ឋមំ សច្ចសវ្ហយបណ្ឌិតចរិយំ

(២៨) បុនាបរំ យទា ហោមិ តាបសោ សច្ចសវ្ហយោ

សច្ចេន លោកំ បាលេសឹ សមគ្គំ ជនមកាសហន្តិ ។

សច្ចសវ្ហយបណ្ឌិតចរិយំ អដ្ឋមំ ។

## នវមំ វដ្ដកបោតកចរិយំ

(២៩) បុនាបរំ យទា ហោមិ មគធេ វដ្ដបោតកោ

អជាតបក្ខោ តរុណោ មំសបេសិ កុលាវកេ ។

មុខតុណ្ឌកេន អាហរិត្វា មាតា បោសយតី មមំ

តស្សា ផស្សេន ជីវាមិ នត្ថិ មេ កាយិកំ ពលំ ។

តថាគតពោលនូវពាក្យសត្យ មិនពោលពាក្យមុសាវាទ ដល់ក្រពើនោះ កុសលធម៌ដទៃ ស្មើនឹងសច្ចៈ របស់តថាគតពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

ចប់ កបិលរាជចរិយា ទី ៧ ។

# សច្ចសវ្ហយបណ្ឌិតចរិយា ទី ៨

(២៨) មានចរិយាដទៃទៀត កាលដែលតថាគតជាតាបសឈ្មោះសច្ចៈ តថាគតបានរក្សាសត្វលោកដោយសច្ច ធ្វើមហាជនឲ្យព្រមព្រៀងគ្នា ។

ចប់ សច្ចសវ្ហយបណ្ឌិតចរិយា ទី ៨ ។

# វដ្ដកបោតកចរិយា ទី ៩

(២៩) ចរិយាដទៃទៀត កាលដែលតថាគតកើតជាកូនសត្វក្រួច ក្នុងអញ្ញប្រទេសមួយ ទៀបដែនមគធៈ ជាសត្វតូចដូចជាដុំសាច់ មិនទាន់ដុះស្លាបនៅក្នុងសំបុក ។ កាលនោះ មាតា (របស់តថាគត) នាំយក (ចំណី) ដោយចំពុះមកចិញ្ចឹមតថាគត តថាគតរស់នៅដោយសារសម្ផស្សរបស់មាតានោះ តថាគត មិនទាន់មានកម្លាំងកាយនៅឡើយ ។

សំវច្ឆរេ គិម្ហសមយេ ទវឌាហោ បទិប្បតិ

ឧបគច្ឆតិ អម្ហាកំ បាវកោ កណ្ហវត្តនិ ។

ធមធមំ ឥតិ ឯវំ(១) សទ្ទាយន្តោ មហាសិខី

អនុបុព្វេន ឈាបេន្តោ អគ្គិ មមមុបាគមិ ។

អគ្គិវេគភយា ភីតា តសិតា មាតា បិតា មម

កុលាវកេ មំ ឆឌ្ឌេត្វា អត្តានំ បរិមោចយុំ ។

បាទេ បក្ខេ បជហាមិ នត្ថិ មេ កាយិកំ ពលំ

សោហំ អគតិកោ តត្ថ ឯវំ ចិន្តេសហំ តទា ។

យេសាហំ ឧបធាវេយ្យំ ភីតោ តសិតវេធិតោ

តេ មំ ឱហាយ បក្កន្តា កថំ មេ អជ្ជ កាតវេ ។

អត្ថិ លោកេ សីលគុណោ សច្ចំ សោចេយ្យនុទ្ទយា

តេន សច្ចេន កាហាមិ សច្ចកិរិយមុត្តមំ ។

---

១ ឱ. ទហូមធូមញ្ចនិច្ឆេរន្តំ ទិស្សតិ ។

ភ្លើងព្រៃ ឆេះព្រៃក្នុងគិម្ហសម័យ រាល់ៗឆ្នាំ អណ្តាតភ្លើង ក៏រាលចូលមកជិតលំនៅ នៃតថាគត ។ អណ្តាតភ្លើងដ៏ធំ កាលធ្វើសម្លេងជាផុំផុំយ៉ាងនេះ ភ្លើងនោះ ឆេះរាលចូលមករកតថាគត ជាលំដាប់ ។ មាតាបិតាតថាគត ភ័យតក់ស្លុតព្រោះខ្លាចសន្ទុះភ្លើង ក៏លះបង់ចោលតថាគត ក្នុងសំបុក ហើយដោះខ្លួនចេញរួចទៅ ។ តថាគត លះបង់នូវជើងនិងស្លាប តថាគតមិនមានកម្លាំងកាយ តថាគតជាសត្វមិនមានដំណើរទៅ ក្នុងទីនោះ កាលណោះ គិតយ៉ាងនេះថា អញភ័យតក់ស្លុតញាប់ញ័រស្ទុះទៅរកមាតាបិតាណា បើមាតាបិតាទាំងនោះ លះបង់អញចេញទៅហើយ តើក្នុងថ្ងៃនេះ អញត្រូវធ្វើ ដូចម្តេច ។ ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយសីលគុណ សច្ចៈ សោចេយ្យៈ (សេចក្តីស្អាត) និងសេចក្តីអាណិត សិងមានក្នុងលោក (បើដូច្នោះ) អញនឹងធ្វើនូវសច្ចកិរិយា ដ៏ឧត្តម ដោយសច្ចៈនោះ ។

អាវជ្ជិត្វា ធម្មពលំ សរិត្វា បុព្វកេ ជិនេ
សច្ចពលមវស្សាយ សច្ចកិរិយមកាសហំ ។
សន្តិ បក្ខា អបត្តនា សន្តិ បាទា អវញ្ចនា
មាតា បិតា ច និក្ខន្តា ជាតវេទ បដិក្កម ។
សហ សច្ចេ កតេ មយ្ហំ មហាបជ្ជលិតោ សិខី
វជ្ជេសិ សោឡស ករីសានិ ឧទកំ បត្វា យថា សិខី
សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ ។

**វដ្ដកបោតកចរិយំ នវមំ ។**

## ទសមំ មច្ឆរាជចរិយំ

(៣០) បុនាបរំ យទា ហោមិ មច្ឆរាជា មហាសរេ
ឧណ្ហេ សុរិយសន្តាបេ សរេ ឧទកំ ខីយថ ។

តថាគតពិចារណាកម្លាំងធម៌ ហើយរឭកព្រះជិនស្រីក្នុងកាលមុន ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌ (នោះ) ថា ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនរួច ជើងទាំងឡាយរបស់ខ្ញុំមាន តែដើរមិនបាន មាតាបិតា (របស់ខ្ញុំចេញ) បាត់ទៅហើយ ម្នាលភ្លើងព្រៃ អ្នកចូរចៀសចេញទៅ ។ ព្រោះសច្ចកិរិយា ដែលតថាគតបានធ្វើហើយ ភ្លើងដែលឆេះសន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីសៈ (ហើយរលត់ក្នុងទីនោះ) ដូចជាគប់ភ្លើងដែលបុគ្គល ជ្រលក់ទៅក្នុងទឹក កុសលធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគត ពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

**ចប់ វដ្តកបោតកចរិយា ទី ៩ ។**

# មច្ឆរាជចរិយា ទី ១០

(៣០) មានចរិយាដទៃទៀត កាលដែលតថាគត កើតជាស្តេចត្រី នៅក្នុងមហាស្រះ លុះដល់គិម្ហសម័យ ដែលមានកំដៅព្រះអាទិត្យយ៉ាងខ្លាំង ទឹកក្នុងស្រះក៏រីងហួតអស់ ។

តតោ កាកា ច គិជ្ឈា ច កង្កា កុលលសេនកា
ភក្ខយន្តិ ទិវា រត្តឹ មច្ឆេ ឧបនិសីទិយ ។
ឯវំ ចិន្តេសហំ តត្ថ សហ ញាតីហិ បីឡិតោ
កេន នុ ខោ ឧបាយេន ញាតី ទុក្ខា បមោចយេ ។
ចិន្តយិត្វាន ធម្មត្ថំ សច្ចំ អទ្ទសំ បស្សយំ
សច្ចេ ឋត្វា បមោចេសឹ ញាតីនំ តំ បរិក្ខយំ ។
អនុស្សរិត្វា សតំ ធម្មំ បរមត្ថំ វិចិន្តយំ
អកាសឹ សច្ចកិរិយំ យំ លោកេ ធុវសស្សតំ ។
យតោ សរាមិ អត្តានំ យតោ បត្តោស្មិ វិញ្ញុតំ
នាភិជានាមិ សញ្ចិច្ច ឯកបាណំបិ ហឹសិតំ ។
ឯតេន សច្ចវជ្ជេន បជ្ជុន្នោ អភិវស្សតុ
អភិត្ថនយ បជ្ជុន្ន និធឹ កាកស្ស នាសយ ។

លំដាប់នោះ ក្អែក ត្មាត ខ្លែងក្រហម ខ្លែងខ្មៅ និងខ្លែងធំ ចុះទៅទំ (លើកក់) ស៊ីនូវត្រីទាំងឡាយ ទាំងយប់ទាំងថ្ងៃ ៗ តថាគតព្រមទាំងពួកញាតិ ត្រូវពួកសត្វមានក្អែកជាដើមបៀតបៀនក្នុងទីនោះហើយ ក៏គិតយ៉ាងនេះថា ញាតិទាំងឡាយ (របស់អញ) នឹងរួចចាកទុក្ខដោយឧបាយ ដូចម្ដេចហ្ន៎ ៗ តថាគតគិតនូវធម៌និងអត្ថ ហើយបានឃើញសច្ចៈ កាលឃើញហើយ ឋិតនៅក្នុងសច្ចៈនោះ ដោះញាតិឲ្យរួច ចាកសេចក្ដីវិនាសធំទៅបាន ៗ តថាគត រឭកនូវធម៌ របស់សប្បុរសទាំងឡាយ ហើយពិចារណានូវបរមត្ថសច្ចៈ ធ្វើនូវសច្ចកិរិយាដែលជាធម្មជាតិទៀងទាត់ក្នុងលោកថា តថាគតរឭកឃើញនូវខ្លួន ក្នុងកាលណា តថាគតបានដល់នូវភាពជាអ្នកដឹងក្ដីក្នុងកាលណា ក្នុងកាលនោះ តថាគតមិនដែលក្លែងបៀតបៀន សូម្បីនូវសត្វណាមួយឡើយ ៗ ដោយពាក្យសច្ចៈនេះ សូមឲ្យមេឃបង្អុរភ្លៀងចុះ ម្នាលមេឃ ចូរអ្នកបង្អុរភ្លៀងចុះមក ចូរអ្នកញុំាងកំណប់ទ្រព្យ របស់ក្អែកឲ្យវិនាសអស់ទៅ ៗ

កាកំ សោកាយ រន្ធេហិ មច្ឆេ សោកា បមោចយ
សហកតេ សច្ចវរេ បជ្ជុន្នោ អភិគជ្ជិយ ។
ថលំ និន្នញ្ច បូរេន្តោ ខណេន អភិវស្សថ
ឯវរូបំ សច្ចវរំ កត្វា វីរិយមុត្តមំ ។
វស្សាបេសឹ មហាមេឃំ សច្ចតេជពលស្សិតោ
សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ ។

មច្ឆរាជចរិយំ ទសមំ ។

## ឯកាទសមំ កណ្ហទីបាយនចរិយំ

(៣១) បុនាបរំ យទា ហោមិ កណ្ហទីបាយនោ ឥសិ
បរោបញ្ញាស វស្សានិ អនភិរតោ ចរឹ អហំ ។
ន កោចិ ឯតំ ជានាតិ អនភិរតិមនំ មម
អហំបិ កស្សចិ នាចិក្ខឹ អរតិ មេ ចរតិ មានសេ ។

ចូរអ្នកញុំាងពួកក្អែកឲ្យសោយសោក ចូរអ្នកញុំាងពួកត្រីឲ្យរួចចាកសោក ៗ មេឃក៏បង្អុរភ្លៀងចុះមក ដំណាលនឹងពាក្យសច្ចៈដ៏ប្រសើរ ដែលតថាគតធ្វើហើយ ៗ តថាគតធ្វើនូវសច្ចៈដ៏ប្រសើរ មានសភាពយ៉ាងនេះ ឲ្យជាព្យាយាមដ៏ឧត្តម ភ្លៀងក៏ធ្លាក់ចុះមក បំពេញនូវទីទួល ទីទាប មួយរំពេច ៗ តថាគត អាស្រ័យកម្លាំងតេជះនៃសច្ចៈ បានញុំាងមហាមេឃឲ្យបង្អុរភ្លៀង គុណធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគត ពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ៗ

ចប់ មច្ឆរាជចរិយា ទី ១០ ៗ

# កណ្ហទីបាយនចរិយា ទី ១១

(៣១) មានចរិយាដទៃទៀត កាលតថាគតជាឥសី ឈ្មោះកណ្ហទីបាយនៈ អផ្សុកហើយ នៅតែប្រព្រឹត្តព្រហ្មចរិយៈ អស់ ៥០ឆ្នាំបាយ ៗ អ្នកណាមួយ មិនដឹងនូវសេចក្តីអផ្សុក ក្នុងចិត្តរបស់តថាគតនុ៎ះទេ ទាំងតថាគតសោត ក៏មិនប្រាប់នូវសេចក្តីមិនត្រេកអរនិងសេចក្តីត្រេកអរក្នុងចិត្ត ដល់អ្នកណាមួយឡើយ ៗ

សព្រហ្មចារី មណ្ឌព្យោ សហាយោ មេ មហាឥសិ
បុព្វកម្មសមាយុត្តោ សូលមារោបនំ លភិ ។
តមហំ ឧបដ្ឋហិត្វាន អារោគ្យមនុបាបយឹ
អាបុច្ឆិត្វាន អាគញ្ឆិំ យំ មយ្ហំ សកមស្សមំ ។
សហាយោ ព្រាហ្មណោ មយ្ហំ ភរិយំ អាទាយ បុត្តកំ
តយោ ជនា សមាគន្ត្វា អាគច្ឆុំ បាហុនាគតំ ។
សម្មោទមានោ តេហិ សហ និសិន្នោ សកមស្សមេ
ទារកោ វដ្ដមនុក្ខិបំ អាសីវិសមកោបយិ ។
តតោ សោ វដ្ដគតំ មគ្គំ អន្វេសន្តោ កុមារកោ
អាសីវិសស្ស ហត្ថេន ឧត្តមង្គំ បរាមសិ ។
តស្ស អាមសនេ កុទ្ធោ សប្បោ វិសពលស្សិតោ
កុបិតោ បរមកោបេន អឌំសិ ទារកំ ខណេ ។

មហាឥសី ឈ្មោះមណ្ឌព្យៈ អ្នកប្រព្រឹត្តធម៌ប្រសើរស្មើគ្នា ជាសម្លាញ់របស់តថាគត ប្រកបដោយបុញ្ញកម្ម ហើយបាននូវការឡើងកាន់ដែកស្រួច ៗ តថាគតថែទាំមណ្ឌព្យតាបសនោះ រហូតបានដល់នូវភាព ជាបុគ្គលជាពេក ហើយលាមកកាន់អាស្រមនៃខ្លួន របស់តថាគតវិញ ៗ ព្រាហ្មណ៍ ជាសំឡាញ់ នាំប្រពន្ធនិងកូនមក ជនទាំង ៣ នាក់ ចួបជុំគ្នាចូលទៅកាន់ទីដែលភ្ញៀវមកហើយ ៗ តថាគតអង្គុយ ក្នុងអាស្រមរបស់ខ្លួន សំណេះសំណាលជាមួយនឹងជនទាំងនោះ ឯទារកបោះកូនឃ្លីលេង បានញុំាងអាសិរពិសឲ្យខឹង ៗ លំដាប់នោះ កុមារនោះស្វែងរកផ្លូវ ដែលកូនឃ្លីនោះរមៀល ក៏យកដៃស្ទាបត្រូវក្បាលអាសិរពិស ៗ ឯពស់ក៏ខឹងនឹងការស្ទាបត្រូវនៃទារកនោះ អាស្រ័យកម្លាំងនៃពិសកម្រើក ក៏ចឹកទារក ក្នុងខណៈនោះ ដោយសេចក្តីក្រោធយ៉ាងខ្លាំង ៗ

## ចតុត្ថំ ចូឡពោធិចរិយំ

សហ ឧដ្ឋា អតិវិសេន  ទារកោ បបតិ ភូមិយំ

តេនាហំ ទុក្ខិតោ អាសឹ  មម វ ហសិតំ ទុក្ខំ ។

ត្យាហំ អស្សាសយិត្វាន  ទុក្ខិតេ សោកសល្លិតេ

បឋមំ អកាសឹ កិរិយំ  អគ្គំ សច្ចវរុត្តមំ ។

សត្តាហមេវាហំ បសន្នចិត្តោ

បុញ្ញត្ថិកោ អចរឹ ព្រហ្មចរិយំ

អថាបរំ យំ ចរិតំ មមំ ឥទំ

វស្សានិ បញ្ញាស សមាធិកានិ ។

អកាមកោ វ ហិ អហញ្ចរាមិ

ឯតេន សច្ចេន សុវត្ថិ ហោតុ

ហតំ វិសំ ជីវតុ យញ្ញទត្តោ ។

## កណ្ហទីបាយនចរិយា ទី ១១

ទារកដែលត្រូវពស់ចឹកហើយ ក៏ដួលលើផែនដី ដោយពិស ដ៏ខ្លាំង មួយរំពេច ព្រោះហេតុនោះ បានជាតថាគតមាន ទុក្ខ ទុក្ខនោះផ្សាយមកដល់តថាគត ។ តថាគតលួងលោម ជនទាំងនោះ ដែលដល់នូវសេចក្ដីទុក្ខ មានសរ គឺសេចក្ដី សោក បានធ្វើសច្ចកិរិយា ដ៏ថ្លៃថ្លាប្រសើរ ឧត្ដមជាជម្ពូងថា

តថាគត មានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ
បានប្រព្រឹត្តព្រហ្មចរិយៈ អស់ ៧ ថ្ងៃ លំដាប់
តទៅ តថាគតប្រព្រឹត្តព្រហ្មចរិយៈណា អស់
៥០ ឆ្នាំប្លាយ ៗ តថាគតប្រព្រឹត្តព្រហ្មចរិយៈ
នោះទាំងអផ្សុក ដោយពាក្យសច្ចៈនេះ សូមសិរី-
សួស្ដីកើតមាន (ដល់យញ្ញទត្តកុមារ) ពិសចូរ
សាបសូន្យទៅ យញ្ញទត្តកុមារ ចូររស់ឡើង ៗ

សហ សច្ចេ កតេ មយ្ហំ   វិសវេគេច វេធិតោ
អពុជ្ឈិត្វាន វុដ្ឋាសិ   អរោគោ ចាសិ មាណវោ
សច្ចេន មេ សមោ នត្ថិ   ឯសា មេ សច្ចបារមីតិ ។

កណ្ហទីបាយនចរិយំ ឯកាទសមំ ។

# ទ្វាទសមំ សុតសោមចរិយំ

(៣២) បុនាបរំ យទា ហោមិ   សុតសោមោ មហីបតិ
គហិតោ បោរិសាទេន   ព្រាហ្មណេ សង្គរំ សរឹ ។
ខត្តិយានំ ឯកសតំ   អាវុណិត្វា ករតលេ
ឯតេ សម្មិលាបេត្វា   យញ្ញត្ថេ ឧបនយី មមំ ។
អាបុច្ឆិ មំ បោរិសាទោ   កឹ ត្វំ ឥច្ឆសិ និស្សជំ
យថាមតឹ តេ កាហាមិ   យទិ មេ ត្វំ បុនេហិសិ ។

យញ្ញទត្តមាណព ដែលញាប់ញ័រដោយកម្លាំងនៃពិស មិនដឹងខ្លួនសោះ ស្រាប់តែក្រោកឡើងរួច តាំងជាបុគ្គលសះ-ស្បើយរោគ ដំណាលនឹងពាក្យសច្ចៈដែលតថាគតធ្វើហើយ គុណធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគត ពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ។

ចប់ កណ្ហទីបាយនចរិយា ទី ១១ ។

# សុតសោមចរិយា ទី ១២

(៣២) មានចរិយាដទៃទៀត កាលដែលតថាគត ឈ្មោះសុតសោម ជាម្ចាស់ផែនដី ត្រូវស្តេចបោរិសាទចាប់ តថា-គត ក៏បាននឹកឃើញនូវពាក្យបដិញ្ញា ដែលខ្លួនបានធ្វើចំពោះនន្ទព្រាហ្មណ៍ ។ ស្តេចបោរិសាទ ដោតក្សត្រ ១០១ អង្គត្រង់បាតដៃ ហើយញុំាំងស្តេចទាំងនោះ ឲ្យស្ងួតស្រពោន ហើយចូលទៅនាំយកតថាគត ក្នុងពេលសម្រេចយញ្ញ ។ ស្តេចបោរិសាទ សួរតថាគតថា អ្នកឯងចង់រួចខ្លួន (អំពីដៃយើង) ឬទេ បើអ្នកអាចត្រឡប់មក (កាន់សំណាក់) យើងវិញ យើងនឹងព្រមធ្វើតាមសេចក្តីពេញចិត្ត របស់អ្នក ។

តេរសមំ សុវណ្ណសាមចរិយំ

តស្ស បដិស្សុណិត្វាន បញ្ហេ អាគមនំ មម

ឧបគន្ត្វា បុរំ រម្មំ រជ្ជំ និយ្យាទយឹ តទា ។

អនុស្សរិត្វា សតំ ធម្មំ បុព្វកំ ជិនសេវិតំ

ព្រាហ្មណស្ស ធនំ ទត្វា បោរិសាទំ ឧបាគមឹ ។

នត្ថិ មេ សំសយោ តត្ថ ឃាតយិស្សតិ វា ន វា

សច្ចវាចានុរក្ខន្តោ ជីវិតំ ចជិតុមុបាគមឹ

សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ ។

សុតសោមចរិយំ ទ្វាទសមំ ។

## តេរសមំ សុវណ្ណសាមចរិយំ

(៣៣) សាមោ យទា វនេ អាសឹ សក្កេន អភិនិម្មិតោ

បវនេ សីហព្យគ្ឃេហិ មេត្តាយ មុបនាមយឹ ។

កាលនោះ តថាគតទទួល (ពាក្យ) ស្តេចបោរិសាទនោះ ហើយ ចូលទៅកាន់បុរីជាទីរីករាយ ប្រគល់រាជ្យ (ដល់មាតាបិតា) នឹងបាច់និយាយថ្វី ដល់ការត្រឡប់មកនៃតថា-គតវិញ ៗ តថាគតរឭកនូវធម៌ របស់សប្បុរសទាំងឡាយ ដែលព្រះជិនស្រីទាំងឡាយ ធ្លាប់សេពក្នុងកាលមុន ឲ្យទ្រព្យដល់ព្រាហ្មណ៍ ហើយចូលទៅកាន់ស្តេចបោរិសាទ ៗ តថាគតមិនមានសេចក្តីសង្ស័យថា ស្តេចបោរិសាទនេះ នឹងសំឡាប់ ឬមិនសម្លាប់នូវអញ ក្នុងទីនោះឡើយ តថាគតរក្សាពាក្យសច្ចៈ ចូលទៅ (កាន់សំណាក់ស្តេចបោរិសាទ) ដើម្បីលះបង់នូវជីវិត គុណធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគត ពុំមានឡើយ នេះជាសច្ចបារមី របស់តថាគត ៗ

ចប់ សុតសោមបរិយា ទី ១២ ។

# សុវណ្ណសាមបរិយា ទី ១៣

(៣៣) កាលដែលតថាគតជាតាបស ឈ្មោះសាមៈ នៅក្នុងអាស្រម ដែលព្រះឥន្ទ្រនិម្មិតឲ្យក្នុងព្រៃ តថាគតញុំាងសីហៈនិងខ្លាធំទាំងឡាយក្នុងព្រៃ ឲ្យចូលមកជិតដោយមេត្តាបាន ៗ

សីហព្យគ្ឃាបិ ទីបីបិ  អច្ឆាបិ មហិសាបិ ច

បសទមិគវរាហាបិ  បរិវារេត្វា វនេ វសិំ ។

ន មំ កោចិ ឧត្តសតិ  នបិហំ ភាយាមិ កស្សចិ

មេត្តាពលេនុបត្ថទ្ធោ  រមាមិ បវនេ តទាតិ ។

សុវណ្ណសាមចរិយំ តេរសមំ ។

# ចុទ្ទសមំ ឯករាជចរិយំ

(៣៤) បុនាបរំ យទា ហោមិ  ឯករាជាតិ វិស្សុតោ

បរមំ សីលំ អធិដ្ឋាយ  បសាសាមិ មហាមហិំ ។

ទស កុសលកម្មបថេ  វត្តាមិ អនវសេសតោ

ចតូហិ សង្គហវត្ថូហិ  សង្គណ្ហាមិ មហាជនំ ។

ឯវំ មេ អប្បមត្តស្ស  ឥធ លោកេ បរត្ថ ច

ទព្វសេនោ ឧបាគន្ត្វា  អច្ឆិន្ទន្តោ បុរំ មម ។

សត្វសីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ក្របី ក្ដាន់ និងជ្រូកព្រៃ មកពោមរោមតថាគត ដែលនៅក្នុងព្រៃ ។ សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគត ក៏មិនខ្លាចសត្វណាមួយឡើយ កាលណោះ កម្លាំងមេត្តាឧបត្ថម្ភតថាគត ឲ្យតថាគតនៅក្នុងព្រៃ ដោយសួស្តី ។

ចប់ សុវណ្ណសាមចរិយា ទី ១៣ ។

## ឯករាជចរិយា ទី ១៤

(៣៤) មានចរិយាដទៃទៀត កាលដែលតថាគត កើតជាស្តេច ឈ្មោះឯករាជ បានអធិដ្ឋានសីលដ៏ក្រៃលែង ហើយគ្រប់គ្រងមហាប្រថពី ក្នុងកាសិករដ្ឋ ។ តថាគតបានប្រព្រឹត្ត កុសលកម្មបថ ១០ ឥតមានសេសសល់ សង្គ្រោះមហាជន ដោយសង្គហវត្ថុទាំង ៤ ។ តថាគតមិនប្រមាទ ក្នុងលោកនេះ និងបរលោកយ៉ាងនេះ វេលានោះ ស្តេចក្នុងដែនកោសល ឈ្មោះទព្វសេន ចូលមកដណ្តើមរាជបុរី របស់តថាគត ។

រាជូបជីវេ និគមេ   សព្វលដ្ឋេ សរដ្ឋកេ
សព្វំ ហត្ថគតំ កត្វា   កាសុយា និក្ខណី មមំ ។
អមច្ចមណ្ឌលំ រជ្ជំ   ផីតំ អន្តេបុរំ មម
អច្ឆិន្ទិត្វាន គហិតំ   បិយបុត្តំវ បស្សហំ
មេត្តាយ មេ សមោ នត្ថិ   ឯសា មេ មេត្តាបារមីតិ ។

ឯករាជចរិយំ ចុទ្ទសមំ ។

## បណ្ណរសមំ មហាលោមហំសចរិយំ

(៣៨) សុសានេ សេយ្យំ កប្បេមិ   ឆវដ្ឋិកំ ឧបនិធាយ
គាមមណ្ឌលា ឧបាគន្ត្វា   រូបំ ទស្សេន្តិ នប្បកំ ។
អបរេ គន្ធញ្ច មាលញ្ច   ភោជនំ វិវិធំ ពហុំ
ឧបាយនានិ ឧបនេន្តិ[១]   ហដ្ឋា សំវិគ្គមានសា ។

---

១ ឱ. ម. ឧបាយ នានុបនេន្តិ ទិស្សតិ ។

ស្ដេចទព្វសេន ធ្វើនូវអ្នកនិគម ព្រមទាំងពួកពល និងអ្នកជនបទ ដែលរស់នៅព្រោះអាស្រ័យស្ដេចទាំងអស់ ឲ្យតាំងនៅក្នុងដៃ ហើយដឹកកប់តថាគតក្នុងរណ្ដៅ ។ តថាគតបានឃើញនូវមណ្ឌលនៃអាមាត្យ រាជ្យ និងកំពង់ដ៏ស្តុកស្តម្ភ របស់តថាគត ដូចកូនជាទីស្រឡាញ់ ដែលត្រូវស្ដេចទព្វសេនដណ្ដើមយកហើយ (ក៏ផ្សាយមេត្តាចំពោះស្ដេចទព្វសេននោះ) គុណធម៌ដទៃ ស្មើនឹងមេត្តា នៃតថាគត ពុំមានឡើយ នេះជាមេត្តាបារមី របស់តថាគត ។

ចប់ ឯកាទសចរិយា ទី ១៤ ។

## មហាលោមហំសចរិយា ទី ១៥

(៣៩) តថាគតសម្រេចសេយ្យាសន៍ កើយខ្នើងសាកសពក្នុងព្រៃស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត (តថាគត) ហើយសម្ដែងនូវប្រការដ៏ប្លែក ច្រើនយ៉ាង ។ ពួកក្មេងដទៃ ជាអ្នកដឹងការណ៍ (ឃើញទារកទាំងឡាយ) ក៏សប្បាយរីករាយ មានចិត្តសង្វេគ ទៅនាំយកគ្រឿងក្រអូប ផ្កាកម្រង ភោជនផ្សេង ៗ ដ៏ច្រើន និងគ្រឿងបណ្ណាការ មកឲ្យតថាគត ។

យេ មេ ទុក្ខំ ឧបហរន្តិ(១) យេ ច ទេន្តិ សុខំ មម

សព្វេសំ សមកោ ហោមិ ទយា កោបោ ន វិជ្ជតិ ។

សុខទុក្ខេ តុលាភូតោ យសេសុ អយសេសុ ច

សព្វត្ថ សមកោ ហោមិ ឯសា មេ ឧបេក្ខាបារមីតិ ។

មហាលោមហំសចរិយំ បណ្ណរសមំ ។

## ឧទ្ទានំ

យុធញ្ជយោ សោមនស្សោ អយោឃរភិសេន ច

សោណនន្ទោ មូកបក្ខោ(២) កបិរាជា សច្ចសវ្ហយោ ។

វដ្ដកោ មច្ឆរាជា ច កណ្ហទីបាយនោ ឥសិ

សុតសោមោ បុន អាសិ(៣) សាមោ ច ឯករាជា ច

ឧបេក្ខាបារមី អាសិ ឥតិ វុត្តំ មហេសិនា ។

---

១ ឱ. ម. ឧបទហន្តិ ។ ២ ឱ. ម. មូគបក្ខោ ។ ៣ ឱ. ម. បុន អាសឹ ។

ពួកក្មេងអ្នកស្រុកណា នាំយកសេចក្តីទុក្ខមកឲ្យតថាគត ពួកក្មេងអ្នកស្រុកណា ឲ្យសេចក្តីសុខដល់តថាគត តថាគតមានចិត្តស្មើ ចំពោះទារកទាំងអស់នោះ មិនអាណិត មិនក្រោធ ។ តថាគត មានចិត្តជាកណ្តាល ក្នុងសុខនិងទុក្ខ ក្នុងយសនិងអយស តថាគត មានចិត្តស្មើក្នុងលោកធម៌ទាំងពួង នេះជាឧបេក្ខាបារមី របស់តថាគត ។

ចប់ មហាលោមហំសចរិយា ទី ១៥ ។

## ឧទ្ទាននៃចរិយានោះ

យុធញ្ជយចរិយា ១ សោមនស្សចរិយា ១ អយោឃរចរិយា ១ ភិសចរិយា ១ សោណនន្ទបណ្ឌិតចរិយា ១ មូគផក្ខចរិយា ១ កបិលរាជចរិយា ១ សច្ចសវ្ហយបណ្ឌិតចរិយា ១ វដ្តកបោតកចរិយា ១ មច្ឆរាជចរិយា ១ កណ្ហទីបាយនចរិយា ១ សុតសោមចរិយា ១ សុវណ្ណសាមចរិយា ១ ឯករាជចរិយា ១ លោមហំសចរិយា ១ ព្រះមហេសីសម្ពុទ្ធ ទ្រង់សំដែងហើយ ដោយប្រការដូច្នេះ ។

## តស្សុទ្ធានំ

ឃរំ ពហុវិធំ ទុក្ខំ សម្បត្តិញ្ច ពហុវិធំ
ភវាភវេ អនុភវិត្វា បត្តោ សម្ពោធិមុត្តមំ ។
ទត្វា ទាតព្វកំ ទានំ សីលំ បូរេត្វា អសេសតោ
និក្ខម្ម បារមឹ គន្ត្វា បត្តោ សម្ពោធិមុត្តមំ ។
បណ្ឌិតេ បរិបុច្ឆិត្វា វីរិយំ កត្វាន ឧត្តមំ
ខន្តិយា បារមឹ គន្ត្វា បត្តោ សម្ពោធិមុត្តមំ ។
កត្វា ទឡ្ហមធិដ្ឋានំ សច្ចវាចានុរក្ខិយ
មេត្តាយ បារមឹ គន្ត្វា បត្តោ សម្ពោធិមុត្តមំ ។
លាភាលាភេ យសាយសេ សម្មាននាវមានេន
សព្វត្ថ សមកោ(១) ហុត្វា បត្តោ សម្ពោធិមុត្តមំ ។

---

១ ឱ. សមាតោ ។

## ឧទ្ទាននៃបរិយាយនោះ

តថាគត រង់ទុក្ខច្រើនប្រការ សោយសម្បត្តិច្រើនប្រការ ក្នុងភពតូចភពធំ ដូចបានរៀបរាប់ មកយ៉ាងនេះ ហើយបានសម្រេច នូវសម្ពោធិញ្ញាណដ៏ឧត្តម ៗ តថាគតបានឲ្យទាន ដែលព្រះពោធិសត្វគប្បីឲ្យ ទាំងបំពេញសីលមិនមានសេសសល់ ហើយចេញទៅកាន់មហាភិនិស្ក្រម បានដល់បារមី សម្រេចនូវសម្ពោធិញ្ញាណ ជាញាណដ៏ឧត្តម ៗ តថាគត បានសាកសួរបណ្ឌិតទាំងឡាយ បានធ្វើព្យាយាមដ៏ឧត្តម បានដល់ខន្តិបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ៗ តថាគត បានធ្វើអធិដ្ឋានយ៉ាងមាំ បានរក្សាសច្ចៈ បានដល់មេត្តាបារមី ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ៗ តថាគតមានចិត្តស្មើ ក្នុងលោកធម៌ទាំងពួង គឺលាភ អលាភ យស អយស សេចក្តីរាប់អាន និងសេចក្តីមើលងាយ ហើយបានសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម ៗ

កោសជ្ជំ ភយតោ ទិស្វា វីរិយារម្ភញ្ច ខេមតោ
អារទ្ធវីរិយា ហោថ ឯសា ពុទ្ធានុសាសនី ។
វិវាទំ ភយតោ ទិស្វា អវិវាទញ្ច ខេមតោ
សមគ្គា សខិលា ហោថ ឯសា ពុទ្ធានុសាសនី ។
បមាទំ ភយតោ ទិស្វា អប្បមាទញ្ច ខេមតោ
ភាវេថដ្ឋង្គិកំ មគ្គំ ឯសា ពុទ្ធានុសាសនី ។

ឥត្ថំ សុទំ ភគវា អត្តនោ បុព្វចរិយំ សម្ភាវយមានោ ពុទ្ធាបទានិយំ នាម ធម្មបរិយាយំ អភាសិត្ថាតិ ។

**ចរិយាបិដកំ និដ្ឋិតំ ។**

## សមោធានគាថា

(៣៦) ទសេតេ បារមី ហោន្តិ ទសេតេ ឧបបារមី
បរមត្ថា ទស ហោន្តិ ពោធិយា បរិបាចកា ។

អ្នកទាំងឡាយគួរឃើញនូវកោសជ្ជៈ ថាជាភ័យ គួរឃើញនូវការប្រារព្ធព្យាយាម ថាជាសេចក្តីក្សេម ហើយប្រឹងប្រែងព្យាយាមចុះ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ គួរឃើញនូវការទាស់ទែង ថាជាភ័យ គួរឃើញនូវការមិនទាស់ទែង ថាជាសេចក្តីក្សេម ហើយចូរព្រមព្រៀងគ្នា ទាំងជាបុគ្គលមានពាក្យពីរោះកេគ្នាចុះ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ មួយទៀត អ្នកទាំងឡាយ គួរឃើញនូវសេចក្តីប្រមាទ ថាជាភ័យ គួរឃើញនូវសេចក្តីមិនប្រមាទ ថាជាសេចក្តីក្សេម ហើយចូរចម្រើនមគ្គ ប្រកបដោយអង្គ ៨ ចុះ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ។

បានឮថា ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរ នូវបុព្វចរិយារបស់ព្រះអង្គ ហើយសម្តែងនូវធម្មបរិយាយ ឈ្មោះពុទ្ធាបទាន ដោយប្រការដូច្នេះ ។

**ចប់ ចរិយាបិដក ។**

# សមោធានកថា

(៣៦) បារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ បារមីទាំងនេះ ជាគ្រឿងញុំាងពោធិញាណ ឲ្យបានសម្រេច

## សមោធានកថា

សិវិរដស្ស សេដ្ឋស្ស  ទានបារមិតា ភវេ
វេស្សន្តរេ ច វេលាមេ  ភវន្តិ ឧបបារមី ។
អកិត្តិវិសយ្ហទានេន  ហោន្តិ តា ឧបបារមី
កុក្កុដសីលសសោ ភូតោ  បរមត្ថា ទានបារមី ។
មហាកបិ ច ឆទ្ទន្តោ  នាគោ ច មាតុបោសកោ
សីលបារមិតា យន្តិ  ឥតិ វុត្តំ មហេសិនា ។
ចម្បេយ្យកោ ភូរិទត្តោ  សីលេន ឧបបារមី
សង្ខបាលោ ច យោ ធីរោ  បរមត្ថា សីលបារមី ។
យុធញ្ជយោ ច គោវិន្ទោ  ហត្ថិបាលោ ច យោ ឃរេ
កល្ហាតិយោ សុសាមោ ច
មឃទេវោ និមិ ទេវ  ហោន្តេតា ឧបបារមី ។

## សមោធានកថា

គឺព្រះបាទសិវិរាជដ៏ប្រសើរ បានបំពេញទានបារមី ព្រះបាទវេស្សន្តរ និងវេលាមព្រាហ្មណ៍ បានបំពេញទានឧបបារមី អកិត្តិតាបស បានបំពេញទាន ដ៏មានកម្លាំង ហៅថាទាន-ឧបបារមី កាលតថាគត កើតជាមាន់ និងទន្សាយដ៏ប្រសើរ បានបំពេញទានបរមត្ថបារមី ។ កាលតថាគត កើតជាស្តេចស្វាក្តី ជាដំរីឆទ្ទន្តក្តី ជាដំរីចិញ្ចឹមមាតាក្តី បានបំពេញសីលបារមី ពាក្យដូច្នេះនេះ ព្រះមហាសីទ្រង់សម្តែងហើយ ។ កាលតថាគតកើតជាស្តេច ឈ្មោះចម្បេយ្យៈ និងជាស្តេចនាគឈ្មោះភូរិទត្ត បានបំពេញសីលឧបបារមី កាលតថាគតកើតជាសង្ខបាលនាគរាជ ជាអ្នកប្រាជ្ញ បានបំពេញសីលបរមត្ថ-បារមី ។ កាលតថាគត កើតជារាជបុត្ត ឈ្មោះយុធញ្ជ័យក្តី ជាមហាគោវិន្ទក្តី ជាហត្ថិបាលក្តី ជាកូនព្រាហ្មណមហា-សាល ឈ្មោះអយោឃរៈក្តី ជាកល្យាតិយៈក្តី ជាសុវណ្ណសាមក្តី ជាមឃទេវបុត្តក្តី ជានេមិរាជក្តី បានបំពេញទានឧបបារមី ។

មហោសធោ ជនសន្ធោ កុណ្ឌលោ ចាបិ តណ្ឌិលោ

តិត្តិរោ ច សកុណោ ច ហោន្តោ ឧបបារមី ។

វិធុរំ សម្ភវំ បញ្ញាយ ឧកោតា ហោន្តិ បារមី

យោ សិស្សោ អាចរិយំ ចោរ សុរិយព្រាហ្មណោ

មាតង្គោ ។

សត្តុភស្តញ្ច បរមត្ថា ឯតា វេ បញ្ញាបារមី

សីលវា វីរយោ រាជា ជាតកំ ជនកា វិញ្ញូ ។

ទឡ្ហបរក្កមោ អាសិ បរមត្ថា វីរិយបារមី

មហាកបិ បញ្ចុ គរុកា វីរិយា ហោន្តិ បារមី ។

ធម្មបាលោ កុមារោ ច ខន្តិយា ហោន្តិ បារមី

ឧបបារមីតិ វុច្ចន្តិ ធម្មធម្មិកមទ្ធវា ។

ខន្តិវាទេន បរមត្ថា ខន្តិបារមិបូរិយា

ពុទ្ធភូមី គវេសន្តោ អកាសិ ទុក្ករំ ពហុំ ។

កាលតថាគត កើតជាមហោសថបណ្ឌិតក្តី ធនវជ្ឈបណ្ឌិតក្តី កុណ្ឌលបណ្ឌិតក្តី តណ្ឌិលបណ្ឌិតក្តី តិត្តិរៈក្តី សកុណៈក្តី នុះ បានបំពេញបញ្ញាឧបបារមី ។ កាលតថាគត កើតជាវិធុរបណ្ឌិតក្តី ជាសម្ភវកុមារក្តី ទាំងពីរនុះ បានបំពេញបញ្ញាបារមី កាលតថាគត កើតជាសុរិយព្រាហ្មណ៍ក្តី ជាមាតង្គបណ្ឌិតក្តី ដែលជាសិស្សអាស្រ័យនូវអាចារ្យ ក្នុងកាលមុន ក៏បានបំពេញនូវបញ្ញាបារមីដែរ ។ ឯបញ្ញាបរមត្ថបារមីនុះឯង (តថាគតបានបំពេញ ក្នុងកាលយោនយកកំណើតកើត) ជាសេនកបណ្ឌិត កាលតថាគត កើតព្រាកជ ជាស្តេចជនក មានសីល មានព្យាយាម មានការប្រឹងប្រែងយ៉ាងមាំ បានបំពេញវីរិយបរមត្ថបារមី កាលតថាគតកើតជាស្តេចស្វា ជាអ្នកគោរពធម៌ ៤ ប្រការ បានបំពេញវីរិយបារមី ។ កាលតថាគត កើតជាធម្មបាលកុមារ បានបំពេញខន្តិបារមី ជាគ្រឿងញាំញីដោយធម៌ នូវបុគ្គលមិនប្រកបដោយធម៌ ហៅថា ខន្តិឧបបារមី ។ កាលតថាគត កើតជាខន្តិវាទីតាបស ស្វែងរកពុទ្ធភូមិ តថាគតបានធ្វើ នូវអំពើដ៏កម្រ ជាច្រើនយ៉ាង ដើម្បីបំពេញ នូវខន្តិបរមត្ថបារមី ដោយខន្តិវាទ ។

## សមោធានគាថា

តទុបរិ សព្វញ្ញុណំ  សសង្ឃកជាតកំ
សម្ពុទ្ធកិច្ចនិព្វាបិតោ  ឯសា បារមិតា ករេ ។
ឧទកោ មគ្គោ ករិត្វាន  អកាសិ សព្វមុត្តមំ
មហាមេឃំ បវស្សេសិ  ឯសា មេ សព្វបារមី ។
សម្ពុទ្ធ ធារំ តារេសិ  ជីវេ សុបារបណ្ឌិតោ
វិសំ សម្ពុទ្ធ ឃាតេសិ  កណ្ហាទីបាយនោ ឥសិ ។
សម្ពុទ្ធ វធកេ ហន្ត្វា  កត្តាសោតំ តរី តទា
ឯសា បារមិតា សព្វ  ហោន្តិ តា ឧបបារមី ។
សុតសោមោ នាម រាជា  រក្ខិត្តា សព្វមុត្តមំ
មោចេតិ ឯកសតំ ខត្យេ  បរមត្ថា សព្វបារមី ។
អធិដ្ឋានេន តីរ ជនោ  បារមី ករិតី តទា
ទុកោ មាតង្គយោ ចេវ  អធិដ្ឋានឧបបារមី ។

## សមោធានកថា

កាលតថាគតកើតជាទន្សាយ និងជាសត្វក្រួប អាស្រ័យនូវគុណគឺសច្ចៈ ដូចមានខាងលើនោះ បានញ៉ាំងភ្លើងឲ្យរលត់ដោយសច្ចៈ នេះក៏ជាសច្ចបារមី ។ កាលតថាគត កើតជាត្រី នៅក្នុងទឹក បានធ្វើនូវសច្ចៈដ៏ឧត្តម ញ៉ាំងមហាមេឃឲ្យបង្អុរចុះ នេះជាសច្ចបារមីរបស់តថាគត ។ កាលតថាគតកើតជាសុបារបណ្ឌិត ជាអ្នកប្រាជ្ញ បានញ៉ាំងទូកឲ្យឆ្លងដោយសច្ចៈ កាលកើតជាឥសី ឈ្មោះកណ្ហទីបាយនៈ បានញ៉ាំងពិសឲ្យសាបរលាបដោយសច្ចៈ កាលកើតជាស្វា បានឆ្លងខ្សែទឹកគង្គាដោយសច្ចៈ នេះជាបារមី របស់តថាគតជាសាស្តាក្នុងកាលនោះ បារមីនោះ ជាសច្ចឧបបារមី ។ កាលតថា-គត កើតជាស្តេចសុតសោម រក្សាសច្ចៈដ៏ឧត្តម ដោះក្សត្រ ១០១ អង្គឲ្យរួច (នេះ) ជាសច្ចបរមត្ថបារមី ។ កាលតថាគតកើតជាកឹធន្ទៈ កាលនោះ មានបារមីដោយការអធិដ្ឋាន កាលកើតជាទុកៈ និងមាតង្គយៈ បានបំពេញអធិដ្ឋានឧបបារមី ។

មុគបក្ខេន បរមត្ថា អធិដ្ឋានំ អាសិ បារមី

មហាកណ្ហោ ច មេត្តាយ តត្ថ ច រាជសោនធា ។

ឯសា ទុវិធា អក្ខាតា មេត្តា បារមិតា ភវេ

សីលេន ព្រហ្មទត្តោ ច យោ វាយំ កណ្ឌិតិណ្ឌកោ ។

អកាសិ នេត្វា បិយស្ស ហោន្តិ តា ឧបបារមី

ឯករាជេន បរមត្ថា ខន្តិ មេត្តាយ ឡទិសោ ។

ទ្វេ សុវា ឧបបារមី បរមត្ថា លោមហំសនំ

ឯតា ទស បារមី មយ្ហំ បដិវេសោ អគ្គពោធិយា ។

ទសតោ បរមា ខន្តិ ទសតោ ខន្តិ ឱនកា

អទ្វានធិកា សព្វា បូរិតា ទសបារមីតិ ។

សមោធានគាថា និដ្ឋិតា ។

ចរិយាបិដកំ សមត្តំ ។

កាលតថាគត កើតជាមូគផក្ខពោធិសត្វ បានបំពេញអធិដ្ឋាន-បារមី កាលកើតជាមហាកណ្ហៈ ប្រព្រឹត្តទៅ ដោយមេត្តា កាលកើតជាពជសោធនៈ (ក៏ប្រព្រឹត្តទៅ) ដោយមេត្តានោះដែរ បារមីទាំងពីរនេះ ហៅថា មេត្តាបារមី ។ កាលតថា-គត កើតជាស្តេចព្រហ្មទត្ត (ប្រព្រឹត្តទៅ) ដោយសីល កាលកើតជាគណ្ឋិតិណ្ឌកៈនេះ (ក៏បានប្រព្រឹត្តទៅ) ដោយសីលដែរ ។ កាលតថាគត កើតជានន្ទៈ បានធ្វើនូវសេចក្តីស្រឡាញ់ (ក្នុងសព្វញ្ញុតញ្ញាណ) បារមីទាំងនោះ ជាឧបបារមី ឯបរមត្ថបារមី បានបំពេញហើយ ក្នុងកាលតថាគតកើតជាស្តេចឯកពជ បារមីដទៃ ប្រាកដស្មើ ដោយមេត្តាបារមីនេះពុំមានឡើយ ។ កាលតថាគតកើតជាសេកទាំងពីរ បានបំពេញឧបបារមី កាលកើតជាលោមហំសនៈ បានបំពេញបរមត្ថ-បារមី ឯបារមី ១០ របស់តថាគតនេះ ជាចំណែកនៃពោធិ-ញាណដ៏ប្រសើរ ។ បារមីទាំងឡាយ មិនលើសអំពី ១០ មិនខ្វះអំពី១០ បារមីទាំងអស់ពេញត្រឹម ១០ មិនខ្វះមិនលើស ។

ចប់ សមោធានកថា ។

ចប់ ចរិយាបិដក ។

# សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស

# ពុទ្ធវំសោ

## មាតិកាបត្តនិ


| មាតិកា | អង្កេ |
| --- | --- |
| រតនចង្កមនកណ្ឌោ | ១ |
| បឋមោ ទីបង្ករពុទ្ធវំសោ | ២១ |
| ទុតិយោ កោណ្ឌញ្ញពុទ្ធវំសោ | ៥៩ |
| តតិយោ មង្គលពុទ្ធវំសោ | ៦៦ |
| ចតុត្ថោ សុមនពុទ្ធវំសោ | ៧៤ |
| បញ្ចមោ រេវតពុទ្ធវំសោ | ៨២ |
| ឆដ្ឋោ សោភិតពុទ្ធវំសោ | ៨៩ |
| សត្តមោ អនោមទស្សិពុទ្ធវំសោ | ៩៧ |
| អដ្ឋមោ បទុមពុទ្ធវំសោ | ១០៤ |
| នវមោ នារទពុទ្ធវំសោ | ១១២ |
| ទសមោ បទុមុត្តរពុទ្ធវំសោ | ១២០ |
| ឯកាទសមោ សុមេធពុទ្ធវំសោ | ១២៨ |
| ទ្វាទសមោ សុជាតពុទ្ធវំសោ | ១៣៥ |

# សុត្តន្តបិដក ខុទ្ទកនិកាយ

# ពុទ្ធវង្ស

## សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| រតនចង្កមកណ្ឌ | ១ |
| ទីបង្ករពុទ្ធវង្ស ទី ១ | ២១ |
| កោណ្ឌញ្ញពុទ្ធវង្ស ទី ២ | ៥៩ |
| មង្គលពុទ្ធវង្ស ទី ៣ | ៦៦ |
| សុមនពុទ្ធវង្ស ទី ៤ | ៧៤ |
| រេវតពុទ្ធវង្ស ទី ៥ | ៨២ |
| សោភិតពុទ្ធវង្ស ទី ៦ | ៨៩ |
| អនោមទស្សិពុទ្ធវង្ស ទី ៧ | ៩៧ |
| បទុមពុទ្ធវង្ស ទី ៨ | ១០៤ |
| នារទពុទ្ធវង្ស ទី ៩ | ១១២ |
| បទុមុត្តរពុទ្ធវង្ស ទី ១០ | ១២០ |
| សុមេធពុទ្ធវង្ស ទី ១១ | ១២៨ |
| សុជាតពុទ្ធវង្ស ទី ១២ | ១៣៥ |

# មាតិកាបត្ដានិ


| មាតិកា | អង្ក |
| --- | --- |
| តេរសមោ បិយទស្សីពុទ្ធវំសោ | ១៤៣ |
| ចុទ្ទសមោ អត្ថទស្សីពុទ្ធវំសោ | ១៥០ |
| បណ្ណរសមោ ធម្មទស្សីពុទ្ធវំសោ | ១៥៧ |
| សោឡសមោ សិទ្ធត្ថពុទ្ធវំសោ | ១៦៤ |
| សត្តរសមោ តិស្សពុទ្ធវំសោ | ១៧១ |
| អដ្ឋារសមោ ផុស្សពុទ្ធវំសោ | ១៧៨ |
| ឯកូនវីសតិមោ វិបស្សីពុទ្ធវំសោ | ១៨៤ |
| វីសតិមោ សិខីពុទ្ធវំសោ | ១៩១ |
| ឯកវីសតិមោ វេស្សភូពុទ្ធវំសោ | ១៩៨ |
| ទ្វាវីសតិមោ កកុសន្ធពុទ្ធវំសោ | ២០៦ |
| តេវីសតិមោ កោនាគមនពុទ្ធវំសោ | ២១២ |
| ចតុវីសតិមោ កស្សបពុទ្ធវំសោ | ២២០ |
| បញ្ចវីសតិមោ គោតមពុទ្ធវំសោ | ២២៨ |
| ពុទ្ធប្បកិណ្ណកកណ្ឌោ | ២៣៣ |
| ធាតុភាជនីយកថា | ២៣៦ |

# សន្លឹកប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| បិយទស្សិពុទ្ធវង្ស ទី ១៣ | ១៤៣ |
| អត្ថទស្សិពុទ្ធវង្ស ទី ១៤ | ១៥០ |
| ធម្មទស្សិពុទ្ធវង្ស ទី ១៥ | ១៥៧ |
| សិទ្ធត្ថពុទ្ធវង្ស ទី ១៦ | ១៦៤ |
| តិស្សពុទ្ធវង្ស ទី ១៧ | ១៧១ |
| ផុស្សពុទ្ធវង្ស ទី ១៨ | ១៧៨ |
| វិបស្សិពុទ្ធវង្ស ទី ១៩ | ១៨៤ |
| សិខិពុទ្ធវង្ស ទី ២០ | ១៩១ |
| វេស្សភូពុទ្ធវង្ស ទី ២១ | ១៩៨ |
| កកុសន្ធពុទ្ធវង្ស ទី ២២ | ២០៦ |
| កោនាគមនពុទ្ធវង្ស ទី ២៣ | ២១២ |
| កស្សបពុទ្ធវង្ស ទី ២៤ | ២២០ |
| គោតមពុទ្ធវង្ស ទី ២៥ | ២២៨ |
| ពុទ្ធបកិណ្ណកកណ្ឌ | ២៣៣ |
| ធាតុភាជនីយកថា | ២៣៦ |

# សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស

# ចរិយាបិដកំ

---

## មាតិកាបត្តានិ

មាតិកា | អង្ក

### ទានបារមិតា


បឋមំ អកិត្តិចរិយំ . . . . . . . . . . . . ២៤០

ទុតិយំ សង្ខព្រាហ្មណចរិយំ . . . . . . . ២៤២

តតិយំ កុរុធម្មចរិយំ . . . . . . . . . . . ២៤៤

ចតុត្ថំ មហាសុទស្សនចរិយំ . . . . . . . . . ២៤៥

បញ្ចមំ មហាគោវិន្ទចរិយំ . . . . . . . . . . ២៤៧

ឆដ្ឋមំ នេមិរាជចរិយំ . . . . . . . . . . ២៤៨

សត្តមំ ចន្ទកុមារចរិយំ . . . . . . . . . . ២៤៩

អដ្ឋមំ សិវិរាជចរិយំ . . . . . . . . . . ២៥០

នវមំ វេស្សន្តរចរិយំ . . . . . . . . . . ២៥៣

ទសមំ សសបណ្ឌិតចរិយំ . . . . . . . . . ២៦៣

# សុត្តន្តបិដក ខុទ្ទកនិកាយ

# ចរិយាបិដក

---

## សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

### ទានបារមី


អកិត្តិចរិយា ទី ១ . . . . . . . . . . . . ២៤០

សង្ខព្រាហ្មណចរិយា ទី ២ . . . . . . . . . ២៤២

កុរុធម្មចរិយា ទី ៣ . . . . . . . . . . . ២៤៤

មហាសុទស្សនចរិយា ទី ៤ . . . . . . . . ២៤៥

មហាគោវិន្ទចរិយា ទី ៥ . . . . . . . . . ២៤៧

នេមិរាជចរិយា ទី ៦ . . . . . . . . . . ២៤៨

ចន្ទកុមារចរិយា ទី ៧ . . . . . . . . . . ២៤៩

សិវិរាជចរិយា ទី ៨ . . . . . . . . . . . ២៥០

វេស្សន្តរចរិយា ទី ៩ . . . . . . . . . . ២៥៣

សសបណ្ឌិតចរិយា ទី ១០ . . . . . . . . ២៦៣

# មាតិកាបត្តនិ

មាតិកា | អង្កៃ

## សីលបារមិតា


បឋមំ សីលវនាគចរិយំ . . . . . . . . . . ២៦៧

ទុតិយំ ភូរិទត្តចរិយំ . . . . . . . . . . ២៦៩

តតិយំ ចម្បេយ្យចរិយំ . . . . . . . . . . ២៧០

ចតុត្ថំ ចូឡពោធិចរិយំ . . . . . . . . . . ២៧២

បញ្ចមំ មហិសរាជចរិយំ . . . . . . . . . . ២៧៤

ឆដ្ឋមំ រុរុមិគចរិយំ . . . . . . . . . . ២៧៥

សត្តមំ មាតង្គចរិយំ . . . . . . . . . . ២៧៨

អដ្ឋមំ ធម្មទេវបុត្តចរិយំ . . . . . . . . . . ២៧៩

នវមំ ជយទិសចរិយំ . . . . . . . . . . ២៨០

ទសមំ សង្ខបាលចរិយំ . . . . . . . . . . ២៨២


## នេក្ខម្មបារមិតា


បឋមំ យុធញ្ជយចរិយំ . . . . . . . . . . ២៨៤

ទុតិយំ សោមនស្សចរិយំ . . . . . . . . . . ២៨៥

តតិយំ អយោឃរចរិយំ . . . . . . . . . . ២៨៨

# សន្លឹកប្រាប់មាតិកា

មាតិកា | ទំព័រ

## សីលបារមិតា


សីលវនាគចរិយា ទី ១ . . . . . . . . . . ២៦៧

ភូរិទត្តចរិយា ទី ២ . . . . . . . . . . ២៦៩

ចម្បេយ្យចរិយា ទី ៣ . . . . . . . . . . ២៧០

ចូឡពោធិចរិយា ទី ៤ . . . . . . . . . . ២៧២

មហិសរាជចរិយា ទី ៥ . . . . . . . . . . ២៧៤

រុរុមិគចរិយា ទី ៦ . . . . . . . . . . ២៧៥

មាតង្គចរិយា ទី ៧ . . . . . . . . . . ២៧៨

ធម្មទេវបុត្តចរិយា ទី ៨ . . . . . . . . . . ២៧៩

ជយទិសចរិយា ទី ៩ . . . . . . . . . . ២៨០

សង្ខបាលចរិយា ទី ១០ . . . . . . . . . . ២៨២


## នេក្ខម្មបារមិតា


យុធញ្ជយចរិយា ទី ១ . . . . . . . . . . ២៨៤

សោមនស្សចរិយា ទី ២ . . . . . . . . . . ២៨៥

អយោឃរចរិយា ទី ៣ . . . . . . . . . . ២៨៨

# មាតិកាបត្តាធិ

មាតិកា អង្កៃ

## នេក្ខម្មបារមិតា


ចតុត្ថំ ភិសចរិយំ . . . . . . . . . . . ២៩០

បញ្ចមំ សោណនន្ទបណ្ឌិតចរិយំ . . . . . . ២៩១

ឆដ្ឋមំ មូគផក្ខចរិយំ . . . . . . . . . ២៩៣

សត្តមំ កបិលរាជចរិយំ . . . . . . . . ២៩៦

អដ្ឋមំ សច្ចសវ្ហយបណ្ឌិតចរិយំ . . . . . . ២៩៧

នវមំ វដ្តកបោតកចរិយំ . . . . . . . . ២៩៧

ទសមំ មច្ឆរាជចរិយំ . . . . . . . . . ២៩៩

ឯកាទសមំ កណ្ហទីបាយនចរិយំ . . . . . . ៣០១

ទ្វាទសមំ សុតសោមចរិយំ . . . . . . . ៣០៤

តេរសមំ សុវណ្ណសាមចរិយំ . . . . . . . ៣០៥

ចុទ្ទសមំ ឯករាជចរិយំ . . . . . . . . ៣០៦

បណ្ណរសមំ មហាលោមហំសចរិយំ . . . . . ៣០៧

សមោធានកថា . . . . . . . . . . . . ៣១០

# សន្លឹកប្រាប់មាតិកា

មាតិកា ទំព័រ

## នេក្ខម្មទិបារមិតា


ភិសចរិយា ទី ៤ . . . . . . . . . . . . . ២៩០

សោណនន្ទបណ្ឌិតចរិយា ទី ៥ . . . . . . . ២៩១

មូគបក្ខចរិយា ទី ៦ . . . . . . . . . . ២៩៣

កបិរាជចរិយា ទី ៧ . . . . . . . . . . . ២៩៦

សច្ចសវ្ហយបណ្ឌិតចរិយា ទី ៨ . . . . . . . ២៩៧

វដ្ដកបោតកចរិយា ទី ៩ . . . . . . . . . ២៩៧

មច្ឆរាជចរិយា ទី ១០ . . . . . . . . . . ២៩៩

កណ្ហទីបាយនចរិយា ទី ១១ . . . . . . . . ៣០១

សុតសោមចរិយា ទី ១២ . . . . . . . . . ៣០៤

សុវណ្ណសាមចរិយា ទី ១៣ . . . . . . . . ៣០៥

ឯករាជចរិយា ទី ១៤ . . . . . . . . . . ៣០៦

មហាលោមហំសចរិយា ទី ១៥ . . . . . . . ៣០៧

សមោធានកថា . . . . . . . . . . . . ៣១១

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | បន្តិលេខាយំ |
|---|---|---|---|
| បាបុណិស្សតិ | បាបុណិស្សសិ | ៤៩ | ១១ |
| អភិវឌ្ឍីស្សុ | អភិវឌ្ឍិស្សុ | ៥២ | ៣ |
| គហុស្ស កល្យិកា នាម | គហុស្សកល្យិកា នាម | ៥៨ | ៦ |
| អះមោទិតា | អាមោទិតា | ៦២ | ១៤ |
| វិវឌ្ឍិស្សាម | វិវឌ្ឍិស្សាម | ៦៣ | ៤ |
| រម្មាវតី នាម | រម្មវតី នាម | ៥៧ | ៤ |
| យថា សុខំ | យថាសុខំ | ៧៤ | ១៤ |
| សន្តិចិត្តាន | សន្តិចិត្តាន | ៧៥ | ១១ |
| ពុជ្ឈិស្សតិ | ពុជ្ឈិស្សតិ | ៧៧ | ៧ |
| វិវដ្ឋិស្សាម | វិវឌ្ឍិស្សាម | ៧៨ | ១២ |
| កោជសតសហស្សានំ | កោដិសតសហស្សានំ | ៨៣ | ៩ |
| ហេស្សន្តុបដ្ឋកា | ហេស្សន្តុបដ្ឋិកា | ៩៣ | ៩ |
| វិវដ្ឋិស្សាម | វិវឌ្ឍិស្សាម | ១១៦ | ១០ |
| អគ្គុបដ្ឋិកា | អគ្គុបដ្ឋកា | ១២៦ | ១២ |
| មន្តាវេត្វា | សន្តាវេត្វា | ៥៨ | ១៣ |
| អមិតយ សោ | អមិតយសោ | ១២៩ | ២ |

# វិរុទ្ធាវិរុទ្ធបត្តំ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្គោ | បង្តិលេខាយំ |
|---|---|---|---|
| តឹសកប្បសហសម្ហិ | តឹសកប្បសហស្សម្ហិ | ១៣០ | ៥ |
| ធម្ម ទេសនេ | ធម្មទេសនេ | ១៣៦ | ៣ |
| អហេសុំ អគ្គសាវកា | អហេសុំ អគ្គសាវិកា | ១៤១ | ១០ |
| កណ្ឌកា | កណ្ដកា | ១៤២ | ៤ |
| សោកនំ នាម | សោកណំ នាម | ១៥៥ | ៤ |
| ទសបារមិបូរិយោ | ទសបារមិបូរិយា | ១៦១ | ១១ |
| សិទ្ធិត្ថស្ស | សិទ្ធត្ថស្ស | ១៦៥ | ៦ |
| ចាតុវណ្ណបរិវុត្តំ | ចាតុវណ្ណបរិវុតំ | ១៧៣ | ២ |
| មហាន្តេន | អហាន្តេន | ១៧៩ | ៤ |
| ទុក្ខរការិកំ | ទុក្ករការិកំ | ១៧៩ | ១០ |
| មិគ្គទាយេ | មិគទាយេ | ១៨២ | ១២ |
| ធាតុវិត្ថារកំ | ធាតុវិត្ថារិកំ | ១៨៣ | ១៣ |
| វិប្បស្សិស្ស | វិបស្សិស្ស | ១៨៥ | ៤ |
| មហាន្តេន | អហាន្តេន | ១៨៥ | ១០ |
| សមាលា នាម | សមាលា ប | ២០៤ | ១០ |
| និប្ពុតិ | និព្វុតិ | ២០៥ | ៣ |

## វិរុទ្ធាវិរុទ្ធបត្តិ

| វិរុទ្ធបាឋោ | អវិរុទ្ធបាឋោ | អង្កេ | រជ្ជុលេខាយំ |
| --- | --- | --- | --- |
| វិភជ្ជិត្វា | វិភជិត្វា | ២០៩ | ៦ |
| កោនាគមពុទ្ធវំសោ | កោនាគមនពុទ្ធវំសោ | ២១៩ | ១ |
| នាមជនិកា | នាម ជនិកា | ២១៧ | ១១ |
| ឥន្ទបត្តបុរេ | ឥន្ទបត្ថបុរេ | ២៣៨ | ១០ |
| ព្រាហ្មៈណា | ព្រាហ្មណា | ២៤៤ | ៥ |
| អាយាចុំ | អយាចុំ | ២៤៤ | ៦ |
| ឥន្ទបត្តេ | ឥន្ទបត្ថេ | ២៤៤ | ៣ |
| បូជិតា | បូជិតោ | ២៤៧ | ៧ |
| នវមំ វេស្សន្តរចរយំ | នវមំ វេស្សន្តរចរិយំ | ២៥៩ | ១ |
| នវមំ វេស្សន្ត ចរិយំ | នវមំ វេស្សន្តរចរិយំ | ២៥៧ | ១ |
| ទុភិន្នំ ឧបង្កមិ | ទុភិន្នំ ឧបសង្កមិ | ២៦២ | ៤ |
| ជីវិតវុត្តិ ការណា | ជីវិតវុត្តិការណា | ២៨៦ | ៣ |
| ហតំ វីសំ | ហតំ វីសំ | ៣០៣ | ១២ |
| បរបត្តា | បរមត្តា | ៣១០ | ១៣ |
| មុគ្គផក្ខេន | មុប្ផផក្ខេន | ៣១៤ | ២ |

# សន្លឹកប្រាប់ពាក្យខុស–ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| បពិត្រព្រហ្ម | ម្នាលព្រហ្ម | ២ | ១៣ |
| ពួកភូមដ្ឋកទេវតា | ពួកភុម្មដ្ឋកទេវតា | ១១ | ១១ |
| ផ្កាមន្ទារវបុស្ស | ផ្កាមន្ទារវៈ | ១០ | ៥ |
| យ៉ាងណាវិញ | យ៉ាងណាមិញ | ៣៤ | ៨ |
| និម្មិត | និមិត្ត | ៣៥ | ១៣ |
| និម្មិត | និមិត្ត | ៣៦ | ២៥ |
| កំពង់ | កំពុង | ៤២ | ១៤ |
| យ៉ាងណា | យ៉ាងណា | ៤៩ | ៣ |
| មយុរប្រាសាទ | មាយុរប្រាសាទ | ៥៧ | ៨ |
| ១០០ យោជន៍ជុំវិញ | ១០ យោជន៍ជុំវិញ | ៥៨ | ១០ |
| ព្រមទាំងវេតា | ព្រមទាំងទេវតា | ៧៨ | ១១ |
| គទៅទៅទៀត | គទៅទៀត | ៧៩ | ៦ |
| ទីពឹងពុំនាក់ | ទីពឹងពំនាក់ | ១២៥ | ៤ |
| ជាអ្នកមិនមានប្រមាទ | ជាអ្នកប្រមាទ | ១៤០ | ១១ |
| ឈ្មោះពេណមុខ | ឈ្មោះទោណមុខ | ១៤៤ | ១២ |

# សន្លឹកប្រាប់ពាក្យខុស - ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ទឹងបប្រើ | ទឹងបម្រើ | ១៥៣ | ១១ |
| នារទពុទ្ធវង្ស ទី ៩ | អត្ថទស្សិពុទ្ធវង្ស ទី ១៤ | ១៨៣ | ១ |
| ព្រះសុទត្ថត្ថេរ | ព្រះសុទត្តត្ថេរ | ១៦២ | ១៣ |
| ទប្ឃង្ហាក | ទបង្ហាក | ១៧៤ | ៦ |
| ព្រះនាមវិបុស្សី | ព្រះនាមវិបស្សី | ១៨៤ | ៤ |
| សមានា ១ | សមាលា ១ | ២០៤ | ១១ |
| ចេញដោយរ | ចេញទៅទ្រង់ព្រះផ្នួសដោយរ | ២០៤ | ៥ |
| មានចិត្តតាំងមាំ ៗ | មានចិត្តតាំងមាំ ទឹងបានជា អគ្គសាវិកា ៗ | ២២៣ | ១៦ |
| ឥន្ទបត្ថបុរី | ឥន្ទបត្តបុរី | ២៣៨ | ១២ |
| ឥន្ទបត្ថបុរី | ឥន្ទបត្តបុរី | ២៤៤ | ៤ |
| ជាក្សតបក្រពត្តិ | ជាក្សត្របក្រពត្តិ | ២៤៥ | ១២ |
| នូវវេស្សកម្មទេវបុត្រ | នូវវិស្សកម្មទេវបុត្រ | ២៥៩ | ១៤ |
| សព្វញ្ញុតញ្ញាណ | សព្វញ្ញុតញ្ញាណ | ២៦១ | ១៥ |
| មានរិយាដទៃទៀត | មានបរិយាដទៃទៀត | ២៦៩ | ២ |

## សន្លឹកប្រាប់ពាក្យខុស-ត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| នេះជាតតិ | នោះជាគតិ | ២៨៧ | ៧ |
| បង់ដោយ | បង់តថាគតដោយ | ២៨៧ | ១០ |
| លះបង់រាជ | លះបង់រាជ្យ | ២៨៨ | ៧ |
| ព្រះបទ្រុះ | ព្រះបទ្រុ | ២៨៩ | ៧ |
| ទន្ទឹង | ទន្ទីង | ២៨៩ | ១៨ |
| គឺហិរិ | គឺហិរិនិងឱត្តប្បៈ | ២៩០ | ១១ |
| សិរិសយនា | សិរីសយនា | ២៩៣ | ១១ |
| នឹងរួបហាកទុក | នឹងរួបហាកទុក្ខ | ៣០០ | ៦ |
| បរត្ថបារមី | បរមត្ថបារមី | ៣១៤ | ៣ |
| បរមត្ថបារមិ | បរមត្ថបារមី | ៣១៤ | ១០ |
| កាលតគត | កាលតថាគត | ៣១៤ | ១២ |

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកខាងក្រោមនេះ ៖

Printing costs were met through the gift of

**Wat. Sotoshu Zenshoji Temple**
The Rev. Shoken Yokoyama
3-2-7 Toitayama, Higashi-ku, Hiroshima-shi, Hiroshima-ken 732 Japan

この本は次の方によって復刻されました。

曹洞宗 禅昌寺 横山正賢
〒732 広島県広島市東区戸坂山3-2-7

ព្រះត្រៃបិដក ភាគទី ១១០ " អភិធម្មបិដក "
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ
ការបោះពុម្ពជាថ្មីឡើងវិញ របស់សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ
បោះពុម្ព ថ្ងៃទី ១០ កក្កដា ឆ្នាំ ១៩៩៤
សហប្រតិបត្តិការរៀបរៀង និងបោះពុម្ពនៅប្រទេសជប៉ុន

TRIPITAKA VOL. 77 (of 110 volumes total)
"ABHIDHAMMA PITAKA"
Published by the Buddhist Institute, Phnom Penh
Reproduced with the kind cooperation of the
TRIPITAKA PUBLISHING COMMITTEE
First edition December 8, 1994
Printed in Japan by Hirosaki Sogo Printing Ltd.

**トリピタカ（南伝大蔵経）全110巻・第77巻アビダンマピタカ（論部）**

---

**発　　行：プノンペン仏教研究所**
復刻救援：カンボジア版トリピタカ(南伝大蔵経)復刻救援委員会
発　　行：1994年12月8日

---

印刷・製本／弘前相互印刷株式会社
製作にあたり弘前相互印刷株式会社の多大な協力を得ました。

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE